ADB

**ឯកសារគោលនយោបាយ**

ដំណាក់កាលរបស់ឯកសារៈ ឯកសារសម្រាប់ការពិគ្រោះយោបល់

ខែ កុម្ភៈ ឆ្នាំ ២០១១

# ការបន្តពង្រឹងយន្តការគណនេយ្យភាព

Asian Development Bank

# ពាក្យកាត់

| | | | |
|---|---|---|---|
| ADB | – | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AM | – | Accountability Mechanism | យន្តការគណនេយ្យភាព |
| AfDB | – | African Development Bank | ធនាគារអភិវឌ្ឍន៍អាហ្វ្រិច |
| BCRC | – | Board Compliance Review Committee | គណៈកម្មាធិការពិនិត្យឡើងវិញលើភាពអនុលោម របស់ក្រុមប្រឹក្សាភិបាល |
| BIC | – | Board Inspection Committee | គណៈកម្មាធិការអធិការកិច្ចរបស់ក្រុមប្រឹក្សាភិបាល |
| BPMSD | – | Budget, Personnel, and Management Systems Department | នាយកដ្ឋានថវិកា, បុគ្គលិក និងប្រព័ន្ធគ្រប់គ្រង |
| CAO | – | Compliance Advisor Ombudsman | ការិយាល័យប្រជាពលរដ្ឋសម្រាប់ផ្តល់ប្រឹក្សាអំពីភាព អនុលោម |
| COSO | – | Central Operations Services Office | ការិយាល័យផ្តល់សេវាប្រតិបត្តិការកណ្តាល |
| CRO | – | Complaint Receiving Officer | មន្ត្រីទទួលពាក្យបណ្តឹង |
| CRP | – | Compliance Review Panel | គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម |
| DEC | – | Development Effectiveness Committee | គណៈកម្មាធិការប្រសិទ្ធភាពនៃការអភិវឌ្ឍ |
| DG | – | Director General | អគ្គនាយក |
| DMC | – | developing member country | ប្រទេសកំពុងអភិវឌ្ឍជាសមាជិក |
| EA | – | Executing Agency | ទីភ្នាក់ងារប្រតិបត្តិ |
| EIB | – | European Investment Bank | ធនាគារវិនិយោគអឺរ៉ុប |
| EBRD | – | European Bank for Reconstruction and Development | ធនាគារអឺរ៉ុបសម្រាប់ការអភិវឌ្ឍ និងស្ថាបនាឡើង វិញ |
| IA | – | implementing agency | ទីភ្នាក់ងារអនុវត្ត |
| IADB | – | Inter-American Development Bank | ធនាគារអភិវឌ្ឍន៍អន្តរអាមេរិច |
| IED | – | Independent Evaluation Department | នាយកដ្ឋានវាយតម្លៃឯករាជ្យ |
| JBIC | – | Japan Bank for International Cooporation | ធនាគារជប៉ុនសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ |
| MDB | – | multilateral development bank | ធនាគារអភិវឌ្ឍន៍ពហុភាគី |

| | | | |
|---|---|---|---|
| NGO | – | nongovernmental organization | អង្គការក្រៅរដ្ឋាភិបាល |
| OCRP | – | Office of the Compliance Review Panel | ការិយាល័យរបស់គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម |
| OM | – | operations manual | សៀវភៅណែនាំអំពីប្រតិបត្តិការការងារ |
| OPIC | – | Overseas Private Investment Corporation | សាជីវកម្មវិនិយោគវិស័យឯកជនក្រៅប្រទេស |
| OSPF | – | Office of the Special Project Facilitator | ការិយាល័យអ្នកគ្រប់គ្រងគម្រោងពិសេស |
| PCR | – | project completion report | របាយការណ៍បញ្ចប់គម្រោង |
| PPS | – | private project sponsor | អ្នកឧបត្ថម្ភគម្រោងឯកជន |
| RAR | – | review and assessment report | របាយការណ៍ពិនិត្យឡើងវិញ និងវាយតម្លៃ |
| RSDD | – | Regional and Sustainable Development Department | នាយកដ្ឋានអភិវឌ្ឍន៍តំបន់ ប្រកបដោយនិរន្តរភាព |
| SPF | – | Special Project Facilitator | អ្នកសម្របសម្រួលគម្រោងពិសេស |
| SPS | – | Safeguard Policy Statement | គោលនយោបាយការពារសង្គម និងបរិស្ថាន |
| STDP | – | South Transport Development Project (Sri Lanka) | គម្រោងអភិវឌ្ឍន៍ផ្លូវគមនាគមន៍ភាគខាងត្បូង (ប្រទេសស្រីលង្កា) |
| TOR | – | Terms of reference | លក្ខខណ្ឌយោង |
| WPBF | – | Working Program and Budget Framework | កម្មវិធីការងារ និងក្របខ័ណ្ឌថវិកា |

## សម្គាល់

នៅក្នុងរបាយការណ៍នេះ, “$” មានន័យថា ដុល្លារសហរដ្ឋអាមេរិច

## សេចក្តីអះអាង

ធនាគារអភិវឌ្ឍនអាស៊ី (ADB) បានខិតខំប្រឹងប្រែងដើម្បីផ្ទៀងផ្ទាត់ទៅលើភាពជាក់លាក់នៃការបកប្រែនេះ។ ភាសាអង់គ្លេសគឺជាភាសាការងាររបស់ ADB ហើយឯកសារច្បាប់ដើមជាភាសាអង់គ្លេសគឺជាឯកសារដែលត្រឹមត្រូវ និងផ្លូវការតែមួយគត់របស់ខ្លួន។ សេចក្តីដកស្រង់ណាមួយចេញពីឯកសារនេះ ត្រូវតែយោងទៅលើឯកសារច្បាប់ដើមក្នុងភាសាអង់គ្លេស។

| | |
|---|---|
| **ប្រធានក្រុមការងារ** | Eduard Westreicher, នាយកប្រតិបត្តិបំរុង ប្រចាំប្រទេសអូទ្រីស, អាល្លឺម៉ង់, លុចសំបួរ, ទួរគី និងចក្រភពអង់គ្លេស |
| **សមាជិក** | Siraj Shamsuddin, នាយកប្រតិបត្តិ ប្រចាំប្រទេសកាហ្សាក់ស្ថង់, ម៉ាលឌីវ, កោះម៉ាស្លល់, ម៉ុងហ្គោលី, ប៉ាគីស្ថាន, ហ្វីលីពីន, ទីម័រខាងកើត |
| | Dereck Rooken-Smith, នាយកប្រតិបត្តិបំរុង ប្រចាំប្រទេសអូស្ត្រាលី, អាហ្សែបៃហ្សង់, កម្ពុជា, ចរចា, ហុងកុង, ចិន, គីរីបាទី, រដ្ឋសហព័ន្ធមីក្រូណេស៊ី, ណាវរុ, សាធារណរដ្ឋប៉ាឡាវ, កោះសូឡូម៉ុង, ទូវ៉ាលូ |
| | Govinda Bahadur Thapa, នាយកប្រតិបត្តិបំរុង ប្រចាំ ប្រទេសប្រ៊ុយណេដារូសាឡឹម, ម៉ាឡេស៊ី, មីយ៉ាន់ម៉ា, ណេប៉ាល់, សឹង្ហបុរី, ថៃ |
| | Rajat M. Nag, អគ្គនាយកគ្រប់គ្រង |
| **លេខាធិការដ្ឋាន *** | Xiaoqin Fan, ប្រធានក្រុមអ្នកឯកទេសផ្នែករៀបចំផែនការ និងគោលនយោបាយ, នាយកដ្ឋានយុទ្ធសាស្ត្រ និងគោលនយោបាយ. |

*យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះជំនួយដ៏មានប្រសិទ្ធភាពរបស់ Angelita Cortez ជាទីប្រឹក្សា, Edeena R. Pike ជាមន្ត្រីផ្នែកយុទ្ធសាស្ត្រ និងគោលនយោបាយ និង Myrna M. Fortu ជាជំនួយការផ្នែករដ្ឋបាលនៃនាយកដ្ឋានយុទ្ធសាស្ត្រ និងគោលនយោបាយ ។

នៅក្នុងការរៀបចំកម្មវិធី ឬយុទ្ធសាស្ត្រសម្រាប់ប្រទេសណាក៏ដោយ, ការផ្តល់ហិរញ្ញប្បទានដល់គម្រោងណាក៏ដោយ ឬតាមរយៈការលើកឡើង ឬលើកយោងអំពីដែនដី ឬតំបន់ភូមិសាស្ត្រណាមួយនៅក្នុងឯកសារនេះ, ធនាគារអភិវឌ្ឍន៍អាស៊ីពុំមានបំណងធ្វើការវិនិច្ឆ័យអំពីស្ថានភាពច្បាប់ ឬស្ថានភាពដទៃទៀតរបស់ដែនដី ឬតំបន់នោះឡើយ ។

# មាតិកា


| | | ទំព័រ |
|---|---|---|
| សង្ខេបរួម | | i |
| I. | សេចក្តីផ្តើម | ១ |
| II. | ការបង្កើតការវិវឌ្ឍនៃយន្តការគណនេយ្យភាព | ៣ |
| | ក. មុខងារអធិការកិច្ចឆ្នាំ ១៩៩៥ | ៣ |
| | ខ. យន្តការគណនេយ្យភាពឆ្នាំ ២០០៣ | ៤ |
| III. | បទពិសោធន៍ចាប់តាំងពីឆ្នាំ ២០០៣ មក | ៦ |
| | ក. ដំណាក់កាលពិគ្រោះយោបល់ | ៦ |
| | ខ. ដំណាក់កាលពិនិត្យឡើងវិញលើភាពអនុលោម | ១០ |
| IV. | ការវាយតម្លៃលើយន្តការគណនេយ្យភាព | ១២ |
| | ក. លទ្ធភាពប្រើប្រាស់ | ១២ |
| | ខ. ភាពជឿជាក់ | ១៦ |
| | គ. ប្រសិទ្ធភាព | ២០ |
| | ឃ. ភាពស័ក្តិសិទ្ធិ | ២៧ |
| | ង. សេចក្តីសង្ខេប | ៤១ |
| V. | ជម្រើស និងការផ្លាស់ប្តូរសំខាន់ៗ ដែលស្នើឡើង | ៤៣ |
| | ក. ការផ្តល់លទ្ធភាពឱ្យមានការប្រើប្រាស់ដំណាក់កាលពិនិត្យឡើងវិញលើភាពអនុលោមដោយផ្ទាល់ | ៤៣ |
| | ខ. ការបង្កើតចំណុចផ្តើមតែមួយ | ៤៦ |
| | គ. ការបញ្ជាក់ឱ្យបានច្បាស់ពីកាលបរិច្ឆេទឱសានវាទ | ៤៧ |
| | ឃ. ការដោះស្រាយបញ្ហានៃការចុះដល់ទីតាំងគម្រោងជាក់ស្តែង | ៤៧ |
| | ង. ការបង្កើនឯករាជ្យភាព និងភាពស័ក្តិសិទ្ធិនៃការពិនិត្យឡើងវិញលើភាពអនុលោម | ៥២ |

ច. ការបង្កើនប្រសិទ្ធភាព ៥៣

ឆ. ការបង្កើនការយល់ដឹង និងលើកកម្ពស់ការរៀនសូត្រ ៥៥

VI. គោលនយោបាយយន្តការគណនេយ្យភាព ដែលបានកែសម្រួលរួច ៥៨

ក. គោលដៅ និងគោលការណ៍ណែនាំ ៥៨

ខ. រចនាសម្ព័ន្ធ ៥៨

គ. ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ ៥៩

ឃ. មុខងារ ៦៣

ង. ភាពសមស្រប ៧២

ច. របៀបដាក់សំណើ ៧៦

ឆ. ការដំណើរការសំណើ ៧៨

ជ. តម្លាភាព និងការផ្សព្វផ្សាយព័ត៌មាន ៩០

ឈ. គោលវិធី ៩១

ញ. ការអនុវត្ត ៩១

VII. ការអនុវត្ត និងតម្រូវការធនធាន ៩២

ក. ការយល់ដឹង និងការរៀនសូត្រ ៩២

ខ. ចំណាយ និងតម្រូវការធនធាន ៩៣

គ. កាលបរិច្ឆេទចូលជាធរមាន និងរយៈពេលអន្តរកាល ៩៤

VIII. សំណើសុំការណែនាំពីក្រុមប្រឹក្សាភិបាល ៩៤

**ឧបសម្ព័ន្ធ**

១. លក្ខខណ្ឌយោងសម្រាប់ការពិនិត្យឡើងវិញលើយន្តការគណនេយ្យភាព ៩៥

២. ការប្រៀបធៀបយន្តការគណនេយ្យភាព ៩៩

៣. ចំនួនករណី នៅតាមយន្តការគណនេយ្យភាពផ្សេងៗ ១០៧

៤. សេចក្តីសង្ខេបអំពីបណ្តឹងមានលក្ខណៈសមស្រប ដែលការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេសទទួលបានៈ ២០០៤-២០១០ ១០៩

| | | |
|---|---|---|
| ៥. | សេចក្តីសង្ខេបអំពីសំណើឱ្យមានការពិនិត្យឡើងវិញលើភាពអនុលោមៈ ២០០៤-២០១០ | ១១៦ |
| ៦. | សេចក្តីសង្ខេបអំពីការវាយតម្លៃលើយន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី | ១២១ |

# សេចក្តីសង្ខេបរួម

១. នៅក្នុងឆ្នាំ ១៩៩៥ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានបង្កើតនូវមុខងារអធិការកិច្ចមួយ ដើម្បីបង្កើតឱ្យមានជាវេទិកាមួយ សម្រាប់ឱ្យអ្នកដែលរងផលប៉ះពាល់ដោយសារគម្រោងអាចធ្វើការតវ៉ាទៅកាន់ស្ថាប័នឯករាជ្យ ចំពោះបញ្ហា ដែលពាក់ព័ន្ធជាមួយនឹងភាពអនុលោមរបស់ធនាគារអភិវឌ្ឍន៍អាស៊ីទៅនឹងគោលនយោបាយ និងនីតិវិធីប្រតិបត្តិរបស់ខ្លួន នៅក្នុងគម្រោងនានា ដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី។ នៅក្នុងឆ្នាំ ២០០៣ បន្ទាប់ពីមានដំណើរការពិនិត្យឡើងវិញយ៉ាងល្អិតល្អន់រួចមក ធនាគារអភិវឌ្ឍន៍អាស៊ីបានដាក់ឱ្យអនុវត្តនូវយន្តការគណនេយ្យភាព (AM) ដែលកំពុងមាននាពេលបច្ចុប្បន្ន បន្ថែមពីលើមុខងារអធិការកិច្ច។ យន្តការគណនេយ្យភាពនេះត្រូវបានតាក់តែងឡើងដើម្បីបង្កើនប្រសិទ្ធភាពនៃកិច្ចការអភិវឌ្ឍន៍ និងគុណភាពគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី, ធ្វើការឆ្លើយតបទៅនឹងការព្រួយបារម្ភរបស់អ្នកដែលរងផលប៉ះពាល់ដោយសារគម្រោង និងផ្តល់យុត្តិធម៌ដល់គ្រប់អ្នកដែលពាក់ព័ន្ធ, ឆ្លុះបញ្ចាំងពីបទដ្ឋានវិជ្ជាជីវៈ និងបច្ចេកទេសក្នុងកម្រិតខ្ពស់បំផុត នៅក្នុងការចាត់ចែងបុគ្គលិក និងការបំពេញប្រតិបត្តិការរបស់ធនាគារ, សម្រេចឱ្យបាននូវឯករាជ្យភាព និងតម្លាភាពតាមដែលអាចធ្វើទៅបាន និងមានប្រសិទ្ធភាពចំណាយប្រសិទ្ធភាពការងារ បន្ថែមពីលើប្រព័ន្ធអភិបាល សវនកម្ម ត្រួតពិនិត្យគុណភាព និងវាយតម្លៃ ដែលកំពុងមានស្រាប់នៅក្នុងធនាគារអភិវឌ្ឍន៍អាស៊ី។

២. នៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំលើកទី ៤៣ របស់ក្រុមប្រឹក្សាភិបាលនៃធនាគារអភិវឌ្ឍន៍អាស៊ី ដែលបានរៀបចំឡើងនៅ Tashkent កាលពីខែ ឧសភា ឆ្នាំ ២០១០, ប្រធានធនាគារអភិវឌ្ឍន៍អាស៊ីបានប្រកាសថា ធនាគារអភិវឌ្ឍន៍អាស៊ីនឹងធ្វើការពិនិត្យឡើងវិញរួមគ្នាមួយរវាងក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងលើយន្តការគណនេយ្យភាពរបស់ធនាគារ (ការពិនិត្យឡើងវិញ)។ ក្រុមការងាររួមគ្នាមួយរបស់ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង ត្រូវបានបង្កើតឡើងសម្រាប់គោលបំណងនេះ។ ក្រុមការងារនេះបានជួលអ្នកជំនាញអន្តរជាតិឯករាជ្យ ២ រូប ដើម្បីជួយធ្វើការពិនិត្យឡើងវិញនេះ។ ការពិនិត្យឡើងវិញនេះមានគោលដៅបូកសរុបបទពិសោធន៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី, ស្រង់យកបទពិសោធន៍របស់យន្តការស្រដៀងៗគ្នានេះដទៃទៀត និងពិនិត្យលើវិសាលភាព ដើម្បីធ្វើការកែលំអយន្តការគណនេយ្យភាពនេះ។ ការពិនិត្យឡើងវិញនេះបានដាក់បញ្ចូលនូវដំណើរការពិគ្រោះយោបល់សាធារណៈដ៏ទូលំទូលាយមួយ។

៣. ការពិនិត្យឡើងវិញនេះប្រើប្រាស់ក្របខ័ណ្ឌនៃលទ្ធភាពអាចប្រើប្រាស់បាន (accessibility) ភាពជឿជាក់ (credibility) ប្រសិទ្ធភាព (efficiency) និងភាពស័ក្តិសិទ្ធិ (effectiveness) (ACEE) ដែលមានការទទួលស្គាល់

ទូលំទូលាយ ដើម្បីធ្វើការវាយតម្លៃយន្តការគណនេយ្យភាពនេះ។ ការពិនិត្យឡើងវិញនេះបានសន្និដ្ឋានថា យន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី គឺជាយន្តការនាំមុខគេមួយ នៅក្នុងការដាក់ឱ្យអនុវត្តជាផ្លូវការនូវមុខងារដោះស្រាយបញ្ហា នៅក្នុងធនាគារអភិវឌ្ឍន៍ពហុភាគី (MDBs) សម្រាប់ប្រតិបត្តិការវិស័យសាធារណៈផង និងវិស័យឯកជនផង។ មុខងារទាំងពីរនៃការពិនិត្យឡើងវិញនេះ គឺការពិគ្រោះយោបល់ និងការពិនិត្យឡើងវិញលើភាពអនុលោម បំពេញឱ្យគ្នាទៅវិញទៅមក, ធានាឱ្យមានតុល្យភាពសមស្របរវាងឯករាជ្យភាព និងប្រសិទ្ធភាព និងមានភាពសមស្របជាទស្សនទាន និងមានសុពលភាពក្នុងការអនុវត្តជាក់ស្តែង។ យន្តការគណនេយ្យភាពនេះមានតម្លាភាពទទួលបានការចូលរួម មានភាពជឿជាក់ និងមានប្រសិទ្ធភាពក្នុងកម្រិតមួយខ្ពស់។ ដំណាក់កាលពិគ្រោះយោបល់ និងដំណាក់កាលពិនិត្យឡើងវិញលើភាពអនុលោម សុទ្ធសឹងតែជាដំណាក់កាលដែលមានប្រយោជន៍ និងសម្រេចបាននូវលទ្ធផលប្រកបដោយប្រសិទ្ធភាព។

៤. ការពិនិត្យឡើងវិញនេះក៏បានលើកឡើងផងដែរថា ធនាគារអភិវឌ្ឍន៍អាស៊ីអាចបន្តពង្រឹងយន្តការគណនេយ្យភាពនេះ ដោយធ្វើការផ្លាស់ប្តូរការងារជាច្រើន។ លក្ខខណ្ឌ ដែលតម្រូវឱ្យអ្នកធ្វើការស្នើសុំត្រូវទៅកាន់ OSPF ជាមុនសិនធ្វើឱ្យមានការយល់ឃើញថា OSPF នេះបានកាត់បន្ថយការតវ៉ានេះមកនៅត្រឹមដំណាក់កាលពិនិត្យឡើងវិញលើភាពអនុលោម និងធ្វើឱ្យមានភាពយឺតយ៉ាវដល់អ្នកដែលចង់ស្នើសុំឱ្យមានការពិនិត្យឡើងវិញលើភាពអនុលោមដោយផ្ទាល់។ ការបែងចែកអណត្តិការងាររវាងមុខងារដោះស្រាយបញ្ហា, ការពិនិត្យឡើងវិញលើភាពអនុលោម និងការចាត់ចែងគម្រោង នៅមិនទាន់មានភាពច្បាស់លាស់នៅឡើយ។ CRP ត្រូវបានតែងតាំងដោយក្រុមប្រឹក្សាភិបាល ទៅតាមអនុសាសន៍របស់ប្រធានធនាគារ ដែលអាចកាត់បន្ថយឯករាជ្យភាពនៃស្ថាប័ននេះពីគណៈគ្រប់គ្រង។ យន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី គឺជាយន្តការមួយ ក្នុងចំណោមយន្តការដែលចំណាយអស់ច្រើនជាងគេរបស់ស្ថាប័នប្រហាក់ប្រហែលគ្នានេះ។ ការយកកាលបរិច្ឆេទចេញរបាយការណ៍បញ្ចប់គម្រោង ធ្វើជាកាលបរិច្ឆេទចុងក្រោយសម្រាប់ដាក់ពាក្យស្នើសុំ ធ្វើឱ្យពុំមានភាពច្បាស់លាស់ និងភាពប្រាកដប្រជា។ លើសពីនេះ ការយល់ដឹងអំពីយន្តការគណនេយ្យភាពនៅមានកម្រិតនៅឡើយ ហើយសហគមន៍មូលដ្ឋានជាច្រើនយល់ឃើញថា ដំណើរការនៃយន្តការគណនេយ្យភាពនេះស៊ីពេលយូរ និងមានភាពស្មុគស្មាញច្រើន។ ដំណាក់កាលពិនិត្យឡើងវិញលើភាពអនុលោមត្រូវបានគេយល់ឃើញថាជាដំណើរការដែលអ្នកពិនិត្យឡើងវិញមានទស្សនៈផ្សេង/ផ្ទុយគ្នា។ គុណតម្លៃនៃការរៀនសូត្រ អំពីយន្តការគណនេយ្យភាព នៅមិនទាន់ត្រូវបានប្រើប្រាស់ឱ្យបានពេញលេញនៅឡើយ។

៥. យោងទៅតាមបទពិសោធន៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី និងរបស់ស្ថាប័នស្រដៀងៗគ្នានេះ ការពិនិត្យឡើងវិញនេះស្នើឱ្យមានការផ្លាស់ប្តូរមួយចំនួន ដើម្បីបន្តពង្រឹងយន្តការគណនេយ្យភាពនេះ។ ការផ្លាស់ប្តូរសំខាន់ៗត្រូវបានសង្ខេបដូចខាងក្រោម។

## ៦. ការបង្កើនលទ្ធភាពអាចប្រើប្រាស់បាន

(i) *បង្កើតនូវចំណុចផ្តើមមួយ* ។ ត្រូវមានបុគ្គលិកម្នាក់ក្នុង OCRP ធ្វើជាមន្ត្រីទទួលពាក្យបណ្តឹង ដើម្បីទទួលយកសំណើទាំងអស់។ ការធ្វើបែបនេះនឹងកែលំអទំនាក់ទំនងរវាងយន្តការគណនេយ្យភាព និងសាធារណជនទូទៅ។

(ii) *ផ្លាស់ប្តូរកាលបរិច្ឆេទកំណត់* ។ ធនាគារអភិវឌ្ឍន៍អាស៊ីគួរផ្លាស់ប្តូរកាលបរិច្ឆេទផុតកំណត់សម្រាប់ដាក់ពាក្យបណ្តឹង ចេញពីកាលបរិច្ឆេទនៃការចេញរបាយការណ៍បញ្ចប់គម្រោង ទៅមួយឆ្នាំក្រោយ បន្ទាប់ពីកាលបរិច្ឆេទបិទកម្ចី។ ការធ្វើបែបនេះនឹងបង្កើនភាពច្បាស់លាស់ និងភាពប្រាកដប្រជានៃកាលបរិច្ឆេទកំណត់។

(iii) *បង្កើនការយល់ដឹង និងធ្វើឱ្យមានបំលាស់ប្តូរវប្បធម៌* ។ OSPF និង OCRP គួរធ្វើសកម្មភាពផ្សព្វផ្សាយឱ្យកាន់តែមានលក្ខណៈជាប្រព័ន្ធ និងមានប្រសិទ្ធភាព នៅក្នុងធនាគារអភិវឌ្ឍន៍អាស៊ី, តាមគម្រោង និងនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិក។ គួរមានបំលាស់ប្តូរវប្បធម៌ ឆ្ពោះទៅប្រើប្រាស់ និងចាត់ទុកយន្តការគណនេយ្យភាពនេះ គឺជាឧបករណ៍វិជ្ជមានមួយសម្រាប់ធ្វើការសិក្សា និងជម្រុញឱ្យមានប្រសិទ្ធភាពនៃការអភិវឌ្ឍន៍។ បុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ីគួរបំពេញនាទីជាកម្លាំងស្នូល សម្រាប់ធ្វើការផ្សព្វផ្សាយព័ត៌មានអំពីយន្តការគណនេយ្យភាព។

## ៧. ពង្រឹងភាពជឿជាក់

(i) *បង្កើនឯករាជ្យភាព* ។ សមាជិករបស់ CRP គួរត្រូវបានតែងតាំងដោយក្រុមប្រឹក្សាភិបាល ផ្អែកទៅតាមអនុសាសន៍របស់គណៈកម្មាធិការពិនិត្យឡើងវិញលើភាពអនុលោមរបស់ក្រុមប្រឹក្សាភិបាល ដោយមានការពិគ្រោះយោបល់ជាមួយប្រធានធនាគារ។ ការធ្វើបែបនេះនឹងបង្កើនឯករាជ្យភាពរបស់ CRP ចេញពីគណៈគ្រប់គ្រង បើប្រៀបជាមួយនឹងការអនុវត្តបច្ចុប្បន្ន ដែលសមាជិក CRP ទទួលបានការតែងតាំងពីក្រុមប្រឹក្សាភិបាល ទៅតាមអនុសាសន៍របស់ប្រធានធនាគារ។

(ii) *បង្កើនភាពឆ្លើយតប និងតម្លាភាព* ។ នាយកដ្ឋានប្រតិបត្តិការគួរតាមដានស្ថានភាពនៃការស្នើសុំ ដែលបញ្ជូនដោយ OSPF ឬ OCRP បន្ថែមពីលើការតាមដានបែបនេះ ដែលកំពុងធ្វើឡើងដោយ OSPF និង OCRP ។ ការធ្វើបែបនេះនឹងបង្កើនតម្លាភាព និងភាពឆ្លើយតបរបស់យន្តការគណនេយ្យភាព ។

## ៨. បង្កើនប្រសិទ្ធភាព

*(i)* *ប្រើប្រាស់ធនធានឱ្យមានប្រយោជន៍ជាអតិបរមា* ។ យន្តការគណនេយ្យភាពនេះ គឺជាយន្តការមួយ ក្នុងចំណោមយន្តការ ដែលអស់ចំណាយច្រើនជាងគេ របស់ស្ថាប័នប្រហាក់ប្រហែលគ្នានេះ ។ ជាទស្សនាទានការចំណាយនានារបស់យន្តការគណនេយ្យភាពនេះគួរបែងចែកជាពីរផ្នែក: (i) ផ្នែក "ចំណាយថេរ" ដើម្បីទ្រទ្រង់ដល់រចនាសម្ព័ន្ធមូលដ្ឋាន សម្រាប់រក្សា និងប្រតិបត្តិការយន្តការគណនេយ្យភាព ដោយមិនគិតពីចំនួននៃការស្នើសុំ និង (ii) "ចំណាយអថេរ" ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរនៃតម្រូវការ ។ ការធ្វើបែបនេះនឹងជួយធានាឱ្យមានការប្រើប្រាស់ធនធានឱ្យមានប្រយោជន៍បំផុត ហើយក្នុងពេលជាមួយគ្នា អាចផ្តល់នូវសេវាយ៉ាងមានប្រសិទ្ធភាពដល់អ្នកដែលរងផលប៉ះពាល់ ។ ក្របខ័ណ្ឌពេលវេលានៃការពិនិត្យតាមដានរបស់ OSPF និង CRP គួររៀបចំកែសម្រួល ឱ្យសមស្របទៅតាមគម្រោងនីមួយៗ ។

*(ii)* *ធ្វើឱ្យដំណើរការនៃយន្តការគណនេយ្យភាពមានភាពងាយស្រួល* ។ ដំណាក់កាលដដែលៗនៅក្នុងដំណើរការនៃយន្តការគណនេយ្យភាពនេះគួរត្រូវបានលុបចោល ហើយគួរកំណត់ក្របខ័ណ្ឌពេលវេលាឱ្យមានភាពប្រាកដនិយម ដើម្បីកាត់បន្ថយចំណាយប្រតិបត្តិការ ។

*(iii)* *កែលំអការសម្របសម្រួល និងការសហការគ្នាជាសក្តានុពលរវាង OSPF និង CRP* ។ OSPF និង OCRP គួរចែករំលែកព័ត៌មានជាមួយគ្នាឱ្យបានពេញលេញ ដើម្បីចៀសវាងការធ្វើការងារត្រួតគ្នា ដែលមិនចាំបាច់ ។

## ៩. បង្កើនភាពស័ក្តិសិទ្ធិ

(i) *ផ្តល់លទ្ធភាពឱ្យមានការប្រើប្រាស់ការពិនិត្យឡើងវិញលើភាពអនុលោមដោយផ្ទាល់* ។ យន្តការគណនេយ្យភាពគួរលុបចោលនូវលក្ខខណ្ឌ ដែលតម្រូវឱ្យអ្នកដែលរងផលប៉ះពាល់ត្រូវឆ្លងកាត់ដំណើរការពិគ្រោះយោបល់ជាមុនសិន មុនពេលដែលពួកគេអាចដាក់ពាក្យសុំឱ្យមានការពិនិត្យឡើងវិញលើភាពអនុលោមបាន ។ ការធ្វើបែបនេះនឹងផ្តល់នូវជម្រើសកាន់តែច្រើនជាងមុន ដល់អ្នកដែលរងផលប៉ះពាល់ដោយសារគម្រោង ។

(ii) *ការចុះដល់ទីតាំង* ។ ភាពមិនប្រាកដប្រជានៅក្នុងការទទួលបានការអនុញ្ញាតពីប្រទេសខ្ចីកម្ចី សម្រាប់ការចុះដល់ទីតាំង គួរត្រូវបានកាត់បន្ថយ។ ដោយសារភាពរសើប និងសារៈសំខាន់នៃការចុះដល់ទីតាំង មានជម្រើសមួយចំនួនត្រូវលើកយកមកធ្វើការពិចារណា។

(iii) *បញ្ជាក់ឱ្យបានច្បាស់ពីអណត្តិការងាររបស់យន្តការគណនេយ្យភាព* ។ ការពិនិត្យឡើងវិញលើភាពអនុលោមមានលក្ខណៈជាការស្វែងរកការពិត។ អ្នកគ្រប់គ្រងគួរឆ្លើយតបចំពោះលទ្ធផលរកឃើញរបស់ CRP និងលើកជាអនុសាសន៍អំពីវិធានការដោះស្រាយ ដើម្បីស្នើសុំការឯកភាពពីក្រុមប្រឹក្សាភិបាល។ ការធ្វើបែបនេះនឹងជួយកំណត់បានយ៉ាងច្បាស់លាស់នូវព្រំដែនរវាងការពិនិត្យឡើងវិញលើភាពអនុលោម ការដោះស្រាយបញ្ហា និងការចាត់ចែងគម្រោង។

# I. សេចក្តីផ្តើម

១. គណនេយ្យភាព គឺជាសមាសធាតុស្នូលមួយនៃអភិបាលកិច្ចល្អ។ ក្នុងនាមជាទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិមួយ ដែលផ្តោតលើការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ នៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក, ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ខិតខំសម្រេចឱ្យបាននូវគណនេយ្យភាព, តម្លាភាព, ភាពបើកចំហ និងការចូលរួមជាសាធារណៈ ក្នុងកម្រិតស្តង់ដាខ្ពស់។ ការរក្សាយន្តការគណនេយ្យភាព ដែលមានប្រសិទ្ធភាព ដើម្បីឆ្លើយតបទៅនឹងការកើតទុក្ខមិនសុខចិត្តរបស់អ្នក ដែលរងផលប៉ះពាល់ដោយសារគម្រោងទទួលហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី មានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីសម្រេចឱ្យបាននូវការអភិវឌ្ឍប្រកបដោយសមធម៌ និងនិរន្តរភាព។ នៅក្នុងស្មារតីនេះ ធនាគារអភិវឌ្ឍន៍អាស៊ីបានបង្កើតមុខងារអធិការកិច្ច[១] នៅក្នុងឆ្នាំ ១៩៩៥ ដើម្បីផ្តល់នូវវេទិកាឯករាជ្យមួយ សម្រាប់ឱ្យអ្នកដែលរងផលប៉ះពាល់ដោយសារគម្រោងអាចលើកឡើងពីការព្រួយបារម្ភរបស់ខ្លួន និងដោះស្រាយបញ្ហានានា ដែលកើតឡើងដោយសារការមិនអនុលោមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ទៅតាមគោលនយោបាយ និងនីតិវិធីប្រតិបត្តិការងាររបស់ខ្លួន។ បន្ថែមពីលើមុខងារអធិការកិច្ចនេះ, ធនាគារអភិវឌ្ឍន៍អាស៊ីបានដាក់ឱ្យប្រើប្រាស់នូវយន្តការគណនេយ្យភាពបច្ចុប្បន្ននេះ (AM)[២] នៅក្នុងឆ្នាំ ២០០៣ បន្ទាប់ពីមានដំណើរការពិនិត្យឡើងវិញដ៏ល្អិតល្អន់មួយរួចមក។ គោលនយោបាយយន្តការគណនេយ្យភាពនេះត្រូវបានប្រកាសចូលជាធរមាន នៅថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៣។

២. គោលនយោបាយយន្តការគណនេយ្យភាពនេះតម្រូវឱ្យគណៈគ្រប់គ្រងធនាគារពិនិត្យឡើងវិញលើការអនុវត្តគោលនយោបាយនេះ ៣ ឆ្នាំ ក្រោយពេលដែលគោលនយោបាយនេះចូលជាធរមាន ពោលគឺមុនបំណាច់ឆ្នាំ ២០០៦។ ការពិនិត្យឡើងវិញនេះត្រូវបានពន្យារពេល ដោយសារតែមានករណីតែមួយចំនួនតូចប៉ុណ្ណោះ មុនឆ្នាំ ២០០៦។[៣] លើសពីនេះ ធនាគារអភិវឌ្ឍន៍អាស៊ីក៏បាន និងកំពុងធ្វើកំណែទម្រង់យុទ្ធសាស្ត្រ និងគោលនយោបាយ ចាប់តាំងពីឆ្នាំ ២០០៥ មក ដោយបានអនុម័តលើក្របខ័ណ្ឌគោលនយោបាយរយៈពេលវែង នៅក្នុងឆ្នាំ ២០០៨ និងគោលនយោបាយការពារសង្គម និងបរិស្ថានថ្មី (SPS) នៅក្នុងឆ្នាំ ២០០៩។ នៅដើមឆ្នាំ ២០១០ ក្រុមប្រឹក្សាភិបាលប្រតិបត្តិ (ឬហៅថាក្រុមប្រឹក្សាភិបាល) និងគណៈគ្រប់គ្រង បានពិចារណាឃើញថា វាដល់ពេលដែលត្រូវធ្វើការពិនិត្យឡើងវិញនេះ និងបានសម្រេចចិត្តធ្វើការពិនិត្យឡើងវិញនេះ រួមគ្នារវាងក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង។ ប្រធានធនាគារបានប្រកាស

---

[១] *ការបង្កើតមុខងារអធិការកិច្ច*, ធនាគារអភិវឌ្ឍន៍អាស៊ី, ១៩៩៥, ទីក្រុងម៉ានីល។

[២] *ការពិនិត្យឡើងវិញលើមុខងារអធិការកិច្ចៈ ការបង្កើតយន្តការគណនេយ្យភាពថ្មី*, ធនាគារអភិវឌ្ឍន៍អាស៊ី, ២០០៣, ទីក្រុងម៉ានីល។

[៣] មុនបំណាច់ឆ្នាំ ២០០៦, គណៈកម្មាធិការពិនិត្យឡើងវិញលើភាពអនុលោមបានទទួលសំណើចំនួន ២ ហើយការិយាល័យរបស់អ្នកសម្របសម្រួលគម្រោងពិសេស បានទទួលពាក្យបណ្តឹងដែលមានលក្ខណៈសមស្របចំនួន ៤។

អំពីការពិនិត្យឡើងវិញនេះ នៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំលើកទី ៤៣ របស់ក្រុមប្រឹក្សាភិបាលធនាគារអភិវឌ្ឍន៍អាស៊ី ដែលបានរៀបចំឡើងនៅទីក្រុង Tashkent កាលពីខែ ឧសភា ឆ្នាំ ២០១០។ ក្រុមការងារមួយត្រូវបានបង្កើតឡើង នៅក្នុងខែ មេសា ឆ្នាំ ២០១០ មានសមាជិក ៤ រូបមកពីក្រុមប្រឹក្សាភិបាល និងអគ្គនាយកគ្រប់គ្រង។ ក្រុមការងារនេះបានបង្ហើយបញ្ចប់លក្ខខណ្ឌយោង (TOR) សម្រាប់ការពិនិត្យឡើងវិញនេះ នៅក្នុងខែ មិថុនា ឆ្នាំ ២០១០ ដោយបានធ្វើការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាភិបាល និងបានជួលអ្នកជំនាញខាងក្រៅឯករាជ្យចំនួន ២ នាក់[៤] ដើម្បីជួយដល់ការពិនិត្យឡើងវិញនេះ។ ឧបសម្ព័ន្ធទី ១ មានរៀបរាប់ពីលក្ខខណ្ឌយោងសម្រាប់ការពិនិត្យឡើងវិញនេះ។

៣. ការពិនិត្យឡើងវិញនេះមានគោលដៅបូកសរុបបទពិសោធន៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី, ទាញបទពិសោធន៍ពីយន្តការស្រដៀងៗគ្នានេះ និងពិនិត្យលើវិសាលភាពសម្រាប់ធ្វើការកែលំអយន្តការគណនេយ្យភាព។ ការពិនិត្យឡើងវិញនេះបានឆ្លងកាត់តាមរយៈដំណើរការពិគ្រោះយោបល់ជាសាធារណៈជាច្រើន ដូចជា ការប្រជុំទល់មុខគ្នា, សិក្ខាសាលាសម្រាប់អ្នកពាក់ព័ន្ធចម្រុះ និងការធ្វើទស្សនកិច្ចទៅកាន់ទីតាំងរបស់គម្រោង។ អ្នកពាក់ព័ន្ធ ដែលត្រូវបានពិគ្រោះយោបល់ រួមមាន អ្នកដែលរងផលប៉ះពាល់ដោយសារគម្រោង, អ្នកទទួលផលរបស់គម្រោង, រដ្ឋាភិបាល, អង្គការក្រៅរដ្ឋាភិបាល, វិស័យឯកជន, សកលវិទ្យាល័យ និងស្ថាប័នស្រាវជ្រាវ, សមាជិកក្រុមប្រឹក្សាភិបាល, គណៈគ្រប់គ្រង និងបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងអ្នកដែលធ្វើការងារផ្នែកយន្តការគណនេយ្យភាពរបស់ស្ថាប័នដទៃទៀត។ ការពិគ្រោះយោបល់ក្នុងប្រទេស និងថ្នាក់តំបន់ ត្រូវបានរៀបចំឡើងនៅក្នុងប្រទេសស្រីលង្ការ, ជប៉ុន, សហរដ្ឋអាមេរិច, អាល្លឺម៉ង់, ឥណ្ឌូនេស៊ី និងហ្វីលីពី ចាប់ពីខែ កញ្ញា ដល់ខែ វិច្ឆិកា ឆ្នាំ ២០១០។ ក្រុមការងារនេះក៏បានស្វែងរកយោបល់ពីសាធារណជន តាមរយៈគេហទំព័រ ដែលត្រូវបានរៀបចំឡើងជាពិសេស សម្រាប់ការពិនិត្យឡើងវិញលើយន្តការគណនេយ្យភាពនេះផងដែរ។[៥] គ្រប់យោបល់សាធារណៈទាំងអស់ ដែលបានទទួល ត្រូវបានផ្សព្វផ្សាយតាមរយៈគេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី រួមគ្នាជាមួយនឹងព័ត៌មានសង្ខេបអំពីការពិគ្រោះយោបល់នៅក្នុងប្រទេស និងឯកសារ, បទបង្ហាញ និងរបាយការណ៍ពិនិត្យឡើងវិញ របស់អ្នកជំនាញខាងក្រៅ។

៤. ឯកសារបង្ហាញពីលទ្ធផលរកឃើញសំខាន់ៗ ដែលទទួលបានពីដំណើរការពិនិត្យឡើងវិញ និងលើកសំណើឱ្យមានការផ្លាស់ប្តូរ ដើម្បីបន្តពង្រឹងលទ្ធភាពប្រើប្រាស់, ភាពជឿជាក់, ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិរបស់យន្តការគណនេយ្យ-ភាព។

---

[៤] អ្នកជំនាញទាំងពីរ រួមមាន បណ្ឌិត Maartje van Putten និងបណ្ឌិត Ishrat Husain.

[៥] http://www.adb.org/AM-REview/.

## II. ការបង្កើត និងការវិវឌ្ឍនៃគោលនយោបាយយន្តការគណនេយ្យភាព

### ក. មុខងារអធិការកិច្ចឆ្នាំ ១៩៩៥

៥. នៅក្នុងខែ ធ្នូ ឆ្នាំ ១៩៩៥, ក្រុមប្រឹក្សាភិបាលរបស់ធនាគារអភិវឌ្ឍន៍អាស៊ីបានអនុម័តលើការបង្កើតមុខងារអធិការកិច្ច។ មុខងារអធិការកិច្ចនេះ គឺជាយន្តការគណនេយ្យភាពទី ៣ របស់ធនាគារអភិវឌ្ឍន៍ពហុភាគី (MDB) បន្ទាប់ពីមានការបង្កើតគណៈកម្មាធិការអធិការកិច្ច នៅក្នុងធនាគារពិភពលោក នៅក្នុងឆ្នាំ ១៩៩៣ និងយន្តការអង្កេតឯករាជ្យ នៅក្នុងធនាគារអភិវឌ្ឍន៍អន្តរអាមេរិច (IADB) នៅក្នុងឆ្នាំ ១៩៩៤ រួចមក។

៦. មុខងារអធិការកិច្ចនេះមានគោលបំណងបង្កើតនូវវេទការមួយ សម្រាប់ឱ្យអ្នកដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង ធ្វើការតវ៉ាទៅកាន់ស្ថាប័នឯករាជ្យមួយអំពីបញ្ហា ដែលពាក់ព័ន្ធនឹងភាពអនុលោមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ទៅតាមគោលនយោបាយ និងនីតិវិធីប្រតិបត្តិការងាររបស់ខ្លួន នៅក្នុងគម្រោង ដែលទទួលបានការគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី។ ចាប់ពីឆ្នាំ ១៩៩៥ ដល់ ២០០៣, ធនាគារអភិវឌ្ឍន៍អាស៊ីបានទទួលសំណើសុំឱ្យមានការធ្វើអធិការកិច្ចចំនួន ៨ ដែលក្នុងនោះសំណើចំនួន ៦ ត្រូវបានចាត់ទុកថាពុំមានលក្ខណៈសមស្រប។ សំណើមួយ ដែលពាក់ព័ន្ធជាមួយនឹងគម្រោងគ្រប់គ្រងទឹកសំណល់ Samut Prakarn[៦] នៅក្នុងប្រទេសថៃ បានឆ្លងកាត់តាមដំណើរការអធិការកិច្ចយ៉ាងពេញលេញ ចាប់ពីខែ មេសា ឆ្នាំ ២០០១ ដល់ ខែ មីនា ឆ្នាំ ២០០២។ សំណើសុំទី ៨ ឱ្យមានការធ្វើអធិការកិច្ចក្នុងគម្រោងធារាសាស្ត្រតាមដងទន្លេ Chashma (ដំណាក់កាលទី ៣) នៅក្នុងប្រទេសប៉ាគីស្ថាន[៧] ត្រូវបានទទួលនៅក្នុង ខែ វិច្ឆិកា ឆ្នាំ ២០០២។ នៅក្នុងខែ មេសា ឆ្នាំ ២០០៣, ក្រុមប្រឹក្សាអភិបាលបានផ្តល់ការអនុញ្ញាតឱ្យមានការធ្វើអធិការកិច្ច ដែលបានចាប់ផ្តើមធ្វើឡើង នៅក្នុងខែ ធ្នូ ឆ្នាំ ២០០៣ និងត្រូវបានបញ្ចប់ នៅក្នុងខែ មិថុនា ឆ្នាំ ២០០៤។ គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម (CRP) ដែលត្រូវបានបង្កើតឡើង ក្រោយការអនុម័តលើគោលនយោបាយយន្តការគណនេយ្យភាព នៅក្នុងឆ្នាំ ២០០៣ បានពិនិត្យតាមដានលើការអនុវត្តអនុសាសន៍របស់គណៈកម្មាធិការអធិការកិច្ច ចាប់ពីឆ្នាំ ២០០៤/០៥ ដល់ឆ្នាំ ២០០៨/០៩។

---

[៦] ធនាគារអភិវឌ្ឍន៍អាស៊ី ១៩៩៥, *របាយការណ៍ និងអនុសាសន៍របស់ប្រធានធនាគារ ផ្ញើទៅកាន់ក្រុមប្រឹក្សាភិបាល ពាក់ព័ន្ធនឹងសំណើកម្ចីដល់ប្រទេសថៃ សម្រាប់គម្រោងគ្រប់គ្រងទឹកសំណល់ Samut Prakarn*, ទីក្រុងម៉ានីល (កម្ចីលេខ 1410-THA ចំនួន ១៥០ លានដុល្លារ, ទទួលបានការអនុម័តក្នុងខែ ធ្នូ ឆ្នាំ ១៩៩៥)។

[៧] ធនាគារអភិវឌ្ឍន៍អាស៊ី ១៩៩១, *របាយការណ៍ និងអនុសាសន៍របស់ប្រធានធនាគារ ផ្ញើទៅកាន់ក្រុមប្រឹក្សាភិបាល: សំណើកម្ចី និងជំនួយបច្ចេកទេសដល់សាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន សម្រាប់គម្រោងធារាសាស្ត្រតាមដងទន្លេចាស្មា* (ដំណាក់កាលទី ៣), ទីក្រុងម៉ានីល (កម្ចីលេខ 1146-PAK ចំនួន ១៨៥ លានដុល្លារ, ទទួលបានការអនុម័តក្នុងខែ ធ្នូ ឆ្នាំ ១៩៩១)។

៧. នៅក្នុងកំឡុងពេលធ្វើអធិការកិច្ចលើគម្រោងគ្រប់គ្រងទឹកសំណល់ Samut Prakarn គេបានដឹងយ៉ាងច្បាស់ថា ដំណើរការអធិការកិច្ច គឺជាដំណើរការដ៏សែនស្មុគស្មាញមួយ។ អធិការកិច្ចនេះក៏បានលើកឡើងពីការព្រួយបារម្ភអំពីឯករាជ្យភាព, ភាពជឿជាក់, តម្លាភាព និងប្រសិទ្ធភាពរបស់មុខងារអធិការកិច្ចផងដែរ។ លក្ខណៈពិសេសរបស់គណៈ-កម្មាធិការ ដែលត្រូវបានជ្រើសរើសចេញពីបញ្ជីអ្នកជំនាញ ទៅតាមករណីមួយៗ ពុំមានអំណោយផលសម្រាប់ការបង្កើនចំណេះដឹង និងជំនាញឡើយ ហើយក៏មិនធានានិរន្តរភាពរបស់គណៈកម្មាធិការ ដែលមានសមាជិកជាអ្នកជំនាញបែបនេះផងដែរ។ ដោយសារតែគណៈកម្មាធិការជំនាញនេះរាយការណ៍ទៅគណៈកម្មាធិការអធិការកិច្ចរបស់ក្រុមប្រឹក្សាភិបាល (BIC), ទំនាក់ទំនងរវាងគណៈកម្មាធិការ និងគណៈកម្មាធិការអធិការកិច្ចរបស់ក្រុមប្រឹក្សាភិបាល និងរវាងគណៈកម្មា-ធិការអធិការកិច្ចរបស់ក្រុមប្រឹក្សាភិបាល និងក្រុមប្រឹក្សាភិបាល ធ្វើឱ្យមានផលប៉ះពាល់ដល់ដំណើរការអធិការកិច្ចនេះ។ កង្វះវិសាលភាពសម្រាប់ដោះស្រាយបញ្ហា ធ្វើឱ្យរាំងស្ទះដល់ការដោះស្រាយបញ្ហា ដែលប្រឈមដោយអ្នកដែលធ្វើការងារជាក់ស្តែង។ ដូច្នេះ នៅក្នុងឆ្នាំ ២០០២ និង ២០០៣, ធនាគារអភិវឌ្ឍន៍អាស៊ីបានពិនិត្យឡើងវិញលើមុខងារអធិការកិច្ច និងបានរៀបចំឱ្យមានការពិគ្រោះយោបល់ខាងក្រៅ និងខាងក្នុងយ៉ាងច្រើន។

៨. ការពិគ្រោះយោបល់ពង្រឹងការគាំទ្រដល់ (i) យន្តការគណនេយ្យភាពឯករាជ្យមួយ ដែលឆ្លើយតបចំពោះបណ្តឹងរបស់អ្នកដែលរងផលប៉ះពាល់ជាអវិជ្ជមាន ក្នុងគម្រោង ដែលទទួលបានជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី និង (ii) ការបង្កើនវិធានការដោះស្រាយបញ្ហា នៅក្នុងក្របខ័ណ្ឌដំណើរការយន្តការគណនេយ្យភាព។ មានការរំពឹងទុកដ៏ខ្ពស់មួយថា យន្តការថ្មីនេះគួរបង្កើនប្រសិទ្ធភាពនៃការអភិវឌ្ឍ និងគុណភាពគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ការពិនិត្យឡើងវិញនេះ ត្រូវបានដាក់បញ្ចូលទៅក្នុងយន្តការគណនេយ្យភាពថ្មីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី នៅក្នុងឆ្នាំ ២០០៣។

## ខ. យន្តការគណនេយ្យភាពឆ្នាំ ២០០៣

៩. ការផ្លាស់ប្តូរសំខាន់ជាងគេបំផុត ដែលដាក់ចេញដោយគោលនយោបាយឆ្នាំ ២០០៣ គឺការបង្កើតនូវដំណាក់កាលពីរដោយឡែកពីគ្នា ប៉ុន្តែបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក នៅក្នុងយន្តការគណនេយ្យភាពនេះ។ ដំណាក់កាលទាំង ២ នេះ រួមមាន (i) ដំណាក់កាលពិគ្រោះយោបល់[៨] ដែលមានអ្នកសម្របសម្រួលគម្រោងពិសេស (SPF) ជាអ្នកឆ្លើយតបទៅនឹងបញ្ហាជាក់លាក់ ដែលអ្នកទទួលរងផលប៉ះពាល់ជួបប្រទះ នៅក្នុងគម្រោង ដែលទទួលជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី តាមរយៈវិធីសាស្ត្រជាច្រើន ដែលមានលក្ខណៈក្រៅផ្លូវការ និងមានភាពបត់បែន និង (ii) ដំណាក់កាលពិនិត្យឡើង

[៨] គោលនយោបាយឆ្នាំ ២០០៣ ហៅដំណាក់កាល "ដោះស្រាយបញ្ហា" ថាជា "ដំណើរការពិគ្រោះយោបល់" ដើម្បីបញ្ចៀសមិនឱ្យមានការរំពឹងទុកមិនប្រាកដនិយមថា គ្រប់បញ្ហាទាំងអស់នឹងត្រូវបានដោះស្រាយធនាគារអភិវឌ្ឍន៍អាស៊ី។

វិញលើភាពអនុលោម [៩] ដែលមានគណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោមជាអ្នកស៊ើបអង្កេតលើការចោទប្រកាន់អំពីការប្រព្រឹត្តល្មើសទៅនឹងគោលនយោបាយ និងនីតិវិធីប្រតិបត្តិការងាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលធ្វើឱ្យមាន ឬទំនងជាធ្វើឱ្យមានផលប៉ះពាល់ដោយផ្ទាល់ដល់អ្នកដែលរងផលប៉ះពាល់ដោយសារគម្រោង។

១០. យន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី គឺជាយន្តការដំបូងរបស់ធនាគារអភិវឌ្ឍន៍ពហុភាគី ដែលលើសពីមុខងារអធិការកិច្ចសុទ្ធសាធ តាមរយៈការអនុវត្តការងារពីរ គឺការដោះស្រាយបញ្ហា និងការពិនិត្យឡើងវិញលើភាពអនុលោម សម្រាប់ប្រតិបត្តិការក្នុងវិស័យឯកជនផង និងវិស័យសាធារណៈផង។ [១០] ការអនុម័តបង្កើតមុខងារដោះស្រាយបញ្ហា គឺជាគំនិតច្នៃប្រឌិតថ្មីដ៏សំខាន់មួយ ដែលទទួលបានការកោតសរសើរពីស្ថាប័នដទៃទៀត។ គេរំពឹងថា គោលវិធីនេះនឹងមានប្រយោជន៍ជាពិសេសដល់អ្នកដែលរងផលប៉ះពាល់ដោយសារគម្រោង តាមរយៈការផ្ដោតការយកចិត្តទុកដាក់លើការដោះស្រាយបញ្ហារបស់ពួកគេ និងផ្ដល់លទ្ធភាពឱ្យពួកគេចូលរួមឱ្យបានសកម្ម នៅក្នុងដំណើរការដោះស្រាយបញ្ហា។ ក្រោមមុខងារអធិការកិច្ចមុន, ចុងក្រោយ នៅចុងដំណើរការដែលអូសបន្លាយយូរ អ្នកដាក់ពាក្យបណ្ដឹងនឹងទទួលបានព័ត៌មានអំពីអ្វីដែលកើតឡើង ចំពោះសំណើសុំរបស់ពួកគេ ប៉ុន្តែបញ្ហារបស់ពួកគេនៅតែមិនទាន់បានដោះស្រាយ។

១១. ការគាំទ្រពិសេសរបស់ស្ថាប័ន ត្រូវបានផ្ដល់ដល់ដំណាក់កាលពិគ្រោះយោបល់ផង និងដំណាក់កាលពិនិត្យឡើងវិញលើភាពអនុលោមផង ដើម្បីធ្វើការឆ្លុះបញ្ចាំងពីលក្ខណៈពិសេស និងតម្រូវការរបស់ដំណាក់កាលទាំងនេះ។ ដំណាក់-កាលពិគ្រោះយោបល់ មានអ្នកសម្របសម្រួលគម្រោងពិសេសម្នាក់ ដែលទទួលបានជំនួយពីការិយាល័យរបស់អ្នកសម្របសម្រួលគម្រោងពិសេស។ អ្នកសម្របសម្រួលគម្រោងពិសេសរាយការណ៍ដោយផ្ទាល់ ទៅកាន់ប្រធានធនាគារ។ ដំណាក់កាលពិនិត្យឡើងវិញលើភាពអនុលោមនេះ មានសមាជិកចំនួន ៣ រូប មកពីគណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម (CRP) ដែលក្នុងនោះមានម្នាក់ជាប្រធាន។ CRP រាយការណ៍ដោយផ្ទាល់ទៅកាន់ក្រុមប្រឹក្សាភិបាលអំពីគ្រប់សកម្មភាពទាំងអស់ លើកលែងតែសកម្មភាពជាក់លាក់ ដើម្បីផ្ដល់ការឯកភាពលើលក្ខខណ្ឌយោង និងក្របខ័ណ្ឌពេលវេលារបស់ CRP និងការពិនិត្យឡើងវិញលើសេចក្ដីព្រាងរបាយការណ៍ពិនិត្យតាមដានរបស់ CRP ដែលក្នុងករណី

---

[៩] ពាក្យ "ការពិនិត្យឡើងវិញលើភាពអនុលោម" ត្រូវបានប្រើប្រាស់ នៅក្នុងគោលនយោបាយឆ្នាំ ២០០៣ ដើម្បីចៀសវាងការភ្ជាប់ទំនាក់ទំនងដោយអវិជ្ជមានជាមួយពាក្យ "អធិការកិច្ច"។

[១០] ការិយាល័យប្រជាពលរដ្ឋសម្រាប់ផ្ដល់ប្រឹក្សាអំពីភាពអនុលោម (CAO) របស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ត្រូវបានបង្កើតដំបូងឡើយដើម្បីដាក់ឱ្យដំណើរការនូវការដោះស្រាយបញ្ហាសម្រាប់ប្រតិបត្តិការក្នុងវិស័យឯកជន។ ធនាគារអភិវឌ្ឍន៍អាស៊ី គឺជាស្ថាប័នដំបូងគេ ដែលបានដាក់ឱ្យដំណើរការនូវការដោះស្រាយបញ្ហាសម្រាប់ប្រតិបត្តិការក្នុងវិស័យសាធារណៈផង និងវិស័យឯកជនផង។

នេះ CRP ត្រូវរាយការណ៍ទៅកាន់គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោមរបស់ក្រុមប្រឹក្សាភិបាល ។ ទាំងអ្នកសម្របសម្រួលគម្រោងពិសេស ទាំងគណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម មានតួនាទីភារកិច្ចធ្វើការពិនិត្យតាមដានលើការអនុវត្តសកម្មភាពដោះស្រាយបញ្ហានានា។

១២. គោលនយោបាយនេះ បានផ្តោតការយកចិត្តទុកដាក់ជាពិសេស លើទំនាក់ទំនងរវាងដំណាក់កាលពិគ្រោះយោបល់ និងដំណាក់កាលពិនិត្យឡើងវិញលើភាពអនុលោម និងការចុះដល់ទីតាំងជាក់ស្តែង។ ពាក់ព័ន្ធជាមួយនឹងទំនាក់ទំនង គោលនយោបាយនេះគួសបញ្ជាក់ថា ការដោះស្រាយបញ្ហាគួរធ្វើឡើងមុនពេលមានការពិនិត្យឡើងវិញលើភាពអនុលោម ដើម្បីផ្តល់លទ្ធភាពឱ្យមានការដោះស្រាយសកម្មភាពភ្លាមៗ សម្រាប់ឆ្លើយតបទៅនឹងការព្រួយបារម្ភរបស់អ្នកដែលរងផលប៉ះពាល់ដោយសារគម្រោង។ ក្នុងពេលជាមួយគ្នា គោលនយោបាយនេះបានផ្តល់នូវជម្រើសឱ្យអ្នកដាក់ពាក្យបណ្តឹង ចាកចេញពីដំណាក់កាលពិគ្រោះយោបល់ និងស្នើសុំឱ្យមានការពិនិត្យឡើងវិញលើភាពអនុលោម។ ពាក់ព័ន្ធនឹងការចុះដល់ទីតាំងជាក់ស្តែង, គោលនយោបាយនេះបានអនុម័តលើគោលវិធីមួយ ដែលថាការចុះដល់ទីតាំងជាក់ស្តែងនេះ គួរធ្វើឡើង តែនៅពេលដែលមានការយល់ព្រមពីប្រទេសខ្ចីតែប៉ុណ្ណោះ។

## III. បទពិសោធន៍ ចាប់តាំងពីឆ្នាំ ២០០៣ មក

### ក. ដំណាក់កាលពិគ្រោះយោបល់

១៣. គិតមកដល់បំណាច់ឆ្នាំ ២០១០ ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេសបានទទួលពាក្យបណ្តឹងចំនួន ៣២ ចាប់តាំងពីពេលដែលយន្តការគណនេយ្យភាពបានចូលជាធរមាន នៅក្នុងខែ ធ្នូ ឆ្នាំ ២០០៣ មក។[១១] ពាក្យបណ្តឹងចំនួន ១១ ក្នុងចំណោមពាក្យបណ្តឹងទាំងនេះ មានលក្ខណៈសមស្របសម្រាប់ដោះស្រាយបញ្ហា។ ចំនួនពាក្យបណ្តឹងកើនឡើងដល់ចំនួនខ្ពស់បំផុត នៅក្នុងឆ្នាំ ២០០៩ ចំនួន ១៣ និងឆ្នាំ ២០១០ ចំនួន ៧។ ជាមធ្យម ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេសទទួលបានពាក្យបណ្តឹងប្រហែលជា ៥ ក្នុងមួយឆ្នាំ (តារាងទី ១)។

[១១] ករណី ដែល OSPF ទទួលបាន ហៅថា "ពាក្យបណ្តឹង" នៅក្នុងគោលនយោបាយឆ្នាំ ២០០៣។

**តារាងទី ១: ចំនួនពាក្យបណ្ដឹង ដែលការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេសទទួលបាន - តាមឆ្នាំ**

| ឆ្នាំ | ចំនួនបណ្ដឹងសរុប | បណ្ដឹងដែលមានលក្ខណៈសមស្រប |
|---|---|---|
| ២០០៤ | ៣ | ២ |
| ២០០៥ | ១ | ១ |
| ២០០៦ | ៦ | ១ |
| ២០០៧ | ២ | ១ |
| ២០០៨ | ០ | ០ |
| ២០០៩ | ១៣ | ៤ |
| ២០១០ | ៧ | ២ |
| **សរុប** | **៣២** | **១១** |

ប្រភព: បញ្ជីបណ្ដឹងរបស់ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០

១៤. ក្នុងចំណោមពាក្យបណ្ដឹងចំនួន ២១ ដែលមិនមានលក្ខណៈសមស្រប, នៅក្នុងពាក្យបណ្ដឹងចំនួន ១៤, អ្នកដាក់ពាក្យបណ្ដឹងពុំបានខិតខំដោយសុច្ឆន្ទៈ ដើម្បីដោះស្រាយបញ្ហាជាមួយនឹងនាយកដ្ឋានប្រតិបត្តិការ, ២ ពាក់ព័ន្ធជាមួយនឹងបញ្ហាលទ្ធកម្ម ដែលត្រូវដោះស្រាយដោយការិយាល័យសេវាប្រតិបត្តិការកណ្ដាល (COSO), ២ ត្រូវបានដាក់ប្ដឹងក្រោយពេលចេញរបាយការណ៍បញ្ចប់គម្រោង (PCRs) និង ៣ មិនពាក់ព័ន្ធជាមួយនឹងគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (តារាងទី ២)។

**តារាងទី ២: មូលហេតុដែលពាក្យបណ្ដឹងត្រូវបានរកឃើញថាមិនមានលក្ខណៈសមស្រប (២០០២-២០១០)**

| មូលហេតុ | ចំនួន | ភាគរយ (%) |
|---|---|---|
| ពាក្យបណ្ដឹងពុំចំបញ្ហាជាមួយនាយកដ្ឋានប្រតិបត្តិការ ដែលមាននៅក្នុងពាក្យបណ្ដឹង | ១៤ | ៦៦,៧ |
| អ្នកដាក់ពាក្យបណ្ដឹងពុំមានទទួលរងផលប៉ះពាល់អវិជ្ជមាន គួរឱ្យកត់សម្គាល់ ដោយសារគម្រោង | ៣ | ១៤,៣ |
| របាយការណ៍បញ្ចប់គម្រោងត្រូវបានចេញរួច | ២ | ៩,៥ |
| ពាក់ព័ន្ធនឹងលទ្ធកម្ម | ២ | ៩,៥ |
| **សរុប** | **២១** | **១០០,០** |

ប្រភព: បញ្ជីបណ្ដឹងរបស់ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០

១៥. មានបណ្តឹងជាងពាក់កណ្តាល (១៧ ក្នុងចំណោម ៣២) ទទួលបានពីអនុតំបន់អាស៊ីកណ្តាល និងខាងលិច បន្ទាប់មកបណ្តឹងពីអាស៊ីខាងត្បូង (៨) និងអាស៊ីអាគ្នេយ៍ (៦) (តារាងទី ៣)។

**តារាងទី ៣: ចំនួនបណ្តឹង ដែលការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេសទទួលបាន – បែងចែកតាមតំបន់**

| តំបន់ | ចំនួន | ភាគរយ (%) |
|---|---|---|
| អាស៊ីខាងត្បូង | ៨ | ២៥,០ |
| អាស៊ីកណ្តាល និងខាងលិច* | ១៧ | ៥៣,១ |
| អាស៊ីអាគ្នេយ៍ | ៦ | ១៨,៨ |
| អាស៊ីខាងកើត | ១ | ៣,១ |
| **សរុប** | **៣២** | **១០០,០** |

* នេះរាប់បញ្ចូលទាំងប្រទេសប៉ាគីស្ថាន.

ប្រភព: បញ្ជីបណ្តឹងរបស់ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០

១៦. វិស័យផ្លូវគមនាគមន៍មានពាក្យបណ្តឹងច្រើនជាងគេ គឺចំនួន ១៤ ស្មើនឹង ៤៣,៨% នៃបណ្តឹងសរុប។ បន្ទាប់មកគឺសេវាផ្គត់ផ្គង់ទឹក និងហេដ្ឋារចនាសម្ព័ន្ធ និងសេវាក្នុងទីក្រុងដទៃទៀត។ ជារួម បណ្តឹងនៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ (ដឹកជញ្ជូន, ទឹក និងថាមពល) ស្មើនឹង ៧៥% នៃបណ្តឹងសរុប (តារាងទី ៤)។

**តារាងទី ៤: បណ្តឹងដែលទទួលបានបែងចែកតាមវិស័យ, ២០០៤-២០១០**

| វិស័យ | ចំនួន | ភាគរយ (%) |
|---|---|---|
| ផ្លូវគមនាគមន៍ | ១៤ | ៤៣,៨ |
| សេវាផ្គត់ផ្គង់ទឹក និងហេដ្ឋារចនាសម្ព័ន្ធ និងសេវាក្នុងទីក្រុងដទៃទៀត | ៦ | ១៨,៨ |
| ថាមពល | ៤ | ១២,៥ |
| កសិកម្ម និងធនធានធម្មជាតិ | ៤ | ១២,៥ |
| ឧស្សាហកម្ម និងពាណិជ្ជកម្ម | ១ | ៣,១ |
| ហេដ្ឋារចនាសម្ព័ន្ធជនបទ | ១ | ៣,១ |
| ការអប់រំ | ១ | ៣,១ |
| ជំនួយបច្ចេកទេសថ្នាក់តំបន់ | ១ | ៣,១ |
| **សរុប** | **៣២** | **១០០,០** |

ប្រភព: បញ្ជីបណ្តឹងរបស់ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០

១៧. ពាក្យបណ្តឹងប្រហែលជា ២ ភាគ ៣ ពាក់ព័ន្ធជាមួយនឹងការតាំងទីលំនៅជាថ្មី, ព័ត៌មានមិនគ្រប់គ្រាន់, ការពិគ្រោះយោបល់ និងការចូលរួម ។ ពាក់ព័ន្ធនឹងការតាំងទីលំនៅជាថ្មី, ពាក្យបណ្តឹងសំខាន់ៗពាក់ព័ន្ធជាមួយនឹងភាពគ្រប់គ្រាន់នៃអត្រាសំណង (តារាងទី ៥) ។

**តារាងទី ៥: បញ្ហា ដែលបានលើកឡើងនៅក្នុងបណ្តឹង, ២០០៤-២០១០**

| ល.រ | បញ្ហា | ចំនួនដង ដែលបានលើកឡើង នៅក្នុងបណ្តឹង | ភាគរយ (%) |
|---|---|---|---|
| ១ | ការតាំងទីលំនៅជាថ្មី | ២៦ | ៣៥.៦ |
| ២ | ព័ត៌មាន | ១២ | ១៦.៤ |
| ៣ | ការពិគ្រោះយោបល់ និងការចូលរួម | ១០ | ១៣.៧ |
| ៤ | កសិកម្ម, ធនធានធម្មជាតិ, បរិស្ថាន | ៩ | ១២.៣ |
| ៥ | សហគមន៍ និងបញ្ហាសង្គម * | ៨ | ១១.០ |
| ៦ | ថាមពល | ២ | ២.៧ |
| ៧ | ដទៃទៀត ** | ៦ | ៨.២ |
| | **សរុប** | **៧៣** | **១០០.០** |

* នេះរាប់បញ្ចូលបញ្ហាយេនឌ័រ ដែលត្រូវបានលើកឡើងម្តង

** ទាំងនេះ រួមមាន បញ្ហាដូចតទៅ: ទំនាក់ទំនងបែងចែក, ទឹកជំនន់, លទ្ធកម្ម, ការផ្អាកកម្ចី, អប់រំ និងការបញ្ចប់កិច្ចសន្យា

ប្រភព: បញ្ជីបណ្តឹងរបស់ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០

១៨. មានបណ្តឹងជាងពាក់កណ្តាលត្រូវបានប្តឹង ដោយមានអង្គការក្រៅរដ្ឋាភិបាលគឺជាអ្នកជួយ (តារាងទី ៦) ។ តួនាទីសកម្មរបស់អង្គការក្រៅរដ្ឋាភិបាល នៅក្នុងការធ្វើជាតំណាងឱ្យអ្នកស្នើសុំ គឺស្របជាមួយនឹងធនាគារអភិវឌ្ឍន៍ពហុភាគីដទៃទៀត ។ ឧទាហរណ៍ នៅក្នុងធនាគារអភិវឌ្ឍន៍អាហ្វ្រិក (AfDB), បណ្តឹងសរុបទាំង ៣ ដែលយន្តការពិនិត្យឡើងវិញដោយឯករាជ្យ (IRM) ទទួលបាន នៅក្នុងឆ្នាំ ២០០៩ ត្រូវបានអង្គការក្រៅរដ្ឋាភិបាលជាអ្នកដាក់ ក្នុងនាមតំណាងឱ្យអ្នកស្នើសុំ ។[១២]

[១២] ធនាគារអភិវឌ្ឍន៍អាហ្វ្រិច - អង្គភាពពិនិត្យឡើងវិញលើភាពអនុលោម និងផ្សះផ្សារ, ២០០៩, *របាយការណ៍ប្រចាំឆ្នាំ ២០០៩ ស្តីពីយន្តការពិនិត្យឡើងវិញដោយឯករាជ្យ*. Tunis.

**តារាងទី ៦: បណ្ដឹងដែលទទួលបានពីអ្នកដែលរងផលប៉ះពាល់ និងអង្គការក្រៅរដ្ឋាភិបាល**

| *ពាក្យបណ្ដឹង* | *ចំនួន* | *ភាគរយ (%)* |
|---|---|---|
| អ្នកដែលរងផលប៉ះពាល់ | ១៤ | ៤៣,៨ |
| អង្គការក្រៅរដ្ឋាភិបាល និងអ្នកដែលរងផលប៉ះពាល់ | ១៨ | ៥៦,៣ |
| **សរុប** | **៣២** | **១០០,០** |

ប្រភព: បញ្ជីបណ្ដឹងរបស់ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០

## ខ. ដំណាក់កាលពិនិត្យឡើងវិញលើភាពអនុលោម

១៩. គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម (CRP) បានទទួលសំណើចំនួន ៣ [១៣] សម្រាប់ការពិនិត្យឡើងវិញលើភាពអនុលោម ចាប់តាំងពីឆ្នាំ ២០០៤ មក ដែលក្នុងនោះមានសំណើចំនួន ២ ដែលមានលក្ខណៈសមស្រប (តារាងទី ៧)។ ឆ្លើយតបទៅតាមការស្នើសុំឱ្យមានការពិនិត្យឡើងវិញលើភាពអនុលោម ក្នុងគម្រោងផ្គត់ផ្គង់ទឹក Nepal Melamchi, CRP បានចុះទៅទីតាំងជាក់ស្ដែង ដើម្បីកំណត់ពីភាពសមស្រប។ គេពុំអាចបញ្ជាក់ពីការចោទប្រកាន់អំពីផលប៉ះពាល់ និងភាពមិនអនុលោមបាននោះឡើយ ដូច្នេះគេបាត់ចាត់ទុកសំណើនេះថាពុំមានលក្ខណៈសមស្រប។ CRP បានធ្វើការពិនិត្យឡើងវិញលើភាពអនុលោមក្នុងគម្រោងអភិវឌ្ឍន៍ផ្លូវគមនាគមន៍ភាគខាងត្បូងរបស់ប្រទេសស្រីលង្ការ (STDP) [១៤] និងបានពិនិត្យតាមដានលើការអនុវត្តសកម្មភាពដោះស្រាយបញ្ហា រយៈពេលជាង ៤ ឆ្នាំកន្លងមកហើយ។ សម្រាប់គម្រោងកែលំអបរិស្ថាន Fuzhou [១៥] នៅក្នុងសាធារណរដ្ឋប្រជាមានិតចិន, CRP បានចេញរបាការណ៍របស់ខ្លួន [១៦] នៅក្នុងខែ តុលា ឆ្នាំ ២០១០ ដោយពុំមានសេចក្ដីសន្និដ្ឋាន។ CRP បានលើកឡើងថា ប្រសិនបើ

---

[១៣] ករណី ដែល CRP ទទួលបាន ហៅថា "សំណើ" នៅក្នុងគោលនយោបាយឆ្នាំ ២០០៣។

[១៤] ធនាគារអភិវឌ្ឍន៍អាស៊ី ១៩៩៩ *របាយការណ៍ និងអនុសាសន៍របស់ប្រធានធនាគារ ផ្ញើទៅកាន់ក្រុមប្រឹក្សាភិបាល អំពីសំណើកម្ចីដល់សាធារណរដ្ឋសង្គមនិយមប្រជាធិបតេយ្យស្រីលង្ការ សម្រាប់គម្រោងអភិវឌ្ឍន៍គមនាគមន៍ភាគខាងត្បូង,* ម៉ានីល (កម្ចីលេខ 1711–SRI[SF])។

[១៥] ធនាគារអភិវឌ្ឍន៍អាស៊ី ២០០៥ *របាយការណ៍ និងអនុសាសន៍របស់ប្រធានធនាគារ ផ្ញើទៅកាន់ក្រុមប្រឹក្សាភិបាល អំពីសំណើកម្ចីដល់សាធារណរដ្ឋប្រជាមានិតចិន សម្រាប់គម្រោងកែលំអបរិស្ថាន Fuzhou* , ម៉ានីល (កម្ចីលេខ 2176-PRC ចំនួន ៥៥,៨ លានដុល្លារ ដែលបានទទួលការអនុម័ត នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៥)។

[១៦] គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម, *របាយការណ៍ផ្ញើទៅកាន់ក្រុមប្រឹក្សាភិបាលអំពីដំណើរការពិនិត្យឡើងវិញលើភាពអនុលោមសម្រាប់សំណើលេខ ២០០៩/០១ ពាក់ព័ន្ធនឹងគម្រោងកែលំអបរិស្ថាន Fuzhou* , ម៉ានីល (ធនាគារអភិវឌ្ឍន៍អាស៊ី កម្ចីលេខ 2176-PRC)។

ពុំមានការចុះទៅដល់ទីតាំងជាក់ស្តែង គេមិនអាចចេញជាលទ្ធផលរកឃើញ ឬលើកឡើងនូវអនុសាសន៍អ្វីនោះទេ។ CRP បានពិនិត្យតាមដានលើការអនុវត្តអនុសាសន៍របស់គណៈកម្មាធិការអធិការកិច្ចសម្រាប់គម្រោងធារាសាស្ត្រតាមទន្លេង Chashma (ដំណាក់កាលទី ៣)[១៧] នៅក្នុងប្រទេសប៉ាគីស្ថាន ពីឆ្នាំ ២០០៤/០៥ ដល់ ២០០៨/០៩ បើទោះបីជាស្ថានភាពសន្តិសុខរារាំងមិនឱ្យ CRP ចុះដល់ទីតាំងជាក់ស្តែង ចាប់តាំងពីឆ្នាំ ២០០៧ មកក៏ដោយ។

**តារាងទី ៧: សំណើសុំការពិនិត្យឡើងវិញលើភាពអនុលោម**

| លេខសំណើ | កាលបរិច្ឆេទទទួល* | ឈ្មោះគម្រោង |
|---|---|---|
| ២០០៩/១ | ៣ មិថុនា ២០០៩ | សាធារណរដ្ឋប្រជាមានិតចិន: គម្រោងកែលំអបរិស្ថាន Fuzhou កម្ចីលេខ 2176-PRC. *មានលក្ខណៈសមស្រប* |
| ២០០៤/២ | ៦ ធ្នូ ២០០៤ | ប្រទេសនេប៉ាល់: Melamchi - កម្ចីលេខ 1820-NEP (SF). *មិនមានលក្ខណៈសមស្រប.* |
| ២០០៤/១ | ២ ធ្នូ ២០០៤ | ប្រទេសស្រីលង្ការ: គម្រោងអភិវឌ្ឍន៍ផ្លូវគមនាគមន៍ភាគខាងត្បូង កម្ចីលេខ 1711-SRI (SF). *មានលក្ខណៈសមស្រប* |
| **អណត្តិពិនិត្យតាមដានពិសេស: គម្រោងធារាសាស្ត្រ Chashma (ជំហានទី ៣)** | | |
| នៅក្នុងខែ សីហា ឆ្នាំ ២០០៤, នាយកបានផ្តល់ការអនុម័តឱ្យCRP ពិនិត្យតាមដានការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ទៅតាមការស្នើសុំឱ្យមានការធ្វើអធិការកិច្ចលើគម្រោងនេះ។ នេះគឺជាអណត្តិពិនិត្យតាមដានពិសេសមួយសម្រាប់ CRP ។ | | |

*ដោយមានព័ត៌មានមូលដ្ឋានចាំបាច់

ប្រភព: បញ្ជីសំណើសុំរបស់ CRP

---

[១៧] ធនាគារអភិវឌ្ឍន៍អាស៊ី ១៩៩១ *របាយការណ៍ និងអនុសាសន៍របស់ប្រធានធនាគារ ផ្ញើទៅកាន់ក្រុមប្រឹក្សាភិបាល: សំណើកម្ចី និងជំនួយបច្ចេកទេសដល់សាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន សម្រាប់គម្រោងធារាសាស្ត្រតាមដងទន្លេចាស្មា* (ដំណាក់កាលទី ៣) , ទីក្រុងម៉ានីល (កម្ចីលេខ 1146-PAK ចំនួន ១៨៥ លានដុល្លារ, ទទួលបានការអនុម័តក្នុងខែ ធ្នូ ឆ្នាំ ១៩៩១)។

## IV. ការវាយតម្លៃលើយន្តការគណនេយ្យភាព

២០. ការស្រាវជ្រាវកាលពីពេលថ្មីៗនេះបានបង្ហាញនូវកត្តាចំនួន ៤ [១៨] ដែលអាចយកមកប្រើប្រាស់ ដើម្បីផ្តល់ការណែនាំដល់ការរៀបចំ និងការវាយតម្លៃលើយន្តការគណនេយ្យភាពមួយ។ កត្តាទាំង ៤ នេះ រួមមាន លទ្ធភាពប្រើប្រាស់ (accessibility), ភាពជឿជាក់ (credibility), ប្រសិទ្ធភាព (efficiency) និងភាពស័ក្តិសិទ្ធិ (effectiveness) ដែលគេនិយមហៅថាលក្ខណៈវិនិច្ឆ័យ ACEE។ លក្ខណៈវិនិច្ឆ័យនីមួយៗមានសមាសធាតុរងជាច្រើន។ លទ្ធភាពប្រើប្រាស់រួមមាន ការយល់ដឹង, ភាពសមស្របសម្រាប់ដាក់សំណើ និងដំណើរការរបស់យន្តការគណនេយ្យភាព។ ភាពជឿជាក់រួមមាន ឯករាជ្យភាព, តម្លាភាព និងការចូលរួម។ ប្រសិទ្ធភាពពាក់ព័ន្ធនឹងពេលវេលាផង និងចំណាយផង ខណៈពេលដែលភាពស័ក្តិសិទ្ធិគ្របដណ្តប់ទូលំទូលាយលើលក្ខណៈ ដែលពាក់ព័ន្ធជាមួយសមត្ថភាព និងលទ្ធផលការងារ ដើម្បីសម្រេចគោលដៅ ដែលចង់បាន។ លក្ខណៈវិនិច្ឆ័យ ACEE មានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក, មិនទាន់មានអស់ និងពុំមានឋានានុក្រមនៃសារៈសំខាន់នោះឡើយ។ ឯកសារនេះប្រើប្រាស់ ACEE ជាក្របខ័ណ្ឌវិភាគមួយ ដើម្បីធ្វើការវាយតម្លៃយន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងកំណត់ពីបញ្ហានានា។

### ក. លទ្ធភាពប្រើប្រាស់

#### ១. ការយល់ដឹង

២១. ទាំងការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស (OSPF) និងការិយាល័យរបស់គណៈកម្មការពិនិត្យឡើងលើភាពអនុលោម (OCRP) បានធ្វើការផ្សព្វផ្សាយ និងពិគ្រោះយោបល់ក្នុងលក្ខណៈជាប្រព័ន្ធជាមួយអ្នកទទួលផលរបស់គម្រោង, អ្នកទទួលផលប៉ះពាល់ដោយសារគម្រោង, រដ្ឋាភិបាល, ក្រុមសង្គមស៊ីវិល, អង្គការក្រៅរដ្ឋាភិបាលវិស័យឯកជន និងវិស័យសាធារណៈ។ ការិយាល័យទាំងពីរប្រើប្រាស់គោលវិធីជាច្រើន ដើម្បីផ្សព្វផ្សាយដល់សហគមន៍មូលដ្ឋាន ដូចជា ការធ្វើទំនាក់ទំនងដោយផ្ទាល់ និងការបង្កើនការយល់ដឹងដល់បុគ្គលិក អង្គការក្រៅរដ្ឋាភិបាល និងរដ្ឋាភិបាល ដែលសុទ្ធតែជាច្រកសំខាន់ៗ សម្រាប់ផ្តល់ព័ត៌មានដល់សហគមន៍មូលដ្ឋាន។ OSPF និង OCRP បានធ្វើការងារជាមួយនាយកដ្ឋានប្រព័ន្ធថវិកា បុគ្គលិក និងគ្រប់គ្រង (BPMSD) របស់ធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីរៀបចំវគ្គបណ្តុះ

---

[១៨] Weiss, Edith Brown, កំណត់សម្គាល់អំពីលក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃស្ថាប័នគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍ពហុភាគី: សន្ទរកថា ថ្លែងទៅកាន់កិច្ចប្រជុំលើកទី ៤ ស្តីពីយន្តការគណនេយ្យភាព, ទីក្រុងឡុង, ប្រទេសអង់គ្លេស, ២១ មិថុនា ២០០៧។ នៅក្នុងការបោះពុម្ពផ្សាយរបស់ធនាគារពិភពលោក ២០០៩ *គណនេយ្យភាពក្នុងធនាគារពិភពលោក: គណៈកម្មការអធិការកិច្ច ក្នុងរយៈពេល ១៥ ឆ្នាំ (ទំព័រ ១០៩-១១៣)* ទីក្រុងវ៉ាស៊ីងតោន

បណ្តុលអំពីការគ្រប់គ្រងទំនាស់ និងការពិនិត្យឡើងវិញលើភាពអនុលោម ក្នុងគោលបំណងបង្កើនសមត្ថភាពរបស់បុគ្គលិក។ នៅក្នុងរយៈពេល ២ ឆ្នាំចុងក្រោយនេះ ចំនួនបណ្តឹងដែលផ្ញើមក OSPF មានការកើនឡើង ដែលអាចដោយសារតែមានការផ្សព្វផ្សាយ និងកំណើនការយល់ដឹងអំពីយន្តការគណនេយ្យភាព។ អ៊ីនធឺណិតគឺជាប្រព័ន្ធផ្សព្វផ្សាយដ៏សំខាន់មួយ សម្រាប់ធ្វើការផ្សព្វផ្សាយចំណេះដឹងអំពីយន្តការគណនេយ្យភាព។ គេហទំព័ររបស់ OSPF និង OCRP មានព័ត៌មានដ៏ច្រើន ដូចជា ជំហានច្បាស់លាស់ ដើម្បីដាក់ពាក្យបណ្តឹងជាដើម។ យុទ្ធសាស្ត្រផ្សព្វផ្សាយរួមគ្នារបស់ OSPF និង OCRP ត្រូវបានអនុម័ត នៅក្នុងឆ្នាំ ២០១០។ ធនាគារអភិវឌ្ឍន៍អាស៊ីក៏បានអនុម័តលើហិរញ្ញប្បទានជំនួយបច្ចេកទេស[១៩] ក្នុងទឹកប្រាក់ចំនួន ២២៥000 ដុល្លារ ដល់ OCRP ផងដែរ ដើម្បីរ៉ាប់រងលើការសាកល្បងកម្មវិធីផ្សព្វផ្សាយនៅកម្រិតអនុតំបន់ នៅក្នុងឆ្នាំ ២០១០។ កម្មវិធីនេះបានចាប់ផ្តើមចេញពីអនុតំបន់ប៉ាស៊ីហ្វិក ហើយរំពឹងថានឹងពង្រីកទៅកាន់ប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិកដទៃទៀត ប្រសិនបើការសាកល្បងនេះទទួលបានជោគជ័យ។

២២. ប៉ុន្តែ ការពិគ្រោះយោបល់នានាបង្ហាញថា ការយល់ដឹងអំពីយន្តការគណនេយ្យភាព នៅមានកម្រិតនៅឡើយ ជាពិសេស នៅក្នុងចំណោមសហគមន៍មូលដ្ឋាន។ ការផ្សព្វផ្សាយព័ត៌មាន ដល់អ្នកដែលមានលទ្ធភាពតិចតួច ដើម្បីប្រើប្រាស់អ៊ីនធឺណិត នៅតែជាបញ្ហាប្រឈមដ៏សំខាន់មួយនៅឡើយ។

## ២. លក្ខណៈវិនិច្ឆ័យ ដើម្បីកំណត់ពីភាពសមស្រប

២៣. លក្ខណៈវិនិច្ឆ័យ ដើម្បីកំណត់ពីភាពសមស្របនៃយន្តការគណនេយ្យភាព គឺស្រដៀងនឹងលក្ខណៈវិនិច្ឆ័យនៃយន្តការរបស់ធនាគារអភិវឌ្ឍន៍ពហុភាគីដទៃទៀតផងដែរ។ លក្ខណៈចំនួន ៣ ដែលធ្វើឱ្យមានការជជែកវែកញែកច្រើនជាងគេ នៅក្នុងការពិគ្រោះយោបល់ គឺ (i) បច្ចុប្បន្ននេះ យ៉ាងហោចណាស់ត្រូវមានមនុស្ស ២ នាក់ ដើម្បីអាចដាក់ពាក្យបណ្តឹងមួយបាន, (ii) កាលបរិច្ឆេទឱសានវាទសម្រាប់ដាក់ពាក្យបណ្តឹង គឺនៅពេលចេញរបាយការណ៍បញ្ចប់គម្រោង និង (iii) មានតែអ្នកដែលទទួលរងផលប៉ះពាល់អវិជ្ជមាន ដោយផ្ទាល់ គួរឱ្យកត់សម្គាល់តែប៉ុណ្ណោះ ដែលអាចដាក់ពាក្យបណ្តឹងបាន។

២៤. **ចំនួនមនុស្សតិចបំផុត ដែលត្រូវមាន** – ធនាគារអភិវឌ្ឍន៍អាស៊ី រួមជាមួយនឹងធនាគារពិភពលោក, AfDB និង ធនាគារជប៉ុនសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ (JBIC) តម្រូវឱ្យមានមនុស្សយ៉ាងហោចណាស់ ២ នាក់ ដើម្បីដាក់

---

[១៩] ធនាគារអភិវឌ្ឍន៍អាស៊ី ២០១០ *ជំនួយបច្ចេកទេសកម្រិតតំបន់សម្រាប់ការផ្សព្វផ្សាយពីអភិបាលកិច្ចល្អ និងប្រសិទ្ធភាពនៃការអភិវឌ្ឍ តាមរយៈយន្តការគណនេយ្យភាព (TA 7572 )* ទីក្រុងម៉ានីល

ពាក្យបណ្ដឹងមួយបាន។ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC), IADB, ធនាគារវិនិយោគអឺរ៉ុប (EIB), ធនាគារអឺរ៉ុបសម្រាប់ការស្ថាបនាឡើងវិញ និងការអភិវឌ្ឍ (EBRD) និងសាជីវកម្មរបស់សហរដ្ឋអាមេរិចសម្រាប់ការវិនិយោគឯកជនក្រៅប្រទេស អនុញ្ញាតឱ្យមានមនុស្សតែម្នាក់អាចដាក់ពាក្យបណឹងមួយបាន។ លក្ខខណ្ឌតម្រូវឱ្យមានមនុស្ស ២ នាក់នេះ មានគោលបំណងជួយដល់ការសម្រាំងដកចេញនូវបណ្ដឹង ដែលគ្មានមូលដ្ឋានច្បាស់លាស់។ មនុស្សមួយចំនួនលើកឡើងថា ពុំគួរមានការរឹតបន្តឹងលើចំនួនមនុស្សតិចបំផុត ដែលអាចដាក់ពាក្យបណ្ដឹងនោះទេ។ ម្យ៉ាងវិញទៀត គេអាចលើកឡើងផងដែរថា ប្រសិនបើមានបញ្ហាកើតមានឡើងពិតប្រាកដ នោះការរកឱ្យបានមនុស្សយ៉ាងហោចណាស់ ២ នាក់ ដើម្បីដាក់ពាក្យបណ្ដឹង មិនគួរជាឧបសគ្គនោះឡើយ។ បណ្ដឹងភាគច្រើន ដែល OSPF និង OCRP ទទួលបានកន្លងមក ត្រូវបានប្ដឹងដោយមនុស្សច្រើនជាង ២ នាក់ ហើយ OSPF និង OCRP ពុំដែលជួបប្រទះនឹងករណីដែលអ្នកស្នើសុំលើកឡើងថា លក្ខខណ្ឌតម្រូវឱ្យមានមនុស្ស ២ នាក់នេះ បង្កឱ្យមានបញ្ហាចំពោះពួកគេនោះទេ។

២៥. **កាលបរិច្ឆេទឱសានវាទ** – កាលបរិច្ឆេទឱសានវាទរបស់យន្តការគណនេយ្យភាព ដើម្បីដាក់ពាក្យបណ្ដឹង គឺកាលបរិច្ឆេទនៃការចេញរបាយការណ៍បញ្ចប់គម្រោង។ មនុស្សមួយចំនួនលើកឡើងថា ផលប៉ះពាល់អវិជ្ជមានផ្នែកបរិស្ថាន ឬសង្គមរបស់គម្រោង អាចកើតឡើង បន្ទាប់ពីគម្រោងបិទជាច្រើនឆ្នាំរួចមក។ ខណៈពេលដែល បើតាមលក្ខណៈបច្ចេកទេស បណ្ដឹងនានាអាចត្រូវបានគេដាក់ប្ដឹង ក្រោយពេលគម្រោងបញ្ចប់ជាច្រើនឆ្នាំរួចមក, ធនាគារអភិវឌ្ឍន៍អាស៊ីនឹងមានឥទ្ធិពលឱ្យប្រទេស ដែលខ្ចីកម្ចីពីធនាគារ ធ្វើការដោះស្រាយផលប៉ះពាល់អវិជ្ជមាន ក្នុងរយៈពេលយូរ ក្រោយពេលគម្រោងត្រូវបានបញ្ចប់នោះទេ។ គេក៏មានការលំបាក ដើម្បីចាត់ទុកថា ផលប៉ះពាល់កើតឡើងដោយសារគម្រោងយូរក្រោយពេលដែលគម្រោងបញ្ចប់នោះដែរ។ ក្នុងចំណោមការអនុវត្តទូទៅនានា ធនាគារអភិវឌ្ឍន៍អាស៊ីកំពុងនាំមុខធនាគារអភិវឌ្ឍន៍ពហុភាគីភាគច្រើន ដោយអនុញ្ញាតឱ្យមានការដាក់ពាក្យបណ្ដឹងរហូតដល់កាលបរិច្ឆេទចេញរបាយការណ៍បញ្ចប់គម្រោង។ ឧបសម្ព័ន្ធទី ២ ធ្វើការប្រៀបធៀបលក្ខណៈសំខាន់ៗរបស់យន្តការគណនេយ្យភាពនៅក្នុងទីភ្នាក់ងារអភិវឌ្ឍន៍ចំនួន ៩ រាប់បញ្ចូលទាំងកាលបរិច្ឆេទឱសានវាទរបស់យន្តការគណនេយ្យភាពផ្សេងៗផងដែរ។

២៦. ប៉ុន្តែ ការប្រើប្រាស់កាលបរិច្ឆេទចេញរបាយការណ៍បញ្ចប់គម្រោង ធ្វើជាកាលបរិច្ឆេទឱសានវាទ បង្កើតឱ្យមានបញ្ហា ដោយសារតែ ជារឿយៗ កាលបរិច្ឆេទនេះពុំមានភាពច្បាស់លាស់។[២០] របាយការណ៍បញ្ចប់គម្រោងត្រូវបានចេញក្នុងចន្លោះពេល ១-២ ឆ្នាំ ក្រោយពេលដែលគម្រោងបញ្ចប់ ហើយគេមានការលំបាកក្នុងការដឹងពីកាលបរិច្ឆេទពិតប្រាកដជាមុន។ ចាំបាច់ត្រូវមានការបង្កើនភាពច្បាស់លាស់អំពីកាលបរិច្ឆេទឱសានវាទនេះ។

---

[២០] នៅក្នុងប្រទេសហ្វីលីពីន, ពាក្យបណ្ដឹងមួយត្រូវបានចាត់ទុកថាពុំមានលក្ខណៈសមស្រប ប្រសិនបើហួសកាលបរិច្ឆេទ PCR តែបន្តិចបន្តួច។

២៧. **ផលប៉ះពាល់ដោយផ្ទាល់ និងពាក់ព័ន្ធ** – មនុស្សមួយចំនួនលើកឡើងថា ដោយសារតែ SPS (២០០៩) ទទួលស្គាល់ផលប៉ះពាល់បរិស្ថានដោយប្រយោល, យន្តការគណនេយ្យភាពនេះក៏គួរពិចារណាលើបណ្តឹងអំពីផលប៉ះពាល់ប្រយោលផងដែរ។ តាមពិតទៅ ផលប៉ះពាល់ដោយប្រយោលលើបរិស្ថានត្រូវបានគេដាក់បញ្ចូលទៅក្នុងគោលនយោបាយការពារបរិស្ថាន និងសង្គមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងស្ថាប័នស្រដៀងៗគ្នានេះជាយូរណាស់មកហើយ។ ឧទាហរណ៍ គោលនយោបាយបរិស្ថាន[២១] របស់ធនាគារអភិវឌ្ឍន៍អាស៊ី ធ្វើការពិចារណាលើផលប៉ះពាល់ប្រយោល ដែលគម្រោងមានមកលើបរិស្ថាន។ ទោះជាយ៉ាងណាក៏ដោយ *ផលប៉ះពាល់ដោយប្រយោលមកលើបរិស្ថាន* ទាំងនេះ អាចបង្កឱ្យមានផលប៉ះពាល់ដោយផ្ទាល់មកលើប្រជាពលរដ្ឋ។ យន្តការគណនេយ្យភាព គឺជាគោលនយោបាយមួយ ផ្អែកទៅតាមគោលនយោបាយប្រតិបត្តិការងារដទៃទៀតរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ពុំមានមូលដ្ឋានគោលនយោបាយ ដើម្បីពង្រីកលក្ខណៈវិនិច្ឆ័យកំណត់ពីភាពសមស្រប ដើម្បីដាក់បញ្ចូលផលប៉ះពាល់ដោយប្រយោល និងដែលមិនគួរឱ្យកត់សម្គាល់នោះទេ។ ស្រដៀងគ្នានេះដែរ បញ្ហាទស្សនាទាន, វិធីសាស្ត្រ និងការវាស់វែង គឺជាកត្តាដែលរារាំងមិនឱ្យមានការពង្រីកបន្ថែម លក្ខណៈវិនិច្ឆ័យទាំងនេះ ដើម្បីដាក់បញ្ចូលផលប៉ះពាល់ដោយប្រយោល និងដែលមិនគួរឱ្យកត់សម្គាល់។

## ៣. ដំណើរការនៃការដាក់ពាក្យបណ្តឹង

២៨. នីតិវិធីសម្រាប់ដាក់ពាក្យបណ្តឹងត្រូវបានបរិយាយយ៉ាងច្បាស់លាស់ នៅក្នុងគោលនយោបាយនេះ, នៅក្នុងសៀវភៅណែនាំអំពីប្រតិបត្តិការការងារ (ផ្នែក L1), គេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី, ខិតប័ណ្ណព័ត៌មាន និងការបោះពុម្ពផ្សាយដទៃទៀតរបស់ OSPF និង OCRP។ សំណើសុំឱ្យមានការពិគ្រោះយោបល់ និងការពិនិត្យឡើងវិញលើភាពអនុលោមអាចសរសេរដោយសង្ខេប ជាភាសាអង់គ្លេស ឬភាសាផ្លូវការ ឬភាសាជាតិរបស់ប្រទេសកំពុងអភិវឌ្ឍជាសមាជិក និងអាចផ្ញើតាមប្រៃសណីយ៍, ទូរសារ, អ៊ីមែល ឬផ្ញើដោយផ្ទាល់មកកាន់ការិយាល័យកណ្តាល ឬស្ថានបេសកកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ អត្តសញ្ញាណរបស់អ្នកដាក់ពាក្យបណ្តឹងនឹងត្រូវលាក់ការសម្ងាត់ ប្រសិនបើអ្នកពាក្យបណ្តឹងចង់បានដូច្នេះ។ អ្នកស្នើសុំត្រូវបានលើកទឹកចិត្តឱ្យលើកឡើងពីគោលនយោបាយជាក់លាក់ នៅពេលធ្វើការរៀបរាប់ពាក្យបណ្តឹងរបស់ខ្លួន ប៉ុន្តែនេះមិនមែនជាលក្ខខណ្ឌតម្រូវដាច់ណាត់នោះទេ។ នេះគឺជាចំណុចសំខាន់មួយ នៅក្នុងការសម្រួលបន្ទុកនៃការដាក់សំណើអ្វីមួយ។

---

[២១] *គោលនយោបាយបរិស្ថានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី*, ធនាគារអភិវឌ្ឍន៍អាស៊ី, ២០០២, ម៉ានីល។

២៩. ការពិគ្រោះយោបល់ ដែលបានធ្វើឡើងជាផ្នែកមួយនៃការពិនិត្យឡើងវិញនេះ បង្ហាញថា ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយសារគម្រោង នៅតែមានការលំបាក នៅក្នុងការដាក់ពាក្យបណ្តឹង។ ធនាគារអភិវឌ្ឍន៍អាស៊ីចាំបាច់ត្រូវស្វែងរកមធ្យោបាយផ្សេងទៀត ដើម្បីសម្រួលដំណើរការនេះ។

## ខ. ភាពជឿជាក់

### ១. ឯករាជ្យភាព

៣០. ឯករាជ្យភាពរបស់យន្តការគណនេយ្យភាព ពាក់ព័ន្ធជាមួយនឹងទិដ្ឋភាពច្រើនយ៉ាង។ វាគ្របដណ្តប់លើទិដ្ឋភាពជាច្រើន ដូចជា ការតែងតាំង, ការរាយការណ៍, ការរៀបចំផែនការការងារ, ការរៀបចំថវិកា និងសំខាន់ជាងគេ គឺសមត្ថភាព ដើម្បីធ្វើការវិនិច្ឆ័យដោយឯករាជ្យ។

៣១. គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម **(CRP)** និង ការិយាល័យគណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម **(OCRP)** - CRP រាយការណ៍ដោយផ្ទាល់អំពីគ្រប់សកម្មភាពទាំងអស់ទៅកាន់ក្រុមប្រឹក្សាភិបាល លើកលែងតែសកម្មភាពជាក់លាក់ដែលពាក់ព័ន្ធនឹងលក្ខខណ្ឌយោង និងក្របខ័ណ្ឌពេលវេលាសម្រាប់ការផ្តល់ការអនុញ្ញាតដល់ការពិនិត្យឡើងវិញលើភាពអនុលោមរបស់ CRP និងការពិនិត្យឡើងវិញលើសេចក្តីព្រាងរបាយការណ៍របស់ CRP ដែលក្នុងករណីនេះ CRP ត្រូវរាយការណ៍ទៅកាន់ BCRC។ សមាជិករបស់ CRP មានអណត្តិ ដែលមិនអាចបន្តទៀតបាន។ នេះត្រូវបានចាត់ទុកថាមានភាពសមស្រប សម្រាប់ការប្រើប្រាស់បទពិសោធន៍ថ្មីៗ និងកាត់បន្ថយឥទ្ធិពលពីខាងក្រៅឱ្យនៅកម្រិតអប្បបរមា។ CRP ត្រូវការការឆ្លើយតបជាវិជ្ជមានពី BCRC[២២] ប៉ុន្តែមិនមែនការឯកភាពលើលក្ខខណ្ឌយោងសម្រាប់ការពិនិត្យឡើងវិញលើភាពអនុលោមនោះទេ។ BCRC ពិនិត្យឡើងវិញលើរបាយការណ៍របស់ CRP និងផ្តល់ជាយោបល់ ប៉ុន្តែមិនធ្វើការផ្លាស់ប្តូររបាយការណ៍នោះទេ ហើយ CRP គឺជាអ្នក ដែលត្រូវធ្វើការសម្រេច

---

[២២] ការប្រើពាក្យ "ការឆ្លើយតបជាវិជ្ជមាន (clearance)" នៅក្នុងគោលនយោបាយឆ្នាំ ២០០៣ ផ្តល់លទ្ធភាពឱ្យBCRC ផ្តោតការយកចិត្តទុកដាក់ និងប្រើប្រាស់អព្យាក្រឹតភាពរបស់ខ្លួន។ តាមរយៈញែកដាច់រវាងពាក្យ "ការឆ្លើយតបជាវិជ្ជមាន" និង "ការឯកភាព", គោលនយោបាយនេះបង្ហាញថា CRP ត្រូវការការឆ្លើយតបវិជ្ជមានពី BCRC មុនពេលធ្វើការងារបន្តទៀត ហើយការធ្វើបែបនេះមិនមែនមានន័យថា BCRC ឯកភាព (ឬមិនឯកភាព) លើខ្លឹមសារអ្វីដែលបានដាក់ឱ្យខ្លួនពិនិត្យឡើយ។ មុខងាររបស់ BCRC នៅក្នុងការផ្តល់ការឆ្លើយតបជាវិជ្ជមានលើលក្ខខណ្ឌយោង ដែលស្នើឡើង និងផ្តល់ជាយោបល់លើសេចក្តីព្រាងរបាយការណ៍ស្តីពីការពិនិត្យឡើងវិញលើភាពអនុលោម គឺដើម្បីធានាថា CRP ពិតជាដំណើរការទៅ ក្នុងវិសាលភាពនៃការពិនិត្យឡើងវិញលើភាពអនុលោមពិតប្រាកដមែន។

ចិត្តថាតើត្រូវឆ្លើយតបចំពោះយោបល់ទាំងនេះ ដោយរបៀបណា។ ចំណុចទាំងនេះបង្ហាញថា CRP ទទួលបានឯករាជ្យភាពក្នុងកម្រិតខ្ពស់ពីគណៈគ្រប់គ្រង និងពីក្រុមប្រឹក្សាភិបាល។

៣២. ការពិនិត្យឡើងវិញនេះបាននាំឱ្យមានការបង្កើតនូវនាយកដ្ឋានវាយតម្លៃឯករាជ្យមួយ (IED) [២៣] នៅក្នុងធនាគារអភិវឌ្ឍន៍អាស៊ី។ មានការលើកឡើងថា ឯករាជ្យភាពរបស់ CRP អាចពង្រឹងបន្ថែមទៀត នៅក្នុងការតែងតាំងសមាជិករបស់ CRP, ការរៀបចំផែនការការងារ, ការរៀបចំថវិកា និងការផ្តល់ព័ត៌មានត្រលប់អំពីការបំពេញការងារ។ បច្ចុប្បន្ននេះ សមាជិករបស់ CRP ត្រូវបានតែងតាំងដោយក្រុមប្រឹក្សាភិបាល ទៅតាមអនុសាសន៍របស់ប្រធានធនាគារ។ ផ្ទុយទៅវិញ អគ្គនាយករបស់នាយកដ្ឋានវាយតម្លៃឯករាជ្យ ត្រូវបានតែងតាំងដោយក្រុមប្រឹក្សាភិបាល ទៅតាមអនុសាសន៍របស់គណៈកម្មាធិការប្រសិទ្ធភាពនៃការអភិវឌ្ឍ (DEC) របស់ក្រុមប្រឹក្សាភិបាល ដោយពិគ្រោះយោបល់ជាមួយនឹងប្រធានធនាគារ។ កម្មវិធីការងារ និងថវិការបស់នាយកដ្ឋានវាយតម្លៃឯករាជ្យ ត្រូវបានពិនិត្យឡើងវិញដោយ DEC និងទទួលបានការឯកភាពពីក្រុមប្រឹក្សាភិបាល ប៉ុន្តែពុំមានដំណើរការរៀបចំកម្មវិធីផ្លូវការ និងថវិកាជាផ្លូវការសម្រាប់ CRP នោះឡើយ, មួយផ្នែកដោយសារតែការងារនេះត្រូវបានធ្វើឡើងទៅតាមតម្រូវការ។ បច្ចុប្បន្ននេះ សមាជិករបស់ CRP ពុំត្រូវបានគេវាយតម្លៃឡើយ ប៉ុន្តែ DEC ផ្តល់នូវព័ត៌មានត្រលប់ជាលាយលក្ខណ៍អក្សរលើលទ្ធផលការងារប្រចាំឆ្នាំ ទៅកាន់អគ្គនាយករបស់នាយកដ្ឋានវាយតម្លៃឯករាជ្យ។

៣៣. បទពិសោធន៍របស់ IED ក៏បង្ហាញឱ្យឃើញផងដែរថា ខណៈពេលដែលឯករាជ្យភាព គឺជាបុរេលក្ខខណ្ឌដ៏សំខាន់មួយ សម្រាប់ធានាភាពជឿជាក់របស់យន្តការនេះ, ឯការជ្យភាពនេះមិនចាំបាច់ និងមិនគួរមានន័យថាជាការនៅដោយឡែកពីគេនោះទេ។ បច្ចុប្បន្ននេះ មានអន្តរកម្មតិចតួចតែប៉ុណ្ណោះរវាង CRP និងគណៈគ្រប់គ្រង និងបុគ្គលិក។ បទពិសោធន៍របស់ IED បង្ហាញថា អន្តរកម្មដែលសមស្របជួយដល់ការចែករំលែកមេរៀន និងការអនុវត្តល្អៗ។ ការពិនិត្យឡើងវិញ ដែលបានធ្វើឡើងដោយ IED ក៏បង្ហាញផងដែរថា ឯករាជ្យតែមួយគត់មិនអាចធានាបាននូវគណនេយ្យភាព និងការវាយតម្លៃដែលមានគុណភាពល្អនោះទេ។ ដូច្នេះ ចាំបាច់ត្រូវមានការត្រួតពិនិត្យឱ្យបានសមស្របពីសំណាក់ក្រុមប្រឹក្សាភិបាល ដើម្បីសម្រួលឱ្យយន្តការឯករាជ្យនេះមានប្រសិទ្ធភាព។ ស្រដៀងគ្នានេះដែរ សម្រាប់តួនាទីរបស់ DEC ពាក់ព័ន្ធនឹង IED, BCRC គួរបំពេញនាទីជាស្ថាប័នបង្គោលមួយសម្រាប់អន្តរកម្មរបស់ CRP ជាមួយក្រុមប្រឹក្សាភិបាល និងជាវេទិកាមួយសម្រាប់ឱ្យមានការពិគ្រោះយោបល់ជាទៀងទាត់អំពីយន្តការគណនេយ្យភាព។

---

[២៣] *ការពិនិត្យឡើងវិញលើឯករាជ្យភាព និងប្រសិទ្ធភាពនៃនាយកដ្ឋានវាយតម្លៃប្រតិបត្តិការ*, ធនាគារអភិវឌ្ឍន៍អាស៊ី, ២០០៨, ម៉ានីល។

៣៤. **ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស** - គោលនយោបាយឆ្នាំ ២០០៣ តម្រូវឱ្យអ្នកសម្របសម្រួលគម្រោងពិសេសមានភាពឯករាជ្យចេញពីប្រតិបត្តិនានា ប៉ុន្តែមិនមែនឯករាជ្យពីគណៈគ្រប់គ្រងនោះទេ។ អ្នកសម្របសម្រួលគម្រោងពិសេសរាយការណ៍ដោយផ្ទាល់ទៅកាន់ប្រធានធនាគារ។ អ្នកសម្របសម្រួលនេះមិនគួរពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងការបង្កើត, ដំណើរការ ឬការអនុវត្តគម្រោងមួយណាឡើយ។

៣៥. ការរៀបចំនេះត្រូវបានធានា ដោយសារមូលហេតុ ២ យ៉ាង។ ទីមួយ ដំណើរការដោះស្រាយបញ្ហាមិនមែនជាការកំណត់ពីការទទួលខុសត្រូវ ឬការដាក់កំហុស ឬការបន្ទោសនោះទេ។ ផ្ទុយទៅវិញ ដំណើរការនេះត្រូវបានរៀបចំឡើង ដើម្បីឱ្យមានការឆ្លើយតបចំពោះពាក្យបណ្តឹង ដោយភាពស្មោះត្រង់ នៅក្នុងគម្រោងដែលជួយដោយធនាគារអភិវឌ្ឍន៍អាស៊ី តាមរយៈវិធីសាស្ត្រក្រៅផ្លូវការ ផ្អែកទៅតាមការឯកភាពគ្នា ដោយមានការយល់ព្រម និងការចូលរួមពីគ្រប់ភាគីទាំងអស់ ដែលពាក់ព័ន្ធ។ អ្នកដែលជឿថាខ្លួនបានទទួលរងផលប៉ះពាល់ជាអវិជ្ជមាន ដោយសារគម្រោង ដែលទទួលជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី អាចប្រើប្រាស់ដំណើរការពិគ្រោះយោបល់នេះ មិនថាគោលនយោបាយ និងនីតិវិធីប្រតិបត្តិការការងាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ត្រូវបានគេអនុលោមតាម ឬអត់នោះទេ[២៤]។ ទីពីរ ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេសចាំបាច់ត្រូវធ្វើការងារយ៉ាងជិតស្និទជាមួយបុគ្គលិករបស់នាយកដ្ឋានប្រតិបត្តិការ នៅក្នុងការដោះស្រាយបញ្ហានានា។ ការខិតខំសម្រេចឱ្យបាននូវតុល្យភាពសមស្របរវាងភាពចាំបាច់នៃគោលដៅរបស់គម្រោងមួយ និងតម្រូវការឱ្យមានចំណេះដឹងគ្រប់គ្រាន់អំពីប្រតិបត្តិការរបស់ធនាគារ និងទំនាក់ទំនងយ៉ាងជិតស្និទជាមួយបុគ្គលិក មានន័យថា ការដាក់ដំណើរការពិគ្រោះយោបល់នេះឱ្យស្ថិតនៅក្រោមគណៈគ្រប់គ្រង គឺជាការរៀបចំដ៏ល្អបំផុត។ ការរាយការណ៍ទៅកាន់ប្រធានធនាគារធានាបាននូវឯករាជ្យភាពក្នុងកម្រិតសមស្របមួយ និងផ្តល់នូវប្រសិទ្ធ-ភាពគ្រប់គ្រាន់ដល់ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស។

៣៦. **ជារួម** យន្តការគណនេយ្យភាពនេះបែងចែកការដោះស្រាយបញ្ហា និងការពិនិត្យឡើងវិញលើភាពអនុលោមថាជាការងារដាច់ដោយឡែកពីគ្នា នៅពេលដែលមានការចោទប្រកាន់ថា គម្រោងដែលជួយដោយធនាគារអភិវឌ្ឍន៍អាស៊ីបង្កឱ្យមានផលប៉ះពាល់អ្វីមួយ។ ការពិគ្រោះយោបល់ត្រូវផ្តោតលើលទ្ធផល និងមិនត្រូវផ្តោតលើកំហុសរបស់ភាគីណាមួយនោះទេ។ ការពិគ្រោះយោបល់ត្រូវមានគោលបំណង ដោះស្រាយបញ្ហា ដោយសន្តិវិធី។ ការពិនិត្យឡើងវិញលើភាពអនុលោមផ្តោតសំខាន់លើភាពអនុលោមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ជាមួយនឹងគោលនយោបាយ និងនីតិវិធីប្រតិបត្តិ

---

[២៤] តួនាទីរបស់អ្នកសម្របសម្រួលគម្រោងពិសេស គឺកំណត់ត្រឹមតែបញ្ហាពាក់ព័ន្ធនឹងធនាគារអភិវឌ្ឍន៍អាស៊ី ទាក់ទងទៅនឹងគម្រោង ដែលទទួលបានជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី។

របស់ខ្លួន និងលើផលប៉ះពាល់ដោយផ្ទាល់ និងគួរឱ្យកត់សម្គាល់ ដែលកើតឡើងដោយសារការមិនអនុលោមតាម។ ការបន្តបែងចែក ដំណាក់កាលទាំង ២ នេះដាច់ពីគ្នា គឺចាំបាច់ ដើម្បីធានាឯករាជ្យភាព និងប្រសិទ្ធភាពរបស់យន្តការគណនេយ្យភាព។

## ២. តម្លាភាព

៣៧. យន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី កំណត់យ៉ាងច្បាស់លាស់អំពីជំហានសម្រាប់ដំណើរការពិគ្រោះយោបល់ និងពិនិត្យឡើងវិញលើភាពអនុលោម និងកំឡុងពេលរំពឹងទុកសម្រាប់ជំហានភាគច្រើន។ យន្តការគណនេយ្យភាពនេះបានរក្សានូវតម្លាភាពក្នុងកម្រិតខ្ពស់ នៅក្នុងការបង្ហាញនូវលទ្ធផលរកឃើញ និងអនុសាសន៍របស់ខ្លួនស្របទៅតាមលក្ខខណ្ឌ ដែលតម្រូវនៅក្នុងគោលនយោបាយប្រាស្រ័យទាក់ទងសាធារណៈ ហើយក្នុងពេលជាមួយគ្នាធានាឱ្យមានការបំពេញបានទៅតាមលក្ខខណ្ឌនៃការលាក់ការសម្ងាត់។ OSPF និង OCRP បានផ្សព្វផ្សាយព័ត៌មានជាច្រើន នៅលើគេហទំព័ររបស់ខ្លួន ដូចជា របាយការណ៍ពិនិត្យឡើងវិញ និងវាយតម្លៃរបស់អ្នកសម្របសម្រួលគម្រោងពិសេស, របាយការណ៍ពិនិត្យឡើងវិញរបស់ CRP, របាយការណ៍ពិនិត្យតាមដានប្រចាំឆ្នាំរបស់ CRP និងការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាលលើការពិនិត្យឡើងវិញលើភាពអនុលោម។

៣៨. ប៉ុន្តែ បច្ចុប្បន្ននេះ ពុំមានប្រព័ន្ធសម្រាប់តាមដានពាក្យបណ្តឹង ដែល OSPF បានបញ្ជូនបន្តទៅកាន់នាយកដ្ឋានប្រតិបត្តិការនោះឡើយ ដោយសារតែអ្នកដាក់ពាក្យបណ្តឹងពុំបានខំប្រឹងប្រែងជាមុន ដោយសុច្ឆន្ទៈ ដើម្បីដោះស្រាយបញ្ហាជាមួយនាយកដ្ឋានទាំងនេះ។ ដូច្នេះ ពុំមានព័ត៌មានជាលក្ខណៈប្រព័ន្ធអំពីដំណើរការ និងលទ្ធផលនៃពាក្យបណ្តឹងទាំងនេះឡើយ។ គម្លាតព័ត៌មាននេះអាចជាកត្តា ដែលធ្វើឱ្យរាំងស្ទះដល់តម្លាភាព និងភាពឆ្លើយតបរបស់យន្តការគណនេយ្យភាព។

## ៣. ការចូលរួម

៣៩. ការចូលរួម និងដំណើរការដែលមានភាពត្រឹមត្រូវ តម្រូវមិនឱ្យមានការដកចេញអ្នករងផលប៉ះពាល់ពីដំណើរការសម្រេចចិត្តឡើយ។ ពាក់ព័ន្ធជាមួយនឹងចំណុចនេះ ការផ្លាស់ប្តូរសំខាន់បំផុតនៅក្នុងគោលនយោបាយស្តីពីយន្តការគណនេយ្យភាព គឺការដាក់ឱ្យអនុវត្តនូវដំណើរការពិគ្រោះយោបល់។ នេះផ្តល់ឱកាសឱ្យអ្នកដែលរងផលប៉ះពាល់អាចចូលរួមយ៉ាងសកម្ម នៅក្នុងការដោះស្រាយបញ្ហា ជាជាងគ្រាន់តែជាអ្នកទទួលលទ្ធផលពីការធ្វើអធិការកិច្ច។ នេះគឺជាមូលដ្ឋានគ្រឹះដ៏សំខាន់មួយរបស់គោលវិធីថ្មីនេះ និងផ្តល់លទ្ធភាពឱ្យមានការចូលរួមកាន់តែច្រើនឡើងពីអ្នកស្នើសុំ។

៤០. វិសាលភាពសម្រាប់ការចូលរួម នៅក្នុងយន្តការគណនេយ្យភាពនេះ អាចត្រូវបានពង្រីងបន្ថែមទៀត។ ទីមួយ យន្តការគណនេយ្យភាពនេះ តម្រូវឱ្យមានការដាក់ពាក្យបណ្តឹងជាមួយនឹងការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេសជាមុនសិន មុនពេលដែលអ្នកដាក់ពាក្យបណ្តឹងអាចស្នើសុំឱ្យមានដំណើរការពិនិត្យឡើងវិញលើភាពអនុលោម។ គោលវិធីតាមបែបចូលរួមលើកឡើងថា អ្នកស្នើសុំគួរអាចធ្វើការសម្រេចចិត្តពីដំណាក់កាល ដែលពួកគេចង់ចាប់ផ្តើមមុនគេ។ ទីពីរ ខុសពីគណៈកម្មការអធិការកិច្ចរបស់ធនាគារពិភពលោក, ដំណាក់កាលពិនិត្យឡើងវិញលើភាពអនុលោម មិនបានផ្តល់ឱកាសឱ្យអ្នកគ្រប់គ្រងធ្វើការឆ្លើយតប មុនពេលមានការកំណត់ពីលក្ខណៈសមស្របនៃការស្នើសុំមួយឡើយ។ ទីបី ប្រទេសដែលខ្ចីកម្ចីពីធនាគារក៏មិនមានឱកាស ដើម្បីឆ្លើយតប មុនពេលដែលមានការកំណត់ពីលក្ខណៈសមស្របសម្រាប់ការពិនិត្យឡើងវិញលើភាពអនុលោមនោះដែរ ឬនៅដំណាក់កាលពេលដែលមានរបាយការណ៍ព្រាងរបស់គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម (បើទោះបីជាគណៈកម្មការនេះមានការទទួលខុសត្រូវជាចម្បងលើការអនុវត្តសកម្មភាពកែតម្រូវក៏ដោយ)។ គម្លាតនេះអាចមានផលប៉ះពាល់លើសុច្ឆន្ទៈ និងប្រសិទ្ធភាពរបស់យន្តការគណនេយ្យភាព។

### ៤. ការពិនិត្យតាមដានលើសកម្មភាពកែតម្រូវ

៤១. យន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ផ្តល់អំណាចឱ្យការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស និងគណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម មានភារកិច្ចពិនិត្យតាមដានលើការអនុវត្តសកម្មភាពកែតម្រូវ។ តួនាទីពិនិត្យតាមដាននេះពង្រឹងភាពជឿជាក់របស់យន្តការគណនេយ្យភាពនេះ។

## គ. ប្រសិទ្ធភាព

### ១. ពេលវេលា

៤២. គោលនយោបាយឆ្នាំ ២០០៣ រំពឹងថា អ្នកសម្របសម្រួលគម្រោងពិសេស (SPF) និងគណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម (CRP) ត្រូវការពេលវេលា ២១ ថ្ងៃ ដើម្បីកំណត់ពីភាពសមស្រប ដើម្បីរៀបចំឱ្យមានការពិគ្រោះយោបល់ ឬការពិនិត្យឡើងវិញលើភាពអនុលោម។ គេរំពឹងថា ដំណើរការពិគ្រោះយោបល់នេះត្រូវចំណាយពេលប្រហែលជា ៣ ខែ ចាប់គិតពីកាលបរិច្ឆេទ ដែលពាក្យបណ្តឹងត្រូវបានដាក់ទៅកាន់ធនាគារអភិវឌ្ឍន៍អាស៊ី។ រយៈពេលនេះមិនរាប់បញ្ចូលពេលវេលាសម្រាប់ការបកប្រែឡើយ, ការស្នើសុំឱ្យមានការបន្ថែមពេលវេលា ដើម្បីផ្តល់ព័ត៌មាន ឬដាក់ឯកសារ និងពេលវេលា ដែលភាគីត្រូវការ ដើម្បីសម្របសម្រួលការដោះស្រាយបញ្ហារបស់ពួកគេ នៅក្នុងកំឡុង

ពេលអនុវត្តសកម្មភាពនេះ។ សម្រាប់ការពិនិត្យឡើងវិញលើភាពអនុលោម, គោលនយោបាយឆ្នាំ ២០០៣ រំពឹងទុកថា "អ្នកស្នើសុំនឹងដឹងពីលទ្ធផលនៃការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាល យ៉ាងហោចណាស់ក្នុងរយៈពេល ១២៨ ថ្ងៃ បន្ទាប់ពីបានទទួលសំណើឱ្យមានការពិនិត្យឡើងវិញលើភាពអនុលោម ដោយធនាគារអភិវឌ្ឍន៍អាស៊ីរួចមក"។ រយៈពេលនេះមិនរាប់ចូលរយៈពេល ដែលភាគីត្រូវការ នៅក្នុងដំណាក់កាលពិគ្រោះយោបល់, រយៈពេលសម្រាប់ធ្វើការបកប្រែ, សំណើសុំបន្ថែមពេលវេលា ដើម្បីផ្តល់ព័ត៌មាន ឬដាក់ឯកសារ និងរយៈពេលសម្រាប់ឱ្យគណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម ធ្វើការពិនិត្យឡើងវិញ ដែលពុំមានពេលវេលាកំណត់ (កថាខណ្ឌទី ១៦)។

៤៣. សម្រាប់ដំណាក់កាលពិគ្រោះយោបល់, ពេលវេលាមធ្យម ដើម្បីកំណត់ពីភាពសមស្រប គឺប្រហែលជា ៤៥ ថ្ងៃ ហើយរយៈពេលមធ្យមចាប់ពីពេលទទួលបានពាក្យបណ្តឹង រហូតដល់ពេលចាប់ផ្តើមអនុវត្តសកម្មភាព គឺប្រហែលជា ១៧០ ថ្ងៃ សម្រាប់គ្រប់ករណីដែលមានភាពសមស្របទាំងអស់។ សម្រាប់ដំណាក់កាលពិនិត្យឡើងវិញលើភាពអនុលោម, រយៈពេលមធ្យមចាប់គិតពីពេលទទួលបានការស្នើសុំ រហូតដល់ពេលពេលដែលគណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោមផ្តល់ព័ត៌មានដល់អ្នកស្នើសុំអំពីភាពសមស្របនៃសំណើរបស់ពួកគេ គឺប្រហែលជា ២០ ថ្ងៃ។ កន្លងមកមានសំណើតែ ២ ប៉ុណ្ណោះ ដែលបានឆ្លងកាត់តាមដំណាក់កាលពិនិត្យឡើងវិញលើភាពអនុលោមបានពេញលេញ។ គេត្រូវការរយៈពេលជាមធ្យមចំនួន ៣៦៧[២៥] ថ្ងៃ ចាប់ពីពេលទទួលបានការស្នើសុំ រហូតដល់ពេលជូនដំណឹងដល់អ្នកស្នើសុំអំពីការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាល លើរបាយការណ៍ពិនិត្យឡើងវិញរបស់គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម។ បទពិសោធន៍របស់យន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍ពហុភាគីដទៃទៀត បង្ហាញថា ជាធម្មតាគេត្រូវការពេលជាងមួយឆ្នាំ ដើម្បីបញ្ចប់ដំណើរការដោះស្រាយបញ្ហា និងពិនិត្យឡើងវិញលើភាពអនុលោម ជាពិសេសសម្រាប់គម្រោងធំៗ ដែលមានលក្ខណៈស្មុគស្មាញ។

៤៤. ការដែលដំណើរការរបស់យន្តការគណនេយ្យភាពនេះត្រូវការរយៈពេលយូរបែបនេះ អាចដោយសារកត្តាជាច្រើន។ ទីមួយ ដំណើរការទាំងនេះមានភាពស្មុគស្មាញ។ មានការស្នើសុំឱ្យមានការបន្តខិតខំប្រឹងប្រែង ដើម្បីធ្វើឱ្យដំណើរការនេះមានភាពងាយស្រួលជាងមុន។ ទីពីរ ធនធានសម្រាប់ផ្តល់ថវិកាដល់យន្តការគណនេយ្យភាព មានកម្រិត។ ប៉ុន្តែ ការពិគ្រោះយោបល់ជាមួយអ្នកដែលធ្វើការងារផ្នែកយន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី បង្ហាញថា កន្លងមក ធនធានមិនមែនជាឧបសគ្គនោះទេ។ ទីបី លក្ខណៈរបស់យន្តការគណនេយ្យភាព។ ការពិគ្រោះយោបល់

---

[២៥] រយៈពេលចាប់គិតពីទទួលបានសំណើ រហូតដល់ពេលផ្តល់ព័ត៌មានដល់អ្នកសំណើ អំពីការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាល គឺ ២២៣ ថ្ងៃ នៅក្នុងករណី STDP , និង ៥១១ ថ្ងៃ នៅក្នុងករណីគម្រោង Fuzhou ។

និងការពិនិត្យឡើងវិញលើភាពអនុលោម គឺដំណើរការដែលមានភាពមមាញឹកខ្លាំង ដែលជារឿយៗ តម្រូវឱ្យមានការជួលអ្នកផ្សះផ្សារ ឬអ្នកជំនាញការ។ ដំណើរការទាំងនេះត្រូវបានផ្តួចផ្តើមចេញពីទីក្រុងម៉ានីល។ ក្រុមការងារអាចចុះទៅតាមប្រទេស តែពេលខ្លះតែប៉ុណ្ណោះ។ ឧទាហរណ៍ ក្នុងកំឡុងពេលចុះដល់ទីតាំងជាក់ស្តែងរបស់គម្រោងផ្តល់ភាពអង់អាចដល់ស្ត្រីសម្រាប់ការអភិវឌ្ឍជនបទ នៅក្នុងប្រទេសឥណ្ឌូនេស៊ី [២៦], សហគមន៍មូលដ្ឋានបានបង្ហាញពីបំណងប្រើប្រាស់ប្រព័ន្ធនៅមូលដ្ឋាន និងការិយាល័យតំណាងប្រចាំប្រទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីពន្លឿនការដោះស្រាយបញ្ហា។

៤៥. គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោមបានកំណត់ពេលវេលាពិនិត្យតាមដានរបស់ខ្លួន រយៈពេល ៥ ឆ្នាំ សម្រាប់គម្រោងនីមួយៗ។ គោលនយោបាយឆ្នាំ ២០០៣ និងផ្នែក ឋ១ នៃសៀវភៅណែនាំអំពីប្រតិបត្តិការការងារ ពុំបានកំណត់ពេលវេលា ៥ ឆ្នាំ សម្រាប់គម្រោងនីមួយៗឡើយ។ ការកំណត់ពេលវេលាតែមួយសម្រាប់គ្រប់ប្រភេទគម្រោងទាំងអស់បែបនេះ មានភាពតឹងរ៉ឹងខ្លាំងពេក និងធ្វើឱ្យអ្នកទទួលរងផលប៉ះពាល់, ធនាគារអភិវឌ្ឍន៍អាស៊ី និងប្រទេសខ្ចីកម្ចី ត្រូវចំណាយពេលវេលា និងធនធាន ដោយពុំទទួលបានតម្លៃបន្ថែមអ្វីទាំងអស់។ ការរៀបចំពេលវេលាឱ្យមានភាពបត់បែនសម្រាប់គម្រោងជាក់លាក់នីមួយៗ នឹងមានប្រសិទ្ធភាពច្រើនជាង។

៤៦. ទិដ្ឋភាពសំខាន់មួយនៃប្រសិទ្ធភាព គឺការចៀសវាងធ្វើការងារដដែលៗ ដោយមិនចាំបាច់។ មានការសម្របសម្រួលតិចតួចតែប៉ុណ្ណោះ រវាងការងាររបស់អ្នកសម្របសម្រួលគម្រោងពិសេស និងគណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម។ ចាំបាច់ត្រូវមានការកែលំអការសម្របសម្រួលការងាររបស់អ្នកសម្របសម្រួលគម្រោងពិសេស និងគណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម ដោយមិនធ្វើឱ្យប៉ះពាល់ដល់ឯករាជ្យភាពរបស់ភាគីទាំង ២ នេះ។

## ២. ការចំណាយ

៤៧. ការចំណាយ ដែលពាក់ព័ន្ធជាមួយនឹងយន្តការគណនេយ្យភាពនេះ គឺជាបញ្ហាធំមួយ - មិនមែនត្រឹមតែចំណាយសម្រាប់ប្រតិបត្តិការការងារដោយផ្ទាល់តែប៉ុណ្ណោះទេ ថែមទាំងការចំណាយប្រយោលនៃពេលវេលារបស់បុគ្គលិក, កំណើនជាសក្តានុពលនៃចំណាយសម្រាប់ការអនុវត្តគម្រោង និងការចំណាយរបស់អ្នកដែលរងផលប៉ះពាល់។ ចំណាយ

---

[២៦] ធនាគារអភិវឌ្ឍន៍អាស៊ី, ២០០០, *របាយការណ៍ និងអនុសាសន៍របស់ប្រធានធនាគារ ផ្ញើទៅកាន់ក្រុមប្រឹក្សាភិបាលអំពីសំណើកម្ចី និងជំនួយបច្ចេកទេសឥតសំណង ដល់សាធារណរដ្ឋឥណ្ឌូនេស៊ី សម្រាប់គម្រោងផ្តល់ភាពអំណាចដល់សហគមន៍ សម្រាប់ការអភិវឌ្ឍជនបទ*, ម៉ានីល (កម្ចីលេខ 1765-INO សម្រាប់ ១១៥ លានដុល្លារ ទទួលបានការអនុម័តក្នុងខែ តុលា ឆ្នាំ ២០០០)។

ប្រតិបត្តិទាំងនេះ ត្រូវរ៉ាប់រងដោយធនាគារអភិវឌ្ឍន៍អាស៊ី។ ចំណាយប៉ាន់ស្មានសម្រាប់ការធ្វើអធិការកិច្ចគម្រោងគ្រប់-គ្រងទឹកកខ្វក់ Samut Prakarn មានចំនួនប្រមាណ ១,៧ លានដុល្លារសហរដ្ឋអាមេរិច បើគិតពីពេលវេលារបស់បុគ្គលិក និងធនធាន របស់ធនាគារអភិវឌ្ឍន៍អាស៊ី និង ២០០០០០ ដុល្លារសហរដ្ឋអាមេរិច សម្រាប់គណៈកម្មការអធិការកិច្ច។ លក្ខខណ្ឌយោងសម្រាប់ធ្វើ អធិការកិច្ចលើគម្រោង Chashma ត្រូវការចំណាយប្រមាណ ៥០០០០០ ដុល្លារសហរដ្ឋ-អាមេរិច តែសម្រាប់គណៈកម្មការ នៅក្នុងឆ្នាំ ២០០៣។

៤៨. តារាងទី ៩ បង្ហាញពីចំណាយប្រតិបត្តិរបស់យន្តការផ្សេងៗ។ IFC CAO មានចំណាយប្រតិបត្តិខ្ពស់ជាងគេ ចំនួន ៣,៣ លានដុល្លារសហរដ្ឋអាមេរិច នៅក្នុងឆ្នាំ ២០០៩។ បន្ទាប់មកគឺគណៈកម្មការអធិការកិច្ចរបស់ធនាគារពិភពលោកចំនួន ៣,១ លានដុល្លារសហរដ្ឋអាមេរិច។ ការចំណាយសម្រាប់យន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ីមានកម្រិតខ្ពស់ជាងគេទី ៣ គឺ ២,១ លានដុល្លារសហរដ្ឋអាមេរិច។

**តារាងទី ៩: ចំណាយប្រតិបត្តិ (គិតជាពាន់ដុល្លារសហរដ្ឋអាមេរិច)**

| ឆ្នាំ | ការពិគ្រោះ-យោបល់របស់ ADB (ជាក់ស្តែង) | ការពិនិត្យឡើងវិញលើភាពអនុលោមរបស់ ADB (ជាក់ស្តែង) | គណៈកម្មការអធិការកិច្ចរបស់ធនាគារពិភពលោក (ជាក់ស្តែង) | ការិយាល័យប្រជាជនសម្រាប់ផ្តល់ដំបូន្មានអំពីភាពអនុលោមរបស់ IFC - (ក្នុងថវិកា) | យន្តការពិនិត្យឡើងវិញដោយឯករាជ្យរបស់ AfDB (ជាក់ស្តែង) | ការិយាល័យគណនេយ្យភាពរបស់ OPIC - (ក្នុងថវិកា) |
|---|---|---|---|---|---|---|
| ២០០៤ | ៦៨៦,៣ | ៩១៩,៣ | ២៦៤៩,២ | ១៩០០,៩ | | |
| ២០០៥ | ៦០៩,៧ | ១១៣៦,៤ | ២៨០៨,៩ | ១៩៦៥,៩ | | |
| ២០០៦ | ៦០២,៥ | ១០៤៥,២ | ២៩៧៦,៩ | ២៥៣៧,២ | ២៤៣,៧ | ២៨,៩ |
| ២០០៧ | ៧០៣,៨ | ១២០៩,៨ | ៣០៦៨,២ | ២៦១៨,៤ | ៣៧៣,៧ | ២២,៦ |
| ២០០៨ | ៨៦១,៨ | ៩៩៤,៥ | ៣២៣៥,៥ | ២៧២១,៤ | ៤៦២,២ | ៤៤,៤ |
| ២០០៩ | ៩០៤,៩ | ១១៩៧,៩ | ៣០៩១,៥ | ៣៣០៦,៩ | ៥២០,៦ | ៦០,៥ |

ADB = ធនាគារអភិវឌ្ឍន៍អាស៊ី, AfDB = ធនាគារអភិវឌ្ឍន៍អាហ្វ្រិច, IFC = សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ, OPIC = សាជីវកម្មវិនិយោគឯកជនក្រៅប្រទេស

ប្រភព: ទិន្នន័យរបស់ធនាគារអភិវឌ្ឍន៍អាស៊ី បានទទួលពី BPMSD ហើយទិន្នន័យរបស់យន្តការគណនេយ្យភាពផ្សេងទៀត បានទទួលពីរបាយការណ៍ប្រចាំឆ្នាំរបស់ស្ថាប័នទាំងនោះ។

៤៩. ការប្រៀបចំណាយប្រតិបត្តិ ដោយធ្វើការប្រៀបធៀបជាមួយចំនួនករណីសម្រាប់ស្ថាប័នស្រដៀងៗគ្នា បង្ហាញថាដំណាក់កាលពិនិត្យឡើងវិញលើភាពអនុលោមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី មានចំណាយប្រតិបត្តិខ្ពស់ សម្រាប់ករណីសរុបទាំងអស់។ ចំនួនករណីសរុប សំដៅលើចំនួនពាក្យបណ្តឹងទាំងអស់ ដែលបានទទួលជារៀងរាល់ឆ្នាំ ចាប់គិតពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០០៩។ ការប្រើប្រាស់តួលេខនេះជាភាគបែង ធ្វើឱ្យការប៉ាន់ប្រមាណចំណាយសម្រាប់ករណីនីមួយៗតិចជាងចំណាយជាក់ស្តែង ដោយសារតែករណីមួយចំនួនត្រូវបានដោះស្រាយ ឬបញ្ចប់សព្វគ្រប់អស់ហើយ ហើយពុំត្រូវការចំណាយអ្វីទាំងអស់។ ពុំមានទិន្នន័យ សម្រាប់ឱ្យមានការប្រៀបធៀបដោយសុក្រឹតសម្រាប់ករណី ដែលយន្តការគណនេយ្យភាពនីមួយៗដោះស្រាយ ជារៀងរាល់ឆ្នាំនោះទេ (រូបភាពទី ១)។ ប៉ុន្តែ ការប្រើតួលេខចំណាយប្រតិបត្តិសរុបពេលមួយឆ្នាំជាភាគយក ធ្វើឱ្យគេអាចទាញចេញជាសេចក្តីសន្និដ្ឋានដូចគ្នាថា ចំណាយប្រតិបត្តិរបស់យន្តការគណនេយ្យ-ភាពនៃធនាគារអភិវឌ្ឍន៍អាស៊ីមានកម្រិតខ្ពស់ បើគិតពីបន្ទុកការងាររបស់យន្តការគណនេយ្យភាពផ្សេងៗ។

៥០. ដោយសារតែយន្តការគណនេយ្យភាពនេះ គឺជាយន្តការ ដែលឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង, ចំណាយប្រតិបត្តិសម្រាប់ករណីនីមួយៗ តែងមានការប្រែប្រួលពីមួយឆ្នាំ ទៅមួយឆ្នាំទៀត ហើយចាំបាច់ត្រូវមានចំណាយមួយចំនួន ដើម្បីរក្សាប្រសិទ្ធភាពរបស់យន្តការគណនេយ្យភាព ដោយមិនគិតពីចំនួនពាក្យបណ្តឹង ដែលបានទទួល។ ធនាគារអភិវឌ្ឍន៍អាស៊ី ចាំបាច់ត្រូវធានាឱ្យមានធនធានគ្រប់គ្រាន់ ដើម្បីធ្វើការឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះការស្នើសុំ របស់អ្នកដែលរងផលប៉ះពាល់ដោយសារគម្រោង ប៉ុន្តែមិនមែនប្រើប្រាស់សមត្ថភាពច្រើនពេក ដែលធ្វើឱ្យមានការប្រើប្រាស់ធនធានកម្រ ដោយពុំមានប្រសិទ្ធភាពនោះទេ។

**រូបភាពទី ១ - ចំណាយប្រតិបត្តិសម្រាប់សម្រាប់ករណីសរុបនីមួយៗ**

(គិតជា ០០០ ដុល្លារសហរដ្ឋអាមេរិច, ឆ្នាំ ២០០៩)



ADB = ធនាគារអភិវឌ្ឍន៍អាស៊ី, AfDB = ធនាគារអភិវឌ្ឍន៍អាហ្វ្រិច, AM = យន្តការគណនេយ្យភាព, CAO = ការិយាល័យប្រជាពលរដ្ឋសម្រាប់ផ្តល់ប្រឹក្សាអំពីការអនុលោម, CRP= គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម, ICIM = យន្តការពិគ្រោះយោបល់ និងស៊ើបអង្កេតឯករាជ្យ, IFC = សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ, IP= គណៈកម្មការអធិការកិច្ច, IRM = យន្តការពិនិត្យឡើងវិញដោយឯករាជ្យ, OA = ការិយាល័យគណនេយ្យភា, OCRP = ការិយាល័យរបស់គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម, OSPF = ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស, OPIC = សាជីវកម្មវិនិយោគឯកជនក្រៅប្រទេស (សហរដ្ឋអាមេរិច), WB=ធនាគារពិភពលោក

ប្រភព: BPMSD , ធនាគារអភិវឌ្ឍន៍អាស៊ី និងរបាយការណ៍ប្រចាំឆ្នាំរបស់យន្តការគណនេយ្យភាពផ្សេងៗ

៥១. បញ្ហារួមមួយរបស់ប្រទេសកំពុងអភិវឌ្ឍជាសមាជិកគឺ យន្តការគណនេយ្យភាពធ្វើឱ្យមានចំណាយជាច្រើន ដែលត្រូវរ៉ាប់រងដោយប្រទេសកំពុងអភិវឌ្ឍជាសមាជិក។ ប្រទេសកំពុងអភិវឌ្ឍជាសមាជិកកំណត់ពីចំណាយមួយចំនួន ដែលអាចមាន ដូចជា (i) ការពន្យារពេលការអនុវត្តគម្រោង ដែលធ្វើឱ្យមានការកើនឡើងនូវចំណាយ, ចំណាយហួសពីថវិកាដែលបានគ្រោងទុក និងពន្យារពេលការផ្តល់ប្រយោជន៍ ខណៈពេលដែលប្រទេសនៅតែត្រូវសងកម្ចី និងការប្រាក់វិញ ទៅតាមកាលវិភាគ ដែលបានគ្រោងទុក, (ii) ការផ្លាស់ប្តូរវិសាលភាព ដែលតម្រូវឱ្យមានការផ្តល់ហិរញ្ញប្បទានបន្ថែម និងធ្វើឱ្យការរៀបចំគម្រោងមិនផ្តល់ប្រយោជន៍ដល់កម្រិតអតិបរមាដល់អ្នកទទួលផល, (iii) សំណងទូទាត់ច្រើនជាងមុន, (iv) ចំណាយរដ្ឋបាលខ្ពស់ជាងមុន និង (v) ចំណាយមិនមែនហិរញ្ញវត្ថុ ដូចជាការបញ្ចៀសហានិភ័យរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីកុំឱ្យគម្រោងមានភាពស្មុគស្មាញ បើទោះបីជាគម្រោងនេះត្រូវមានលក្ខណៈស្មុគស្មាញក៏ដោយ, កង្វះការច្នៃប្រឌិតថ្មី និងនិន្នាការផ្តោតលើភាពអនុលោម ជាជាងលើលទ្ធផលនៃការអភិវឌ្ឍ។ រដ្ឋាភិបាលប្រទេសស្រីលង្ការបានប៉ាន់ប្រមាណពីចំណាយពាក់ព័ន្ធនឹងយន្តការគណនេយ្យភាពសម្រាប់គម្រោង STDP ប្រមាណ ៥ ពាន់លាន Rs (៤៥ លានដុល្លារសហរដ្ឋអាមេរិច) ដោយសារកត្តាជាច្រើន។ កត្តាទីមួយ ការពន្យារពេលផ្ទេរការដ្ឋានគម្រោង និងការផ្តល់កិច្ចសន្យាសាងសង់។ កិច្ចសន្យា ដែលត្រូវបានចុះហត្ថលេខារវាងក្រសួងផ្លូវថ្នល់ (និយោជក) និងក្រុមហ៊ុនម៉ៅការ (Kumagai Gumi) នៅក្នុងខែ ធ្នូ ឆ្នាំ ២០០២ តម្រូវឱ្យក្រសួងផ្លូវថ្នាក់ផ្ទេរការដ្ឋានគម្រោង ដែលផ្នែករបស់ធនាគារអភិវឌ្ឍន៍អាស៊ី ទៅឱ្យក្រុមហ៊ុនម៉ៅការ នៅដើមឆ្នាំ ២០០៤។ ប៉ុន្តែ ការផ្ទេរជាក់ស្តែងត្រូវបានធ្វើឡើង នៅក្នុងឆ្នាំ ២០០៦។ រដ្ឋាភិបាលប្រទេសស្រីលង្ការបានលើកឡើងថា អ្នកដែលទទួលរងផលប៉ះពាល់ដោយសារគម្រោងមួយចំនួនបដិសេធមិនព្រមចាកចេញ សូម្បីតែក្រោយពេលដែលពួកគេបានទទួលសំណងរួច ហើយព្រមចាកចេញតែនៅពេលដែលមានដីកាពីតុលាការកំពូលតែប៉ុណ្ណោះ។ រដ្ឋាភិបាលប្រទេសស្រីលង្ការបានលើកឡើងថា ការពិនិត្យឡើងវិញរបស់គណៈ-កម្មការពិនិត្យឡើងវិញលើភាពអនុលោមមិនចាំបាច់ធ្វើឡើយ ក្រោយពេលមានសេចក្តីសម្រេចរបស់តុលាការឧទ្ធរណ៍នៅក្នុងឆ្នាំ ២០០២ និងសាលដីការបស់តុលាការកំពូល នៅក្នុងខែ មករា ឆ្នាំ ២០០៤ រួចមក ហើយក្រោយពេលដែលគណៈកម្មការអធិការកិច្ចរបស់ធនាគារអភិវឌ្ឍន៍អាស៊ីបានចាត់ទុកការស្នើសុំរបស់អ្នកស្នើសុំដដែលនេះ ថាពុំមានលក្ខណៈ

សមស្រប នៅក្នុងឆ្នាំ ២០០១ រួចមក។ ដោយសារតែការពន្យារពេលផ្ទេរការដ្ឋានគម្រោងនេះ, ក្រុមហ៊ុនម៉ៅការបានទាមទារសំណងចំនួន ២ ដោយសារតែការខកខានរបស់និយោជក ក្នុងការផ្តល់កម្មសិទ្ធិលើការដ្ឋានឱ្យពួកគេ។ ការទាម-ទារទាំង ៣ នេះមានតម្លៃសរុបប្រហែលជា ៣,៨ ពាន់លាន Rs (៣៦ លានដុល្លារសហរដ្ឋអាមេរិច)។ ឥលូវនេះ ការទាមទារទាំងនេះកំពុងឆ្លងកាត់ដំណើរការមជ្ឈត្តការអន្តរជាតិ។ រដ្ឋាភិបាលបានកត់សម្គាល់ថា បញ្ហាស្រដៀងគ្នានេះមិនបានកើតឡើងនៅក្នុងកំណាត់ផ្លូវដដែលនេះ ដែលទទួលបានសហហិរញ្ញប្បទានពី JBIC ឡើយ។ ទីពីរ ការបន្តកិច្ចសន្យាសម្រាប់ក្រុមហ៊ុនម៉ៅការ, ទីប្រឹក្សាត្រួតពិនិត្យសំណង់, ការថែទាំបរិក្ខារនានារបស់វិស្វករ និងចំណាយពាក់ព័ន្ធដោយសារតែនិយោជកខកខានមិនបានផ្ទេរការដ្ឋានគម្រោង។ ទីបី មានការកើនឡើងនូវចំណាយ ដោយសារតែតម្លៃទំនិញមានការកើនឡើង។ អត្រាអតិផរណាប្រចាំឆ្នាំជាមធ្យម នៅក្នុងប្រទេសស្រីលង្ការ គឺប្រហែលជា ១២% ពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០០៩។ កាលបរិច្ឆេទបញ្ចប់គម្រោងត្រូវបានបន្តថែម ៤ ឆ្នាំទៀត ដល់ចុងឆ្នាំ ២០១០។ ការអនុវត្តបានពន្យារពេល ហើយកត្តាដទៃទៀតបានធ្វើឱ្យចំណាយមានការកើនឡើងខ្ពស់ឆ្ងាយពីថវិកា ដែលបានគ្រោងទុក។ រដ្ឋាភិបាលបានស្នើសុំកម្ចីបន្ថែម ហើយធនាគារអភិវឌ្ឍន៍អាស៊ីបានអនុម័តផ្តល់ហិរញ្ញប្បទានកម្ចីបន្ថែមចំនួន ៩០ លានដុល្លារ នៅថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០០៨។[២៧] នៅក្នុងគម្រោង Chashma , គម្រោងគ្រោងនឹងបញ្ចប់ នៅចុងឆ្នាំ ២០០៤ នៅពេលមានការចាប់ផ្តើមការធ្វើអធិការកិច្ច នៅពេលដែលការសាងសង់របស់គម្រោងចំនួន ៩៩% បានបញ្ចប់ និងកម្ចីរបស់ធនាគារអភិវឌ្ឍន៍អាស៊ីចំនួន ៨០% ត្រូវបានបើកផ្តល់រួចហើយ។ ផ្អែកទៅតាមអនុសាសន៍របស់គណៈកម្ម-ការអធិការកិច្ច, កាលបរិច្ឆេទបញ្ចប់កម្ចីនេះត្រូវបានបន្តរយៈពេល ៥ ឆ្នាំទៀត។ របាយការណ៍បញ្ចប់គម្រោងបានបង្ហាញថា ទឹកប្រាក់ចំនួន ១២,៥ លានដុល្លារសហរដ្ឋអាមេរិច នៃកម្ចីសរុបរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ត្រូវបានបើកផ្តល់ជាក់ស្តែង សម្រាប់ការអនុវត្តផែនការសកម្មភាពកែតម្រូវ។ ធនធានបន្ថែម ដើម្បីបង្កើតមជ្ឈមណ្ឌលដោះស្រាយពាក្យបណ្តឹងដែលបង្កើតឡើងដោយអាជ្ញាធរទឹក និងការអភិវឌ្ឍថាមពល ត្រូវបានរ៉ាប់រង ដោយរដ្ឋាភិបាល។

៩២. ដោយសារតែគេមិនអាចគណនាចំណាយរបស់យន្តការគណនេយ្យភាពឱ្យបានសុក្រឹតគ្រប់ពេល ដោយសារតែមានកត្តាជាច្រើន ដែលពាក់ព័ន្ធ, ជាការពិត យន្តការគណនេយ្យភាពតែងតម្រូវឱ្យប្រទេសកំពុងអភិវឌ្ឍជាសមាជិកជា

---

[២៧] ធនាគារអភិវឌ្ឍន៍អាស៊ី, ២០០៨, *សំណើកម្ចី និងជំនួយបច្ចេកទេសឥតសំណងបន្ថែម សម្រាប់គម្រោងអភិវឌ្ឍន៍តំបន់ភាគខាងត្បូង (ប្រទេសស្រីលង្ការ)* ម៉ានីល។

អ្នករ៉ាប់រងចំណាយ។ ឧទាហរណ៍ នៅក្នុងរបាយការណ៍ពិនិត្យតាមដានប្រចាំឆ្នាំ ២០០៨-០៩[២៨] , គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោមបានលើកឡើងថា គណៈកម្មការ "ដឹងថា គ្រប់ការងារកែតម្រូវទាំងអស់ ដើម្បីកែតម្រូវបញ្ហានៃភាពមិនអនុលោមនៅក្នុងគម្រោងមួយ ត្រូវការពេលវេលាបន្ថែម និងអាចត្រូវការចំណាយបន្ថែម រាប់បញ្ចូលទាំងចំណាយ ដែលត្រូវរ៉ាប់រងដោយប្រទេសខ្ចីកម្ចី។ គណៈកម្មការក៏បានធ្វើការសន្និដ្ឋានផងដែរថា មានចំណាយបន្តបន្ទាប់ផ្សេងទៀត ដែលប្រទេសខ្ចីកម្ចីត្រូវរ៉ាប់រង សម្រាប់ការអនុវត្តអនុសាសន៍ ដែលបានទទួលការឯកភាពពីក្រុមប្រឹក្សា-ភិបាល" (កថាខ័ណ្ឌទី ៤១)។ អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺ ចំណាយនានា ដែលកើតឡើងដោយសារភាពមិនអនុលោមរបស់ធនាគារអភិវឌ្ឍន៍អាស៊ីទៅតាមគោលនយោបាយ និងនីតិវិធីរបស់ខ្លួន ត្រូវរ៉ាប់រងដោយអ្នកខ្ចីកម្ចី។ នេះគឺជាមូលហេតុចម្បងមួយ ដែលធ្វើឱ្យអ្នកខ្ចីកម្ចីមិនមានភាពងាយស្រួល និងមានការស្ទាក់ស្ទើរ ក្នុងការទទួលយកការពិនិត្យឡើងវិញលើភាពអនុលោម រួមទាំង ការចុះទៅកាន់ទីតាំងជាក់ស្តែងរបស់គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោមផងដែរ។ ធនាគារអភិវឌ្ឍន៍អាស៊ីចាំបាច់ត្រូវប្រឈមនឹងបញ្ហានេះ ដើម្បីធានាថាយន្តការគណនេយ្យភាពនេះមានភាពជឿជាក់ និងមានភាពជាម្ចាស់ពីសំណាក់ប្រទេសកំពុងអភិវឌ្ឍជាសមាជិក។

៥៣. ដំណើរការរបស់យន្តការគណនេយ្យភាព ក៏តម្រូវឱ្យអ្នកដែលរងផលប៉ះពាល់ដោយសារគម្រោង ត្រូវចំណាយពេលវេលា និងធនធានផងដែរ។ ដំណើរការអូសបន្លាយពេលដ៏វែងបែបនេះទាមទារពេលវេលា និងកិច្ចខិតខំប្រឹងប្រែងរបស់ប្រជាពលរដ្ឋ និងដាក់បន្ទុកដ៏ធ្ងន់ធ្ងរមួយលើការងារ និងជីវភាពប្រចាំថ្ងៃរបស់ពួកគេ។ គេចាំបាច់ត្រូវធានានូវមានការកាត់បន្ថយចំណាយប្រតិបត្តិការ សម្រាប់ការដោះស្រាយបញ្ហា ដែលប្រឈមដោយអ្នកដែលរងផលប៉ះពាល់ដោយ-សារគម្រោង។ ដោយសារមូលហេតុនេះហើយ យន្តការគណនេយ្យភាពនេះគួរលើកទឹកចិត្តឱ្យមានការប្រើប្រាស់យ៉ាងពេញលេញនូវប្រព័ន្ធរបស់ប្រទេស, យន្តការដោះស្រាយការកើតទុក្ខមិនសុខចិត្តនៅកម្រិតគម្រោង និងកិច្ចខិតខំប្រឹងប្រែងរបស់នាយកដ្ឋានប្រតិបត្តិការ នៅក្នុងការបង្ការបញ្ហា, ការដោះស្រាយបញ្ហា និងការលើកទឹកចិត្តឱ្យមានការអនុលោមឱ្យបានឆាប់។

## ខ. ភាពស័ក្តិសិទ្ធិ

### ១. រចនាសម្ព័ន្ធរបស់យន្តការគណនេយ្យភាព

---

[២៨] គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ២០០៩ *របាយការណ៍ពិនិត្យតាមដានប្រចាំឆ្នាំ ២០០៧-២០០៨ ផ្ញើទៅកាន់ក្រុមប្រឹក្សាភិបាលអំពីការអនុវត្តសកម្មភាពកែតម្រូវ ផ្អែកទៅតាមសំណើសុំឱ្យមានការធ្វើអធិការកិច្ចលើគម្រោងផ្លូវសាស្ត្រតាមដងទន្លេចាស្មា (ដំណាក់កាលទី ៣) នៅក្នុងប្រទេសប៉ាគីស្ថាន (កម្ចីរបស់ធនាគារអភិវឌ្ឍន៍អាស៊ីលេខ 1146-PAK[SF])* , ម៉ានីល។

៥៤. យន្តការគណនេយ្យភាពជម្រុញឱ្យមានទិដ្ឋភាពថ្មីមួយរបស់គណនេយ្យភាព។ ទិដ្ឋភាពនេះមានមុខងារចំនួន ២ ដោយឡែកពីគ្នា ប៉ុន្តែមានទំនាក់ទំនងជាមួយគ្នាៈ ដំណាក់កាលពិគ្រោះយោបល់ និងដំណាក់កាលពិនិត្យឡើងវិញលើភាពអនុលោម។ រចនាសម្ព័ន្ធនេះបានទទួលការអនុម័ត នៅក្នុងឆ្នាំ ២០០៣ បន្ទាប់ពីមានការពិគ្រោះយោបល់ដ៏ច្រើនរួចមក។ ការពិគ្រោះយោបល់ នៅក្នុងឆ្នាំ ២០១០ បង្ហាញថា រចនាសម្ព័ន្ធជាមូលដ្ឋាននេះនៅតែមានភាពល្អប្រសើរ និងកំពុងអនុវត្តតាមច្រើនឡើងៗ ដោយយន្តការគណនេយ្យភាពរបស់ទីភ្នាក់ងារអភិវឌ្ឍន៍ដទៃទៀត។

## ២. ភាពពាក់ព័ន្ធ

៥៥. ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេសបានទទួលពាក្យបណ្តឹងចំនួន ៣២ ហើយគណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោមបានទទួលសំណើចំនួន ៣ ចាប់តាំងពីឆ្នាំ ២០០៤ មក។ មនុស្សមួយចំនួនអះអាងថា សំណើដែលគណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោមទទួលបាននេះ មានចំនួនទាបពេក។ មុនពេលធ្វើការវិភាគលើមូលហេតុ ដែលធ្វើឱ្យមានការប្រើប្រាស់គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោមតិចតួច, បទពិសោធន៍របស់ធនាគារអភិវឌ្ឍន៍ពហុភាគីដទៃទៀត អាចបង្កើតនូវបរិបទសម្រាប់ការវិភាគនេះ។ គណៈកម្មការអធិការកិច្ចរបស់ធនាគារពិភពលោក បានស៊ើបអង្កេតសំណើចំនួន ៣២ នៅក្នុងកំឡុងពេល ១៧ ឆ្នាំ នៃការមានគណៈកម្មការនេះ ចាប់ពីឆ្នាំ ១៩៩៣ ដល់ ឆ្នាំ ២០១០ គិតជាមធ្យមគឺតិចជាង ២ ករណីក្នុងមួយឆ្នាំ សម្រាប់ស្ថាប័នមួយ ដែលគម្រោង/កម្មវិធីសរុបមានទំហំធំជាងគម្រោង/កម្មវិធីរបស់ធនាគារអភិវឌ្ឍន៍អាស៊ីជិត ៤ ដង។ ផ្នែកធានាភាពអនុលោមរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ បានដោះស្រាយករណីពិនិត្យឡើងវិញលើភាពអនុលោមចំនួន ១៨ ចាប់តាំងពីឆ្នាំ ២០០ មក ដែលក្នុងនោះមានករណីចំនួន ៩ បានឆ្លងកាត់ដំណើរការវាយតម្លៃភាពអនុលោមបឋម ប៉ុន្តែត្រូវបានរកឃើញថាពុំមានលក្ខណៈសមស្របសម្រាប់សវនកម្មលើភាពអនុលោម, ករណីចំនួន ៦ បានឆ្លងកាត់តាមដំណើរការសវនកម្មលើភាពអនុលោមពេញលេញ និង ៣ ទៀត កំពុងស្ថិតនៅក្នុងដំណើរការ។ ធនាគារអភិវឌ្ឍន៍អាហ្វ្រិច បានទទួលករណីចំនួន ៦ ចាប់តាំងពីឆ្នាំ ២០០៧ មក ដែលក្នុងនោះករណីចំនួន ២ មានលក្ខណៈសមស្រប សម្រាប់ការពិនិត្យឡើងវិញលើភាពអនុលោម។ ទិន្នន័យទាំងនេះបង្ហាញថា ពាក្យបណ្តឹងក្នុងបរិមាណទាបបែបនេះ គឺជារឿងធម្មតាតែប៉ុណ្ណោះ។ ឧបសម្ព័ន្ធទី ៣ បង្ហាញពីចំនួនករណី ដែលយន្តការគណនេយ្យភាពផ្សេងៗទទួលបាន។

៥៦. ដំណើរការពិគ្រោះយោបល់នេះបង្ហាញពីមូលហេតុផ្សេងៗ ដែលធ្វើឱ្យធនាគារអភិវឌ្ឍន៍អាស៊ី ទទួលបានសំណើតិចតួចសម្រាប់ការពិនិត្យឡើងវិញលើភាពអនុលោម។ ទីមួយ យន្តការបង្ការ និងដោះស្រាយបញ្ហា នៅកម្រិតជាច្រើន ពីក្រោមឡើងលើ ត្រូវបានដាក់ឱ្យអនុវត្ត ដែលក្នុងនោះរួមមានយន្តការដោះស្រាយការកើតទុក្ខមិនសុខចិត្ត នៅកម្រិត

គម្រោង, កម្រិតនាយកដ្ឋានប្រតិបត្តិការ និងកម្រិតយន្តការគណនេយ្យភាព។ ការកើតទុក្ខមិនសុខចិត្តភាគច្រើនត្រូវបានដោះស្រាយនៅកម្រិតគម្រោង ដោយទីភ្នាក់ងារប្រតិបត្តិ និងទីភ្នាក់ងារអនុវត្ត។ ឧទាហរណ៍ នៅក្នុងគម្រោង STDP រដ្ឋាភិបាលប្រទេសស្រីលង្ការបានបង្កើតនូវគណៈកម្មាធិការលទ្ធកម្មដីធ្លី និងដោះស្រាយផលប៉ះពាល់មួយ និងគណៈ-កម្មាធិការលទ្ធកម្មដីធ្លី និងដោះស្រាយផលប៉ះពាល់ជាន់ខ្ពស់មួយទៀត។ អ្នកដែលរងផលប៉ះពាល់ភាគច្រើនបានទទួលដំណោះស្រាយយ៉ាងពេញចិត្តចំពោះដំណោះស្រាយរបស់ពួកគេ តាមរយៈយន្តការទាំងនេះ។ គោលនយោបាយស្តីពីការការពារផលប៉ះពាល់សង្គម និងបរិស្ថាន តម្រូវឱ្យមានការបង្កើតយន្តការដោះស្រាយការកើតទុក្ខមិនសុខចិត្ត នៅកម្រិតគម្រោង ដើម្បីផ្តល់ការឆ្លើយតបឱ្យបានឆាប់រហ័សដល់អ្នកដែលរងផលប៉ះពាល់។ ផ្នែកនៃគោលនយោបាយស្តីពីការការពារផលប៉ះពាល់សង្គម និងបរិស្ថាននេះ បានចូលជាធរមាន នៅក្នុងខែ មករា ឆ្នាំ ២០១០។ យន្តការដោះស្រាយការកើតទុក្ខមិនសុខចិត្តសម្រាប់គម្រោង អាចមានន័យថា នាពេលអនាគត នឹងមានករណីតិចតួចតែប៉ុណ្ណោះ ដែលនឹងត្រូវបានគេនាំមកឱ្យយន្តការគណនេយ្យភាពធ្វើការដោះស្រាយ (រូបភាពទី ២)។[២៩]

### រូបភាពទី ២: ក្របខ័ណ្ឌដោះស្រាយបញ្ហា និងធានាឱ្យមានភាពអនុលោមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី




កំណត់សម្គាល់: រូបភាពនេះមិនឆ្លើយតបចំពោះភាគរយបញ្ហាជាក់ស្តែង ដែលដោះស្រាយដោយយន្តការផ្សេងៗគ្នានោះទេ។

---

[២៩] កត្តា ដែលអាចធ្វើឱ្យមានតុល្យភាពឡើងវិញបានគឺ មូលហេតុអាចបង្កើនទំហំនៃចំនួនគម្រោងទាំងអស់។ លើសពីនេះ, ជាមួយនឹងការផ្សព្វផ្សាយព័ត៌មាន និងការបង្កើនការយល់ដឹង, អាចមានចំណេះដឹងបន្ថែមទៀតអំពីយន្តការគណនេយ្យភាព និងមានពាក្យបណ្តឹងកាន់តែច្រើនជាងមុន។

CRP = គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម, OSPF = ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស

៥៧. បន្ថែមពីលើទីភ្នាក់ងារប្រតិបត្តិ និងទីភ្នាក់ងារអនុវត្ត, នាយកដ្ឋានប្រតិបត្តិការក៏ដោះស្រាយបញ្ហានៃការអនុវត្តផងដែរ ដូចជា ការដោះស្រាយបញ្ហារបស់អ្នករងផលប៉ះពាល់ដោយសារគម្រោង ជាប្រចាំថ្ងៃជាដើម។ យូរទៅ បុគ្គលិករបស់ធនាគារ និងទីភ្នាក់ងារប្រតិបត្តិ កាន់តែយល់ពីគោលនយោបាយស្តីពីការការពារសង្គម និងបរិស្ថាន និងកាន់តែដឹងពីការបង្ការបញ្ហាមិនឱ្យកើតមានឡើង។ ការបំពេញទៅតាមដំណើរការពិគ្រោះយោបល់ និងពិនិត្យឡើងវិញលើភាពអនុលោម តម្រូវការពេលវេលាបុគ្គលិក និងធនធានជាច្រើន។ ដូច្នេះ គេបានខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង ដើម្បីបង្ការកុំឱ្យបញ្ហាកើតមានឡើង និងដោះស្រាយបញ្ហាទាំងនោះឱ្យបានឆាប់។ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ គ្រប់នាយកដ្ឋានប្រចាំតំបន់ទាំងអស់បានបង្កើតនូវអង្គភាពទទួលបន្ទុកការការពារផលប៉ះពាល់បរិស្ថាន និងសង្គម ដើម្បីដោះស្រាយបញ្ហា និងធានាឱ្យមានការអនុលោមឱ្យបានឆាប់។ ការបណ្តុះបណ្តាលជច្រើនអំពីការការពារផលប៉ះពាល់បរិស្ថាន និងសង្គម ត្រូវបានរៀបចំឡើង នៅក្នុងធនាគារអភិវឌ្ឍន៍អាស៊ី និងប្រទេសកំពុងអភិវឌ្ឍជាសមាជិក។ ដូច្នេះ ពាក្យបណ្តឹង ដែលដាក់ទៅកាន់អ្នកសម្របសម្រួលគម្រោងពិសេស និងគណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម គួរមានតែក្នុងករណីលើកលែងតែប៉ុណ្ណោះ។

៥៨. តួនាទីរបស់នាយកដ្ឋានប្រតិបត្តិការ ក្នុងនាមជាយន្តការដោះស្រាយបញ្ហា និងធានាឱ្យមានភាពអនុលោម គួរទទួលបានការទទួលស្គាល់ឱ្យបានពេញលេញ នៅក្នុងក្របខ័ណ្ឌយន្តការគណនេយ្យភាព។ ការធានាឱ្យមានភាពអនុលោមជាមួយនឹងគោលនយោបាយ និងនីតិវិធីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី គឺជាការទទួលខុសត្រូវដ៏សំខាន់មួយ របស់នាយក-ដ្ឋានប្រតិបត្តិការ។ ពេលខ្លះ មានការចាត់វិធានការភ្លាមៗ។ ឧទាហរណ៍ គម្រោងផ្លូវលេខ ៦[៣០] នៅក្នុងប្រទេសហ្វីលីពីនប្រឈមនឹងបញ្ហាលទ្ធកម្មដីធ្លី និងការតាំងទីលំនៅជាថ្មីធំៗជាច្រើន ដោយសារការរៀបចំគម្រោងធ្វើឡើងមិនបានល្អ និងមានការអនុម័តលើគោលនយោបាយស្តីពីការការពារផលប៉ះពាល់បរិស្ថាន និងសង្គម ក្រោយពេលដែលកម្ចីនេះចូលជាធរមាន។ ជាការកែតម្រូវ, ធនាគារអភិវឌ្ឍន៍អាស៊ីបានស្នើឱ្យរដ្ឋាភិបាលហ្វីលីពីនចាត់វិធានការ ដើម្បីអនុលោមទៅតាមគោលនយោបាយថ្មីស្តីពីការតាំងទីលំនៅជាថ្មី របស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ការធ្វើបែបនេះមិនអាចទទួលយកបានសម្រាប់រដ្ឋាភិបាលឡើយ។ ចុងក្រោយ បន្ទាប់ពីមានការពិគ្រោះយោបល់ជាច្រើនលើករួចមក រដ្ឋាភិបាលបានផ្តល់សំណងដល់គ្រួសារ ដែលទទួលរងផលប៉ះពាល់ និងបានរៀបចំផែនការតាំងទីលំនៅជាថ្មី ដែលទទួលបានការឯកភាពពីធនាគារអភិវឌ្ឍន៍អាស៊ី។ ក្រោយមក នៅក្នុងពេលពិនិត្យឡើងវិញលើគម្រោង និងក្នុងកំឡុងពេលបេសកកម្មរៀបចំរបាយការណ៍

[៣០] ធនាគារអភិវឌ្ឍន៍អាស៊ី ១៩៩៦ *របាយការណ៍ និងអនុសាសន៍របស់ប្រធានធនាគារផ្ញើរទៅកាន់ក្រុមប្រឹក្សាភិបាលៈ សំណើកម្ចី និងជំនួយឥតសំណង (JSF) ដល់ប្រទេសហ្វីលីពីន សម្រាប់គម្រោងផ្លូវលេខ ៦,* ម៉ានីល។

បញ្ចប់គម្រោង មានការបញ្ជាក់ថា គ្រួសារដែលរងផលប៉ះពាល់ដោយសារគម្រោងមានជីវភាពរស់នៅប្រហាក់ប្រហែល ឬប្រសើរជាងមុន ក្រោយពេលមានការតាំងទីលំនៅជាថ្មី។ ស្រដៀងគ្នានេះដែរ ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្អាកនូវសមាសធាតុការងារសាងសង់មួយចំនួន ក្នុងគម្រោងវិនិយោគលើវិស័យអភិវឌ្ឍន៍ផ្លូវជាតិរបស់ប្រទេសប៉ាគីស្ថាន [៣១] ដោយសារការពន្យារពេលការទូទាត់សំណង និងផ្អាកការសាងសង់ផ្លូវក្រោមដី បន្ទាប់ពីបណ្ដឹងមួយត្រូវបានដាក់ទៅកាន់ការិយាល័យរបស់អ្នកសម្របសម្រួលគម្រោងពិសេស។ ការងារទាំងនេះត្រូវបានបន្តឡើងវិញ តែក្រោយពេលដែលបញ្ហាទាំងនេះត្រូវបានដោះស្រាយយ៉ាងពេញលេញតែប៉ុណ្ណោះ។ សកម្មភាពទាំងនេះត្រូវបានធ្វើឡើង ដោយពុំមានដំណើរការពិនិត្យឡើងវិញលើភាពអនុលោមជាផ្លូវការឡើយ។

៥៩. ការស្រាវជ្រាវអំពីយន្តការគណនេយ្យភាព បង្ហាញពីភាពចាំបាច់ឱ្យមានយន្តការជាច្រើន នៅក្នុងស្ថាប័នមួយ ដើម្បីដោះស្រាយបញ្ហារបស់អ្នកដែលរងផលប៉ះពាល់ដោយសារគម្រោង។ ប្រព័ន្ធរបស់ធនាគារអភិវឌ្ឍន៍អាស៊ីអនុលោមទៅតាមគោលការណ៍នេះ។ ការបង្ការបញ្ហា, ការដោះស្រាយបញ្ហា និងការឆាប់អនុលោម គឺមានប្រយោជន៍សម្រាប់អ្នកដែលរងផលប៉ះពាល់, ធនាគារអភិវឌ្ឍន៍អាស៊ី និងប្រទេសកំពុងអភិវឌ្ឍជាសមាជិក។ ដំណោះស្រាយនៅមូលដ្ឋានជាក់ស្ដែង មានល្បឿនលឿនជាង, អស់ចំណាយតិចជាង និងធ្វើឱ្យមានចំណាយប្រតិបត្តិការទាបជាង ជម្រើសយន្តការគណនេយ្យភាពដទៃទៀត។ ជាការពិត ការពិគ្រោះយោបល់នេះបង្ហាញថា ចំណុចខ្លាំងពិសេសមួយនៃប្រព័ន្ធរបស់ធនាគារអភិវឌ្ឍន៍អាស៊ី គឺការបន្តមានអង្គភាពសម្រាប់ដោះស្រាយបញ្ហា។ រចនាសម្ព័ន្ធច្រើនជាន់បែបនេះ ជួយធ្វើឱ្យមានការប្រើប្រាស់ធនធានកម្ររបស់អ្នករងផលប៉ះពាល់, ប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិក និងធនាគារអភិវឌ្ឍន៍អាស៊ីបានល្អបំផុត។

៦០. កត្តាទី ២ ដែលជាមូលហេតុនៃការស្នើសុំឱ្យមានការពិនិត្យឡើងវិញលើភាពអនុលោមក្នុងកម្រិតទាបបែបនេះ គឺដោយសារការយល់ដឹង និងលទ្ធភាពប្រើប្រាស់ (សូមមើលកថាខណ្ឌ ២១-២២)។ នីតិវិធី ដែលត្រូវការចំណាយពេលច្រើនរបស់យន្តការគណនេយ្យភាព អាចរារាំងមិនឱ្យអ្នកដែលចង់ដាក់ពាក្យបណ្ដឹមប្រើប្រាស់យន្តការនេះ។

៦១. មូលហេតុទី ៣ អាចជាលក្ខខណ្ឌតម្រូវឱ្យអ្នកដែលរងផលប៉ះពាល់ ដំបូងត្រូវចាប់ផ្ដើមពីដំណាក់កាលពិគ្រោះ-យោបល់ជាមុនសិន មុនពេលដែលពួកគេអាចធ្វើការស្នើសុំឱ្យមានការពិនិត្យឡើងវិញលើភាពអនុលោម។ បើទោះបីជាអ្នកដាក់ពាក្យបណ្ដឹងងាយស្រួលចាកចេញពីដំណាក់កាលពិគ្រោះយោបល់ និងដាក់សំណើឱ្យមានការពិនិត្យឡើងវិញលើ

---

[៣១] ធនាគារអភិវឌ្ឍន៍អាស៊ី ១៩៩៦ *របាយការណ៍ និងអនុសាសន៍របស់ប្រធានធនាគារផ្ញើរទៅកាន់ក្រុមប្រឹក្សាភិបាល: សំណើកម្ចីវិធីហិរញ្ញប្បទានពហុផ្នែក និងសំណើកម្ចីដល់ប្រទេសប៉ាគីស្ថាន សម្រាប់កម្មវិធីវិនិយោគវិស័យអភិវឌ្ឍន៍ផ្លូវជាតិ*, ម៉ានីល។

ភាពអនុលោម បន្ទាប់បានទាក់ទងទៅកាន់ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេសដំបូងរួចក៏ដោយ មានមនុស្សមួយចំនួនអះអាងថា លក្ខខណ្ឌតម្រូវបែបនេះអាចធ្វើឱ្យទាញយកចិត្តការយកចិត្តទុកដាក់ចេញពីការពិនិត្យឡើងវិញលើភាពអនុលោម។ គេចាំបាច់ត្រូវពិនិត្យឡើងវិញលើសនិទានភាព ដើម្បីចាប់ផ្តើមពីការដោះស្រាយបញ្ហាជាមុនសិន និងធ្វើការបញ្ជាក់ឱ្យបានច្បាស់លាស់អំពីអណត្តិការងារ និងទំនាក់ទំនងរវាងការដោះស្រាយបញ្ហា និងការពិនិត្យឡើងវិញលើភាពអនុលោម។

## ៣. ការបញ្ជាក់ឱ្យបានច្បាស់លាស់អំពីអណត្តិការងារ

៦២. **ទំនាក់ទំនងរវាងការដោះស្រាយបញ្ហា និងការពិនិត្យឡើងវិញលើភាពអនុលោម**។ ក្រោមគោលនយោបាយស្តីពីយន្តការគណនេយ្យភាពបច្ចុប្បន្ន, អ្នកដាក់ពាក្យបណ្តឹងត្រូវចាប់ផ្តើមជាមួយដំណាក់កាលពិគ្រោះយោបល់សិន ប៉ុន្តែពួកគេអាចចាកចេញពីដំណាក់កាលពិគ្រោះយោបល់ និងបន្តទៅកាន់ដំណាក់កាលពិនិត្យឡើងវិញលើភាពអនុលោមមុនពេលកំណត់។ គោលនយោបាយយន្តការគណនេយ្យភាពបានអនុម័តយកលំដាប់លំដោយបែបនេះ ដើម្បីឆ្លើយតបទៅនឹងបណ្តឹងបន្ទាន់អំពីផលប៉ះពាល់ដោយផ្ទាល់ ដែលពាក់ព័ន្ធ មុនពេលចាប់ផ្តើមឆ្លើយទៅនឹងសំណួរពាក់ព័ន្ធនឹងភាពអនុលោម។ គេជឿជាក់ថា អ្នកដែលរងផលប៉ះពាល់ដោយសារគម្រោង ចាប់អារម្មណ៍ជាមួយការដោះស្រាយពាក្យបណ្តឹងរបស់ពួកគេជាមុនសិន ជាជាងផ្តោតលើការកំណត់ពីភាពមិនអនុលោមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ទៅតាមគោលនយោបាយរបស់ខ្លួន ដែលជាលទ្ធផល អាចមិនធ្វើឱ្យមានដំណោះស្រាយពេញចិត្តចំពោះបញ្ហារបស់អ្នកដាក់ពាក្យបណ្តឹង។ ការផ្តល់នូវជម្រើស ដើម្បីចាកចេញពីការពិគ្រោះយោបល់ គឺដើម្បីធានាយ៉ាងណាឱ្យអ្នកដាក់ពាក្យបណ្តឹងមានសេរីភាពជ្រើសរើសរវាងការពិគ្រោះយោបល់ និងការពិនិត្យឡើងវិញលើភាពអនុលោម។

៦៣. លក្ខខណ្ឌតម្រូវឱ្យមានការចាប់ផ្តើមជាមួយនឹងការពិគ្រោះយោបល់ បង្កើតឱ្យមានបញ្ហាចំនួន ២។ ទីមួយ អ្នកពាក់ព័ន្ធមួយចំនួន ជាពិសេស អង្គការក្រៅរដ្ឋាភិបាល លើកឡើងថា ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេសបានធ្វើឱ្យរាំងស្ទះ មិនឱ្យអ្នកដាក់ពាក្យបណ្តឹងចូលទៅដល់ដំណាក់កាលពិនិត្យឡើងវិញលើភាពអនុលោម។ នេះធ្វើឱ្យមានការយល់ឃើញថា ដោយសារតែមានលក្ខខណ្ឌតម្រូវបែបនេះ ការពិនិត្យឡើងវិញលើភាពអនុលោមអាចផ្តល់នូវដំណោះ-ស្រាយតិចតួចតែប៉ុណ្ណោះ។ ទីពីរ លក្ខខណ្ឌតម្រូវនេះបានធ្វើឱ្យមានភាពយឺតយ៉ាវ សម្រាប់អ្នកដែលចង់ប្រើប្រាស់ការពិនិត្យឡើងវិញលើភាពអនុលោមតែម្តង។ ធនាគារអភិវឌ្ឍន៍អាស៊ីចាំបាច់ត្រូវតែពិចារណាផ្តល់លទ្ធភាពឱ្យអ្នកដាក់ពាក្យបណ្តឹង អាចប្រើប្រាស់ដំណាក់កាលពិនិត្យឡើងវិញលើភាពអនុលោម ដោយផ្ទាល់។

៦៤. យន្តការគណនេយ្យភាពឆ្នាំ ២០០៣ ទទួលស្គាល់ថា ធនាគារអភិវឌ្ឍន៍អាស៊ីមិនស្ថិតនៅក្នុងស្ថានភាពមួយ ដើម្បីធ្វើការដោះស្រាយបញ្ហាផង និងធ្វើការពិនិត្យឡើងវិញលើភាពអនុលោមផង ក្នុងពេលជាមួយគ្នា ចាប់ពីដំបូងទៅនោះទេ។ តាមពិតទៅ ដំណើរការដែលធ្វើឡើងព្រមគ្នាទទួលរងផលប៉ះពាល់ ដោយសារបញ្ហានីតិវិធី និងអនុវត្តជាច្រើន និងអាចមានហានិភ័យ ធ្វើដំណើរការទាំងពីរនេះពុំមានប្រសិទ្ធភាព។ ការស៊ើបអង្កេតទាំង ២ នេះអាចប៉ះពាល់គ្នាទៅវិញទៅមក, ត្រូវការឱ្យមានការគិតផ្សេងៗគ្នា និងត្រូវការពេលវេលា និងធនធានជាច្រើនពីធនាគារអភិវឌ្ឍន៍អាស៊ីផង និងពីអ្នកដែលទទួលរងផលប៉ះពាល់ផង។

៦៥. **ទំនាក់ទំនងរវាងការពិនិត្យឡើងវិញលើភាពអនុលោម, ការដោះស្រាយបញ្ហា និងការចាត់ចែងគម្រោង។** គោលនយោបាយយន្តការគណនេយ្យភាពផ្តល់ភារកិច្ចចំនួន ៣ ដល់គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម: ដើម្បីធ្វើការពិនិត្យឡើងវិញលើភាពអនុលោម, ផ្តល់អនុសាសន៍អំពីសកម្មភាពកែតម្រូវ និងធ្វើការពិនិត្យតាមដានការអនុវត្តអនុសាសន៍ទាំងនេះ។ ភារកិច្ចផ្តល់អនុសាសន៍អំពីសកម្មភាពកែតម្រូវ បន្ទាប់ពីការពិនិត្យឡើងវិញលើភាពអនុលោម គឺផ្ទុយទៅនឹងភារកិច្ចរបស់គណៈកម្មការអធិការកិច្ចរបស់ធនាគារពិភពលោក ដែលជាស្ថាប័នស្វែងរកព័ត៌មាន[៣២]។ គណៈកម្មការអធិការកិច្ចនេះមិនផ្តល់អនុសាសន៍អំពីវិធានការកែតម្រូវ ដល់ក្រុមប្រឹក្សាភិបាលរបស់ធនាគារនោះទេ។ គណៈកម្មាធិការនេះគ្រាន់តែផ្តល់ព័ត៌មានអំពីភាពមិនអនុលោមរបស់ធនាគារពិភពលោក និងផលប៉ះ-ពាល់ ដែលកើតឡើងដោយសារភាពមិនអនុលោមនេះ។ គណៈគ្រប់គ្រងរបស់ធនាគារពិភពលោកផ្តល់ជាអនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលអំពីវិធានការកែតម្រូវ ផ្អែកទៅតាមលទ្ធផលរកឃើញរបស់គណៈកម្មការខាងលើ។

៦៦. ភារកិច្ចរបស់គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម ដើម្បីផ្តល់អនុសាសន៍នេះ បង្កើតបញ្ហាចំនួនពីរ។ ទីមួយ ភារកិច្ចនេះបង្កើតឱ្យមានភាពមិនច្បាស់លាស់នៃព្រំដែនរវាងការពិនិត្យឡើងវិញលើភាពអនុលោម និងការដោះ-ស្រាយបញ្ហា។ ដោយសារតែព្រំដែនមិនច្បាស់លាស់នេះហើយ, មានការយល់ថា គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម គឺជាស្ថាប័នឧទ្ធរណ៍នៅកម្រិតខ្ពស់ទៅវិញ ដែលផ្ទុយពីគោលបំណងរបស់គោលនយោបាយឆ្នាំ ២០០៣។ ទីពីរ ភារកិច្ចនេះក៏ធ្វើឱ្យព្រំដែនរវាងការពិនិត្យឡើងវិញលើភាពអនុលោម និងការចាត់ចែងគម្រោងមានភាពមិនច្បាស់លាស់ផងដែរ។ អនុសាសន៍កន្លងមកផ្តោតតែលើការរៀបចំ និងការអនុវត្តគម្រោងតែប៉ុណ្ណោះ។ ឧទាហរណ៍ នៅក្នុងគម្រោង Chashma, គណៈកម្មការអធិការកិច្ចបានផ្តល់អនុសាសន៍ឱ្យពន្យារពេលកាលបរិច្ឆេទបញ្ចប់គម្រោងរយៈពេលជាច្រើនឆ្នាំទៅមុខទៀត និងឱ្យធនាគារអភិវឌ្ឍន៍អាស៊ីធ្វើការពិភាក្សាជាមួយរដ្ឋាភិបាលរបស់ប្រទេសប៉ាគីស្ថាន ដើម្បីធានាឱ្យ

---

[៣២] ធនាគារពិភពលោក ១៩៩៩ *ការបញ្ជាក់ពីការបិនិត្យឡើងវិញទីពីររបស់ក្រុមប្រឹក្សាភិបាល លើគណៈកម្មការអធិការកិច្ច*, ទីក្រុងវ៉ាស៊ីងតោន

មានការផ្ដល់មូលនិធិរយៈពេលវែង (យ៉ាងហោចណាស់រយៈពេល ៥ ឆ្នាំ) សម្រាប់ការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន។ គណៈកម្មការអធិការកិច្ចក៏ផ្ដល់អនុសាសន៍ឱ្យធនាគារអភិវឌ្ឍន៍អាស៊ីផ្ដល់នូវធនធានមនុស្សឱ្យបានគ្រប់គ្រាន់ "... ដើម្បីធានាឱ្យមានការគាំទ្រក្នុងកម្រិតពេញចិត្ត និងការពិនិត្យតាមដានលើការអនុវត្តផែនការតាំងទីលំនៅជាថ្មី, ផែនការគ្រប់-គ្រងបរិស្ថាន ឬវិធានការដទៃទៀត ដូចដែលតម្រូវនៅក្រោមគោលនយោបាយស្ដីពីការការពារផលប៉ះពាល់សង្គម និងបរិស្ថានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី"។ នៅក្នុងរបាយការណ៍ពិនិត្យតាមដានប្រចាំឆ្នាំរបស់ខ្លួន[៣៣], គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោមបានលើកឡើងថា ខ្លួនពុំមានចំណេះដឹងស្ថាប័ន ដើម្បីធ្វើការវិនិច្ឆ័យអំពីបញ្ហានេះឡើយ ហើយបញ្ហានេះគួរទុកឱ្យអ្នកគ្រប់គ្រងជាអ្នកដោះស្រាយ។ លើសពីនេះ សកម្មភាពកែតម្រូវចាំបាច់ត្រូវទទួលបានការឯកភាពពីអ្នកខ្ចីកម្ចី ដែលទទួលខុសត្រូវជាចម្បងលើការអនុវត្តសកម្មភាព។ ការពិភាក្សា និងចរចាអំពីសកម្មភាពនានាជាមួយអ្នកខ្ចីកម្ចី គឺហួសពីភារកិច្ចនៃការពិនិត្យឡើងវិញលើភាពអនុលោម។ ម្យ៉ាងវិញទៀត អនុសាសន៍ណាក៏ដោយ ដែលពុំមានការឯកភាពពីអ្នកខ្ចីកម្ចី គឺជាអនុសាសន៍ដែលគ្មានន័យ។

## ៤. យន្តការគណនេយ្យភាព គឺជាផ្នែកដ៏សំខាន់មួយនៃយន្តការធានាគុណភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី

៦៧. ការរៀបចំតាក់តែងយន្តការគណនេយ្យភាពទទួលស្គាល់ថា ធនាគារអភិវឌ្ឍន៍អាស៊ីមានប្រព័ន្ធត្រួតពិនិត្យ, សវនកម្ម, វាយតម្លៃ, ចែករំលែកមេរៀនល្អៗ ជាច្រើនរួចហើយ។ យន្តការគណនេយ្យភាពបំពេញបន្ថែមលើប្រព័ន្ធ ដែលមានស្រាប់របស់ធនាគារ ដោយបានបង្កើតនូវយន្តការឆ្លើយតបតាមតម្រូវការរបស់អ្នករងផលប៉ះពាល់ដោយសារគម្រោង ដើម្បីធ្វើការដោះស្រាយបញ្ហា និងដើម្បីឱ្យធនាគារអភិវឌ្ឍន៍អាស៊ីផ្ដោតលើបញ្ហាមិនអនុលោម ដែលបានបង្ក ឬទំនងជាបង្កឱ្យមានផលប៉ះពាល់ដោយផ្ទាល់។

៦៨. យន្តការគណនេយ្យភាពឆ្លុះបញ្ចាំងយ៉ាងពេញលេញនូវទស្សនៈវិជ្ជារបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលថា ការបង្ការបញ្ហា និងការឆាប់អនុលោម គួរត្រូវបានប្រើប្រាស់ឱ្យដល់កម្រិតអតិបរមា។ នៅក្នុងពេលរៀបចំគម្រោង, ធនាគារអភិវឌ្ឍន៍អាស៊ីមានប្រព័ន្ធមួយ សម្រាប់ធ្វើការត្រួតពិនិត្យល្អិតល្អន់លើផ្នែកជាច្រើន ដូចជា ផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ សេដ្ឋកិច្ច ការការពារសង្គម និងបរិស្ថាន និងអភិបាលកិច្ចជាដើម។ លើសពីនេះទៅទៀត កិច្ចប្រជុំពិនិត្យឡើងវិញរបស់គណៈគ្រប់គ្រង និងកិច្ចប្រជុំពិនិត្យឡើងវិញរបស់បុគ្គលិក ធ្វើការពិនិត្យឡើងវិញលើគម្រោង ដែលបានស្នើឡើង ដោយ

---

[៣៣] គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោមនៃយន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី, ២០១០, របាយការណ៍ពិនិត្យតាមដានប្រចាំឆ្នាំ ផ្ញើរទៅកាន់ក្រុមប្រឹក្សាភិបាល ២០០៨-២០០៩ ស្ដីពីការអនុវត្តសកម្មភាពកែតម្រូវសម្រាប់គម្រោងធារាសាស្ត្រតាមដងទន្លេចាស្មា (ដំណាក់កាលទី ៣) ក្នុងប្រទេសប៉ាគីស្ថាន, ម៉ានីល។

ពិនិត្យលើលក្ខណៈសម្បត្តិរបស់គម្រោងផង និងលើភាពអនុលោមរបស់គម្រោង ទៅតាមគោលនយោបាយ និងនីតិវិធីរបស់ធនគារផង។ នាយកដ្ឋានអភិវឌ្ឍន៍តំបន់ប្រកបដោយនិរន្តរភាព (RSDD) ដែលមានមន្ត្រីម្នាក់ជាប្រធានផ្នែកធានាភាពអនុលោម (CCO) ធ្វើការពិនិត្យឡើងវិញលើទិដ្ឋភាពការពារសង្គម និងបរិស្ថាន របស់គ្រប់គម្រោងទាំងអស់ ដែលស្នើឡើង។ គម្រោងមួយអាចបញ្ជូនទៅកាន់ក្រុមប្រឹក្សាភិបាលបាន តែក្រោយពេលដែលមានការឯកភាពពី CCO តែប៉ុណ្ណោះ។ ការិយាល័យគ្រប់គ្រងហានិភ័យទទួលខុសត្រូវលើការគ្រប់គ្រងជារួមលើហានិភ័យផ្នែកឥណទាន, ទីផ្សារ និងប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ក្រុមប្រឹក្សាភិបាលពិនិត្យមើលគម្រោងនីមួយៗ ដែលត្រូវគេបានស្នើឡើងផ្អែកទៅតាមរបាយការណ៍ និងអនុសាសន៍របស់ប្រធានធនាគារ។ នៅក្នុងពេលអនុវត្ត មានការដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធត្រួតពិនិត្យ សវនកម្ម និងវាយតម្លៃជាច្រើន។ ការិយាល័យសេវាប្រតិបត្តិការកណ្តាល (COSO) ផ្តោតការយកចិត្តទុកដាក់សំខាន់លើបញ្ហាលទ្ធកម្ម។ ការិយាល័យអគ្គសវនករធ្វើសវនកម្មជាទៀងទាត់លើសកម្មភាពហិរញ្ញវត្ថុ រដ្ឋបាលសកម្មភាពពាក់ព័ន្ធនឹងគម្រោង និងសកម្មភាពដទៃទៀត និងលើប្រព័ន្ធព័ត៌មាន។ ការិយាល័យប្រឆាំងអំពើពុករលួយ និងសុច្ចរិតភាពឆ្លើយតបចំពោះការចោទប្រកាន់អំពីការបោកបន្លំ និងអំពើពុករលួយ នៅក្នុងសកម្មភាព ដែលទទួលបានហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី។ សាលាក្តីរដ្ឋបាល គឺជាយន្តការខាងក្រៅមួយ ដែលពិនិត្យឡើងវិញលើការសម្រេចចិត្តរបស់គណៈគ្រប់គ្រងលើការងារបុគ្គលិក។ នៅក្នុងកំឡុង និងក្រោយពេលអនុវត្តគម្រោង, នាយកដ្ឋានវាយតម្លៃឯករាជ្យធ្វើការវាយតម្លៃលើលទ្ធផលការងាររបស់គម្រោង ដែលទទួលបានហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី ដែលបានបញ្ចប់ទៅហើយ, ធ្វើការវាយតម្លៃលើផលប៉ះពាល់ និងធ្វើការសិក្សាវាយតម្លៃពិសេស សម្រាប់គម្រោងដែលបានបញ្ចប់ទៅហើយផង និងគម្រោងដែលកំពុងអនុវត្តផង។ មានគណៈកម្មាធិការជាច្រើនរបស់ក្រុមប្រឹក្សាភិបាលដែលធ្វើការងារត្រួតពិនិត្យ ដូចជា គណៈកម្មាធិការសវនកម្ម, ថវិកា, ធនធានមនុស្ស, ពិនិត្យឡើងវិញលើភាពអនុលោម, ប្រសិទ្ធភាពនៃការអភិវឌ្ឍ និងក្រមសីលធម៌។ យន្តការទាំងនេះត្រូវបានរៀបចំឡើង ដើម្បីធានាថាប្រតិបត្តិ-ការនានារបស់ធនាគារ ត្រូវបានធ្វើឡើង ដោយអនុលោមទៅតាមគោលនយោបាយ និងគោលការណ៍ណែនាំអំពីប្រតិបត្តិការការងារ ដែលបានទទួលការអនុម័ត និងធានាយ៉ាងណាឱ្យមានការបញ្ជ្រាបគណនេយ្យភាព នៅក្នុងគ្រប់សកម្មភាពទាំងអស់របស់ធនាគារ។ នៅក្នុងករណីដែលពុំមានប្រព័ន្ធ ទស្សនៈវិជ្ជារបស់ធនាគារគឺ ត្រូវធ្វើការឆ្លើយតបជាបន្ទាន់ និងធ្វើការកាត់បន្ថយបញ្ហាប្រកបដោយប្រសិទ្ធភាព នៅពេលដែលបញ្ហាទាំងនោះកើតមានឡើង។

៦៩. យន្តការគណនេយ្យភាពនេះបំពេញតួនាទីពិសេសដ៏សំខាន់មួយ ដោយធ្វើការឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកដែលរងផលប៉ះពាល់ដោយសារគម្រោង និងធ្វើការដោះស្រាយបញ្ហាពិតប្រាកដ ដែលបានកើតមានឡើង នៅក្នុងកំឡុងពេលអនុវត្ត។ ដោយសារមូលហេតុនេះហើយ លក្ខណៈសំខាន់គួរឱ្យកត់សម្គាល់ជាងគេរបស់យន្តការគណនេយ្យ-

ភាពទាំងនេះគឺ យន្តការទាំងនេះធ្វើអន្តរាគមន៍ តែនៅពេលដែលអ្នកទទួលរងផលប៉ះពាល់ដោយសារគម្រោងដាក់ការស្នើសុំមួយប៉ុណ្ណោះ។ លក្ខណៈនេះគឺខុសពីមុខងារសវនកម្ម ដែលមានការផ្តួចផ្តើមធ្វើឡើង ដើម្បីធ្វើការត្រួតពិនិត្យចោះៗ។ ដោយសារមូលហេតុនេះហើយ គ្រប់យន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍ពហុភាគីត្រូវបង្កើតឱ្យមានទំនាក់ទំនងរវាងការខូចខាតក្នុងកម្រិតគួរឱ្យកត់សម្គាល់ ជាមួយនឹងភាពមិនអនុលោមរបស់ធនាគារអភិវឌ្ឍន៍ពហុភាគីជាមួយគោលនយោបាយ និងនីតិវិធីរបស់ខ្លួន។[៣៤]

៧០. ដើម្បីធានាឱ្យមានការចែករំលែកមេរៀន បើទោះបីជាពុំមានការចោទប្រកាន់ពីការបង្កផលប៉ះពាល់ក៏ដោយ, នាយកដ្ឋាននានា ដូចជា នាយកដ្ឋានវាយតម្លៃឯករាជ្យ និងនាយកដ្ឋានអភិវឌ្ឍន៍តំបន់ប្រកបដោយនិរន្តរភាព ក៏ធ្វើការពិនិត្យឡើងវិញលើភាពអនុលោមជាមួយគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីផងដែរ នៅក្នុងកំឡុង និងក្រោយពេលអនុវត្តគម្រោង បើទោះបីជាពុំមានការចោទប្រកាន់អ្វីក៏ដោយ។ ការពិនិត្យឡើងវិញទាំងនេះធ្វើការពិនិត្យលើភាពអនុលោម និងធ្វើការវិភាគពីមូលហេតុ ដែលធ្វើឱ្យបញ្ហាមិនអនុលោមកើតមានឡើង ដូចជា ថាតើគោល-នយោបាយទាំងនេះមានលក្ខណៈល្អប្រសើរពីដំបូងដែរឬទេ។ ខណៈពេលដែលការពិនិត្យឡើងវិញរបស់គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោមត្រូវបានគេធ្វើឡើង ទៅតាមតម្រូវការ, ការពិនិត្យឡើងវិញរបស់នាយកដ្ឋានវាយ-តម្លៃឯករាជ្យ និងនាយកដ្ឋានអភិវឌ្ឍន៍តំបន់ប្រកបដោយនិរន្តរភាព គឺជាគំនិតផ្តួចផ្តើមរបស់ធនាគារអភិវឌ្ឍន៍អាស៊ីដោយខ្លួនឯង និងធ្វើទៅតាមតម្រូវការរបស់អ្នកពាក់ព័ន្ធ។ ឧទាហរណ៍ នាយកដ្ឋានវាយតម្លៃឯករាជ្យអនុវត្តសកម្មភាពវាយតម្លៃ ដើម្បីជួយឱ្យក្រុមប្រឹក្សាភិបាល, គណៈគ្រប់គ្រងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងអ្នកធ្វើសេចក្តីសម្រេចចិត្តនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិក ដឹងថាតើធនធាននានាត្រូវបានគេយកទៅចំណាយសមស្របដែរឬទេ និងថាតើលទ្ធផលនានាត្រូវបានសម្រេច ទៅតាមការគ្រោងទុកដែរឬទេ។ ការវាយតម្លៃរបស់នាយកដ្ឋានវាយតម្លៃឯករាជ្យគ្របដណ្តប់លើគ្រប់ទិដ្ឋភាពទាំងអស់នៃប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដូចជា គោលនយោបាយ, យុទ្ធសាស្ត្រ, ការអនុវត្ត និងនីតិវិធីនានា ជាដើម។ ការវាយតម្លៃទាំងនេះផ្តោតសំខាន់លើការផ្តល់ព័ត៌មានត្រលប់ប្រកបដោយប្រសិទ្ធភាពលើការអនុវត្តការងារ និងការប្រើប្រាស់មេរៀន ដែលទទួលបាន ដើម្បីបង្កើនប្រសិទ្ធភាពនៃការអភិវឌ្ឍរបស់ប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងដើម្បីលើកកម្ពស់ការចូលរួមចំណែកនៃប្រតិបត្តិការទាំងនេះ ចំពោះការ

---

[៣៤] ការពិនិត្យឡើងវិញទី ២ របស់គណៈកម្មការអធិការកិច្ចរបស់ធនាគារពិភពលោក នៅក្នុងឆ្នាំ ១៩៩៩ បានបញ្ជាក់សារជាថ្មី ពីសារៈសំខាន់នៃលក្ខខណ្ឌនេះ។ ដំណោះស្រាយរបស់ធនាគារពិភពលោកបានកាត់បន្ថយតួនាទីរបស់គណៈកម្មការ នៅក្នុងការពិនិត្យលើភាពអនុលោមជាមួយនឹងគោលនយោបាយប្រតិបត្តិការការងារ ហើយក្នុងពេលជាមួយគ្នាផ្តោតការយកចិត្តទុកដាក់លើតួនាទីរបស់ខ្លួន នៅក្នុងការភ្ជាប់ទំនាក់ទំនងផលប៉ះពាល់ជាក់ស្តែង ឬដែលអាចកើតមានឡើង ជាមួយប្រជាពលរដ្ឋមូលដ្ឋាន និងដោយសារតែភាពមិនអនុលោម។

អភិវឌ្ឍរបស់ប្រទេសកំពុងអភិវឌ្ឍជាសមាជិក។ ការអនុវត្តសកម្មភាពត្រួតគ្នានឹងសកម្មភាពរបស់យន្តការដែលមានស្រាប់ទាំងនេះ គឺជាអ្វីដែលមិនចាំបាច់ និងជាអ្វីដែលគេមិនចង់បាន។ ការបញ្ជាក់ឱ្យបានច្បាស់អំពីទំនាក់ទំនងទាំងនេះជួយឱ្យយន្តការគណនេយ្យភាពបន្តបំពេញតួនាទីជាយន្តការមួយ ដែលផ្តោតសំខាន់លើអ្នកដែលរងផលប៉ះពាល់ដោយសារគម្រោង និងលើប្រសិទ្ធភាពនៃការអភិវឌ្ឍរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

## ៥. ការចុះដល់ទីតាំងជាក់ស្តែង

៧១. ការចុះដល់ទីតាំងជាក់ស្តែង ដែលធ្វើឡើងដោយគណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម (CRP) មិនអាចធ្វើបានឡើង ប្រសិនបើប្រទេសខ្ចីកម្ចីបដិសេធចំពោះការស្នើសុំរបស់ CRP ដើម្បីចុះដល់ទីតាំងជាក់ស្តែងនេះ។ ដើម្បីធានាឱ្យមានការចុះដល់ទីតាំងជាក់ស្តែង, អ្នកពាក់ព័ន្ធមួយចំនួនចង់បានយ៉ាងខ្លាំងឱ្យការចុះដល់ទីតាំងជាក់ស្តែងនេះត្រូវបានកំណត់នៅក្នុងខចែងមួយ នៅក្នុងកិច្ចព្រមព្រៀងកម្ចី ថាចាំបាច់ត្រូវតែធ្វើ។ ពួកគេលើកឡើងថា ការបដិសេធរបស់ប្រទេសខ្ចីកម្ចីមិនឱ្យCRP ចុះដល់ទីតាំងជាក់ស្តែង នឹងធ្វើប៉ះពាល់ដល់ភាពជឿជាក់ និងប្រសិទ្ធភាពរបស់យន្តការគណនេយ្យភាពនេះ។ អ្នកពាក់ព័ន្ធដទៃទៀតលើកឡើងថា ពុំមានមូលដ្ឋាន ដើម្បីឱ្យធនាគារអភិវឌ្ឍន៍អាស៊ីទទូចឱ្យមានភាពចាំបាច់ត្រូវតែចុះដល់ទីតាំងជាក់ស្តែងនោះទេ ដោយសារតែដំណើរការពិនិត្យឡើងវិញលើភាពអនុលោមនេះ គឺពាក់ព័ន្ធជាមួយនឹងការអនុលោមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ទៅតាមគោលនយោបាយ និងនីតិវិធីរបស់ខ្លួនតែប៉ុណ្ណោះពោលគឺមិនមែនអំពីការប្រព្រឹត្តិខុសទៅនឹងកាតព្វកិច្ចរបស់ប្រទេសខ្ចីកម្ចីឡើយ ហើយប្រទេសខ្ចីកម្ចីមានសិទ្ធិគ្រប់បែបយ៉ាង ដើម្បីបដិសេធមិនឱ្យមានការចុះដល់ទីតាំងជាក់ស្តែង។ ពួកគេបានលើកឡើងថា លក្ខខណ្ឌតម្រូវបែបនេះគឺជាការរំលោភយ៉ាងធ្ងន់ធ្ងរមួយលើបូរណភាពរបស់ប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិក ហើយមានការលំបាកផ្នែកច្បាប់ និងការអនុវត្តជាក់ស្តែងជាច្រើន ដើម្បីពង្រឹងការអនុវត្តលក្ខខណ្ឌតម្រូវសម្រាប់ការចុះដល់ទីតាំងជាក់ស្តែងបែបនេះ។

៧២. បញ្ហានៃការចុះដល់ទីតាំងជាក់ស្តែងនេះ បានធ្វើឱ្យមានភាពចម្រូងចម្រាស់, ធ្វើឱ្យមានគំនិតយល់ឃើញផ្សេងៗពីគ្នា ទាំងក្នុង និងក្រៅធនាគារអភិវឌ្ឍន៍អាស៊ី និងបង្កើតឱ្យមានហានិភ័យចំពោះកិត្តិនាមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី, គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម និងប្រទេសកំពុងអភិវឌ្ឍជាសមាជិក។ ដោយប្រើប្រាស់បទពិសោធន៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី និងរបស់ធនាគារអភិវឌ្ឍន៍ពហុភាគីដទៃទៀត, ធនាគារអភិវឌ្ឍន៍អាស៊ីចាំបាច់ត្រូវបង្កើតនូវគោលវិធីសមស្របមួយ ដើម្បីដោះស្រាយបញ្ហាជុំវិញការចុះដល់ទីតាំងជាក់ស្តែងនេះប្រកបដោយប្រសិទ្ធភាព។

## ៦. មេរៀនដែលទទួលបាន

៧៣. កត្តាលើកទឹកចិត្តសំខាន់ៗជាងគេ ដែលធ្វើឱ្យមានការបង្កើតយន្តការគណនេយ្យភាពនៅតាមធនាគារអភិវឌ្ឍន៍ពហុភាគីគឺថា ព័ត៌មានត្រលប់ ដែលទទួលបានពីពាក្យបណ្តឹងផ្សេងៗ នឹងក្លាយទៅជាធនធានដ៏សម្បូរបែបមួយ សម្រាប់ផ្តល់មេរៀនដល់បុគ្គលិក, គណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាល។ តាមពិតទៅ យន្តការគណនេយ្យភាពបានចូលរួមចំណែកធ្វើឱ្យមានការចែករំលែកមេរៀនពីសំណាក់ធនាគារអភិវឌ្ឍន៍អាស៊ី និងប្រទេសកំពុងអភិវឌ្ឍជាសមាជិក។ លទ្ធផលរកឃើញរបស់ OSPF និង OCRP ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ តាមរយៈគេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

៧៤. ចំណុចខ្លាំងពិសេសមួយរបស់គោលនយោបាយឆ្នាំ ២០០៣ គឺការផ្តោរការយកចិត្តទុកដាក់របស់គោលនយោបាយលើតួនាទីរបស់ OSPF នៅក្នុងការលើកកម្ពស់ និងពង្រឹងមុខងារដោះស្រាយបញ្ហាផ្ទៃក្នុងរបស់នាយកដ្ឋានប្រតិបត្តិការ។ OSPF ជួយកំណត់ការអនុវត្តល្អៗ សម្រាប់បង្កើត និងដំណើរការយន្តការដោះស្រាយការកើតទុក្ខមិនសុខចិត្ត នៅក្នុងគម្រោងដែលមានលក្ខណៈស្មុគស្មាញ និងមានភាពរសើប។ ឧទាហរណ៍ ផ្អែកទៅតាមមេរៀន ដែលទទួលបានពីគម្រោងអភិវឌ្ឍន៍ផ្លូវគមនាគមន៍ភាគខាងត្បូង (STDP), OSPF បានបង្កើតនូវមគ្គុទេសក៍មួយសម្រាប់រៀបចំ និងអនុវត្តយន្តការដោះស្រាយការកើតទុក្ខមិនសុខចិត្ត សម្រាប់គម្រោងផ្លូវថ្នល់។ ការស្រាវជ្រាវ ដែលបានធ្វើឡើងដោយមជ្ឈមណ្ឌលវិភាគភាពក្រីក្រ បានរកឃើញថា STDP បានសម្រេចនូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ នៅក្នុងការឆ្លើយតបចំពោះការកើតទុក្ខមិនសុខចិត្ត។ លទ្ធភាពប្រើប្រាស់យន្តការនេះរបស់អ្នកដែលទទួលរងផលប៉ះពាល់ ត្រូវបានបង្កើនតាមរយៈការបង្កើនចំនួនគណៈកម្មាធិការដោះស្រាយការកើតទុក្ខមិនសុខចិត្ត និងបែងចែកគណៈកម្មាធិការទាំងនេះ នៅកម្រិតផ្ទៃក ជាជាងនៅកម្រិតស្រុក។ ការយល់ឃើញរបស់អ្នករងផលប៉ះពាល់ចំពោះយន្តការដោះស្រាយការកើតទុក្ខមិនសុខចិត្តមានលក្ខណៈវិជ្ជមាន ដោយសារតែពួកគេទទួលបានការគោរព និងទទួលបានសំណាងច្រើនជាងមុន។ OSPF ក៏បានបង្កើតនូវគោលការណ៍ណែនាំ សម្រាប់បង្កើត និងអនុវត្តយន្តការដោះស្រាយការកើតទុក្ខមិនសុខចិត្ត នៅតាមប្រទេសកំពុងអភិវឌ្ឍជាសមាជិកផងដែរ។ ផលិតផលចំណេះដឹងរបស់ OSPF ទាំងនេះ គឺជាធនធានដ៏មានសារៈប្រយោជន៍សម្រាប់ការរៀនសូត្រ និងធ្វើការកែលំអប្រតិបត្តិការងាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ដើម្បីសម្របសម្រួលដល់ការរៀនសូត្រ, OCRP បានបង្កើតនូវវេទិការមួយនៅលើប្រព័ន្ធអ៊ីនធឺណិត ដើម្បីឱ្យអ្នកដែលធ្វើការងារពាក់ព័ន្ធនឹងយន្តការគណនេយ្យភាពផ្សេងៗគ្នា ធ្វើការផ្លាស់ប្តូរគំនិតយោបល់ជាមួយគ្នា[៣៥]។ ការិយាល័យនេះក៏បានបង្កើតនូវប្រព័ន្ធមួយ ដើម្បីធ្វើការតាមដានការអនុវត្តសកម្មភាពកែតម្រូវផងដែរ។ នៅក្នុងប្រទេសស្រីលង្ការ, ការអនុវត្តគោលនយោ-

[៣៥] ធនាគារអភិវឌ្ឍន៍អាស៊ី ២០០៩, *ការសាកល្បងបង្កើតក្រុមអ្នកជំនាញផ្នែកយន្តការគណនេយ្យភាពឯករាជ្យ* (ការស្រាវជ្រាវ និងការអភិវឌ្ឍ), ម៉ានីល (ឯកភាពក្នុងទឹកប្រាក់ ១៥០,០០០ ដុល្លារ)។ បណ្តាញនេះអាចរកបានលើ http://iamnet .adb.org ។

បាយការពារសង្គម និងបរិស្ថាន របស់ធនាគារអភិវឌ្ឍន៍អាស៊ី នៅក្នុងគម្រោង STDP បាននាំឱ្យមានការបង្កើតប្រព័ន្ធការពារសង្គម និងបរិស្ថាន និងប្រព័ន្ធដោះស្រាយការកើតទុក្ខមិនសុខចិត្តរបស់រដ្ឋាភិបាល ហើយយន្តការគណនេយ្យភាពបានធ្វើឱ្យការប្រើប្រាស់ប្រព័ន្ធទាំងនេះកាន់តែមានលក្ខណៈប្រសើរឡើង។ ជាផ្នែកមួយនៃការបង្កើនកិច្ចខិតខំប្រឹងប្រែងចែករំលែកមេរៀន និងផ្សព្វផ្សាយព័ត៌មាន, OSPF និង OCRP បានចាប់ផ្តើមផ្តល់ការបណ្តុះបណ្តាលជាប្រចាំដល់បុគ្គលិករបស់ខ្លួន និងបង្កើនការផ្សព្វផ្សាយព័ត៌មាន នៅតាមប្រទេសកំពុងអភិវឌ្ឍជាសមាជិក។

៧៥. នៅពេលដែលធនាគារអភិវឌ្ឍន៍អាស៊ីរីកចម្រើនក្លាយជាស្ថាប័នអភិវឌ្ឍន៍ និងនៅពេលដែលស្ថាប័ននានា ដែលប្រើយន្តការនេះ ប្រមូលបានបទពិសោធន៍កាន់តែច្រើនឡើង, យន្តការគណនេយ្យភាពនេះ ត្រូវបានបុគ្គលិក, គណៈគ្រប់-គ្រង និងក្រុមប្រឹក្សាភិបាលយល់ឃើញថាជាឧបករណ៍មួយ សម្រាប់ឱ្យធនាគារអភិវឌ្ឍន៍អាស៊ីធ្វើការឆ្លើយតបយ៉ាងវិជ្ជមានចំពោះការពិនិត្យពិច័យរបស់សាធារណជន និងរៀនសូត្រពីរបៀប ដែលអាចបំពេញការងារឱ្យបានកាន់តែប្រសើរជាងមុន។ ប៉ុន្តែ អារម្មណ៍ដែលគិតថា ការពិនិត្យឡើងវិញលើភាពអនុលោម គឺជាការព្យាយាមរកអ្វីដែលផ្ទុយនឹងអ្វី ដែលកំពុងធ្វើឡើង នៅតែមាន។ ចាំបាច់ត្រូវមានទំនាក់ទំនង និងការចែករំលែកព័ត៌មានបន្ថែមទៀតរវាង, OSPF, CRP, បុគ្គលិក និងគណៈគ្រប់គ្រង ដើម្បីឱ្យមានការពិគ្រោះយោបល់ និងការរៀនសូត្រពីគ្នាទៅវិញទៅមកក្នុងលក្ខណៈស្ថាបនា។ ទំនាក់ទំនងរវាងគ្នានឹងគ្នា ដែលកាន់តែមានលក្ខណៈវិជ្ជមាន នឹងចូលរួមចំណែកធ្វើឱ្យមានការផ្លាស់ប្តូរវប្បធម៌ពីការចាត់ទុកការពិនិត្យឡើងវិញលើភាពអនុលោមថាជាដំណើរការអវិជ្ជមាន ទៅជាដំណើរការមួយ ដែលជាឧបករណ៍វិជ្ជមានសម្រាប់ធ្វើការរៀនសូត្រ និងអភិវឌ្ឍន៍។

## ៧. លទ្ធផលនៃការពិគ្រោះយោបល់ និងការពិនិត្យឡើងវិញលើភាពអនុលោម

៧៦. **ដំណាក់កាលពិគ្រោះយោបល់** - ក្នុងចំណោមបណ្តឹង ដែលមានលក្ខណៈសមស្របចំនួន ១១ ដែល OSPF ទទួលបាន, បណ្តឹងចំនួន ៥ ត្រូវបានដោះស្រាយពេញលេញ ឬដោយផ្នែក, ៤ កំពុងបន្តដោះស្រាយ, ១ មិនត្រូវបានដោះស្រាយ និង ១ ត្រូវបានដកចេញវិញ។ ទាំងបណ្តឹងដែលមិនទាន់ដោះស្រាយ ទាំងបណ្តឹងដែលត្រូវបានដកចេញសុទ្ធតែបានផ្ញើរទៅកាន់គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម [៣៦]។ សម្រាប់ពាក្យបណ្តឹងដែលមិនមានលក្ខណៈសមស្រប, OSPF ជូនដំណឹងដល់អ្នកដាក់ពាក្យបណ្តឹងពីរបៀបបន្តស្វែងរកដំណោះស្រាយចំពោះការកើតទុក្ខមិនសុខ

[៣៦] ករណីដែលត្រូវបានដកចេញ គឺគម្រោងផ្គត់ផ្គង់ទឹក Melamchi។ ករណីនេះត្រូវបានផ្ញើទៅកាន់ CRP ដែលរកឃើញថាករណីនេះ មិនមានលក្ខណៈសមស្រប។ ករណីដែលមិនបានដោះស្រាយ គឺពាក់ព័ន្ធជាមួយនឹងគម្រោងកែលំអបរិស្ថាន Fuzhou ដែលត្រូវបានដាក់ទៅកាន់ CRP ផងដែរ។

ចិត្តរបស់ពួកគេ តាមរយៈនាយកដ្ឋានប្រតិបត្តិការ។ ការប្រាស្រ័យទាក់ទងជាមួយនាយកដ្ឋានប្រតិបត្តិការ បង្ហាញថា មានបញ្ហាជាច្រើន ត្រូវបានដោះស្រាយ បន្ទាប់ពីមានទំនាក់ទំនងសមស្របរួចមក។ នេះឆ្លុះបញ្ចាំងពីទិដ្ឋភាពមួយនៃ ប្រតិបត្តិការការងាររបស់ OSPF ដែលហាក់បីដូចជាមិនស្តែងចេញឱ្យឃើញច្បាស់លាស់ ប៉ុន្តែមានសារៈសំខាន់។ OSPF បានបំពេញនូវតួនាទីក្រៅផ្លូវការ នៅក្នុងការភ្ជាប់ទំនាក់ទំនងអ្នកដែលរងផលប៉ះពាល់ ជាមួយនឹងបុគ្គលិកពាក់ព័ន្ធរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ការកើនឡើងនូវចំនួនពាក្យបណ្តឹង ចាប់តាំងពីឆ្នាំ ២០០៩ មក បង្ហាញពីកំណើនការយល់ដឹងថា យន្តការនេះពិតជាផ្តល់នូវដំណោះស្រាយប្រាកដមែន នៅក្នុងករណីមានបញ្ហា។ នៅក្នុងគ្រប់ករណីទាំងអស់, OSPF ជូនដំណឹងដល់អ្នករងផលប៉ះពាល់ថា ពួកគេអាចត្រលប់មកកាន់ OSPF វិញ ប្រសិនបើពួកគេនៅតែមិនពេញចិត្ត បន្ទាប់ពីបានដោះស្រាយបញ្ហាជាមួយនាយកដ្ឋានប្រតិបត្តិការហើយ។ នៅពេលដែលពាក្យបណ្តឹងមួយត្រូវបានរកឃើញថាពុំមានលក្ខណៈសមស្រប, OSPF ក៏ជូនដំណឹងដល់អ្នកដាក់ពាក្យបណ្តឹងផងដែរថា ពួកគេអាចមានជម្រើសដាក់ការស្នើសុំទៅកាន់គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម។ ដូច្នេះ ដំណាក់កាលពិគ្រោះយោបល់នេះគឺជាច្រកដ៏មានប្រយោជន៍មួយ ដើម្បីធ្វើការដោះស្រាយបញ្ហារបស់អ្នកដែលរងផលប៉ះពាល់ និងភ្ជាប់ទំនាក់ទំនងពួកគេជាមួយនាយកដ្ឋានប្រតិបត្តិការ ក៏ដូចជាជាមួយគណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម។ សេចក្តីសង្ខេបអំពីដំណើរការពិគ្រោះយោបល់ និងលទ្ធផលពាក់ព័ន្ធនឹងពាក្យបណ្តឹង ដែលមានលក្ខណៈសមស្រប មានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី ៤។

៧៧. **ដំណាក់កាលពិនិត្យឡើងវិញលើភាពអនុលោម** – ចាប់តាំងពីឆ្នាំ ២០០៤ មក, គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម (CRP) បានពិនិត្យឡើងវិញលើភាពអនុលោមរបស់គម្រោង STDP និងបានធ្វើការពិនិត្យតាមដានការអនុវត្តអនុសាសន៍របស់គណៈកម្មការអធិការកិច្ច សម្រាប់គម្រោងធារាសាស្ត្រត្រើយខាងស្តាំ Chashma (ដំណាក់កាលទី ៣)។ ការអនុវត្តតាមអនុសាសន៍សម្រាប់គម្រោងទាំងពីរនេះ គឺធ្វើឡើងក្នុងកម្រិតពេញចិត្ត។ សម្រាប់គម្រោងធារាសាស្ត្រត្រើយខាងស្តាំ Chashma (ដំណាក់កាល ទី ៣), CRP បានរកឃើញថា គិតមកដល់ឆ្នាំ ២០០៩, ធនាគារអភិវឌ្ឍន៍អាស៊ីបានបំពេញតាមអនុសាសន៍ ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល ចំនួន ២៤ ក្នុងចំណោមអនុសាសន៍ទាំង ២៩, មានវឌ្ឍនភាពគ្រប់គ្រាន់ នៅក្នុងការអនុលោមតាមដោយអន្លឹជាមួយអនុសាសន៍ចំនួន ៤ ហើយអនុសាសន៍ ១ ទៀត មិនអាចឱ្យធនាគារអភិវឌ្ឍន៍អាស៊ីអនុលោមតាមបាន ដោយសារព្រឹត្តិការណ៍ ដែលបានកើតឡើង។ CRP បានធ្វើការពិនិត្យឡើងវិញលើភាពអនុលោមក្នុងគម្រោង STDP នៅក្នុងឆ្នាំ ២០០៥ និងបានពិនិត្យតាមដានលើការអនុវត្ត

ចាប់តាំងពីពេលនោះមក។ CRP ទាញជាសេចក្តីសន្និដ្ឋាន នៅក្នុងរបាយការណ៍ពិនិត្យតាមដានប្រចាំឆ្នាំទី ៤[៣៧] របស់ខ្លួនថា ក្នុងចំណោមអនុសាសន៍ទាំង ១៩, មានអនុសាសន៍ចំនួន ១៧ ទទួលបានភាពអនុលោមពេញលេញ ហើយអនុសាសន៍ចំនួន ២ មានភាពអនុលោមដោយអន្លឹ។ ការពិគ្រោះយោបល់ នៅក្នុងប្រទេសស្រីលង្ការ បង្ហាញថា ការងាររបស់ CRP បានជួយដោះស្រាយបញ្ហា ដែលប្រជាពលរដ្ឋជួបប្រទះ និងមានសារៈសំខាន់ នៅក្នុងការសម្របសម្រួលការកែលំអប្រព័ន្ធរបស់រដ្ឋាភិបាល។ ខណៈពេលដែលកាលពីពេលដំបូង CRP ត្រូវបានគេយល់ឃើញថាយន្តការសម្រាប់ចាប់កំហុស, ក្រោយមក ការបំពេញការងាររបស់គណៈកម្មការនេះបានទទួលការសរសើរ នៅពេលដែលគេយល់ឃើញថា CRP គឺជាយន្តការ ដែលមានតុល្យភាព។ ឧបសម្ព័ន្ធទី ៥ បង្ហាញព័ត៌មានសង្ខេបអំពីដំណើរការ និងលទ្ធផលនៃការស្នើសុំដែល CRP ធ្វើការដោះស្រាយ។

## ខ. សេចក្តីសង្ខេប

៧៨. យន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី មានភាពលេចធ្លោ ក្នុងនាមជាយន្តការការនាំមុខគេមួយដែលដាក់បញ្ចូលការដោះស្រាយបញ្ហា នៅក្នុងយន្តការគណនេយ្យភាព សម្រាប់ប្រតិបត្តិការ នៅក្នុងវិស័យសាធារណៈផង និងវិស័យឯកជនផង។ យន្តការគណនេយ្យភាពមានតម្លាភាព, ការចូលរួម, ភាពជឿជាក់ និងប្រសិទ្ធភាពក្នុងកម្រិតខ្ពស់។ យន្តការគណនេយ្យភាពមានចំណុចខ្លាំងផ្សេងៗជាច្រើន ដូចជា:

(i) គោលវិធីជាវិជ្ជមាននៃការផ្តោតលើការដោះស្រាយបញ្ហា ធ្វើឱ្យយន្តការគណនេយ្យភាពនេះមានភាពសម្បូរបែប និងជាពិសេស ផ្តល់ប្រយោជន៍ដល់អ្នកដែលរងផលប៉ះពាល់ដោយសារគម្រោង។

(ii) ការរាយការណ៍របស់ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស ទៅកាន់ប្រធានធនាគារ និងរបស់គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម ទៅកាន់ក្រុមប្រឹក្សាភិបាល មានភាពស័ក្តិសមទៅនឹងអណត្តិការងារ និងភាពចាំបាច់របស់យន្តការទាំងពីរនេះ និងអាចធានាបាននូវតុល្យភាពរវាងឯករាជ្យភាព និងប្រសិទ្ធភាព។

---

[៣៧] ធនាគារអភិវឌ្ឍន៍អាស៊ី, គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោមរបស់យន្តការគណនេយ្យភាព, ២០១០, *របាយការណ៍ពិនិត្យតាមដានប្រចាំឆ្នាំ ផ្ញើទៅកាន់ក្រុមប្រឹក្សាភិបាលចាប់ពីថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០០៩ ដល់ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១០ ស្តីពីការអនុវត្តសកម្មភាពកែតម្រូវសម្រាប់គម្រោងអភិវឌ្ឍន៍តមនាគមន៍ភាគខាងត្បូង នៅក្នុងប្រទេសស្រីលង្ការ,* ម៉ានីល។

(iii) យន្តការគណនេយ្យភាពបានជួយសម្រួលការរៀនសូត្រ នៅក្នុងធនាគារអភិវឌ្ឍន៍អាស៊ី និងប្រទេសកំពុងអភិវឌ្ឍជាសមាជិក ។

(iv) អណត្តិពិនិត្យតាមដានរបស់ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស និងគណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម បង្កើនភាពជឿជាក់របស់យន្តការគណនេយ្យភាព ។

(v) ការបង្ហាញព័ត៌មានជាសាធារណៈ ដែលមានលក្ខណៈជាប្រព័ន្ធ បានចូលរួមចំណែកបង្កើនតម្លាភាពក្នុងកម្រិតខ្ពស់ ដោយបានធ្វើការពិចារណាយ៉ាងសមស្របលើភាពលាក់ការសម្ងាត់

(vi) យន្តការគណនេយ្យភាពទទួលបានការចូលរួម ។ មុខងារដោះស្រាយបញ្ហាផ្តល់លទ្ធភាពឱ្យអ្នកដែលរងផលប៉ះពាល់ដោយសារគម្រោង ចូលរួមយ៉ាងសកម្ម នៅក្នុងការសម្រេចចិត្ត ជាជាងគ្រាន់តែជាអ្នកចាំទទួលបានលទ្ធផលពីអធិការកិច្ច ។

(vii) ទាំងដំណាក់កាលពិគ្រោះយោបល់ ទាំងដំណាក់កាលពិនិត្យឡើងវិញលើភាពអនុលោម សុទ្ធតែមានភាពពាក់ព័ន្ធ និងសម្រេចបាននូវលទ្ធផលប្រកបដោយប្រសិទ្ធភាព ។

៧៩. ធនាគារអភិវឌ្ឍន៍អាស៊ីអាចបន្តពង្រឹងយន្តការគណនេយ្យភាព នៅក្នុងផ្នែកខាងក្រោមៈ

(i) អ្នករងផលប៉ះពាល់ពុំអាចប្រើប្រាស់ដំណាក់កាលពិនិត្យឡើងវិញលើភាពអនុលោមបានដោយផ្ទាល់ ។

(ii) ចាំបាច់ត្រូវមានច្រកចូលតែមួយ សម្រាប់ឱ្យអ្នករងផលប៉ះពាល់ដោយសារគម្រោងដាក់ពាក្យបណ្តឹង ។

(iii) ប្រើប្រាស់របាយការណ៍បញ្ចប់គម្រោង ជាកាលបរិច្ឆេទឱសានវាទសម្រាប់ការដាក់ពាក្យបណ្តឹង ខ្វះភាពប្រាកដប្រជា និងភាពច្បាស់លាស់ ។

(iv) ការចុះដល់ទីតាំងជាក់ស្តែងរបស់គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម អាចជាបញ្ហាចម្រូងចម្រាស់ ។

(v) ឯករាជ្យភាពរបស់គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម អាចធ្វើការកែលំអបន្ថែមទៀត ។

(vi) ព្រំដែនរវាងការពិនិត្យឡើងវិញលើភាពអនុលោម និងការដោះស្រាយបញ្ហា និងរវាងការពិនិត្យឡើងវិញលើភាពអនុលោម និងការគ្រប់គ្រងគម្រោង នៅពុំទាន់មានភាពច្បាស់លាស់ឱ្យបានគ្រប់គ្រាន់នៅឡើយ ។

(vii) គុណតម្លៃរបស់យន្តការគណនេយ្យភាព ក្នុងនាមជាមុខងារសម្រាប់ធ្វើការរៀនសូត្រ គួរពង្រឹងបន្ថែមទៀត ។

(viii) ដំណើរការនៃយន្តការគណនេយ្យភាពអាចធ្វើឱ្យកាន់តែមានភាពសាមញ្ញ ។

(ix) យន្តការគណនេយ្យភាព គឺជាយន្តការមួយ ក្នុងចំណោមយន្តការ ដែលចំណាយអស់ច្រើនជាងគេ សម្រាប់ករណីនីមួយៗ បើប្រៀបធៀបជាមួយនឹងស្ថាប័នស្រដៀងៗគ្នានេះ ។

(x) ការយល់ដឹងអំពីយន្តការគណនេយ្យភាពនេះ គឺនៅមានកម្រិតនៅឡើយ ។

៨០. ឧបសម្ព័ន្ធទី ៦ សង្ខេបចំណុចខ្លាំង និងចំណុចខ្សោយរបស់យន្តការគណនេយ្យភាព និងផ្នែកដែលអាចធ្វើការកែលំអបន្ថែមទៀត ដោយអនុវត្តតាមក្របខ័ណ្ឌ ACEE ។

## V. ជម្រើស និងបំលាស់ប្តូរសំខាន់ៗ ដែលបានស្នើឡើង

៨១. ផ្នែកនេះរៀបរាប់ពីជម្រើស និងអនុសាសន៍សំខាន់ៗ ដែលក្រុមការងារកំពុងយកមកធ្វើការពិចារណា ។

### ក. ការផ្តល់លទ្ធភាពឱ្យមានការប្រើប្រាស់ដំណាក់កាលពិនិត្យឡើងវិញលើភាពអនុលោម

៨២. មានជម្រើសជាច្រើន ត្រូវបានលើកយកមកធ្វើការពិចារណា ដើម្បីដោះស្រាយបញ្ហានៃការយល់ឃើញ និងបញ្ហាជាក់ស្តែង ដែលពាក់ព័ន្ធជាមួយនឹងលក្ខខណ្ឌតម្រូវរបស់គោលនយោបាយបច្ចុប្បន្ន ដែលតម្រូវឱ្យអ្នករងផលប៉ះពាល់ដោយសារគម្រោងត្រូវចាប់ផ្តើមជាមួយនឹងដំណាក់កាលពិគ្រោះយោបល់ជាមុនសិន ។

៨៣. **ជម្រើសទី ១: ស្ថានភាពដដែលដូចបច្ចុប្បន្ន** – ក្រោមគោលវិធីនេះ អ្នកស្នើសុំត្រូវចាប់ផ្តើមជាមួយដំណាក់កាលពិគ្រោះយោបល់ជាមុនសិន ប៉ុន្តែ ពួកគេអាចចាកចេញពីដំណាក់កាលនេះ និងបន្តទៅដំណាក់កាលពិនិត្យឡើងវិញលើភាពអនុលោម នៅពេលណាក៏បាន ។ គោលវិធីនេះផ្តោតអាទិភាពដំបូងលើការដោះស្រាយបញ្ហារបស់អ្នកដែលរងផលប៉ះពាល់ ដោយសារគម្រោង ។ គោលវិធីបែបនេះមានភាពស័ក្តិសមសម្រាប់បណ្តឹងភាគច្រើន ផ្អែកទៅតាមបទពិសោធន៍ចាប់តាំងពីឆ្នាំ ២០០៣ មក ដែលបង្ហាញថា បញ្ហាភាគច្រើន ដែលបានកើតឡើង គឺបញ្ហាជាក់លាក់ ដែលពាក់ព័ន្ធជាមួយនឹងការពិគ្រោះយោបល់, ការចូលរួម, ការចែករំលែកព័ត៌មាន និងអត្រាសំណង ។ ប៉ុន្តែ ការបន្តធ្វើតាមគោលវិធីនេះនឹងធ្វើឱ្យបញ្ហាពាក់ព័ន្ធនឹងការយល់ឃើញបច្ចុប្បន្ននៅតែមាន និងធ្វើឱ្យមានការពន្យារពេលដល់អ្នក ដែលចង់ស្នើឱ្យមានការពិនិត្យឡើងវិញលើភាពអនុលោមដោយផ្ទាល់ ។

៨៤. **ជម្រើសទី ២: ដំណើរការស្របគ្នា** - គោលវិធីបែបនេះគ្របដណ្តប់លើការដោះស្រាយបញ្ហាផង និងលើការពិនិត្យឡើងវិញលើភាពអនុលោមផង។ គោលវិធីបែបនេះជួបប្រទះនឹងបញ្ហានីតិវិធី និងបញ្ហាអនុវត្ត ជាច្រើន។ ការដោះស្រាយបញ្ហា និងការពិនិត្យឡើងវិញលើភាពអនុលោម ត្រូវការនូវផ្នត់គំនិត និងគោលវិធីផ្សេងៗពីគ្នា។ ការដោះ-ស្រាយបញ្ហា មានគោលបំណងបង្កើតឱ្យមានការឯកភាពគ្នាជារួម ខណៈពេលដែលការពិនិត្យឡើងវិញលើភាពអនុលោមមានគោលបំណងកំណត់ពីភាពមិនអនុលោមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ជាមួយនឹងគោលនយោបាយប្រតិបត្តិការការងាររបស់ខ្លួន។ ដំណើរការស្របគ្នាបែបនេះអាចធ្វើឱ្យមានការភ័ន្តច្រឡំ និងមានភាពស្មុគស្មាញ។ វាក៏អាចធ្វើឱ្យមានចំណាយយ៉ាងច្រើន និងពុំមានប្រសិទ្ធភាព សម្រាប់អ្នកស្នើសុំ, ធនាគារអភិវឌ្ឍន៍អាស៊ី និងប្រទេសកំពុងអភិវឌ្ឍជាសមាជិកផងដែរ។ ការដោះស្រាយបញ្ហាផង និងការពិនិត្យឡើងវិញលើភាពអនុលោមផង ក្នុងពេលជាមួយគ្នា ក៏ពុំមានសង្គតភាពជាមួយនឹងបទពិសោធន៍ ចាប់ពីឆ្នាំ ២០០៣ មកផងដែរ ដែលបង្ហាញថា ការស្នើសុំភាគច្រើនគឺពាក់ព័ន្ធជាមួយនឹងបញ្ហាជាក់លាក់។ នៅក្នុងករណីគម្រោង STDP, នៅពេលដែលដំណើរការស្របគ្នាជាមួយនឹងគណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម ត្រូវបានផ្តួចផ្តើមបង្កើតឡើង, អ្នកស្នើសុំបាត់បង់ចំណាប់អារម្មណ៍លើការសម្របសម្រួលដែលកំពុងបន្តមានជាមួយនឹងការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស ដែលធ្វើការឱ្យសម្របសម្រួលនេះពុំមានប្រសិទ្ធភាព (អារម្ភកថារបស់របាយការណ៍ប្រចាំ ២០០៥ របស់ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស)។ ដោយសារតែមូលហេតុទាំងនេះហើយ ទើបពុំមានយន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍ពហុភាគីណាអនុវត្តដំណើរការស្របពេលជាមួយគ្នាបែបនេះឡើយ។

៨៥. **ជម្រើសទី ៣: ការសម្រេចចិត្តរួមគ្នាដោយអ្នកសម្របសម្រួលគម្រោងពិសេស (SPF) និងគណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម (CRP)** - គោលវិធីបែបនេះចង់ឱ្យមានការពិនិត្យឡើងវិញរួមគ្នាលើការស្នើសុំពីសំណាក់ SPF និង CRP និងឱ្យមានការរៀបចំសកម្មភាពរួមគ្នា ដែលមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិក្នុងកម្រិតខ្ពស់បំផុត។ ការសម្រេចចិត្តនេះត្រូវបានផ្សព្វផ្សាយទៅដល់អ្នកស្នើសុំ ហើយប្រសិនបើអ្នកស្នើសុំមិនចង់បានដំណោះស្រាយផ្សេង ឬប្រសិនបើពុំមានភាពចាំបាច់យ៉ាងច្បាស់លាស់ឱ្យ CRP ធ្វើការពិនិត្យឡើងវិញលើភាពអនុលោមភ្លាមៗទេ, នោះដំណើរ-ការពិគ្រោះយោបល់ នឹងត្រូវចាប់ផ្តើមធ្វើភ្លាមតែម្តង ហើយក្នុងពេលជាមួយគ្នា CRP អាចចាប់ផ្តើមរៀបចំផែនការពិនិត្យឡើងវិញលើភាពអនុលោម ដែលអាចធ្វើឡើងនៅចុងដំណាក់កាលពិគ្រោះយោបល់។ បន្ទាប់ពីមានការបញ្ចប់ ឬបញ្ឈប់ការពិគ្រោះយោបល់រួច, CRP នឹងពិនិត្យឡើងវិញលើស្ថានភាព រួចធ្វើការវិនិច្ឆ័យ (i) ថាតើបញ្ហានៃភាពអនុលោម នៅបន្តមានទៀតដែរឬទេ និង (ii) ថាតើបញ្ហាទាំងនេះមានភាពធ្ងន់ធ្ងរគ្រប់គ្រាន់ ដើម្បីធានាឱ្យមានការពិនិត្យឡើងវិញលើភាពអនុលោមដែរឬទេ។ គុណសម្បត្តិរបស់គោលវិធីនេះគឺ (i) គោលវិធីនេះ ប្រើប្រាស់ជំនាញរបស់ CRP

និង SPF ចាប់ពីដំណាក់កាលដំបូងពេលទើបទទួលបានសំណើតែម្តង, (ii) ធានានូវតម្លាភាពក្នុង និងក្រៅយន្តការគណនេយ្យភាព និង (iii) ផ្តល់លទ្ធភាពឱ្យ CRP រៀបចំផែនការ និងធ្វើអធិការកិច្ចក្នុងរយៈពេលខ្លីជាង និងមានប្រសិទ្ធភាពជាង។ ប៉ុន្តែ គោលវិធីបែបផ្តួចផ្តើមជាមុនរបស់ CRP ពុំមានភាពស្របគ្នាជាមួយនឹងអណត្តិការងាររបស់យន្តការគណនេយ្យភាពឡើយ ហើយអាចធ្វើឱ្យមានទំនាស់ផលប្រយោជន៍កើតមានឡើង។ យន្តការគណនេយ្យភាពមិនមែនជាមុខងារអធិការកិច្ចនោះទេ។ ការពិនិត្យឡើងវិញលើភាពអនុលោមផ្តោតសំខាន់លើ (i) ការបញ្ជាក់ពីភាពមិនអនុលោម, (ii) ការបញ្ជាក់ពីការចោទប្រកាន់អំពីផលប៉ះពាល់ និង (iii) ភ្ជាប់ទំនាក់ទំនងផលប៉ះពាល់ជាមួយនឹងភាពមិនអនុលោមខាងដើម។ គ្រប់ទិដ្ឋភាពទាំងនេះត្រូវកើតមានក្នុងពេលស្របគ្នា។ គោលវិធីផ្អែកតាមការផ្គត់ផ្គង់នេះ គឺត្រួតគ្នាជាមួយនឹងយន្តការសវនកម្ម និងត្រួតពិនិត្យ ដែលកំពុងត្រូវបានគេកំពុងអនុវត្ត។ លើសពីនេះ គោលវិធីនេះស្ថិតក្រោមការដឹកនាំរបស់ SPF និង CRP ខណៈពេលអ្នករងផលប៉ះពាល់ដោយសារគម្រោងមានជម្រើសតិចតួចតែប៉ុណ្ណោះ។

៨៦. **ជម្រើសទី ៤ - ជម្រើសខ្លះៗ សម្រាប់អ្នកស្នើសុំ** - គោលវិធីនេះផ្តល់លទ្ធភាពឱ្យអ្នកស្នើសុំធ្វើការជ្រើសរើសថាតើពួកគេចង់ចាប់ផ្តើមជាមួយការពិគ្រោះយោបល់ ឬជាមួយនឹងដំណាក់កាលពិនិត្យឡើងវិញលើភាពអនុលោម។ ពួកគេអាចចាកចេញពីដំណាក់កាលពិគ្រោះយោបល់នេះ នៅពេលណាក៏បាន។ ប៉ុន្តែ អ្នកស្នើសុំអាចចាកចេញពីដំណាក់កាលពិនិត្យឡើងវិញបាន តែនៅពេលដែល CRP រកឃើញថាសំណើពុំមានលក្ខណៈសមស្រប ឬនៅក្នុងករណីដែលការស្នើសុំមានលក្ខណៈសមស្រប នៅពេលដែលដំណាក់កាលពិនិត្យឡើងវិញលើភាពអនុលោមបានបញ្ចប់រួចរាល់។ ហេតុផលដែលធ្វើឱ្យមានការរឹតបន្តឹងបែបនេះ គឺដោយសារតែការពិនិត្យឡើងវិញលើភាពអនុលោម គឺជាដំណើរការជាផ្លូវការមួយដែលត្រូវការចំណាយច្រើន ហើយមិនគួរលះបង់ចោលភ្លាម នៅពេលដែលទើបតែនឹងចាប់ផ្តើមនោះទេ។ គោលវិធីនេះផ្តល់ឱ្យអ្នកស្នើសុំនូវជម្រើសប្រើប្រាស់ដំណាក់កាលពិគ្រោះយោបល់ក៏បាន ឬដំណាក់កាលពិនិត្យឡើងវិញលើភាពអនុ-លោមក៏បាន ដោយផ្ទាល់។ ប៉ុន្តែ គោលវិធីនេះមិនអនុញ្ញាតឱ្យអ្នកស្នើសុំចាកចេញពីការពិនិត្យឡើងវិញលើភាពអនុលោមឡើយ នៅពេលដែលដំណើរការនេះកំពុងបន្ត។ អ្នកស្នើសុំអាចពុំមានព័ត៌មានគ្រប់គ្រាន់ អំពីថាតើពួកគេគួរចាប់ផ្តើមពីដំណាក់កាលណាទៅ។ ក្រោមគោលវិធីនេះ ពួកគេមានឱកាសតិចតួចប៉ុណ្ណោះ ដើម្បីពិនិត្យឡើងវិញលើការសម្រេចចិត្តរបស់ពួកគេ ប្រសិនបើពួកគេចាប់ផ្តើមពីការពិនិត្យឡើងវិញលើភាពអនុលោមទៅ។

៨៧. **ជម្រើសទី ៥: ជម្រើសពេញលេញសម្រាប់អ្នកស្នើសុំ** - យន្តការគណនេយ្យភាពគួរផ្អែកទៅតាមតម្រូវការរបស់អ្នកដែលរងផលប៉ះពាល់ដោយសារគម្រោង។ យន្តការនេះគួរផ្តល់លទ្ធភាពឱ្យអ្នកដែលរងផលប៉ះពាល់ដោយសារគម្រោង អាចប្រើប្រាស់ការពិនិត្យឡើងវិញលើភាពអនុលោម ដោយផ្ទាល់។ ក្រោមគោលវិធីនេះ អ្នកស្នើសុំនឹងធ្វើការសម្រេចចិត្តអំពីដំណាក់កាល ដែលពួកគេចង់ចាប់ផ្តើមមុន។ អ្នកស្នើសុំអាចចាកចេញពីដំណាក់កាលពិគ្រោះយោបល់ ឬ

ដំណាក់កាលពិនិត្យឡើងវិញលើភាពអនុលោម ពេលណាក៏បាន។ ដំណើរការបន្ត ដែលពួកគេកំពុងស្ថិតនៅ នឹងត្រូវបាន បញ្ឈប់ ប្រសិនបើអ្នកស្នើសុំចាកចេញ។ គុណសម្បត្តិរបស់គោលវិធីនេះគឺថា គោលវិធីនេះផ្តល់អំណាចឱ្យអ្នកស្នើសុំមាន ជម្រើស។ គោលវិធីនេះមានភាពសមស្របជាមួយអណត្តិការងាររបស់យន្តការគណនេយ្យភាព ដែលជាយន្តការផ្អែកទៅ តាមតម្រូវការ។ គោលវិធីនេះមានការចូលរួម និងងាយស្រួលអនុវត្ត។ គោលវិធីនេះអនុញ្ញាតឱ្យអ្នកស្នើសុំពិនិត្យ និង ពិចារណាឡើងវិញលើការសម្រេចចិត្តរបស់ពួកគេ។ ទិដ្ឋភាពនេះមានសារៈសំខាន់ជាពិសេស ដោយសារតែព័ត៌មានក្នុង ពាក្យបណ្តឹងអាចមានតិចតួច នៅដំណាក់កាលដំបូង ហើយគេអាចផ្លាស់ប្តូរការសម្រេចចិត្ត បន្ទាប់ពីមានព័ត៌មានថ្មីៗ។ គុណសម្បត្តិរបស់គោលវិធីបែបនេះគឺ ការពិគ្រោះយោបល់ ឬការពិនិត្យឡើងវិញលើភាពអនុលោមអាចត្រូវបានគេ បញ្ឈប់ ក្នុងកំឡុងពេលរបស់ដំណើរការ និងក្រោយពេលដែលអ្នកស្នើសុំ, ធនាគារអភិវឌ្ឍន៍អាស៊ី និងប្រទេសកំពុង អភិវឌ្ឍជាសមាជិក បានចំណាយខ្លះរួចទៅហើយ នៅក្នុងការអនុវត្តតាមដំណើរការនេះ។ ប៉ុន្តែ ចំណុចខ្លាំងរបស់គោលវិធី បែបនេះមានច្រើនជាងចំណុចខ្សោយ។ គួរមានការបង្កើតនូវកញ្ចប់ព័ត៌មានជាមូលដ្ឋាន និងទម្រង់គំរូ ដើម្បីជួយសម្រប សម្រួលឱ្យអ្នកស្នើសុំធ្វើការសម្រេចចិត្តឱ្យបានល្អ។

៨៨. គួរអនុវត្តទៅតាមគោលវិធីនេះ បន្ទាប់ពីមានការពិចារណាយ៉ាងប្រុងប្រយ័ត្នលើគោលវិធី ៤ ផ្សេងទៀត។

## ខ. ការបង្កើតចំណុចផ្តើមតែមួយ

៨៩. ដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកស្នើសុំ, ធនាគារអភិវឌ្ឍន៍អាស៊ីគួរបង្កើតចំណុចផ្តើមតែមួយ ដើម្បីទទួលយក គ្រប់សំណើទាំងអស់។ មន្ត្រីទទួលពាក្យបណ្តឹង (CRO) ដែលជាជនបង្គោល គួរបំពេញនាទីជាជនបង្គោលដំបូង សម្រាប់ អ្នករងផលប៉ះពាល់ដោយសារគម្រោង។ CRO ត្រូវបញ្ជូនសំណើទៅកាន់ SPF, CRP, និងនាយកដ្ឋានប្រតិបត្តិការ (ឬ នាយកដ្ឋាន ឬការិយាល័យពាក់ព័ន្ធដទៃទៀត) ទៅតាមការចង់បានរបស់អ្នកស្នើសុំ និងលក្ខណៈរបស់បញ្ហា។

៩០. CRO គួរជាផ្នែកមួយនៃ OCRP។ ការមាន CRO នៅក្នុង OCRP នឹងផ្តល់ឱ្យមន្ត្រីរូបនេះនូវឯករាជ្យភាព ក្នុងកម្រិតខ្ពស់ បើប្រៀបជាមួយការដាក់មន្ត្រីរូបនេះ នៅក្នុង OSPF ឬនាយកដ្ឋានដទៃទៀត។ ការធ្វើបែបនេះក៏មាន ប្រសិទ្ធភាពជាងបង្កើតការិយាល័យថ្មី ដែលតម្រូវឱ្យមានចំណាយរដ្ឋបាលបន្ថែមផងដែរ។ ជម្រើសដាក់ OSPF និង OCRP បញ្ចូលគ្នា អាចកាត់បន្ថយការគាំទ្រ ដែល SPF និង CRP ត្រូវការ សម្រាប់ការបំពេញមុខងាររៀងៗខ្លួន។ CRO នឹងគាំទ្រដល់មុខងារដែលមានស្រាប់របស់ SPF និង CRP ដោយពុំធ្វើឱ្យប៉ះពាល់ដល់ឯករាជ្យភាព និង ប្រសិទ្ធភាពរបស់យន្តការទាំងពីរនេះ។

## គ. ការបញ្ជាក់ឱ្យបានច្បាស់ពីកាលបរិច្ឆេទឱសានវាទ

៩១. គោលវិធីបច្ចុប្បន្ន នៅក្នុងការកំណត់ពីកាលបរិច្ឆេទឱសានវាទ ផ្អែកទៅតាមរបាយការណ៍បញ្ចប់គម្រោង ពុំមានភាពច្បាស់លាស់ និងភាពប្រាកដប្រជាគ្រប់គ្រាន់ឡើយ។ ជម្រើសមួយ ដែលត្រូវបានគេយកមកធ្វើការពិចារណា គឺការពន្យារកាលបរិច្ឆេទឱសានវាទ សម្រាប់ដាក់ការស្នើសុំ ពេលខ្លះឱ្យហួសពីកាលបរិច្ឆេទចេញរបាយការណ៍បញ្ចប់គម្រោង។ ប៉ុន្តែ ដោយសារការចេញរបាយការណ៍បញ្ចប់គម្រោងនេះគឺពុំមានភាពប្រាកដប្រជា, ការពន្យារកាលបរិច្ឆេទឱសានវាទផ្អែកទៅតាមរបាយការណ៍បញ្ចប់គម្រោងនេះ នឹងមិនអាចដោះស្រាយបញ្ហានេះបានឡើយ។ ជម្រើសដែលប្រសើរជាងនេះ គឺត្រូវប្រើកាលបរិច្ឆេទបិទកម្ចី ជាចំណុចដៅ។ កាលបរិច្ឆេទឱសានវាទសម្រាប់ដាក់សំណើ អាច ១ ឆ្នាំ ក្រោយកាលបរិច្ឆេទបញ្ចប់កម្ចី។ ការប្រើកាលបរិច្ឆេទបញ្ចប់កម្ចីផ្តល់នូវភាពច្បាស់លាស់ និងភាពប្រាកដប្រជាច្រើនជាង។ លើសពីនេះទៅទៀត ព័ត៌មានអំពីកាលបរិច្ឆេទបញ្ចប់កម្ចី គឺមានរួចជាស្រេចសម្រាប់សាធារណជន។

## ឃ. ការចុះដល់ទីតាំងគម្រោងជាក់ស្តែង

៩២. បញ្ហាចុះដល់ទីតាំងគម្រោងជាក់ស្តែង គឺជាបញ្ហារសើប និងជាបញ្ហាសំខាន់។ ក្រុមការងារបានពិចារណាលើជម្រើសជាច្រើន ដើម្បីដោះស្រាយបញ្ហានេះ។

៩៣. **ជម្រើសទី ១ : ស្ថានភាពដដែលដូចបច្ចុប្បន្ន** – ការរៀបចំបច្ចុប្បន្នសម្រាប់ការចុះដល់ទីតាំងជាក់ស្តែង នៅក្នុងគោលនយោបាយដែលមានស្រាប់ ត្រូវបានដាក់ចេញនៅក្នុងកថាខណ្ឌទី ៥៥ និង ៥៦ របស់គោលនយោបាយនេះ។ គោលនយោបាយនេះចែងថា "គោលវិធីដ៏ល្អមួយ គឺត្រូវធ្វើការពិគ្រោះយោបល់អំពីការចុះដល់ទីតាំងជាក់ស្តែងនេះជាមួយនឹងប្រទេសខ្ចីកម្ចី... ស្នើសុំការឯកភាពជាមុនពីប្រទេសខ្ចីកម្ចី ក្រោមការសន្មតថា ការឯកភាពនេះនឹងត្រូវផ្តល់ឱ្យជាប្រចាំ, នេះគឺជាអ្វីដែលគេចង់បានជំនួសឱ្យគោលវិធីដាក់បញ្ចូលលក្ខខណ្ឌនេះ នៅក្នុងកិច្ចព្រមព្រៀងកម្ចី" (កថាខណ្ឌទី ៥៦)។ ខណៈពេលដែលគោលនយោបាយនេះកំណត់យ៉ាងច្បាស់អំពីគោលការណ៍នៃការតម្រូវឱ្យមានការឯកភាពពីប្រទេសខ្ចីកម្ចី, គោលនយោបាយនេះមិនបានលើកឡើងពីដំណើរការ និងការទទួលខុសត្រូវលើការទទួលបានការឯកភាពពីប្រទេសខ្ចីកម្ចីឡើយ។ នៅក្នុងការអនុវត្តជាក់ស្តែង, គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោមជាអ្នកទទួលខុសត្រូវ លើការស្នើសុំការឯកភាពនេះ។ ការដាក់បញ្ចូល (i) ការតម្រូវឱ្យមានការឯកភាពពីប្រទេសខ្ចីកម្ចី និង (ii) ការដាក់បន្ទុកឱ្យគណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោមទទួលខុសត្រូវលើការស្នើសុំការឯកភាព ពុំមានប្រសិទ្ធភាព នៅក្នុងគ្រប់ករណីទាំងអស់ឡើយ។

៩៤. **ជម្រើសទី ២: ការតម្រូវឱ្យមានការចុះដល់ទីតាំងជាក់ស្តែង** - ជម្រើសនេះពាក់ព័ន្ធនឹងការដាក់បញ្ចូលខចែង អំពីការតម្រូវឱ្យមានការចុះដល់ទីតាំងជាក់ស្តែង ទៅក្នុងកិច្ចព្រមព្រៀងកម្ចី។ គុណសម្បត្តិរបស់គោលវិធីបែបនេះគឺ វាតម្រូវឱ្យការទទួលយកការចុះដល់ទីតាំងជាក់ស្តែង ជាកាតព្វកិច្ចរបស់ប្រទេសខ្ចីកម្ចី។ នៅក្នុងទ្រឹស្តី គោលវិធីបែបនេះ អាចលុបចោលនូវភាពមិនប្រាកដប្រជាបាន។ ប៉ុន្តែ គោលវិធីបែបនេះប្រឈមនឹងបញ្ហាអនុវត្ត និងបញ្ហាច្បាប់ជាច្រើន។ ការតម្រូវឱ្យមានការចុះដល់ទីតាំងជាក់ស្តែងបែបនេះ ត្រូវបានគេយល់ឃើញថាជា ការរំលោភនឹងបូរណភាពរបស់ជាតិមួយ និងផ្ទុយពីគោលការណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី និងការអនុវត្តការងារក្នុងភាពជាដៃគូជាមួយប្រទេសកំពុងអភិវឌ្ឍជាសមាជិក។ គោលវិធីបែបនេះក៏ផ្ទុយទៅនឹងស្មារតីនៃសេចក្តីប្រកាសទីក្រុងប៉ារីស និងរបៀបវារៈទីក្រុងអាក្រា ដែលផ្តោតការយកចិត្តទុកដាក់លើភាពជាដៃគូរវាងប្រទេសផ្តល់ជំនួយ និងស្ថាប័នទទួលជំនួយផងដែរ។

៩៥. ខណៈពេលដែលធនាគារអភិវឌ្ឍន៍អាស៊ីមានជម្រើសផ្អាក ឬលុបចោលកម្ចី នៅពេលដែលប្រទេសខ្ចីកម្ចីប្រព្រឹត្តផ្ទុយនឹងកិច្ចព្រមព្រៀងកម្ចី, ការដាក់ទោសទណ្ឌបែបនេះមិនអាចដោះស្រាយបញ្ហា ដែលអ្នកដាក់ពាក្យបណ្តឹងជួបប្រទះនោះទេ ហើយអាចធ្វើឱ្យគម្រោងទាំងមូលប្រឈមនឹងភាពប្រថុយប្រថានថែមទៀតផង។ លើសពីនេះទៅទៀត ការលុបចោលកម្ចី ដោយសារតែប្រទេសខ្ចីកម្ចីបដិសេធមិនឱ្យមានការចុះដល់ទីតាំងរបស់គម្រោង នឹងធ្វើឱ្យមានចំណុចខ្សោយដ៏ធំមួយ: គេដាក់ទោសទណ្ឌលើប្រទេសខ្ចីកម្ចី នៅពេលដែលការពិនិត្យឡើងវិញលើភាពអនុលោមមានគោលដៅធ្វើការស៊ើបអង្កេតលើភាពមិនអនុលោមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលជាអ្នកផ្តល់កម្ចី ពោលគឺមិនមែនរបស់ប្រទេសកំពុងអភិវឌ្ឍជាសមាជិក ដែលជាអ្នកខ្ចីកម្ចីនោះឡើយ។ ទោះបីជាមាន ឬមិនមានខចែង នៅក្នុងកិច្ចព្រមព្រៀងកម្ចីក៏ដោយ, ក្រុមការងារដែលមានបេសកកម្មចុះទៅកាន់ប្រទេសកំពុងអភិវឌ្ឍជាសមាជិក ជាធម្មតា តែងទទួលបានទិដ្ឋាការយល់ព្រម។ ការតម្រូវឱ្យមានការចុះដល់ទីតាំងគម្រោងជាក់ស្តែងបែបនេះនឹងមិនអាចអនុវត្តទៅបានឡើយ ប្រសិនបើគេមិនអាចទទួលបានទិដ្ឋាការទាំងនេះ។ ដូច្នេះ ជម្រើសនេះនឹងមិនដោះស្រាយបញ្ហានេះឡើយ ហើយអាចធ្វើឱ្យបញ្ហាដែលមានស្រាប់កាន់តែរីកធំថែមទៀតផង។ ដោយសារតែមូលហេតុទាំងនេះហើយ ពុំមានគោលនយោបាយយន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍ពហុភាគីណាតម្រូវឱ្យមានការចុះដល់ទីតាំងគម្រោងជាក់ស្តែងឡើយ។

៩៦. **ជម្រើសទី ៣: គោលវិធីបែបសហប្រតិបត្តិការ** - ក្រោមគោលវិធីនេះ ការចុះដល់ទីតាំងគម្រោងជាក់ស្តែងរបស់គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម ត្រូវប្រើគោលការណ៍ និងការអនុវត្ត ដូចគ្នានឹងគោលការណ៍ និងការអនុវត្ត ដែលប្រើសម្រាប់គ្រប់បេសកកម្មទាំងអស់របស់ធនាគារអភិវឌ្ឍន៍អាស៊ី ដោយមិនចាំបាច់ប្រើប្បញ្ញត្តិច្បាប់។ គោលវិធីថ្មីនេះមានគោលបំណងបង្កើនប្រសិទ្ធភាពនៃការប្រាស្រ័យទាក់ទងរវាងធនាគារអភិវឌ្ឍន៍អាស៊ី និងប្រទេសកំពុងអភិវឌ្ឍជាសមាជិក។ គោលវិធីនេះក៏ផ្តោតការយកចិត្តទុកដាក់លើបញ្ហាទំនាក់ទំនង និងឥរិយាបថ នៅក្នុងគោលវិធី

បច្ចុប្បន្ន ដែលកើតឡើងដោយសារពុំមានកំណត់ឱ្យបានច្បាស់លាស់អំពីការទទួលខុសត្រូវ និងរបៀបស្នើសុំការឯកភាពពីប្រទេសខ្ចីកម្ចី នៅក្នុងគោលនយោបាយបច្ចុប្បន្ន។ គោលនយោបាយនេះផ្អែកទៅតាមបទពិសោធន៍ នៅក្នុងការចុះបេសកកម្មរបស់គណៈគ្រប់គ្រង និងបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ គោលវិធីនេះក៏មានភាពចាំបាច់ផងដែរ ដោយសារការរំពឹងទុករបស់សង្គមស៊ីវិលអំពីភាពគ្រប់ជ្រុងជ្រោយនៃយន្តការដោះស្រាយបញ្ហារបស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ មានការកើនឡើង ចាប់តាំងពីគោលនយោបាយនេះ ត្រូវបានអនុម័ត នៅក្នុងឆ្នាំ ២០០៣ រួចមក។ គោលជំហររបស់គោលនយោបាយឆ្នាំ ២០០៣ ដែលថា "ការចុះដល់ទីតាំងជាក់ស្តែងមានសារៈសំខាន់ សម្រាប់ធានាប្រសិទ្ធភាពនៃការពិនិត្យឡើងវិញលើភាពអនុលោម, ការចូលរួមរបស់អ្នកពាក់ព័ន្ធ និងការផ្ទៀងផ្ទាត់ដោយឯករាជ្យលើអង្គហេតុ និងការចោទប្រកាន់អំពីការប្រព្រឹត្តផ្ទុយទៅនឹងគោលនយោបាយ" (កថាខ័ណ្ឌទី ៥៥) ឥលូវនេះ ប្រហែលជាកាន់តែមានភាពទូលំទូលាយ ជាងនៅក្នុងឆ្នាំ ២០០៣។ លើសពីនេះ ចាប់តាំងពីការអនុម័តលើគោលនយោបាយការពារសង្គម និងបរិស្ថាន នៅក្នុងឆ្នាំ ២០០៩ រួចមក, មានការរំលេចឱ្យឃើញយ៉ាងច្បាស់អំពីសារៈសំខាន់នៃការអនុលោមទៅតាមគោលនយោបាយការពារសង្គម និងបរិស្ថានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ដោយសារការវិវឌ្ឍទាំងអស់នេះហើយ សំខាន់ត្រូវទទួលស្គាល់ពីមូលហេតុ ដែលធ្វើឱ្យការចុះបេសកកម្មការងាររបស់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងប្រទេសខ្ចីកម្ចី មានភាពងាយស្រួលជាង បើប្រៀបជាមួយនឹងការចុះដល់ទីតាំងជាក់ស្តែងសម្រាប់ការពិនិត្យឡើងវិញលើភាពអនុលោម។

៩៧. ការគ្រប់គ្រងទំនាក់ទំនង គឺជាសមាសធាតុមួយ ក្នុងចំណោមសមាសធាតុស្នូលនានា នៃការចូលរួមរបស់គណៈ-គ្រប់គ្រង និងបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី ជាមួយប្រទេសខ្ចីកម្ចី ដែលជាសមាជិក។ ការិយាល័យតំណាងប្រចាំប្រទេស គឺជាចំណុចផ្តោតពិសេសនៃការចូលរួមនេះ ហើយការទទួលខុសត្រូវមួយ ក្នុងចំណោមការទទួលខុសត្រូវចម្បងនានារបស់ ការិយាល័យតំណាងប្រចាំប្រទេស គឺការគ្រប់គ្រងទំនាក់ទំនងនៅក្នុងប្រទេស។ ធនធានសុច្ឆន្ទៈនេះត្រូវបានបុគ្គលិករបស់ធនាគារប្រើប្រាស់ ដើម្បីសុំការឯកភាពសម្រាប់បេសកកម្មនានា។ គេគួរប្រើប្រាស់ធនធាននេះ ដើម្បីផ្តល់លទ្ធភាពឱ្យគណៈកម្មការពិនិត្យ ឡើងវិញលើភាពអនុលោម ចុះដល់ទីតាំងគម្រោងជាក់ស្តែង។ ក្រោមការរៀបចំកិច្ចសហប្រតិបត្តិការនេះ, គណៈគ្រប់គ្រង និងបុគ្គលិកនឹងសម្របសម្រួល, ផ្តល់ជំនួយ និងប្រើប្រាស់ទំនាក់ទំនងរបស់ពួកគេជាមួយប្រទេសខ្ចីកម្ចី នៅក្នុងការរៀបចំសុំការឯកភាពសម្រាប់ការចុះបេសកកម្ម និងការចុះដល់ទីតាំងគម្រោងជាក់ស្តែងដោយរលូន។ នេះគឺជាកាតព្វកិច្ចរបស់គណៈគ្រប់គ្រង ដែលតម្រូវឱ្យមានការខិតខំប្រឹងប្រែងសហការរួមប្រកបដោយអត្ថន័យ និងប្រសិទ្ធភាព ជាមួយប្រទេសខ្ចីកម្ចី។ គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោមគួរស្នើសុំជំនួយពីនាយកប្រតិបត្តិរបស់ប្រទេសខ្ចីកម្ចី ដែលពាក់ព័ន្ធ។ គុណសម្បត្តិរបស់ជម្រើសនេះ មានរៀបរាប់ដូចខាងក្រោម។

(i) **តម្រឹមស្របជាមួយនឹងផលប្រយោជន៍រួម:** វាគឺដើម្បីផលប្រយោជន៍ទ្វេទិសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី, ប្រទេសកំពុងអភិវឌ្ឍជាសមាជិក និងគណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម ក្នុងការធានាឱ្យយន្តការគណនេយ្យភាពមានដំណើរការទៅដោយរលូន។ ផលប្រយោជន៍រួមទាំងនេះ គឺជាមូលដ្ឋានសម្រាប់គោលវិធីបែបសហការ។

(ii) **មានសង្គតភាពជាមួយភ័ស្តុតាងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី:** បុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ីចុះបំពេញបេសកកម្មជាច្រើនដង នៅក្នុងមួយឆ្នាំៗ។ បេសកកម្មទាំងអស់សុទ្ធតែត្រូវបានទទួលយកដោយប្រទេសកំពុងអភិវឌ្ឍជាសមាជិក ដូចគ្នានឹងការចុះធ្វើទស្សនកិច្ចរបស់ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេសផងដែរ។ នេះរំលេចឱ្យឃើញពីប្រសិទ្ធភាពនៃគោលវិធីបែបសហការ។ ខណៈពេលដែលអាចមានភ័ស្តុតាងខុសគ្នាខ្លះ នៅក្នុងករណីគណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម, ការសន្មតរបស់គោលនយោបាយមុន ដែលថាការចុះដល់ទីតាំងគម្រោងជាក់ស្តែងនឹងទទួលបានការអនុញ្ញាតជាប្រចាំ គួររក្សាទុកដដែល។

(iii) **មានសង្គតភាពជាមួយគោលវិធីរបស់ធនាគារអភិវឌ្ឍន៍ពហុភាគីដទៃទៀត:** ពុំមានយន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍ពហុភាគីណាតម្រូវឱ្យមានការចុះដល់ទីតាំងគម្រោងជាក់ស្តែងឡើយ ហើយក៏ពុំមានយន្តការគណនេយ្យភាព របស់ធនាគារអភិវឌ្ឍន៍ពហុភាគីណា ធ្លាប់ជួបប្រទះការលំបាក នៅក្នុងការរៀបចំការចុះដល់ទីតាំងជាក់ស្តែងបែបនេះដែរ[៣៨]។ គោលវិធីបែបសហការនេះមានដំណើរការយ៉ាងល្អ នៅក្នុងយន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍ពហុភាគីដទៃទៀត។

(iv) **មានភាពអំណោយផលដល់ការដោះស្រាយវិវាទ:** គោលវិធីនេះផ្តល់លទ្ធភាពឱ្យមានការពិភាក្សាអំពីការចុះដល់ទីតាំងគម្រោងជាក់ស្តែង និងមានការបំភ្លឺអំពីការយល់ច្រឡំនានា នៅពេលមានការមិនឯកភាពគ្នា។ នៅក្នុងករណីមួយចំនួនតូច ដែលប្រទេសកំពុងអភិវឌ្ឍជាសមាជិកមានការស្ទាក់ស្ទើរចំពោះសំណើចុះបំពេញបេសកកម្មរបស់បុគ្គលិក ឬគណៈគ្រប់គ្រងរបស់ធនាគារ, ការប្រាស្រ័យទាក់ទងដែលមានប្រសិទ្ធភាពតែងអាចដោះស្រាយបញ្ហាបាន។ ច្រកប្រាស្រ័យទាក់ទងនឹងត្រូវបានបិទ ប្រសិនបើគោលវិធីបែបសហការនេះមិនត្រូវបានប្រើប្រាស់

---

[៣៨] គណៈកម្មការអធិការកិច្ចរបស់ធនាគារពិភពលោក បានទទួលពាក្យបណ្តឹងចំនួន ៧០ ចាប់តាំងពីឆ្នាំ ១៩៩៤ មក។ ខណៈពេលគណៈកម្មការនេះជួបនឹងការបដិសេធរបស់ប្រទេសចំពោះការចុះទៅកាន់ទីតាំងគម្រោងជាក់ស្តែងម្តង នៅចុងទស្សវត្សរ៍ ១៩៩០, ចាប់តាំងពីពេលនោះមក មិនដែលមានការជំទាស់ដោយប្រទេសឡើយ។ ការចុះដល់ទីតាំងជាក់ស្តែងពីសំណាក់គណៈកម្មការអធិការកិច្ច និងកិច្ចប្រជុំជាច្រើន ត្រូវបានរៀបចំឡើងដោយការិយាល័យប្រចាំប្រទេសរបស់ធនាគារពិភពលោក។

ទេនោះ ។ គោលវិធីដែលមានលក្ខណៈរឹងត្អឹង នឹងបង្កើតឱ្យមានគោលជំហររឹងត្អឹង និងភាពទ័លច្រក ដែលពុំផ្តល់ឱកាសមានការពិភាក្សាបន្តទៀតបាន ។

(v) **យល់ពីការព្រួយបារម្ភរបស់ប្រទេសកំពុងអភិវឌ្ឍជាសមាជិក (DMC)** - គោលនយោបាយគណនេយ្យភាពសង្គមគួសបញ្ជាក់ថា គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោមត្រូវពិនិត្យឡើងវិញលើភាពមិនអនុលោមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ទៅតាមគោលនយោបាយ និងនីតិវិធីប្រតិបត្តិការការងាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ចំណុចនេះគួរជាចំណុចផ្តោតសំខាន់បន្តទៀត ។ ការបន្តធ្វើដូច្នេះនឹងជួយឱ្យទទួលបានការទទួលយករបស់ DMC លើការពិនិត្យឡើងវិញលើភាពអនុលោម ។ ប៉ុន្តែ វាមិនអាចលុបចោលការព្រួយបារម្ភទាំងអស់របស់ DMCបាននោះទេ ។ ទីមួយ DMC អាចត្រូវបានគេគិតថា ពាក់ព័ន្ធជាមួយនឹងការពិនិត្យឡើងវិញលើភាពអនុលោមនេះ ។ ស្ថានភាពជាក់ស្តែងគឺ ធនាគារអភិវឌ្ឍន៍អាស៊ីមិនមែនជាអ្នកអនុវត្តគម្រោងឡើយ ។ ប្រទេសខ្ចីកម្ចីជាអ្នកអនុវត្តគម្រោង ។ បន្ទាប់ពីគម្រោងមួយទទួលបានការឯកភាព, ធនាគារអភិវឌ្ឍន៍អាស៊ីទទួលខុសត្រូវធានាយ៉ាងណាឱ្យប្រទេសខ្ចីកម្ចីអនុវត្តគម្រោងនេះ ដោយអនុលោមទៅតាមគោលនយោបាយ និងនីតិវិធីដែលពាក់ព័ន្ធរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។ គេមិនអាចលុបចោលទាំងស្រុងនូវការយល់ឃើញថា នេះគឺជាការខកខានរបស់រដ្ឋាភិបាល ក្នុងការអនុលោមទៅតាមគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលរដ្ឋាភិ-បាលបានព្រមព្រៀងនោះទេ ។ ទីពីរ រដ្ឋាភិបាលក៏អាចមានការព្រួយបារម្ភអំពីការពន្យារពេល និងការចំណាយដទៃទៀត ដែលកើតឡើង ដោយសារការពិនិត្យឡើងវិញនេះផងដែរ ។ រដ្ឋាភិបាលក៏អាចព្រួយបារម្ភផងដែរថា អាចនឹងមានការផ្អាក ឬលុបចោលកម្ចី បន្ទាប់ពីការពិនិត្យឡើងវិញរបស់គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោមរួច ។ ត្រូវមានការប្រាស្រ័យទាក់ទងជាប្រចាំ និងញឹកញាប់ ជាមួយប្រទេសខ្ចីកម្ចី ដើម្បីទទួលបានការឯកភាពរបស់ពួកគេលើការចុះដល់ទីតាំងគម្រោងជាក់ស្តែង ដែលត្រូវធ្វើឡើងដោយគណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម ។ គោលវិធីមួយ ដែលមានការប្រាស្រ័យទាក់ទងតែម្តងចប់ និងពុំមានការប្រាស្រ័យទាក់ទងឱ្យបានទូលំទូលាយ ទំនងជានឹងមិនទទួលបានជោគជ័យឡើយ ។

៩៨. **ជម្រើសទី ៤: ការចុះដល់ទីតាំងគម្រោងជាក់ស្តែង ដោយគណៈកម្មាធិការពិនិត្យឡើងវិញលើភាពអនុលោមរបស់ក្រុមប្រឹក្សាភិបាល (BCRC), គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម (CRP), និងសមាជិកក្រុម-ប្រឹក្សាភិបាលមកពីប្រទេសខ្ចីកម្ចី** - ក្រោមគោលវិធីនេះ នៅពេលដែលប្រទេសខ្ចីកម្ចីមួយបដិសេធសំណើសុំចុះដល់ទីតាំងគម្រោងជាក់ស្តែងរបស់ CRP, ការចុះដល់ទីតាំងជាក់ស្តែងនេះនឹងធ្វើឡើងដោយក្រុមការងារមួយក្រុម ដែល

មានសមាសភាពជាសមាជិករបស់ CRP, សមាជិករបស់ BCRC និងសមាជិកក្រុមប្រឹក្សាភិបាល ដែលតំណាងឱ្យប្រទេសខ្ចីកម្ចី។ CRP, BCRC និងតំណាងរបស់ក្រុមប្រឹក្សាភិបាល ដែលតំណាងឱ្យប្រទេសខ្ចីកម្ចី នឹងស្នើសុំជំនួយពីនាយកដ្ឋានប្រចាំប្រទេស/ការិយាល័យតំណាងប្រចាំប្រទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ឱ្យជួយសម្របសម្រួលការមកធ្វើទស្សនកិច្ចរបស់ពួកគេមកកាន់ប្រទេស ដែលកំពុងមានការពិនិត្យឡើងវិញលើភាពអនុលោម។ គោលវិធីបែបនេះមានលទ្ធភាពខ្ពស់ ក្នុងការទទួលបានការឯកភាពពីប្រទេសខ្ចីកម្ចី។ ប៉ុន្តែ ការធ្វើបែបនេះអាចធ្វើឱ្យ BCRC និងសមាជិកក្រុមប្រឹក្សាភិបាល ដែលតំណាងឱ្យប្រទេសខ្ចីកម្ចី ស្ថិតក្នុងស្ថានភាពនៃទំនាស់ផលប្រយោជន៍។ លើសពីនេះ ការបញ្ជូនបញ្ហាដល់ក្រុមប្រឹក្សាភិបាល អាចធ្វើឱ្យបញ្ហាកាន់រីកធំឡើង។

៩៩. **ជម្រើសទី ៥: ការចុះដល់ទីតាំងគម្រោងជាក់ស្តែង ដោយភាគីទី ៣** – ក្រោមគោលវិធីនេះ, CRP នឹងស្នើសុំឱ្យភាគីទីបី ជាអ្នកចុះដល់ទីតាំងជាក់ស្តែងរបស់គម្រោង។ គុណសម្បត្តិរបស់គោលវិធីនេះគឺ គោលវិធីនេះគឺជាច្រកមួយសម្រាប់ដោះស្រាយបញ្ហា និងធ្វើឱ្យមានការព្រមព្រៀងទ្វេទិសរវាង CRP និងប្រទេសខ្ចីកម្ចី។ ដោយឡែកគុណវិបត្តិវិញគឺ CRP គឺជាភាគីទីបីរួចទៅហើយ។ ការស្នើឱ្យមានការចូលរួមពីភាគីទីបី សម្រាប់ភាគីទីបី អាចជាការបញ្ចៀសមិនចង់ដោះស្រាយបញ្ហា ឬជាការធ្វើឱ្យបញ្ហាកាន់តែស្មុគស្មាញ ជាជាងដោះស្រាយបញ្ហាទាំងនេះ។

១០០. ក្រុមការងារកំពុងធ្វើការពិចារណាលើគ្រប់ជម្រើសទាំងអស់ខាងលើ និងភាពខុសប្លែកគ្នានៃជម្រើសទាំងនេះ។ ក្រុមការងារនឹងផ្តល់នូវទស្សនៈយល់ឃើញរបស់ខ្លួន ផ្អែកទៅតាមយោបល់ដែលទទួលបានរហូតមកដល់បច្ចុប្បន្ននេះ និងយោបល់ដែលទទួលបានពីការពិគ្រោះយោបល់បន្តទៀត។ ខណៈពេលដែលក្រុមការងារពេញចិត្តនឹងជម្រើសទី ៣, ក្រុមការងារនឹងបន្តពិចារណាថាតើជម្រើសនេះអាចឆ្លើយតបដោយរបៀបណាទៅនឹងស្ថានភាព ដែលការចុះដល់ទីតាំងគម្រោងជាក់ស្តែង នៅតែទទួលបានការបដិសេធ។

## ខ. ការបង្កើនឯករាជ្យភាព និងប្រសិទ្ធភាពនៃការពិនិត្យឡើងវិញលើភាពអនុលោម

១០១. **ឯករាជ្យភាព** – មានការផ្លាស់ប្តូរមួយចំនួន ចេញពីគំរូរបស់នាយកដ្ឋានវាយតម្លៃឯករាជ្យ ដែលត្រូវបានស្នើឡើង ដើម្បីបង្កើនឯករាជ្យភាពរបស់ CRP។ ដំបូង, សមាជិករបស់ CRP គួរទទួលបានការតែងតាំងពីក្រុមប្រឹក្សា-ភិបាល ផ្អែកទៅតាមអនុសាសន៍របស់ BCRC ដោយមានការពិគ្រោះយោបល់ជាមួយនឹងប្រធានធនាគារ ខុសពីការអនុវត្តបច្ចុប្បន្ន ដែលក្រុមប្រឹក្សាភិបាលត្រូវធ្វើការតែងតាំង ទៅតាមអនុសាសន៍របស់ប្រធានធនាគារ។ ទីពីរ ដំណើរការរៀបចំផែនការការងារ និងរៀបចំថវិកា គួរត្រូវបានពង្រឹងបន្ថែមទៀត។ ប្រធាន CRP គួរទទួលខុសត្រូវលើការរៀបចំផែនការការងារប្រចាំឆ្នាំ និងថវិការបស់ CRP និង OCRP បញ្ចូលគ្នា។ ផែនការទាំងនេះគួរទទួលបានការគាំទ្រពី

BCRC, ពិនិត្យឡើងវិញដោយគណៈកម្មាធិការថវិការបស់ក្រុមប្រឹក្សាភិបាល និងទទួលបានការឯកភាពចុងក្រោយពីក្រុមប្រឹក្សាភិបាល ។

១០២. ដើម្បីបង្កើនគណនេយ្យភាព, BCRC គួរផ្តល់ព័ត៌មានត្រលប់ជាលាយលក្ខណ៍អក្សរអំពីលទ្ធផលការងារប្រចាំឆ្នាំទៅឱ្យគ្រប់សមាជិកទាំងអស់របស់ CRP ។ គំនិតយោបល់របស់ប្រធាន CRP គួរយកមកធ្វើការពិចារណា នៅពេលដែល BCRC ផ្តល់ព័ត៌មានត្រលប់ដល់សមាជិកពីររូបទៀតរបស់ CRP ។

១០៣. **ភាពស័ក្តិសិទ្ធិ** – យន្តការគណនេយ្យភាពគួរផ្តល់ឱកាសឱ្យអ្នកគ្រប់គ្រងធ្វើការឆ្លើយតប មុនពេលមានការកំណត់ពីភាពសមស្របនៃសំណើសុំឱ្យមានការពិនិត្យឡើងវិញលើភាពអនុលោម ។ ស្របគ្នាជាមួយនឹងគោលការណ៍ភាពជាដៃគូ, CRP គួរព្យាយាមជម្រុញឱ្យមានការចូលរួមពីរដ្ឋាភិបាលរបស់ប្រទេសកំពុងអភិវឌ្ឍជាសមាជិក និងអ្នកពាក់ព័ន្ធដទៃទៀត នៅក្នុងដំណើរការពិនិត្យឡើងវិញទាំងមូល ។ ប្រទេសខ្ចីកម្ចីគួរទទួលបានព័ត៌មានអំពីការស្នើសុំនេះ មុនពេលមានការកំណត់ពីលក្ខណៈសមស្របរបស់វា ហើយគួរមានឱកាសឆ្លើយតបទៅនឹងសេចក្តីព្រាងរបាយការណ៍របស់ CRP ។

១០៤. ដើម្បីកំណត់ឱ្យបានច្បាស់លាស់នូវទំនាក់ទំនងរវាងការពិនិត្យឡើងវិញលើភាពអនុលោម, ការដោះស្រាយបញ្ហា និងការចាត់ចែងគម្រោង និងដើម្បីធានាថា យន្តការគណនេយ្យភាពនេះពិតជាមានគោលដៅជាក់លាក់ និងអាចបំពេញបន្ថែមប្រកបដោយប្រសិទ្ធភាពលើប្រព័ន្ធគ្រប់គ្រងគម្រោង ដែលមានស្រាប់, ការពិនិត្យឡើងវិញលើភាពអនុលោមនេះគួរមានលក្ខណៈជាការស្វែងរកអង្គហេតុ ។ ការពិនិត្យឡើងវិញលើភាពអនុលោមគួរផ្តោតលើការបញ្ជាក់ពីការចោទប្រកាន់អំពីផលប៉ះពាល់ដោយផ្ទាល់ និងក្នុងកម្រិតគួរឱ្យកត់សម្គាល់ និងថាតើផលប៉ះពាល់ទាំងនេះកើតឡើងដោយសារការខកខានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី នៅក្នុងការអនុលោមទៅតាមគោលនយោបាយ និងនីតិវិធីប្រតិបត្តិការការងាររបស់ខ្លួនដែរឬទេ ។ បន្ទាប់ពីបានទទួលលទ្ធផលរកឃើញរបស់ CRP រួចហើយ, គណៈគ្រប់គ្រងនឹងដាក់ចេញនូវវិធានការ និង/ឬផែនការសកម្មភាព ដោយមានការឯកភាពពីប្រទេសខ្ចីកម្ចី ។ អនុសាសន៍ និង/ឬផែនការសកម្មភាពទាំងនេះ នឹងទទួលបានការឯកភាពពីក្រុមប្រឹក្សាភិបាល ។ CRP គួរពិនិត្យតាមដានការអនុវត្តអនុសាសន៍ និង/ឬផែនការសកម្មភាពនេះ ។

## ច. ការបង្កើនប្រសិទ្ធភាព

### ១. ការសម្រួលដំណើរការ

១០៥. ដំណើរការនៃយន្តការគណនេយ្យភាពគួរមានភាពសាមញ្ញ និងមានការបញ្ជាក់បានច្បាស់លាស់។ ដំណើរការពិគ្រោះយោបល់ នាពេលបច្ចុប្បន្ននេះ តម្រូវឱ្យអ្នកដាក់ពាក្យបណ្តឹងផ្តល់នូវយោបល់ជាលាយលក្ខណ៍អក្សរលើរបាយ-ការណ៍ពិនិត្យឡើងវិញ និងរបាយការណ៍វាយតម្លៃរបស់ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស (OSPF)។ បទពិសោធន៍កន្លងមកបង្ហាញថា នេះគឺជាដាក់បន្ទុកដល់អ្នកដាក់ពាក្យបណ្តឹង និងធ្វើឱ្យយឺតយ៉ាវដល់ដំណើរការទាំងនេះ ដូច្នេះការផ្តល់យោបល់របស់អ្នកដាក់ពាក្យបណ្តឹងនេះគួរតែជាជម្រើស ទៅតាមការចង់បានរបស់អ្នកដាក់ពាក្យបណ្តឹង។ គេអាចទទួលបានព័ត៌មានត្រលប់របស់អ្នកដាក់ពាក្យបណ្តឹង តាមរយៈមធ្យោបាយដែលលឿន និងកាន់តែងាយស្រួល ដូចជា តាមរយៈកិច្ចប្រជុំ, ការពិភាក្សា និងការនិយាយតាមទូរស័ព្ទ ជាដើម។ ខណៈពេលដែល OSPF គួរផ្តល់ព័ត៌មានដល់ប្រធានធនាគារអំពីពាក្យបណ្តឹង និងលទ្ធផលនានា, លក្ខខណ្ឌបច្ចុប្បន្ន ដែលតម្រូវឱ្យOSPF ធ្វើការពិគ្រោះយោបល់ជាមួយប្រធានធនាគារអំពីជំហាននីតិវិធី គឺមិនចាំបាច់មានឡើយ។

១០៦. ដើម្បីកាត់បន្ថយការធ្វើការងារត្រួតគ្នា, OSPF និង CRP គួរបន្តចែករំលែកព័ត៌មាន និងការវិភាគជាមួយគ្នាទៅវិញទៅមកឱ្យបានពេញលេញ ពាក់ព័ន្ធជាមួយនឹងការស្នើសុំនេះ។ ប៉ុន្តែ OSPF និង CRP នឹងធ្វើការកំណត់ដោយឯករាជ្យពីរបៀបប្រើប្រាស់ព័ត៌មាន និងការវិភាគនេះ។

១០៧. នាយកដ្ឋានប្រតិបត្តិការ និងយន្តការដោះស្រាយការកើតទុក្ខមិនសុខចិត្តនៅថ្នាក់មូលដ្ឋាន គួរមានវិសាលភាពបន្ថែមទៀត សម្រាប់គ្របដណ្តប់លើការដោះស្រាយបញ្ហា។ ក្នុងកំឡុងពេលពិគ្រោះយោបល់ក្នុងប្រទេស កាលពីឆ្នាំ ២០១០ សហគមន៍មូលដ្ឋានបានបង្ហាញពីបំណងប្រាថ្នារបស់ពួកគេ ចង់ឱ្យមានការដោះស្រាយបញ្ហានៅក្នុងមូលដ្ឋានដោយផ្ទាល់ ដើម្បីពន្លឿនដំណើរការ។ ជាការឆ្លុះបញ្ចាំងពីបំណងប្រាថ្នានេះ, OSPF អាចធ្វើប្រតិភូកម្មការដោះស្រាយបញ្ហា ដោយពេញលេញ ឬដោយផ្នែក ទៅឱ្យនាយកដ្ឋានប្រតិបត្តិការដែលពាក់ព័ន្ធ នៅដំណាក់កាលណាក៏បាន ប្រសិនបើការិយាល័យនេះពិចារណាឃើញថា ការធ្វើបែបនេះនឹងបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃការដោះស្រាយបញ្ហា។ អ្នកសម្របសម្រួលគម្រោងពិសេស (SPF) គួរធ្វើការសម្រេចអំពីកម្រិត និងបែបបទនៃការចូលរួមរបស់ខ្លួន ទៅតាមករណីជាក់ស្តែង។ SPF និង CRP គួររិះរកវិធីគ្រប់បែបយ៉ាង ដើម្បីប្រើប្រាស់សមត្ថភាពដោះស្រាយបញ្ហា និងធានាឱ្យមានភាពអនុលោម នៅកម្រិតប្រទេស គម្រោង និងនាយកដ្ឋានប្រតិបត្តិការឱ្យបានពេញលេញ ដើម្បីបង្កើនប្រសិទ្ធភាព និងកាត់បន្ថយចំណាយប្រតិបត្តិការ។

១០៨. SPF និង CRP គួរប្រើប្រាស់ក្របខ័ណ្ឌពេលវេលាសម្រាប់ការពិនិត្យតាមដាន ដែលមានភាពបត់បែនជាមុន និងដែលត្រូវបានរៀបចំឡើងជាពិសេស សម្រាប់គម្រោងនីមួយៗ។ ជាទូទៅ ការពិនិត្យតាមដានរបស់ SPF គួរធ្វើឡើង មិនឱ្យហួសពី ២ ឆ្នាំ ហើយជាទូទៅ ការពិនិត្យតាមដានរបស់ CRP គួរធ្វើឡើងមិនឱ្យហួសពី ៣ ឆ្នាំឡើយ។

## ២. ការបង្កើនប្រសិទ្ធភាពចំណាយ

១០៩. ដោយសារតែយន្តការគណនេយ្យភាពមានលក្ខណៈឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង, ចំណាយរបស់យន្តការគណនេយ្យភាពអាចបែងចែកជា ២ ផ្នែកៈ (i) "ចំណាយថេរ[៣៩]" ដោយមិនគិតពីចំនួនពាក្យបណ្តឹង ដើម្បីរក្សា និងបន្តដំណើរការរបស់យន្តការគណនេយ្យភាព និង (ii) "ចំណាយអថេរ" ទៅតាមតម្រូវការ និងបន្ទុកការងារជាក់ស្តែង។ រចនាសម្ព័ន្ធចម្ងតាសម្រាប់ OSPF និង OCRP អាចមានបុគ្គលិកអន្តរជាតិម្នាក់ និងបុគ្គលិករដ្ឋបាល/ក្នុងស្រុកម្នាក់ បន្ថែមពីលើ SPF និងសមាជិកទាំង ៣ នាក់របស់ CRP។ OSPF បច្ចុប្បន្ននេះ មានបុគ្គលិកអន្តរជាតិម្នាក់ និង បុគ្គលិករដ្ឋបាល/ក្នុងស្រុក ២ នាក់ បន្ថែមលើ SPF។ ដោយឡែក OCRP វិញ មានបុគ្គលិកអន្តរជាតិ ២ នាក់ និង បុគ្គលិករដ្ឋបាល/ក្នុងស្រុក ២ នាក់ បន្ថែមលើសមាជិកទាំង ៣ នាក់របស់ CRP។ គោលនយោបាយឆ្នាំ ២០០៣ បានចែងថា ប្រធានរបស់ CRP ត្រូវ "ធ្វើការងារពេញម៉ោង យ៉ាងហោចណាស់រយៈពេល ១ ឆ្នាំ" ដើម្បីរៀបចំ OCRP, រៀបចំនីតិវិធីប្រតិបត្តិការការងារ និងនីតិវិធីរដ្ឋបាល និងបំពេញការងារដែលពាក់ព័ន្ធដទៃទៀត (កថាខ័ណ្ឌទី ៩៧)។ នៅក្នុងការអនុវត្តជាក់ស្តែង ប្រធានរបស់ CRPបាន និងកំពុងធ្វើការងារពេញម៉ោង ឬក្រៅម៉ោង នៅក្នុងរយៈពេល ៧ ឆ្នាំចុងក្រោយនេះ។ គោលនយោបាយយន្តការគណនេយ្យភាព ដែលកែសម្រួលថ្មីនេះ នឹងនៅតែរក្សាភាពបត់បែននេះ។ មុនពេលមានការតែងតាំងប្រធានរបស់ CRPម្តងៗ, BCRC នឹងពិនិត្យឡើងវិញលើភាពចាំបាច់ សម្រាប់ឱ្យប្រធានរូបនេះធ្វើការងារពេញម៉ោង ឬក្រៅម៉ោង ហើយបន្ទាប់មក ផ្តល់ជាអនុសាសន៍ទៅឱ្យក្រុមប្រឹក្សាភិបាល។

## ឆ. ការបង្កើនការយល់ដឹង និងលើកកម្ពស់ការរៀនសូត្រ

១១០. ការបង្កើនការយល់ដឹង គឺជាកត្តាសំខាន់មួយ នៅក្នុងការបង្កើនប្រសិទ្ធភាពរបស់យន្តការគណនេយ្យភាព។ យុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានរួមគ្នារបស់ OSPF និង OCRP គួរគាំទ្រដល់សកម្មភាព ៣ ប្រភេទផ្សេងៗគ្នាៈ ទីមួយ

---

[៣៩] ពាក្យថាចំណាយថេរ នៅក្នុងឯកសារនេះ សំដៅលើធនធាន ដែលត្រូវមាន ដើម្បីគាំទ្រដល់រចនាសម្ព័ន្ធជាមូលដ្ឋានរបស់យន្តការគណនេយ្យ-ភាព ដោយមិនគិតពីចំនួនសំណើ។ នេះរួមមានចំនួនបុគ្គលិក, ការិយាល័យ និងមធ្យោបាយរូបវិន្តដទៃទៀត ដើម្បីរក្សា និងដំណើរការយន្តការគណនេយ្យភាព។ ចំណាយអថេរ គឺពាក់ព័ន្ធជាមួយនឹងធនធាន ដែលត្រូវមាន ដើម្បីធ្វើការឆ្លើយតបចំពោះតម្រូវការដែលឡើងចុះ ដែលអាចបំពេញបាន ឧទាហរណ៍ ដោយជួលទីប្រឹក្សា និងបុគ្គលិកកិច្ចសន្យា ជាដើម។

បង្កើនការយល់ដឹងរបស់បុគ្គលិកធនាគារអភិវឌ្ឍន៍អាស៊ី, ទីពីរ ធ្វើការផ្សព្វផ្សាយព័ត៌មានដល់ក្រុមការងារគម្រោងរបស់រដ្ឋាភិបាល, ទីបី ធ្វើការងារជាមួយបុគ្គលិករបស់ការិយាល័យតំណាងប្រចាំប្រទេស និងអនុវត្តកម្មវិធីផ្សព្វផ្សាយព័ត៌មានឱ្យបានទៀងទាត់ នៅតាមប្រទេសកំពុងអភិវឌ្ឍជាសមាជិក ដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល។ ការិយាល័យតំណាងប្រចាំប្រទេស នីមួយៗគួរមានមន្ត្រីបង្គោលផ្នែកដោះស្រាយការកើតទុក្ខមិនសុខចិត្តម្នាក់ អាចធ្វើការក្រៅម៉ោង ឬពេញម៉ោង ដើម្បីធ្វើការងារជាមួយនឹងក្រុមការងារគម្រោង ក្នុងការដោះស្រាយការកើតទុក្ខមិនសុខចិត្ត និងការផ្សព្វផ្សាយព័ត៌មានអំពីយន្តការគណនេយ្យភាព។ យន្តការគណនេយ្យភាពនេះគួរត្រូវបានគេចាត់ទុកថាជាឧបករណ៍មួយសម្រាប់ការរៀនសូត្រ និងធានាប្រសិទ្ធភាពនៃការអភិវឌ្ឍ ជាជាងជាយន្តការសម្រាប់ចាប់កំហុស។ បុគ្គលិកប្រតិបត្តិការ គួរជាច្រកដ៏សំខាន់មួយ សម្រាប់ការផ្សព្វផ្សាយព័ត៌មានអំពីយន្តការគណនេយ្យភាពនេះ។

១១១. យន្តការគណនេយ្យភាពគួរកែសម្រួលពាក្យពេចន៍មួយចំនួន ដើម្បីសម្រួច និងបញ្ជាក់ឱ្យបានច្បាស់អំពីសាររបស់យន្តការគណនេយ្យភាព។ ទីមួយ "ដំណាក់កាលពិគ្រោះយោបល់" គួរដាក់ឈ្មោះថា "មុខងារដោះស្រាយបញ្ហា" វិញ។ មូលហេតុ ដែលគោលនយោបាយឆ្នាំ ២០០៣ ដាក់ថា "ពិគ្រោះយោបល់" គឺដោយសារតែការបារម្ភថា ការប្រើពាក្យ "ដោះស្រាយបញ្ហា" អាចធ្វើឱ្យមានការរំពឹងថា គ្រប់បញ្ហាទាំងអស់នឹងត្រូវបានដោះស្រាយដោយ OSPF។ ប៉ុន្តែការពិគ្រោះយោបល់ ដែលធ្វើឡើងជាផ្នែកមួយនៃការពិនិត្យឡើងវិញនេះ បង្ហាញថា ពុំមានហានិភ័យគួរឱ្យកត់សម្គាល់ពាក់ព័ន្ធជាមួយនឹងការប្រើប្រាស់ពាក្យនេះឡើយ។ ការប្រើពាក្យ "ដោះស្រាយបញ្ហា" នឹងអាចឆ្លុះបញ្ចាំងកាន់តែសុក្រឹតអំពីលក្ខណៈ និងគោលដៅរបស់មុខងារនេះ។ ទីពីរ គោលនយោបាយឆ្នាំ ២០០៣ ចាត់ទុកករណី ដែលទទួលដោយ OSPF ថាជា "ពាក្យបណ្តឹង" ខណៈពេលដែលករណី ដែលទទួលដោយ CRP ថាជា "ការស្នើសុំ" ហើយអ្នកដែលស្នើសុំឱ្យមានដំណើរការទាំងនេះ ត្រូវបានគេហៅថា "អ្នកស្នើសុំ"។ ទីបី ដោយសារតែអ្នកស្នើសុំមានជម្រើសស្នើសុំឱ្យមានការដោះស្រាយបញ្ហា ឬការពិនិត្យឡើងវិញលើភាពអនុលោម, ពាក្យ "ដំណាក់កាល" អាចមានន័យថា គោលវិធីជាដំណាក់-កាលៗនឹងត្រូវគេប្រើជំនួសពាក្យ "មុខងារ"។

១១២. គ្រប់ការស្នើសុំទាំងអស់ ដែលទទួលដោយ SPF និង CRP គួរមានការតាមដានឱ្យដឹង ដើម្បីលើកកម្ពស់ការរៀនសូត្រ។ ការតាមដានបែបនេះគួរបន្តធ្វើចំពោះការស្នើសុំទាំងឡាយ ដែលត្រូវបានបញ្ជូនមកកាន់នាយកដ្ឋានប្រតិបត្តិការ។ ការធ្វើបែបនេះផ្តល់នូវប្រភពព័ត៌មានដ៏សម្បូរបែប សម្រាប់វិភាគពីនិន្នាការ, ទម្រង់, ភាពញឹកញាប់ និងលក្ខណៈរបស់បញ្ហា។ ព័ត៌មានស៊ីជម្រៅ ដែលទទួលបានពីការវិភាគនេះ នឹងមានប្រយោជន៍សម្រាប់បណ្តុះបណ្តាល និងបង្កើនការយល់ដឹងរបស់ក្រុមការងារគម្រោងអំពីទីកន្លែង ដែលមានចំនួនការស្នើសុំច្រើនជាងគេ។

១១៣. OSPF និង OCRP គួរចែករំលែកមេរៀន ដែលទទួលបានពីការងាររបស់ខ្លួនឱ្យបានសកម្ម។ និន្នាការ និង មេរៀនដូចៗគ្នា ដែលទទួលបានពីយន្តការគណនេយ្យភាព នឹងធ្វើឱ្យងាយស្រួលយល់អំពីការរៀបចំ និងអនុវត្តគម្រោង។ បច្ចុប្បន្ននេះ OSPF និង OCRP ផលិតរបាយការណ៍ប្រចាំឆ្នាំរៀងៗខ្លួន។ ដើម្បីបង្កើនការសហការគ្នា គួរមានការ បង្កើតរបាយការណ៍ប្រចាំឆ្នាំរបស់យន្តការគណនេយ្យភាពរួម ដែលផ្តល់នូវការវិភាគតាមបែបជាប្រព័ន្ធ លើការស្នើសុំ ដែលទទួលបានជារៀងរាល់ឆ្នាំ។ របាយការណ៍ប្រចាំឆ្នាំរបស់យន្តការគណនេយ្យភាពគួរដាក់បញ្ចូលផងដែរនូវគំនិត យោបល់របស់នាយកដ្ឋានវាយតម្លៃឯករាជ្យ (IED) និងនាយកដ្ឋានអភិវឌ្ឍន៍តំបន់ (RSDD) ប្រកបដោយនិរន្តរភាព (ប្រធានផ្នែកធានាភាពអនុលោម) អំពីបញ្ហាដែលពាក់ព័ន្ធនឹងយន្តការគណនេយ្យភាព។ កិច្ចខិតខំប្រឹងប្រែងសហការគ្នា រវាងនាយកដ្ឋាននានា នៅក្នុងការប្រើប្រាស់មេរៀន និងគំនិតយោបល់ដែលទទួលបាន នឹងធ្វើឱ្យយន្តការគណនេយ្យភាព នេះកាន់តែមានភាពសម្បូរបែប និងផ្តល់នូវការណែនាំដល់បុគ្គលិក នៅក្នុងការរៀបចំគម្រោងថ្មី ដែលមានលក្ខណៈ ស្រដៀងគ្នានេះ។

១១៤. អន្តរកម្ម (ទំនាក់ទំនង) រវាងយន្តការគណនេយ្យភាព, ក្រុមប្រឹក្សាភិបាល, គណៈគ្រប់គ្រង និងបុគ្គលិក នឹង ពន្លឿនការអនុវត្តមេរៀន ដែលទទួលបាន។ OSPF និង OCRP គួររៀបចំឱ្យមានជាកិច្ចប្រជុំជាទៀងទាត់ ដើម្បីផ្តល់ ព័ត៌មានសង្ខេបដល់ BCRC (ឧទាហរណ៍ រៀងរាល់ត្រីមាស)។ កិច្ចប្រជុំមួយ ក្នុងចំណោមកិច្ចប្រជុំទាំងនេះ អាចដាក់ បញ្ចូលទៅក្នុងកិច្ចប្រជុំផ្សព្វផ្សាយព័ត៌មានអំពីរបាយការណ៍ប្រចាំឆ្នាំរបស់យន្តការគណនេយ្យភាព ដែលត្រូវបានរៀបចំ ឡើងដោយ OSPF, OCRP, IED, និង RSDD។ OSPF, OCRP, IED, និង RSDD ក៏គួរបង្ហាញ របាយការណ៍ប្រចាំឆ្នាំអំពីយន្តការគណនេយ្យភាពដល់គណៈគ្រប់គ្រងផងដែរ។ OSPF និង OCRP គួររៀបចំការ បណ្តុះបណ្តាល និងសិក្ខាសាលាសម្រាប់បុគ្គលិក។ គេហទំព័ររបស់ OSPF និង OCRP គួរធ្វើសមាហរណកម្មបញ្ចូលគ្នា ឱ្យកាន់តែប្រសើរឡើង ក្រោមក្របខ័ណ្ឌយន្តការគណនេយ្យភាពរួម។ អន្តរកម្មទាំងនេះនឹងផ្តល់ប្រយោជន៍ឱ្យធនាគារ អភិវឌ្ឍន៍អាស៊ី ដើម្បីបញ្ចៀសមិនឱ្យបញ្ហាដដែលៗកើតមានឡើងម្តងទៀត និងសម្រួលឱ្យមានការផ្លាស់ប្តូរវប្បធម៌ ដើម្បីប្រើប្រាស់ និងចាត់ទុកយន្តការគណនេយ្យភាពនេះ ថាជាឧបករណ៍វិជ្ជមានសម្រាប់ចែករំលែកមេរៀន ដែលទទួល បាន។

## VI. គោលនយោបាយយន្តការគណនេយ្យភាព ដែលត្រូវបានកែសម្រួលឡើងវិញរួច

១១៥. ផ្នែកនេះបង្ហាញពីគោលនយោបាយយន្តការគណនេយ្យភាព ដែលបានស្នើឡើង។ ផ្នែកនេះប្រើប្រាស់គោល-នយោបាយឆ្នាំ ២០០៣ ធ្វើជាមូលដ្ឋាន និងដាក់បញ្ចូលអនុសាសន៍ ដែលបានលើកឡើងនៅក្នុងផ្នែកទី V និងការផ្លាស់ប្តូរដទៃទៀត។

### ក. គោលដៅ និងគោលការណ៍ណែនាំ

១១៦. យន្តការគណនេយ្យភាពមានគោលដៅ បង្កើតនូវវេទិកាឯករាជ្យ និងប្រកបដោយប្រសិទ្ធភាពមួយ សម្រាប់ឱ្យអ្នកដែលរងផលប៉ះពាល់ជាអវិជ្ជមាន ដោយសារគម្រោង ដែលទទួលបានជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី បង្ហាញពីការព្រួយបារម្ភរបស់ពួកគេ និងស្វែងរកដំណោះស្រាយចំពោះបញ្ហារបស់ពួកគេ ក៏ដូចជាស្នើសុំឱ្យមានការពិនិត្យឡើងវិញលើការចោទប្រកាន់អំពីភាពមិនអនុលោម ជាមួយនឹងគោលនយោបាយ និងនីតិវិធីប្រតិបត្តិការការងាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលបង្កឱ្យមានផលប៉ះពាល់ដោយផ្ទាល់ និងគួរឱ្យកត់សម្គាល់មកលើពួកគេ។

១១៧. យន្តការគណនេយ្យភាពនេះត្រូវបានរៀបចំឡើង ដើម្បី (i) បង្កើនប្រសិទ្ធភាពអភិវឌ្ឍន៍ និងគុណភាពគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី, (ii) ឆ្លើយតបចំពោះការព្រួយបារម្ភរបស់អ្នកដែលរងផលប៉ះពាល់ដោយសារគម្រោង និងផ្តល់យុត្តិធម៌សម្រាប់គ្រប់អ្នកពាក់ព័ន្ធទាំងអស់, (iii) ឆ្លុះបញ្ចាំងពីស្តង់ដារវិជ្ជាជីវៈ និងបច្ចេកទេសក្នុងកម្រិតខ្ពស់បំផុត នៅក្នុងការចាត់ចែងបុគ្គលិក និងប្រតិបត្តិការការងាររបស់ធនាគារ, (iv) សម្រេចឱ្យបាននូវឯករាជ្យភាព និងតម្លាភាពខ្ពស់បំផុត តាមដែលអាចធ្វើទៅបាន និង (v) មានប្រសិទ្ធភាពផ្នែកចំណាយ, មានប្រសិទ្ធភាពទូទៅ និងជាការបំពេញបន្ថែមលើប្រព័ន្ធត្រួតពិនិត្យ, សវនកម្ម, ត្រួតពិនិត្យគុណភាព និងវាយតម្លៃ ដែលមានស្រាប់ នៅក្នុងធនាគារអភិវឌ្ឍន៍អាស៊ី។

### ខ. រចនាសម្ព័ន្ធ

១១៨. បទពិសោធន៍ចាប់តាំងពីឆ្នាំ ២០០៣ មក បង្ហាញយ៉ាងច្បាស់លាស់ពីភាពចាំបាច់ ដើម្បីធ្វើការកំណត់ឱ្យបានច្បាស់លាស់នូវព្រំដែនរវាងមុខងារដោះស្រាយបញ្ហា និងពិនិត្យឡើងវិញលើភាពអនុលោម។ យន្តការគណនេយ្យភាពដែលត្រូវបានកែសម្រួលរួចនេះ នឹងបន្តមុខងារទាំងពីរនេះនេះទៀត ពោលគឺ (i) មុខងារដោះស្រាយដោះស្រាយបញ្ហាក្រោមការដឹកនាំរបស់ SPF ដែលនឹងធ្វើការឆ្លើយតបចំពោះបញ្ហាជាក់លាក់របស់ប្រជាពលរដ្ឋមូលដ្ឋាន ដែលរងផល-ប៉ះពាល់ ដោយសារគម្រោងដែលទទួលបានជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី ដោយប្រើប្រាស់វិធីសាស្ត្រក្រៅផ្លូវការ និង

បត់បែនជាច្រើន និង (ii) មុខងារពិនិត្យឡើងវិញលើភាពអនុលោម ដែលធ្វើឡើងដោយ CRP ធ្វើការស៊ើបអង្កេតលើការចោទប្រកាន់អំពីភាពមិនអនុលោមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ទៅតាមគោលនយោបាយ និងនីតិវិធីប្រតិបត្តិ-ការការងាររបស់ខ្លួន ដែលបង្ក ឬទំនងជាបង្កឱ្យមានផលប៉ះពាល់ដោយផ្ទាល់ និងគួរឱ្យកត់សម្គាល់ ដល់អ្នកដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង។

១១៩. ដើម្បីរក្សាមុខងារដោះស្រាយបញ្ហា និងពិនិត្យឡើងវិញលើភាពអនុលោម និងដើម្បីផ្តល់នូវភាពងាយស្រួលដល់ការប្រើប្រាស់ចំណុចផ្តើមតែមួយសម្រាប់អ្នកដែលរងផលប៉ះពាល់ដោយសារគម្រោង, រចនាសម្ព័ន្ធជាមូលដ្ឋាន ដែលមានមុខងារពីរនេះ នឹងទទួលបានការបំពេញបន្ថែមដោយមន្ត្រីទទួលពាក្យបណ្តឹង ដែលជាអ្នកទទួលគ្រប់សំណើទាំងអស់ ហើយបន្ទាប់មកបញ្ជូនសំណើទាំងនោះ ទៅកាន់ OSPF, CRP, នាយកដ្ឋានប្រតិបត្តិការ ឬនាយកដ្ឋាន និងការិយាល័យដទៃទៀត ទៅតាមការចង់បានរបស់អ្នកស្នើសុំ និងលក្ខណៈរបស់បញ្ហា។ មន្ត្រីទទួលពាក្យបណ្តឹងត្រូវចម្លងព័ត៌មាននេះទៅឱ្យគ្រប់នាយកដ្ឋាន និងការិយាល័យពាក់ព័ន្ធទាំងអស់។

## គ. ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ

១២០. ការវាយតម្លៃលើយន្តការគណនេយ្យភាពបង្ហាញឱ្យឃើញពីភាពចាំបាច់ ដើម្បីបែងចែកចំណាយថេរសម្រាប់គាំទ្រដល់ប្រតិបត្តិការការងារជាមូលដ្ឋានរបស់យន្តការគណនេយ្យភាព ចេញពីចំណាយអថេរ ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងបន្ទុកការងារ។ ការបែងចែកធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ សម្រាប់យន្តការគណនេយ្យភាពនេះ នឹងឆ្លុះបញ្ចាំងពីការពិចារណា ដើម្បីធានាឱ្យមានប្រសិទ្ធភាព នៅក្នុងការប្រើប្រាស់ធនធាន និងផ្តល់នូវការឆ្លើយតប ពោះអ្នកដែលរងផលប៉ះពាល់ ដោយសារគម្រោង។

### ១. មុខងារដោះស្រាយបញ្ហា

១២១. OSPF គឺជាការិយាល័យមួយ ដែលដឹកនាំដោយអ្នកសម្របសម្រួលគម្រោងពិសេស (SPF)។ រចនាសម្ព័ន្ធជាមូលដ្ឋានរបស់ OSPF រួមមាន SPF, បុគ្គលិកអន្តរជាតិម្នាក់ និងបុគ្គលិករដ្ឋបាល/ក្នុងស្រុក ២ នាក់។ SPF គឺជាអ្នកទទួលបានការតែងតាំងពិសេស មានឋានៈស្មើនឹងអគ្គនាយក និងត្រូវបានតែងតាំងដោយប្រធានធនាគារ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាភិបាលរួចមក។ SPF រាយការណ៍ដោយផ្ទាល់ទៅកាន់ប្រធានធនាគារ។ ប្រសិនបើចាំបាច់ ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុបន្ថែម នឹងទទួលបានការអនុម័តតាមរយៈកម្មវិធីការងារ និងដំណើរការក្របខ័ណ្ឌថវិកា។ នាយកដ្ឋានថវិកា, ផែនការ និងប្រព័ន្ធគ្រប់គ្រង (BPMSD) នឹងចាត់ចែងដំណើរការរដ្ឋបាល ទៅតាម

គោលការណ៍ណែនាំរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ OSPF អាចជួលអ្នកជំនាញបច្ចេកទេស ធ្វើជាទីប្រឹក្សា ទៅតាម *គោលការណ៍ណែនាំអំពីការប្រើប្រាស់ទីប្រឹក្សា* របស់ធនាគារអភិវឌ្ឍន៍អាស៊ី និងការរៀបចំដទៃទៀត ដែលធនាគារអភិវឌ្ឍន៍អាស៊ីពេញចិត្ត ដើម្បីជួយធ្វើការងារឱ្យ OSPF ដូចជា សកម្មភាពពិនិត្យតាមដាន ជាដើម។

១២២. លក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើសអ្នកសម្របសម្រួលគម្រោងពិសេស រួមមាន (i) សមត្ថភាពធ្វើការងារយ៉ាងហ្មត់ចត់ និងផ្តល់យុត្តិធម៌ដល់សំណើនានា, (ii) មានសុច្ចរិតភាព និងឯករាជ្យភាពពីនាយកដ្ឋានប្រតិបត្តិការ, (iii) មានបទពិសោធន៍ជាមួយការងារអភិវឌ្ឍន៍ និងមានចំណេះដឹងពីជីវភាពរស់នៅ នៅក្នុងប្រទេសកំពុងអភិវឌ្ឍ និង (iv) មានចំណេះដឹង និងបទពិសោធន៍អំពីប្រតិបត្តិការការងាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ឬស្ថាប័នប្រហាក់ប្រហែល និង/ឬមានបទពិសោធន៍ជាមួយវិស័យឯកជន។ អណត្តិរបស់ SPF មានរយៈពេល ៣ ឆ្នាំ អាចបន្តទៀតបាន។ SPF មិនត្រូវធ្វើការងារ នៅក្នុងនាយកដ្ឋានប្រតិបត្តិការណាឱ្យបានយ៉ាងហោចណាស់រយៈពេល ៥ ឆ្នាំ មុនពេលទទួលការតែងតាំង។ SPF ត្រូវបង្ហាញព័ត៌មានដល់គ្រប់អ្នកពាក់ព័ន្ធទាំងអស់ភ្លាម បន្ទាប់ពីដឹងថាខ្លួនមានផលប្រយោជន៍ផ្ទាល់ខ្លួន ឬការពាក់ព័ន្ធពីមុន នៅក្នុងការងារនេះ។ នៅក្នុងការបំពេញមុខងាររបស់ខ្លួន, SPF នឹងអាចជួបជាមួយបុគ្គលិកទាំងអស់ និងគណៈគ្រប់គ្រងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងអាចប្រើប្រាស់គ្រប់ឯកសារទាំងអស់របស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែល SPF ចាត់ទុកថាមានភាពពាក់ព័ន្ធ លើកលែងតែព័ត៌មានផ្ទាល់ខ្លួន ដែលជាធម្មតាត្រូវបានហាមឃាត់មិនឱ្យមើល។

១២៣. ការបំពេញការងាររបស់ SPF នឹងត្រូវវាយតម្លៃ ដោយប្រធានធនាគារ។ ការរៀបចំផែនការការងារ និងការរៀបចំថវិការបស់ OSPF គឺធ្វើដូចគ្នានឹងនាយកដ្ឋានដទៃទៀតរបស់ធនាគារអភិវឌ្ឍន៍អាស៊ីដែរ។ នឹងមានភាពបត់បែនគ្រប់គ្រាន់ នៅក្នុងផែនការការងារ និងថវិកា ដើម្បីបំពេញទៅតាមលក្ខណៈឆ្លើយតបទៅតាមតម្រូវការជាក់ស្តែងនៃការងាររបស់ OSPF។

## ២. មុខងារពិនិត្យឡើងវិញលើភាពអនុលោម

១២៤. **គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម (CRP)** – CRP នឹងមានសមាជិកចំនួន ៣ នាក់ ដែលក្នុងនោះមានម្នាក់គឺជាប្រធាន។ សមាជិករបស់ CRP នឹងត្រូវបានតែងតាំងដោយក្រុមប្រឹក្សាភិបាល (BCRC) បន្ទាប់ពីបានទទួលអនុសាសន៍ពីគណៈកម្មាធិការពិនិត្យឡើងវិញលើភាពអនុលោមរបស់ក្រុមប្រឹក្សាភិបាល និងធ្វើការពិគ្រោះយោបល់ជាមួយប្រធានធនាគាររួចមក។ ដំណើរការស្វែងរក និងជ្រើសរើស នឹងធ្វើឡើងក្រោមការដឹកនាំរបស់ BCRC និងអាចតម្រូវឱ្យមានការប្រើប្រាស់ក្រុមហ៊ុនស្វែងរកខាងក្រៅ ប្រសិនបើ BCRC យល់ថាចាំបាច់។

១២៥. សមាជិកម្នាក់ៗរបស់គណៈកម្មការ នឹងមានអណត្តិរយៈពេល ៥ ឆ្នាំ មិនអាចបន្តទៀតបាន។ សមាជិក ២ នាក់របស់គណៈកម្មការនេះ មានប្រភពពីប្រទេសនៅក្នុងតំបន់ ដោយយ៉ាងហោចណាស់ត្រូវមានម្នាក់មកពីប្រទេសកំពុងអភិវឌ្ឍជាសមាជិក។ សមាជិកទី ៣ របស់គណៈកម្មការនេះ គឺមកពីប្រទេសក្រៅតំបន់នេះ។ លក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើសសមាជិករបស់គណៈកម្មការនេះ រួមមាន (i) សមត្ថភាពធ្វើការងារយ៉ាងហ្មត់ចត់ និងផ្តល់យុត្តិធម៌ ដល់សំណើនានា ដែលដាក់មកឱ្យពួកគេ, (ii) មានសុច្ចរិតភាព និងឯករាជ្យភាពពីគណៈគ្រប់គ្រង, (iii) មានបទពិសោធន៍ជាមួយការងារអភិវឌ្ឍន៍ និងមានចំណេះដឹងពីជីវភាពរស់នៅ នៅក្នុងប្រទេសកំពុងអភិវឌ្ឍ និង (iv) មានចំណេះដឹង និងបទ-ពិសោធន៍អំពីប្រតិបត្តិការការងាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ឬស្ថាប័នប្រហាក់ប្រហែល និង/ឬមានបទពិសោធន៍ជាមួយវិស័យឯកជន។ ប្រធាន, ប្រធានបម្រុង, ទីប្រឹក្សារបស់ប្រធាន, គណៈគ្រប់គ្រង, បុគ្គលិក និងទីប្រឹក្សា ពុំមានលក្ខណៈសមស្រប ដើម្បីធ្វើជាសមាជិករបស់ CRP ឡើយ រហូតដល់យ៉ាងហោចណាស់រយៈពេល ៣ ឆ្នាំ ក្រោយពេលដែលពួកគេបានបំពេញការងារជាមួយធនាគារអភិវឌ្ឍន៍អាស៊ីលើកចុងក្រោយ។ សមាជិករបស់គណៈកម្មការអាចត្រូវបានដកចេញ តាមរបៀបដូចគ្នានឹងការតែងតាំងដែរ ពោលគឺដោយសារធ្វើការងារពុំមានប្រសិទ្ធភាព ឬប្រព្រឹត្តទង្វើមិនត្រឹមត្រូវ។ សមាជិករបស់គណៈកម្មការនឹងពុំអាចចូលរួមនៅការពិនិត្យឡើងវិញលើភាពអនុលោមបានឡើយ ប្រសិនបើគាត់មានប្រយោជន៍ផ្ទាល់ខ្លួន ឬធ្លាប់មានការពាក់ព័ន្ធពីមុនមក។

១២៦. CRP ត្រូវរាយការណ៍ទៅកាន់ក្រុមប្រឹក្សាភិបាល តាមរយៈ BCRC លើកលែងតែអំពីសកម្មភាពជាក់លាក់ដែល CRP ត្រូវរាយការណ៍ទៅកាន់ BCRC។ សមាជិក CRP ត្រូវបានលើកលែងចេញពីដំណើរការពិនិត្យឡើងវិញលើការបំពេញការងារប្រចាំឆ្នាំ។ ប៉ុន្តែ ប្រធាន BCRC ដោយមានការពិគ្រោះយោបល់ជាមួយសមាជិកផ្សេងទៀតរបស់ BCRC នឹងផ្តល់នូវព័ត៌មានត្រលប់ប្រចាំឆ្នាំជាលាយលក្ខណ៍អក្សរអំពីការបំពេញការងាររបស់សមាជិក CRP។ ព័ត៌មានត្រលប់របស់ប្រធាន CRP នឹងត្រូវបានយកមកធ្វើការពិចារណា នៅពេលផ្តល់ព័ត៌មានត្រលប់អំពីសមាជិករបស់ CRP ២ នាក់ទៀត។

១២៧. មុនពេលមានការតែងតាំងប្រធាន CRP ថ្មី, BCRC នឹងពិនិត្យឡើងវិញលើភាពចាំបាច់ ថាតើប្រធានថ្មីនេះត្រូវធ្វើការពេញម៉ោង ឬក្រៅម៉ោង ហើយផ្តល់ជាអនុសាសន៍ទៅឱ្យក្រុមប្រឹក្សាភិបាល ដើម្បីសុំការឯកភាព។ ប្រសិនបើត្រូវធ្វើការងារពេញម៉ោង, បៀវត្សរបស់ប្រធាន CRP នឹងត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល បន្ទាប់ពីបានទទួលអនុសាសន៍របស់ BCRC ដោយមានការពិគ្រោះយោបល់ជាមួយប្រធានធនាគាររួចមក។ កំណើនបៀវត្សប្រចាំឆ្នាំរបស់ប្រធាន CRP គឺស្មើនឹងកំណើនបៀវត្សគិតជាមធ្យមសម្រាប់អនុប្រធានធនាគារ។ ប្រសិនបើត្រូវធ្វើការងារ

ក្រៅម៉ោង សមាជិករបស់ CRP នឹងទទួលបានបៀវត្សប្រហាក់ប្រហែលនឹងយន្តការគណនេយ្យភាពដទៃទៀត ហើយនឹងមានការទូទាត់សម្រាប់ចំណាយរបស់ពួកគេ ។

១២៨. នៅក្នុងការបំពេញមុខងាររបស់ខ្លួន, CRP នឹងអាចជួបជាមួយបុគ្គលិក និងគណៈគ្រប់គ្រងទាំងអស់របស់ធនាគារអភិវឌ្ឍន៍អាស៊ី និងអាចប្រើប្រាស់ឯកសារទាំងអស់របស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែល CRP ចាត់ទុកថាមានភាពពាក់ព័ន្ធ លើកលែងតែព័ត៌មានផ្ទាល់ ដែលជាធម្មតា ត្រូវបានហាមឃាត់មិនឱ្យមើល ។

១២៩. ការិយាល័យរបស់គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម (OCRP) - OCRP នឹងផ្តល់ការគាំទ្រដល់ CRP ។ OCRP នឹងដឹកនាំដោយដោយប្រធាន CRP ។ រចនាសម្ព័ន្ធជាមូលដ្ឋានរបស់ OCRP រួមមាន មន្ត្រីវិជ្ជាជីវៈម្នាក់ដែលបំពេញការងារជាលេខាធិការ និងបុគ្គលិករដ្ឋបាល/ក្នុងស្រុក ២ នាក់។ ប្រធាន CRP ដោយមានការពិគ្រោះ-យោបល់ជាមួយសមាជិក CRP ដទៃទៀត អាចស្នើសុំធនធានមនុស្ស និង/ឬធនធានហិរញ្ញវត្ថុបន្ថែមទៀត នៅក្នុងករណីចាំបាច់ ។ ធនធានបន្ថែមទាំងនេះនឹងទទួលបានការគាំទ្រពី BCRC ដោយមានការពិគ្រោះយោបល់ជាមួយប្រធានធនាគារ និងមានការឯកភាពពីក្រុមប្រឹក្សាភិបាល ។ លេខាធិការរបស់ OCRP ត្រូវតែងតាំងដោយប្រធានធនាគារ ហើយត្រូវរាយការណ៍ទៅកាន់ប្រធាន CRP ។ នាយកដ្ឋានថវិកា, ផែនការ និងប្រព័ន្ធគ្រប់គ្រង (BPMSD) នឹងចាត់ចែងដំណើរការរដ្ឋបាល ពាក់ព័ន្ធជាមួយនឹងបុគ្គលិករបស់ OCRP ទៅតាមគោលការណ៍ណែនាំរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។

១៣០. បុគ្គលិករបស់ OCRP គឺជាបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី ហើយលក្ខខណ្ឌការងាររបស់ពួកគេ គឺដូចគ្នានឹងបុគ្គលិកផ្សេងទៀតរបស់ធនាគារអភិវឌ្ឍន៍អាស៊ីដែរ ដូចដែលបានកំណត់នៅក្នុងវិធានបុគ្គលិក និងបទបញ្ជារដ្ឋបាលរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។ គោលការណ៍នៃការមិនហាមឃាត់បុគ្គលិក OCRP ពីការផ្ទេរទៅ និងមកពីផ្នែកដទៃទៀតរបស់ធនាគារអភិវឌ្ឍន៍អាស៊ី គឺដោយសារតែសារៈសំខាន់នៃការរក្សាតុល្យភាពរវាងអ្នកខាងក្នុង និងអ្នកខាងក្រៅ ។ ដូចដែលបានបង្ហាញ តាមរយៈបទពិសោធន៍របស់នាយកដ្ឋានវាយតម្លៃឯករាជ្យ, ភាពបត់បែននៃការចល័តបុគ្គលិកនេះគួរជួយការពារមិនឱ្យមានការចាត់ទុក CRP ថាជាយន្តការដោយឡែកពីគេ និងធ្វើឱ្យការពិនិត្យឡើងវិញលើភាពអនុលោម និងប្រតិបត្តិការការងារ ទទួលបាននូវចំណេះដឹង និងបទពិសោធន៍ដ៏សម្បូរបែបពីបុគ្គលិករបស់ធនាគារ ។

១៣១. ប្រធាន CRP ទទួលខុសត្រូវលើការរៀបចំកម្មវិធីការងារ និងថវិកាប្រចាំឆ្នាំរបស់ CRP និង OCRP បញ្ចូលគ្នា ។ កម្មវិធីការងារ និងថវិកាប្រចាំឆ្នាំ នឹងទទួលបានការគាំទ្រពី BCRC ដោយមានការពិគ្រោះយោបល់ជាមួយប្រធានធនាគារ និងពិនិត្យឡើងវិញដោយគណៈកម្មាធិការពិនិត្យឡើងវិញលើថវិការបស់ក្រុមប្រឹក្សាភិបាល ។ បន្ទាប់មក សំណើ

ថវិកានឹងត្រូវបង្ហាញទៅកាន់ក្រុមប្រឹក្សា ដើម្បីសុំការឯកភាព ដោយឡែកពីថវិការដ្ឋបាលរួមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។ ចាំបាច់ត្រូវធានាឱ្យមានភាពបត់បែនគ្រប់គ្រាន់ នៅក្នុងកម្មវិធីការងារ និងការរៀបចំថវិកា ដើម្បីសម្របទៅតាមលក្ខណៈឆ្លើយតបទៅនឹងតម្រូវការនៃការងាររបស់ CRP និង OCRP ។ CRP អាចជួលអ្នកជំនាញបច្ចេកទេសឱ្យធ្វើជាទីប្រឹក្សា ស្របទៅតាម*គោលការណ៍ណែនាំអំពីការប្រើប្រាស់ទីប្រឹក្សា* របស់ធនាគារអភិវឌ្ឍន៍អាស៊ី និងការរៀបចំផ្សេងទៀត ដែលធនាគារអភិវឌ្ឍន៍អាស៊ីពេញចិត្ត ដើម្បីដល់ការងាររបស់ខ្លួន ដូចជា ការពិនិត្យតាមដានក្រោយមានការពិនិត្យឡើងវិញលើភាពអនុលោមជាដើម ។

១៣២. **គណៈកម្មាធិការពិនិត្យឡើងវិញលើភាពអនុលោមរបស់ក្រុមប្រឹក្សាភិបាល (BCRC)-** BCRC មានសមាជិករបស់ក្រុមប្រឹក្សាភិបាលចំនួន ៦ នាក់ ក្នុងនោះមានសមាជិកក្រុមប្រឹក្សាភិបាលក្នុងតំបន់ចំនួន ៤ នាក់ (យ៉ាងហោចណាស់មាន ៣ នាក់ ត្រូវមកពីប្រទេសខ្ចីកម្ចី) និងសមាជិកក្រុមប្រឹក្សាក្រៅតំបន់ ២ នាក់ ។ សមាជិករបស់ BCRC នឹងត្រូវបានតែងតាំង ទៅតាមវិធាន និងនីតិវិធីរបស់ក្រុមប្រឹក្សាភិបាល ។ ការិយាល័យលេខាធិការនឹងផ្តល់ការគាំទ្រលេខាធិការដល់ BCRC ។

### ៣. ដំបូន្មានច្បាប់

១៣៣. ការិយាល័យអគ្គមេធាវី ទទួលខុសត្រូវផ្តល់ដំបូន្មានដល់ OSPF, OCRP, CRP និង BCRC ពាក់ព័ន្ធជាមួយនឹងស្ថានភាពច្បាប់, សិទ្ធិ និងកាតព្វកិច្ចរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ក្រោមធម្មនុញ្ញរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងកិច្ចព្រមព្រៀងនានា ដែលធនាគារអភិវឌ្ឍន៍អាស៊ីគឺជាភាគី និងលើបញ្ហាផ្សេងទៀត ពាក់ព័ន្ធជាមួយសិទ្ធិ និងកាតព្វកិច្ចរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ទាក់ទិនទៅនឹងសំណើសុំឱ្យមានការដោះស្រាយបញ្ហា ឬការពិនិត្យឡើងវិញលើភាពអនុលោម នៅក្រោមគោលនយោបាយនេះ ។

## ឃ. មុខងារ

### ១. ការដោះស្រាយបញ្ហា

១៣៤. មុខងារដោះស្រាយបញ្ហា នឹងជួយអ្នកដែលរងផលប៉ះពាល់ដោយសារគម្រោង ដោះស្រាយបញ្ហាជាក់លាក់ ដែលបង្កឡើងដោយសារគម្រោង ដែលទទួលជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី តាមរយៈវិធីសាស្ត្រផ្លូវការ ផ្អែកទៅតាមការឯកភាពគ្នាជារួម ដោយមានការយល់ព្រម និងការចូលរួមពីគ្រប់ភាគីទាំងអស់ ដែលពាក់ព័ន្ធ តាមរយៈការប្រើប្រាស់គោលវិធី (i) ការសន្ទនាបែបពិគ្រោះយោបល់, (ii) ការចែករំលែកព័ត៌មាន, (iii) ការស្វែងរកអង្គហេតុរួមគ្នា ឬ (iv) ការ

ផ្សះផ្សារ ។ អ្នកសម្របសម្រួលគម្រោងពិសេសអាចស្នើប្រើប្រាស់គោលវិធីផ្សេងៗ ដើម្បីដោះស្រាយបញ្ហា ដូចជា ការរៀបចំឱ្យមានកិច្ចប្រជុំជាមួយអ្នកពាក់ព័ន្ធផ្សេងៗ, ការរៀបចំ និងសម្របសម្រួលដំណើរការពិគ្រោះយោបល់ ឬការចូលរួម នៅក្នុងការពិនិត្យឡើងវិញលើការស្វែងរកអង្គហេតុនៃស្ថានភាពមួយ ។ មុខងារដោះស្រាយបញ្ហា គឺផ្អែកទៅតាមលទ្ធផល ។ មុខងារនេះមិនផ្តោតលើការកំណត់ និងការដាក់ការបន្ទោសនោះទេ ប៉ុន្តែលើការរិះរកវិធី ដើម្បីដោះស្រាយបញ្ហារបស់អ្នករងផលប៉ះពាល់ដោយសារគម្រោង ដែលទទួលបានជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី ។ មុខងារដោះស្រាយបញ្ហារបស់អ្នកសម្របសម្រួលគម្រោងពិសេស ក៏មានគោលបំណងពង្រឹងដំណើរការផ្ទៃក្នុងរបស់នាយកដ្ឋានប្រតិបត្តិការផងដែរ ហើយត្រូវបានរៀបចំឡើង ដើម្បីលើកកម្ពស់មុខងារដោះស្រាយបញ្ហាផ្ទៃក្នុង ។

១៣៥. ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស នឹង៖

(i) សុំពីនាយកដ្ឋានប្រតិបត្តិការនូវឯកសារ និងការវិភាគទាំងអស់ ដែលពាក់ព័ន្ធជាមួយសំណើ ។

(ii) សម្របសម្រួលការសន្ទនាបែបពិគ្រោះយោបល់, ប្រើការិយាល័យរបស់ខ្លួន និង/ឬសម្របសម្រួលការបង្កើតយន្តការផ្សះផ្សារ ។

(iii) ជូនដំណឹងដល់ក្រុមប្រឹក្សាភិបាល និងអ្នកសម្របសម្រួលផ្សេងទៀតអំពីលទ្ធផលនៃសកម្មភាពពិគ្រោះយោបល់ជាក់លាក់ ។

(iv) ប្រមូល និងចងក្រងបទពិសោធន៍ផ្នែកការដោះស្រាយបញ្ហាខាងក្នុង និងខាងក្រៅ ដើម្បីផ្តល់ព័ត៌មានត្រលប់ទៅឱ្យប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដូចជា បទពិសោធន៍ផ្នែកការបង្កើត ដំណើរការ និងអនុវត្តគម្រោង ជាដើម ។

(v) ផ្តល់ការគាំទ្រ និងដំបូន្មានទូទៅដល់នាយកដ្ឋានប្រតិបត្តិការ អំពីសកម្មភាពដោះស្រាយបញ្ហារបស់នាយកដ្ឋានទាំងនោះ ប៉ុន្តែមិនមែនសម្រាប់ករណីជាក់លាក់ ដែលកំពុងពិនិត្យឡើងវិញដោយនាយកដ្ឋានប្រតិបត្តិការទាំងនោះឡើយ ។

(vi) ធ្វើការងារជាមួយការិយាល័យរបស់គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម ដើម្បីធ្វើបច្ចុប្បន្នកម្មកញ្ចប់ព័ត៌មានមូលដ្ឋាន សំដៅផ្តល់នូវព័ត៌មានដែលសាមញ្ញ និងច្បាស់លាស់អំពីយន្តការគណនេយ្យភាពនេះ ។ កញ្ចប់ព័ត៌មាននេះនឹងត្រូវផ្ញើទៅឱ្យអ្នកស្នើសុំ នៅពេលបញ្ជាក់ថាបានទទួលសំណើរបស់ពួកគេ ។ កញ្ចប់ព័ត៌មាននេះនឹងបង្ហាញឱ្យឃើញពីសកម្មភាពកែតម្រូវផ្សេងៗ ដែលស្ថិតនៅក្រោមមុខងារទាំងពីរនេះ ឧ. មុខងារពិគ្រោះយោបល់មានគោលបំណងដោះស្រាយបញ្ហា ដែលកើតមានជាក់ស្តែង និងសម្របសម្រួលការដោះស្រាយបញ្ហានេះ ហើយ

មុខងារពិនិត្យឡើងវិញលើភាពអនុលោមផ្តោតសំខាន់លើការស៊ើបអង្កេតលើការចោទប្រកាន់អំពីភាពមិនអនុលោមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ទៅតាមគោលនយោបាយ និងនីតិវិធីប្រតិបត្តិការការងាររបស់ខ្លួន។

(vii) សហការជាមួយ OCRP, ដើម្បីរៀបចំ និងបោះពុម្ពផ្សាយរបាយការណ៍ប្រចាំឆ្នាំអំពីយន្តការគណនេយ្យភាព[៤០] ។ របាយការណ៍ទាំងនេះនឹងបង្ហាញពីនិន្នាការ និងមេរៀនថ្មីៗ ដែលទទួលបានពីបទពិសោធន៍របស់ផង OSPF និងរបស់ OCRP ផង។ របាយការណ៍ទាំងនេះក៏អាចដាក់បញ្ចូលបញ្ហា និងមេរៀន ដែលពាក់ព័ន្ធជាមួយនឹងយន្តការគណនេយ្យភាព ទទួលបានពីការងាររបស់នាយកដ្ឋានវាយតម្លៃឯករាជ្យ និងនាយកដ្ឋានអភិវឌ្ឍន៍តំបន់ប្រកបដោយនិរន្តរភាពផងដែរ។

(viii) សហការជាមួយ OCRP ដើម្បីរៀបចំកិច្ចប្រជុំបង្ហាញព័ត៌មានដោយសង្ខេបរួមគ្នាប្រចាំត្រីមាសដល់ BCRC អំពីសំណើនានា។ កិច្ចប្រជុំមួយ ក្នុងចំណោមកិច្ចប្រជុំទាំងនេះ អាចរៀបចំរួមគ្នាជាមួយនឹងកិច្ចប្រជុំបង្ហាញព័ត៌មានដោយសង្ខេប អំពីរបាយការណ៍ប្រចាំឆ្នាំអំពីយន្តការគណនេយ្យភាព។

(ix) អនុវត្តកម្មវិធីផ្សព្វផ្សាយព័ត៌មាន នៅក្នុងធនាគារអភិវឌ្ឍន៍អាស៊ី និងដល់សាធារណជន។ ការផ្សព្វផ្សាយព័ត៌មានរបស់ OSPF ត្រូវដាក់បញ្ចូលការណែនាំជារួមអំពីយន្តការគណនេយ្យភាព ហើយក្នុងពេលជាមួយគ្នាផ្តោតគោលដៅលើប្រធានបទជាក់លាក់។

(x) កែលំអសោភ័ណ្ឌភាពនៃគេហទំព័ររបស់យន្តការគណនេយ្យភាព។ គេហទំព័ររបស់ OSPF និង OCRP ត្រូវភ្ជាប់ទំនាក់ទំនងជាមួយនឹងទំព័ររួម។ ទំព័រទាំងនេះនឹងត្រូវបានធ្វើបច្ចុប្បន្នកម្ម និងកែសម្រួលជាប្រចាំ ដើម្បីបង្កើនលទ្ធភាពទទួលបានព័ត៌មាន និងភាពគ្រប់ជ្រុងជ្រោយរបស់ព័ត៌មាន។ និង

(xi) អនុវត្តសកម្មភាពដទៃទៀត ដែលចាំបាច់ ដើម្បីដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាព។

---

[៤០] ប្រធាន CRP, SPF, DG IED, និង DG RSDD អាចឆ្លាស់វេនគ្នាធ្វើជាប្រធាន សម្រាប់រៀបចំមេរៀន និង/ឬផ្នែកដែលពាក់ព័ន្ធផ្សេងទៀត នៃរបាយការណ៍ប្រចាំឆ្នាំរបស់យន្តការគណនេយ្យភាព។

១៣៦. មុខងារដោះស្រាយបញ្ហាមិនមែនជំនួសឱ្យមុខងារចាត់ចែងគម្រោង និងដោះស្រាយបញ្ហា ដែលកំពុងមាននៅតាមនាយកដ្ឋានប្រតិបត្តិការ ដែលជាអ្នកមានការទទួលខុសត្រូវបឋមលើការឆ្លើយតបចំពោះបញ្ហារបស់សហគមន៍ ដែលរងផលប៉ះពាល់នោះទេ។ អ្នកសម្របសម្រួលគម្រោងពិសេស អនុវត្តតួនាទីរបស់ខ្លួន តែសម្រាប់បញ្ហាពាក់ព័ន្ធនឹងធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងគម្រោង ដែលទទួលបានជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ីតែប៉ុណ្ណោះ។ អ្នកសម្របសម្រួលគម្រោងពិសេសនឹងមិនជ្រៀតជ្រែកក្នុងការងារផ្ទៃក្នុងរបស់ប្រទេសកំពុងអភិវឌ្ឍជាសមាជិក ហើយនឹងមិនធ្វើការផ្សះផ្សាររវាងអ្នកស្នើសុំ និងអាជ្ញាធរមូលដ្ឋានឡើយ។

## ២. មុខងារពិនិត្យឡើងវិញលើភាពអនុលោម

### ក. គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម

១៣៧. CRP នឹងធ្វើការស៊ើបអង្កេតលើការចោទប្រកាន់អំពីភាពមិនអនុលោមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ទៅនឹងគោលនយោបាយ និងនីតិវិធីប្រតិបត្តិការការងាររបស់ខ្លួន នៅក្នុងគម្រោង ដែលទទួលបានជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី ដែលធ្វើឱ្យមានផលប៉ះពាល់អវិជ្ជមានដល់ប្រជាពលរដ្ឋមូលដ្ឋាន ដោយផ្ទាល់ និងគួរឱ្យកត់សម្គាល់ នៅក្នុងពេលបង្កើត ដំណើរការ ឬអនុវត្តគម្រោង។ ការពិនិត្យឡើងវិញលើភាពអនុលោមនេះ មិនមានគោលបំណងធ្វើការស៊ើបអង្កេតលើប្រទេសខ្ចីកម្ចី, ទីភ្នាក់ងារប្រតិបត្តិ, អ្នកខ្ចីកម្ចី ឬអ្នកគាំទ្រគម្រោងឯកជន (PPS) នោះទេ។ ទង្វើរបស់ភាគីដទៃទៀតទាំងនេះ នឹងយកមកធ្វើការពិចារណា តែក្នុងវិសាលភាព ដែលពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងការវាយតម្លៃលើភាពអនុលោមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ជាមួយនឹងគោលនយោបាយ និងនីតិវិធីប្រតិបត្តិការការងាររបស់ខ្លួនតែប៉ុណ្ណោះ។ ការពិនិត្យឡើងវិញលើភាពអនុលោមនេះ ពុំមានគោលបំណង ផ្តល់នូវការកែតម្រូវដូចវិធានការតុលាការដូចជា អធិបញ្ញោ ឬការសងការខូចខាតជាប្រាក់នោះទេ។

១៣៨. គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោមនឹងៈ

(i) វិភាគលើការស្នើសុំឱ្យមានការពិនិត្យឡើងវិញលើភាពអនុលោម។

(ii) ចូលរួមជាមួយអ្នកពាក់ព័ន្ធទាំងអស់ ដូចជា គណៈគ្រប់គ្រង និងបុគ្គលិក, អ្នកស្នើសុំ, រដ្ឋាភិបាលរបស់ប្រទេសកំពុងអភិវឌ្ឍជាសមាជិក ឬអ្នកឧបត្ថម្ភគម្រោងឯកជន និងសមាជិកក្រុមប្រឹក្សា-ភិបាល ដែលតំណាងឱ្យប្រទេសពាក់ព័ន្ធ ដើម្បីស្វែងយល់លំអិតអំពីបញ្ហា ដែលត្រូវពិនិត្យ នៅក្នុងកំឡុងពេលពិនិត្យឡើងវិញលើភាពអនុលោម។

(iii) សម្របសម្រួលសកម្មភាពរបស់ខ្លួន ក្នុងកម្រិតសមស្រប ជាមួយយន្តការពិនិត្យឡើងវិញលើភាព

អនុលោមរបស់ស្ថាប័នសហហិរញ្ញប្បទានផ្សេងទៀត ដែលកំពុងធ្វើការពិនិត្យឡើងវិញលើភាពអនុលោមដោយឡែក នៅក្នុងគម្រោងតែមួយ ។

(iv) រៀបចំការពិនិត្យឡើងវិញដោយល្អិតល្អន់ និងដោយសត្យានុម័តលើការអនុលោមទៅតាមគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។

(v) ពិគ្រោះយោបល់ជាមួយគណៈគ្រប់គ្រង និងបុគ្គលិក, អ្នកស្នើសុំ, រដ្ឋាភិបាលរបស់ប្រទេសកំពុងអភិវឌ្ឍជាសមាជិក ឬអ្នកឧបត្ថម្ភគម្រោងឯកជន និងសមាជិកក្រុមប្រឹក្សាភិបាល ដែលតំណាងឱ្យប្រទេសពាក់ព័ន្ធ អំពីលទ្ធផលរកឃើញបឋមរបស់ខ្លួន ។

(vi) ចេញសេចក្តីព្រាងរបាយការណ៍ដល់អ្នកគ្រប់គ្រង អ្នកស្នើសុំ និងអ្នកខ្ចី ។

(vii) ចេញរបាយការណ៍ចុងក្រោយដល់ក្រុមប្រឹក្សាភិបាល ដោយមានដាក់បញ្ចូលលទ្ធផលដែលបានរកឃើញ ។

(viii) ពិនិត្យតាមដានការអនុវត្តសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាល និងបង្កើតរបាយការណ៍ពិនិត្យតាមដានប្រចាំឆ្នាំ ។

(ix) សហការជាមួយ OSPF, ដើម្បីរៀបចំ និងបោះពុម្ពផ្សាយរបាយការណ៍ប្រចាំឆ្នាំអំពីយន្តការគណនេយ្យភាព ។ របាយការណ៍ទាំងនេះនឹងបង្ហាញពីនិន្នាការ និងមេរៀនថ្មីៗ ដែលទទួលបានពីបទពិសោធន៍របស់ផង OSPF និងរបស់ OCRP ផង ។ របាយការណ៍ទាំងនេះក៏អាចដាក់បញ្ចូលបញ្ហា និងមេរៀន ដែលពាក់ព័ន្ធជាមួយនឹងយន្តការគណនេយ្យភាព ទទួលបានពីការងាររបស់នាយកដ្ឋានវាយតម្លៃឯករាជ្យ និងនាយកដ្ឋានអភិវឌ្ឍន៍តំបន់ប្រកបដោយនិរន្តរភាពផង ដែរ (នឹងត្រូវផ្តល់ដោយនាយកដ្ឋានទាំងនេះ) ។

(x) សហការជាមួយ OSPF ដើម្បីរៀបចំកិច្ចប្រជុំបង្ហាញព័ត៌មានដោយសង្ខេបរួមគ្នាប្រចាំត្រីមាសដល់ BCRC អំពីសំណើនានា ។ កិច្ចប្រជុំមួយ ក្នុងចំណោមកិច្ចប្រជុំទាំងនេះ អាចរៀបចំរួមគ្នាជាមួយនឹងកិច្ចប្រជុំបង្ហាញព័ត៌មានដោយសង្ខេប អំពីរបាយការណ៍ប្រចាំឆ្នាំអំពីយន្តការគណនេយ្យភាព ។

(xi) បង្កើតបញ្ជីឈ្មោះក្រុមអ្នកជំនាញបច្ចេកទេសឯករាជ្យ ដែលអាចជួយដល់ CRP នៅក្នុងការបំពេញការងាររបស់ខ្លួន ។ និង

(xii) សម្របសម្រួលជាមួយយន្តការគណនេយ្យភាពរបស់ស្ថាប័នដទៃទៀត ។

១៣៩. ប្រធាន CRP នឹង:

(i) បំពេញគ្រប់មុខងារទាំងអស់របស់ CRP ។

(ii) បែងចែកការងារឱ្យសមាជិករបស់ CRP ធ្វើការពិនិត្យឡើងវិញលើភាពអនុលោមជាក់លាក់ និងពិនិត្យតាមដានកិច្ចការនានា ដោយពិគ្រោះយោបល់ជាមួយ BCRC ។

(iii) រៀបចំកម្មវិធីការងារ និងថវិការប្រចាំឆ្នាំសម្រាប់ CRP និង OCRP ។

(iv) ដោយមានការពិគ្រោះយោបល់ជាមួយសមាជិកដទៃទៀតរបស់ CRP , អនុវត្តកម្មវិធីការងាររបស់ CRP និងរាយការណ៍ទៀងទាត់ទៅកាន់ក្រុមប្រឹក្សាភិបាលអំពីសកម្មភាពរបស់ CRP តាមរយៈ BCRC

(v) វាយតម្លៃលេខាធិការរបស់ OCRP និងបុគ្គលិកពាក់ព័ន្ធដទៃទៀតរបស់ OCRP ។ និង

(vi) ផ្តល់ធាតុចូលដល់ព័ត៌មានត្រលប់របស់ BCRC លើការបំពេញការងារប្រចាំឆ្នាំ ដែលត្រូវផ្តល់ទៅឱ្យសមាជិក CRP ។

## ខ. ការិយាល័យរបស់គណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម (OCRP)

១៤០. OCRP នឹង:

(i) ផ្តល់ការគាំទ្រដល់ការងាររបស់ CRP

(ii) ធ្វើការងារជាមួយ OSPF ដើម្បីបង្កើតនូវកញ្ចប់ព័ត៌មានជាមូលដ្ឋានសាមញ្ញ ច្បាស់លាស់ និងសង្ខេបខ្លី អំពីយន្តការគណនេយ្យភាព ដែលត្រូវផ្ញើទៅឱ្យអ្នកស្នើសុំ នៅពេលបញ្ជាក់ថាបានទទួលសំណើរបស់ពួកគេ។ កញ្ចប់ព័ត៌មាននេះនឹងបង្ហាញពីសកម្មភាពកែតម្រូវផ្សេងៗ ដែលមាននៅក្រោមមុខងារទាំង ២ ឧទាហរណ៍ មុខងារដោះស្រាយបញ្ហា មានគោលបំណងដោះស្រាយបញ្ហានៅនឹងមូលដ្ឋានជាក់ស្តែង និងធ្វើការសម្របសម្រួលដំណោះស្រាយចំពោះបញ្ហា ហើយមុខងារពិនិត្យឡើងវិញលើភាពអនុលោមផ្តោតសំខាន់លើការនាំឱ្យគម្រោងមានភាពអនុលោម និង/ឬកាត់បន្ថយផលប៉ះពាល់ ទៅតាមការសមស្រប ដោយអនុវត្តតាមការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាលអំពីលទ្ធផលនៃការពិនិត្យឡើងវិញលើភាពអនុលោម ។

(iii) អនុវត្តកម្មវិធីផ្សព្វផ្សាយព័ត៌មានផ្ទៃក្នុង និងដល់សាធារណជន។ ការផ្សព្វផ្សាយព័ត៌មានរបស់ OCRP ត្រូវមានការណែនាំជារួមអំពីយន្តការគណនេយ្យភាព ខណៈពេលផ្តោតគោលដៅលើ

ប្រធានបទជាក់លាក់ ។

(iv) សម្របសម្រួលជាមួយ OSPF, នាយកដ្ឋានប្រតិបត្តិការ, មជ្ឈមណ្ឌលអង្គការក្រៅរដ្ឋាភិបាល និងនាយកដ្ឋានទំនាក់ទំនងសាធារណៈ ដើម្បីធានាថាការផ្សព្វផ្សាយព័ត៌មានដល់សាធារណជនត្រូវបានដាក់បញ្ចូលទៅក្នុងសកម្មភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលត្រូវបានរៀបចំឡើងដើម្បីលើកកម្ពស់អន្តរកម្ម (ទំនាក់ទំនង) ជាមួយអ្នកទទួលផលគម្រោង ឬអ្នកពាក់ព័ន្ធ រាប់បញ្ចូលទាំងក្រុមសង្គមស៊ីវិលផងដែរ ។ និង

(v) សម្របសម្រួលការប្រាស្រ័យទាក់ទង និងការសម្របសម្រួលរបស់ CRP ជាមួយក្រុមប្រឹក្សា-ភិបាល, គណៈគ្រប់គ្រង, OSPF និងបុគ្គលិក ។

### គ. មន្ត្រីទទួលពាក្យបណ្ដឹង (OCRP)

១៤១. បុគ្គលិកមកពី OCRP នឹងត្រូវចាត់ឱ្យបំពេញតួនាទីជា CRO ដែលនឹងៈ

(i) ទទួលគ្រប់សំណើទាំងអស់ ហើយបញ្ជាក់ប្រាប់ភ្លាមទៅអ្នកដាក់សំណើវិញថាបានទទួល ។

(ii) បន្ទាប់ពីទទួលសំណើនីមួយៗរួច, រៀបចំឱ្យមានជាកិច្ចប្រជុំជាមួយបុគ្គលិក OSPF ដែលពាក់ព័ន្ធ ដើម្បីរួមគ្នាពិនិត្យលើសំណើ និងធ្វើការសម្រេចចិត្តថាតើត្រូវបញ្ជូនបន្តទៅកាន់ SPF, CRP, នាយកដ្ឋានប្រតិបត្តិការ ឬការិយាល័យ និងនាយកដ្ឋានដទៃទៀតដែរឬអត់ ។

(iii) រៀបចំលិខិតរួមគ្នាមួយជាមួយនឹងបុគ្គលិក OSPF ដោយធ្វើការសង្ខេបពីមូលហេតុ នៃការបញ្ជូនការស្នើសុំទៅកាន់ការិយាល័យ ឬនាយកដ្ឋានជាក់លាក់ណាមួយ ហើយត្រូវបញ្ជូនលិខិតនេះទៅកាន់អ្នកសម្របសម្រួលគម្រោងពិសេស, ប្រធាន CRP និងនាយកដ្ឋានប្រតិបត្តិការដែលពាក់ព័ន្ធដោយចម្លងជូន ។

(iv) បញ្ជូនសំណើទៅកាន់ OSPF ប្រសិនបើអ្នកដាក់សំណើស្នើឱ្យមានការដោះស្រាយបញ្ហា, ទៅកាន់ប្រធាន CRP ប្រសិនបើអ្នកដាក់សំណើស្នើឱ្យមានការពិនិត្យឡើងវិញលើភាពអនុលោម, ទៅកាន់នាយកដ្ឋានប្រតិបត្តិការ ប្រសិនបើកន្លងមក ពុំមានការខិតខំប្រឹងប្រែងដោយសុច្ឆន្ទៈពីសំណាក់អ្នកស្នើសុំ ដើម្បីដោះស្រាយបញ្ហាជាមួយនឹងនាយកដ្ឋានប្រតិបត្តិការដែលពាក់ព័ន្ធ, ឬទៅកាន់នាយកដ្ឋាន និងការិយាល័យពាក់ព័ន្ធដទៃទៀត ប្រសិនបើសំណើនេះហួសពីអណត្តិការងាររបស់យន្តការគណនេយ្យភាព (ឧ. បញ្ហាពុករលួយ និងបញ្ហាលទ្ធកម្ម ជាដើម) ។ ដោយសារតែការកំណត់ថាតើកន្លងមក មានការខិតខំប្រឹងប្រែងដោយសុច្ឆន្ទៈឬអត់ មិនមែនជាការងារដែល

ងាយស្រួលនោះ, ការវាយតម្លៃលើលក្ខណៈសមស្របរបស់ CRP និង SPF គួរធ្វើការពិនិត្យឡើងវិញថាតើមានការបំពេញទៅតាមលក្ខខណ្ឌនេះដែរឬអត ។

(v) ចុះបញ្ជីសំណើ ដែលទទួលបាន ។

(vi) ចម្លងជូនផ្នែកដែលពាក់ព័ន្ធ ឧ. OSFP, CRP, ឬនាយកដ្ឋានប្រតិបត្តិការដែលពាក់ព័ន្ធ ប្រសិនបើសំណើទាំងនេះមិនត្រូវបានបញ្ជូនទៅកាន់ផ្នែកទាំងនោះ ។

(vii) ផ្តល់ព័ត៌មានដល់អ្នកស្នើសុំ អំពីអ្នកដែលពួកគេត្រូវទាក់ទងបន្តទៀត ។

១៤២. CRO បំពេញតួនាទីផ្តល់សេវាបញ្ជូនសំណើ ទៅកាន់ការិយាល័យ និងនាយកដ្ឋានពាក់ព័ន្ធ អាស្រ័យទៅតាមការចង់បានរបស់អ្នកស្នើសុំ និងលក្ខណៈរបស់បញ្ហា ។ CRO ត្រូវបំពេញមុខងារនេះមិនលំអៀង និងអព្យាក្រិត និងប្រើឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងកម្រិតទាបបំផុត ។

## ឃ. គណៈកម្មាធិការពិនិត្យឡើងវិញលើភាពអនុលោមរបស់ក្រុមប្រឹក្សាភិបាល (BCRC)

១៤៣. BCRC នឹង:

(i) ផ្តល់ការឯកភាពដល់សំណើលក្ខខណ្ឌយោង (TOR) របស់ CRP សម្រាប់ការពិនិត្យឡើងវិញលើភាពអនុលោម មុនពេលដែល CRP បញ្ចេញលក្ខខណ្ឌយោងទាំងនេះ ។

(ii) ផ្តល់យោបល់លើសេចក្តីព្រាងរបាយការណ៍ពិនិត្យឡើងវិញលើភាពអនុលោមរបស់ CRP ។

(iii) ពិនិត្យឡើងវិញលើសេចក្តីព្រាងរបាយការណ៍របស់ CRP អំពីការពិនិត្យតាមដានសកម្មភាពកែតម្រូវ ដែលទទួលបានការឯកភាពពីក្រុមប្រឹក្សាភិបាល បន្ទាប់ពីមានការពិនិត្យឡើងវិញលើភាពអនុលោម មុនពេលដែល CRP បង្ហើយបញ្ចប់សេចក្តីព្រាងរបាយការណ៍ទាំងនោះ ។

(iv) ធ្វើការសម្រេចចិត្ត និងកែសម្រួលក្របខ័ណ្ឌពេលវេលាពិនិត្យតាមដានរបស់ CRP ។

(v) ពិនិត្យឡើងវិញ និងគាំទ្រដល់ផែនការការងារ និងថវិកាប្រចាំឆ្នាំរួមគ្នារបស់ CRP និង OCRP ។

(vi) ស្វែងរកសមាជិក CRP សក្តានុពល ដោយធ្វើការពិគ្រោះយោបល់ជាមួយប្រធានធនាគារ ។

(vii) ផ្តល់នូវព័ត៌មានត្រលប់ជាលាយលក្ខណ៍អក្សរ ទៅកាន់សមាជិករបស់ CRP ទាំងអស់អំពីការបំពេញការងាររបស់ពួកគេ ។ ព័ត៌មានត្រលប់របស់ប្រធាន CRP នឹងត្រូវយកមកធ្វើការពិចារណានៅក្នុងព័ត៌មានត្រលប់អំពីសមាជិកដទៃទៀតរបស់ CRP ។ និង

(viii) បំពេញតួនាទីជាជនបង្គោលសម្រាប់ការប្រាស្រ័យទាក់ទង និងការសន្ទនារបស់ CRP ជាមួយ

ក្រុមប្រឹក្សាភិបាលអំពីយន្តការគណនេយ្យភាព។

១៤៤. មុខងាររបស់ BCRC ក្នុងការផ្តល់ការឯកភាពលើសំណើលក្ខខណ្ឌយោង និងផ្តល់យោបល់លើសេចក្តីព្រាងរបាយការណ៍ពិនិត្យឡើងវិញលើភាពអនុលោម គឺដើម្បីធានាថា CRP បំពេញការងារ នៅក្នុងក្របខ័ណ្ឌនៃការពិនិត្យឡើងវិញលើភាពអនុលោម។ BCRC នឹងពិនិត្យឡើងវិញលើរបាយការណ៍ពិនិត្យតាមដានរបស់ CRP ដើម្បីធានាថា CRP បានអនុវត្តនូវដំណើរការក្នុងកម្រិតជាទីពេញចិត្ត នៅក្នុងការពិនិត្យតាមដានការអនុវត្តសកម្មភាពកែតម្រូវនានា ដែលទទួលបានការឯកភាពពីក្រុមប្រឹក្សាភិបាល បន្ទាប់ពីមានការពិនិត្យឡើងវិញលើភាពអនុលោមរួចមក។

### ង. ក្រុមប្រឹក្សាភិបាល

១៤៥. ការទទួលខុសត្រូវចម្បងរបស់ក្រុមប្រឹក្សាភិបាល ពាក់ព័ន្ធជាមួយនឹង CRP រួមមាន:

(i) ត្រួតពិនិត្យការងាររបស់ CRP។

(ii) តែងតាំង និង/ឬដកសមាជិករបស់ CRP ទៅតាមអនុសាសន៍របស់ BCRC ដោយមានការពិគ្រោះយោបល់ជាមួយប្រធានធនាគារ។

(iii) ពិចារណា និងផ្តល់ការឯកភាពលើរបាយការណ៍របស់ CRP និងផ្តល់ការឯកភាពលើការប្រកាសជាសាធារណៈនូវរបាយការណ៍នេះ។

(iv) ពិចារណា និងផ្តល់ការឯកភាពលើអនុសាសន៍ និង/ឬសកម្មភាពរបស់គណៈគ្រប់គ្រង ដែលជាការឆ្លើយតបទៅនឹងលទ្ធផលរកឃើញរបស់ CRP។ និង

(v) ពិនិត្យឡើងវិញ និងផ្តល់ការឯកភាពលើគោលនយោបាយយន្តការគណនេយ្យភាព។

៣. គណៈគ្រប់គ្រង និងបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី

១៤៦. គណៈគ្រប់គ្រង និងបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ីត្រូវ:

(i) ធានាថា OSPF និង CRP អាចទទួលបានព័ត៌មានយ៉ាងពេញលេញ ដើម្បីបំពេញមុខងាររបស់ពួកគេ។

(ii) ផ្តល់ជំនួយដល់ OSPF ចំពោះការដោះស្រាយបញ្ហា។

(iii) សម្របសម្រួលជាមួយ CRP ពាក់ព័ន្ធនឹងការពិនិត្យឡើងវិញលើភាពអនុលោម។

(iv) ផ្តល់ជាអនុសាសន៍ និង/ឬបង្កើតផែនការសកម្មភាព ដើម្បីឱ្យគម្រោងមានភាពអនុលោម ជាការ

ឆ្លើយតបទៅនឹងលទ្ធផលរកឃើញរបស់ការពិនិត្យឡើងវិញលើភាពអនុលោម ។ អនុសាសន៍ និង ផែនការសកម្មភាពទាំងនេះគួរទទួលបានការឯកភាពពីអ្នកខ្ចីកម្ចី ។

(v) ជួយដល់ការរៀបចំចុះបេសកកម្មរបស់ OSPF, CRP, និង OCRP និងផ្ដល់ជំនួយដទៃទៀត ក្នុងករណីចាំបាច់ ។

(vi) តាមដានពាក្យបណ្ដឹង ដែលត្រូវបានបញ្ជូនទៅកាន់នាយកដ្ឋានប្រតិបត្តិការ ដោយសារតែពុំមាន កិច្ចខិតខំប្រឹងប្រែងដោយសុច្ឆន្ទៈពីសំណាក់អ្នកស្នើសុំ ដើម្បីដោះស្រាយបញ្ហាជាមួយនឹងនាយក-ដ្ឋានប្រតិបត្តិការ ។

## ខ. លក្ខណៈសមស្រប (Eligibility)

### ១. តើអ្នកណាដែលអាចដាក់សំណើបាន?

១៤៧. សម្រាប់មុខងារដោះស្រាយបញ្ហា និងមុខងារពិនិត្យឡើងវិញលើភាពអនុលោម, (i) សំណើអាចដាក់ដោយ ក្រុមមនុស្សចាប់ពី ២ នាក់ឡើងទៅ នៅក្នុងប្រទេសខ្ចីកម្ចី ដែលជាទីតាំងរបស់គម្រោងទទួលជំនួយពីធនាគារអភិវឌ្ឍន៍ អាស៊ី ឬនៅក្នុងប្រទេសជាសមាជិក ដែលនៅជាប់នឹងប្រទេសខ្ចីកម្ចី ដែលទទួលរងផលប៉ះពាល់អវិជ្ជមាន ដោយផ្ទាល់ និងគួរឱ្យកត់សម្គាល់, (ii) តំណាងរបស់អ្នកដែលរងផលប៉ះពាល់ ឬ (iii) តំណាងដែលមិនស្ថិតនៅក្នុងមូលដ្ឋាន នៅក្នុង ករណីលើកលែង ដែលពុំអាចរកតំណាងនៅមូលដ្ឋានបាន ហើយមានការយល់ព្រមពី SPF ឬ CRP ។ ប្រសិនបើសំណើ ត្រូវបានដាក់តាមរយៈតំណាង, សំណើនេះត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីអ្នកដែលរងផលប៉ះពាល់ដោយសារគម្រោង និង អ្នកតំណាងពួកគេ និងបង្ហាញភស្តុតាងអំពីការអនុញ្ញាតឱ្យអ្នកតំណាង ធ្វើជាតំណាងអ្នកដែលរងផលប៉ះពាល់ទាំងនេះ ។

១៤៨. សម្រាប់ការពិនិត្យឡើងវិញលើភាពអនុលោម, សំណើក៏អាចដាក់ដោយសមាជិកក្រុមប្រឹក្សាភិបាលរបស់ ធនាគារអភិវឌ្ឍន៍អាស៊ីម្នាក់ ឬច្រើននាក់ បន្ទាប់ពីពេលដែលពួកគេបានលើកឡើងពីការព្រួយបារម្ភរបស់ពួកគេជាមួយ នឹងគណៈគ្រប់គ្រងរួចមក ជាពិសេស នៅក្នុងករណីពាក់ព័ន្ធនឹងការចោទប្រកាន់ពីការប្រព្រឹត្តធ្ងន់ធ្ងរល្មើសទៅនឹងគោល-នយោបាយ និងនីតិវិធីប្រតិបត្តិការការងាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ទាក់ទិននឹងគម្រោងទទួលបានជំនួយពីធនាគារ អភិវឌ្ឍន៍អាស៊ី ដែលកំពុងបន្តអនុវត្ត ហើយដែលមាន ឬទំនងជានឹងមានផលប៉ះពាល់អវិជ្ជមាន ដោយផ្ទាល់ និងគួរ ឱ្យកត់សម្គាល់ ដល់សហគមន៍ ឬក្រុមមនុស្សផ្សេងទៀត ដែលរស់នៅជាប់នឹងប្រទេសខ្ចីកម្ចី ។ ការពិនិត្យឡើងវិញលើ ភាពអនុលោម ដែលស្នើដោយសមាជិកក្រុមប្រឹក្សាភិបាល នឹងមិនប៉ះពាល់ ឬរឹតបន្តឹងសិទ្ធិ ដែលមានស្រាប់របស់ សមាជិកក្រុមប្រឹក្សាភិបាល ដើម្បីស្នើ ឬផ្ដួចផ្ដើមឱ្យមានការពិនិត្យឡើងវិញលើគោលនយោបាយ និងនីតិវិធីប្រតិបត្តិការ

ការងាររបស់ធនាគារអភិវឌ្ឍន៍អាស៊ីឡើយ។

១៤៩. ពាក្យ "គម្រោង ដែលទទួលបានជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី" សំដៅលើគម្រោង ដែលទទួលបានហិរញ្ញប្បទាន ឬនឹងទទួលបានហិរញ្ញប្បទាន ឬត្រូវបានចាត់ចែង ឬនឹងត្រូវបានចាត់ចែង ដោយធនាគារអភិវឌ្ឍន៍អាស៊ី។ ការដាក់សំណើទៅកាន់ SPF ឬ CRP នឹងមិនផ្អាក ឬធ្វើឱ្យប៉ះពាល់ដល់ការបង្កើត ដំណើរការ ឬការអនុវត្តគម្រោងឡើយ លុះត្រាតែមានការឯកភាពពីប្រទេសកំពុងអភិវឌ្ឍជាសមាជិក ឬអ្នកឧបត្ថម្ភគម្រោងឯកជនដែលពាក់ព័ន្ធ និងធនាគារអភិវឌ្ឍន៍អាស៊ី។

## ២. វិសាលភាព និងការដកចេញ

### ក. មុខងារដោះស្រាយបញ្ហា

១៥០. សំណើនឹងត្រូវបានដកចេញ ប្រសិនបើសំណើទាំងនេះ

(i) លើកឡើងពីសកម្មភាព ដែលមិនពាក់ព័ន្ធនឹងសកម្មភាព ឬការខកខានមិនបានធ្វើសកម្មភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី នៅក្នុងការបង្កើត ដំណើរការ ឬអនុវត្តគម្រោង ដែលទទួលបានជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី

(ii) លើកឡើងពីបញ្ហា ដែលត្រូវបានយកមកធ្វើការពិចារណាដោយ SPF រួចហើយ

(iii) លើកឡើងពីបញ្ហា ដែលអ្នកស្នើសុំពុំមានខិតខំប្រឹងប្រែងដោយសុច្ឆន្ទៈ ដើម្បីធ្វើការដោះស្រាយជាមួយនាយកដ្ឋានប្រតិបត្តិការដែលពាក់ព័ន្ធ ឬតាមរយៈយន្តការដោះស្រាយការកើតទុក្ខមិនសុខចិត្តរបស់គម្រោង ដែលពាក់ព័ន្ធ

(iv) លើកឡើងពីការសម្រេចចិត្ត របស់ធនាគារអភិវឌ្ឍន៍អាស៊ី, អ្នកខ្ចីកម្ចី ឬទីភ្នាក់ងារប្រតិបត្តិ ឬអ្នកឧបត្ថម្ភគម្រោងឯកជន ពាក់ព័ន្ធនឹងលទ្ធកម្មទំនិញ និងសេវាកម្ម រាប់បញ្ចូលទាំងសេវាផ្តល់ប្រឹក្សាផង

(v) លើកឡើងពីការចោទប្រកាន់អំពីការបោកបន្លំ ឬអំពើពុករលួយ នៅក្នុងគម្រោង ដែលទទួលបានជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី និងដែលប្រព្រឹត្តដោយបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី

(vi) លើកឡើងពីគម្រោង ដែលទទួលបានជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី ដែលកាលបរិច្ឆេទបញ្ចប់

កម្ម[៤១] បានកន្លងផុតទៅច្រើនមួយឆ្នាំ ឬលើសពីមួយឆ្នាំទៅហើយ

(vii) លើកឡើងពីភាពគ្រប់គ្រាន់ ឬភាពសមស្រប របស់គោលនយោបាយ និងនីតិវិធីប្រតិបត្តិការ ដែលមានស្រាប់របស់ធនាគារអភិវឌ្ឍន៍អាស៊ី

(viii) ជាសំណើកំប៉ិកកំប៉ុក មួលបង្កាច់ តិចតួច ឬស្មើឡើង ដើម្បីបានប្រយោជន៍ក្នុងការប្រកួតប្រជែង

(ix) ស្ថិតនៅក្នុងយុត្តាធិការរបស់គណៈកម្មាធិការឧទ្ធរណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី ឬសាលាក្តីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ឬពាក់ព័ន្ធជាមួយនឹងការងារបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី និង/ឬ

(x) លើកឡើងពីការងារក្នុងការិយាល័យមិនមែនប្រតិបត្តិការ របស់ធនាគារអភិវឌ្ឍន៍អាស៊ី ដូចជាការងារហិរញ្ញវត្ថុ និងរដ្ឋបាល ជាដើម

## ខ. មុខងារពិនិត្យឡើងវិញលើភាពអនុលោម

១៥១. CRP នឹងពិនិត្យថាតើផលប៉ះពាល់ដោយផ្ទាល់ និងគួរឱ្យកត់សម្គាល់ ដែលលើកឡើងនៅក្នុងពាក្យបណ្តឹងរបស់អ្នកស្នើសុំ គឺជាលទ្ធផលនៃការខកខានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងការអនុវត្តទៅតាមគោលការណ៍ និងនីតិវិធីប្រតិបត្តិការការងាររបស់ខ្លួន នៅក្នុងការបង្កើត ដំណើរការ ឬការអនុវត្តគម្រោងទទួលបានជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ីដែរឬទេ។ គ្រប់ប្រភេទសំណើទាំងអស់ ដែលត្រូវបានដកចេញពីមុខងារដោះស្រាយបញ្ហា ក៏នឹងត្រូវដកចេញពីវិសាលភាពរបស់មុខងារពិនិត្យឡើងវិញលើភាពអនុលោមផងដែរ លើកលែងតែចំណុច (ii) ខាងលើ។ លើសពីនេះសម្រាប់គោលបំណងនៃការពិនិត្យឡើងវិញលើភាពអនុលោម, សំណើខាងក្រោមនេះក៏ត្រូវបានដកចេញផងដែរៈ

(i) បណ្តឹងពាក់ព័ន្ធនឹងសកម្មភាព ដែលជាការទទួលខុសត្រូវរបស់ភាគីដទៃទៀត ដូចជា អ្នកខ្ចីកម្ចី, ទីភ្នាក់ងារប្រតិបត្តិ ឬអ្នកខ្ចីកម្ចីសក្តានុពល ប្រសិនបើទង្វើរបស់ភាគីទាំងនេះមិនពាក់ព័ន្ធដោយផ្ទាល់ ជាមួយនឹងការវាយតម្លៃលើភាពអនុលោមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ទៅតាមគោល-នយោបាយ និងនីតិវិធីប្រតិបត្តិការការងាររបស់ខ្លួន។

---

[៤១] សម្រាប់ប្រតិបត្តិការតាមកម្មវិធី ដូចជា កម្មវិធីហិរញ្ញប្បទានពហុផ្នែក, ហិរញ្ញប្បទានបន្ថែម, ចង្កោមកម្មវិធី, កាលបរិច្ឆេទឱសានវាទគឺទៅអាស្រ័យទៅតាមផ្នែក (ឬសមមូលរបស់វា)។ កាលបរិច្ឆេទឱសានវាទ គឺរយៈពេល ១ ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទបិទកម្ចី របស់ផ្នែក (ឬសមមូល)។ មានន័យថា មុនពេលដាក់បញ្ចូលកាលបរិច្ឆេទបញ្ចប់កម្ចី ជាមួយផ្នែកក្រោយៗទៀត (ឬសមមូល) នៅក្នុងករណីមួយចំនួន។ សម្រាប់គម្រោង ដែលកាលបរិច្ឆេទបិទកម្ចីត្រូវទុកចំហ បន្ទាប់ពីការបញ្ចប់គម្រោង សម្រាប់គោលបំណងនៃការទូទាត់ការប្រាក់, កាលបរិច្ឆេទឱសានវាទ គឺ ១ ឆ្នាំ ក្រោយកាលបរិច្ឆេទបញ្ចប់គម្រោង។

(ii) បណ្តឹង ដែលមិនពាក់ព័ន្ធជាមួយនឹងភាពមិនអនុលោមរបស់ធនាគារអភិវឌ្ឍន៍ ទៅតាមគោល-នយោបាយ និងនីតិវិធីប្រតិបត្តិការការងាររបស់ខ្លួន ។

(iii) បណ្តឹងពាក់ព័ន្ធជាមួយនឹងច្បាប់ គោលនយោបាយ និងបទប្បញ្ញត្តិរបស់រដ្ឋាភិបាលនៃប្រទេសកំពុងអភិវឌ្ឍជាសមាជិកដែលពាក់ព័ន្ធ ប្រសិនបើបណ្តឹងទាំងនេះមិនពាក់ព័ន្ធជាមួយនឹងភាពអនុលោមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ទៅតាមគោលនយោបាយ និងនីតិវិធីប្រតិបត្តិការការងាររបស់ខ្លួន ។ និង

(iv) បណ្តឹងអំពីបញ្ហា ដែល CRP បានលើកយកមកធ្វើការពិចារណារួចហើយ ។

១៥២. វិសាលភាពនៃការពិនិត្យឡើងវិញលើភាពអនុលោមគឺ "ភាពអនុលោមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ទៅតាមគោលនយោបាយ និងនីតិវិធីប្រតិបត្តិការការងាររបស់ខ្លួន" ពាក់ព័ន្ធនឹងការបង្កើត ដំណើរការ ឬការអនុវត្តគម្រោងដែលទទួលបានជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី ។ គោលនយោបាយ និងនីតិវិធីប្រតិបត្តិការការងារទាំងនេះ ត្រូវបានដាក់បញ្ចូលទៅក្នុងផ្នែកពាក់ព័ន្ធរបស់សៀវភៅណែនាំអំពីប្រតិបត្តិការការងារ (OM) ។ គោលនយោបាយ និងនីតិវិធីទាំងនេះមិនរាប់បញ្ចូលគោលការណ៍ណែនាំ និងឯកសារ ឬសេចក្តីថ្លែងស្រដៀងគ្នានេះឡើយ ។ ក្រុមប្រឹក្សាភិបាលនឹងធ្វើការសម្រេចចិត្ត ថាតើគោលនយោបាយមួយ គឺជាគោលនយោបាយប្រតិបត្តិការការងារ ដែលត្រូវមានការពិនិត្យឡើងវិញលើភាពអនុលោមឬអត់ ហើយ CRP នឹងកំណត់ថាតើផ្នែកណារបស់គោលនយោបាយ និងនីតិវិធីប្រតិបត្តិការការងារទាំងមិនត្រូវបានគេអនុលោមតាម បន្ទាប់ពីបានធ្វើការពិនិត្យឡើងវិញលើភាពអនុលោមរួចមក ។ នៅក្នុងការកំណត់ពីភាពសមស្របរបស់សំណើមួយ, CRP ត្រូវមើលឃើញថា ពិតជាមានភស្តុតាងគ្រប់គ្រាន់នៃវត្តមានរួមគ្នារបស់ (i) ផលប៉ះពាល់ដោយផ្ទាល់ និងគួរឱ្យកត់សម្គាល់ ដែលបង្កឡើងដោយគម្រោង ដែលទទួលជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី, (ii) ភាពមិនអនុលោមក្នុងកម្រិតធ្ងន់ធ្ងរ និង (iii) ទំនាក់ទំនងរវាងភាពមិនអនុលោម ជាមួយនឹងផលប៉ះពាល់នេះ ។

១៥៣. ចំពោះការពិនិត្យឡើងវិញលើភាពអនុលោម, គោលនយោបាយ និងនីតិវិធីប្រតិបត្តិការការងារដែលពាក់ព័ន្ធ គឺអាស្រ័យលើថាតើសំណើដែលបានលើកឡើងពាក់ព័ន្ធជាមួយនឹងគម្រោង ដែលត្រូវបានគេស្នើឡើង ឬគម្រោង ដែលកំពុងអនុវត្ត ។ "គម្រោង ដែលត្រូវបានគេស្នើឡើង" គឺសំដៅលើគម្រោង ដែលកំពុងរៀបចំ ហើយដែលពុំទាន់ទទួលបានការឯកភាពពីក្រុមប្រឹក្សាភិបាល ឬប្រធានធនាគារ ។ សម្រាប់គម្រោង ដែលត្រូវបានគេស្នើឡើង, ការពិនិត្យឡើងវិញនឹងធ្វើលើគោលនយោបាយ និងនីតិវិធី ដែលចូលជាធរមាន នៅពេលដែលសំណើត្រូវបានដាក់ទៅកាន់ CRP ។ សម្រាប់គម្រោង ដែលកំពុងអនុវត្ត, ការពិនិត្យឡើងវិញនឹងធ្វើលើគោលនយោបាយ និងនីតិវិធី ដែលចូលជាធរមាន នៅពេលដែលក្រុមប្រឹក្សាភិបាលផ្តល់ការឯកភាពលើគម្រោង ប្រសិនបើពុំមានការបញ្ជាក់ផ្សេង នៅក្នុងឯកសារកម្ចី ឬឯកសារ

ដែលពាក់ព័ន្ធផ្សេងទៀត។ CRP នឹងមិនធ្វើការពិចារណាលើគោលនយោបាយ និងនីតិវិធីរបស់ស្ថាប័នដទៃទៀតឡើយ លើកលែងតែក្នុងកម្រិត ដែលគោលនយោបាយ និងនីតិវិធីរបស់ធនាគារអភិវឌ្ឍន៍អាស៊ីលើកឡើងយ៉ាងច្បាស់លាស់អំពីគោលនយោបាយ និងនីតិវិធីរបស់ស្ថាប័នទាំងនោះ។

## ច. របៀបដាក់សំណើ?

១៥៤. សំណើត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងយកល្អ គួរផ្ញើទៅកាន់ "មន្ត្រីទទួលពាក្យបណ្តឹង (CRO)"។ សំណើនឹងត្រូវបានទទួលតាមរយៈបញ្ញើរ, ទូរសារ, អ៊ីមេល ឬការផ្ញើរដោយផ្ទាល់ទៅ CRO នៅការិយាល័យកណ្តាលរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ សំណើក៏នឹងទទួលដោយការិយាល័យរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដូចជា ស្ថានបេសកកម្ម ឬការិយាល័យតំណាងជាដើម ដែលនឹងបញ្ជូនសំណើទាំងនេះបន្តទៅកាន់ CRO។ ភាសាផ្លូវការរបស់យន្តការគណនេយ្យភាព គឺភាសាអង់គ្លេស ប៉ុន្តែសំណើអាចសរសេរជាភាសាផ្លូវការ ឬភាសានៅមូលដ្ឋានរបស់ប្រទេសកំពុងអភិវឌ្ឍជាសមាជិករបស់ធនាគារអភិវឌ្ឍន៍អាស៊ីក៏បាន។ នៅក្នុងករណីដែលសំណើត្រូវបានសរសេរដោយប្រើប្រាស់ភាសាផ្សេងក្រៅពីភាសាអង់គ្លេស, គេត្រូវការពេលវេលាបន្ថែម សម្រាប់ការបកប្រែ។ អត្តសញ្ញាណរបស់អ្នកដាក់សំណើនឹងរក្សាជាការសម្ងាត់ ប្រសិនបើមានការស្នើសុំឱ្យមានការរក្សាការសម្ងាត់ ប៉ុន្តែសំណើអនាមិកនឹងមិនត្រូវបានទទួលយកឡើយ។

១៥៥. សំណើត្រូវបញ្ជាក់ពីចំណុច ដូចខាងក្រោម:

(i) ឈ្មោះ, មុខតំណែង, អាសយដ្ឋាន និងព័តិមានទំនាក់ទំនងរបស់អ្នកដាក់សំណើ និងតំណាងរបស់ពួកគេ បើមាន

(ii) ប្រសិនបើសំណើមួយត្រូវបានធ្វើឡើង តាមរយៈតំណាង, ត្រូវមានការបញ្ជាក់ពីអត្តសញ្ញាណរបស់អ្នករងផលប៉ះពាល់ដោយសារគម្រោង ដែលត្រូវបានគេតំណាងឱ្យនៅក្នុងការដាក់សំណើ និងភ័ស្តុតាងបង្ហាញពីការអនុញ្ញាត ដែលពួកគេផ្តល់ដល់តំណាងរបស់ពួកគេ

(iii) ថាតើអ្នកដាក់សំណើជ្រើសរើសឱ្យមានការរក្សាការសម្ងាត់អំពីអត្តសញ្ញាណរបស់ពួកគេដែរឬទេ

(iv) ថាតើអ្នកដាក់សំណើចង់ឆ្លងកាត់តាមការដោះស្រាយបញ្ហាសិនជាមួយ OSPF ឬការពិនិត្យឡើងវិញជាមុនជាមួយ CRP

(v) សេចក្តីពណ៌នាសង្ខេបអំពីគម្រោង ដែលទទួលបានជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី ដោយមានរៀបរាប់ពីឈ្មោះ និងទីតាំងរបស់គម្រោង

(vi) សេចក្តីពណ៌នាអំពីផលប៉ះពាល់ដោយផ្ទាល់ និងគួរឱ្យកត់សម្គាល់ ដែលបានបង្ក ឬទំនងជានឹងបង្កឡើងដោយគម្រោង ដែលទទួលបានជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី ដែលទទួលរងដោយអ្នកដាក់សំណើ

(vii) ការពន្យល់ពីមូលហេតុ ដែលអ្នកដាក់សំណើទាមទារថា ផលប៉ះពាល់ដោយផ្ទាល់ និងគួរឱ្យកត់សម្គាល់ ដែលពួកគេចោទប្រកាន់នេះ គឺជា ឬនឹងជាលទ្ធផលនៃការខកខានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ទៅតាមគោលនយោបាយ និងនីតិវិធីប្រតិបត្តិការការងាររបស់ខ្លួន នៅក្នុងការបង្កើត, ដំណើរការ ឬការអនុវត្តគម្រោង ដែលទទួលបានជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី

(viii) សេចក្តីពិពណ៌នាអំពីគោលនយោបាយ និងនីតិវិធីប្រតិបត្តិការការងារ ដែលមិនត្រូវបានគេអនុលោមតាម ដោយធនាគារអភិវឌ្ឍន៍អាស៊ី នៅក្នុងការ បង្កើត, ដំណើរការ ឬការអនុវត្តគម្រោង ដែលទទួលបានជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី ប្រសិនបើដឹង

(ix) សេចក្តីពិពណ៌នាអំពីកិច្ចខិតខំប្រឹងប្រែង ដោយសុច្ឆន្ទៈរបស់អ្នកដាក់សំណើ ដើម្បីដោះស្រាយបញ្ហាជាមុនសិន ជាមួយនាយកដ្ឋានប្រតិបត្តិការ ឬជាមួយយន្តការដោះស្រាយការកើតទុក្ខមិនសុខចិត្ត ដែលពាក់ព័ន្ធ និងលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងទាំងនេះ

(x) បើអាច សេចក្តីពិពណ៌នាអំពីកិច្ចខិតខំប្រឹងប្រែងរបស់អ្នកដាក់សំណើ ដើម្បីស្វែងរកការឆ្លើយតបចំពោះសំណើរបស់ពួកគេជាមួយ OSPF ឬ CRP និងលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងទាំងនេះ

(xi) លទ្ធផល ឬសកម្មភាពកែតម្រូវចង់បាន ដែលអ្នករងផលប៉ះពាល់ដោយសារគម្រោងជឿថា ធនាគារអភិវឌ្ឍន៍អាស៊ីគួរផ្តល់ ឬគួរជួយ តាមរយៈយន្តការគណនេយ្យភាពនេះ

(xii) ការពន្យល់ពីមូលហេតុ ដែលគេមិនអាចផ្តល់ព័ត៌មានខាងលើនេះបាន និង

(xiii) បញ្ហា ឬអង្គហេតុពាក់ព័ន្ធដទៃទៀត ដែលមានឯកសារគាំទ្រច្បាស់លាស់

១៥៦. ប្រសិនបើ OSPF ឬ CRP ជឿថា គេមិនអាចរក្សាការសម្ងាត់អំពីអត្តសញ្ញាណរបស់អ្នកដាក់សំណើបានទេ ពួកគេគួរផ្តល់ព័ត៌មានដល់អ្នកដាក់សំណើអំពីហានិភ័យនេះ និងផ្តល់ឱកាសឱ្យពួកគេពិចារណាឡើងវិញលើសំណើរបស់ពួកគេ ។

១៥៧. OSPF និង CRP ត្រូវធ្វើការកំណត់ដោយឯករាជ្យ ថាតើសំណើនេះបំពេញទៅតាមលក្ខណៈវិនិច្ឆ័យសមស្របរបស់ពួកគេដែរឬទេ ។ OSPF និង CRP នឹងចែករំលែកព័ត៌មាន និងការវិភាគអំពីសំណើនេះដោយពេញលេញ ជាមួយគ្នាទៅវិញទៅមក ។ ប៉ុន្តែ OSPF និង CRP ត្រូវធ្វើការកំណត់ដោយឯករាជ្យពីរបៀបប្រើប្រាស់ព័ត៌មាន និងការវិភាគ

នេះ។

## ឆ. ការចាប់ផ្តើមដំណើរការលើសំណើ

១៥៨. អ្នកដាក់សំណើត្រូវធ្វើការសម្រេចចិត្តថាតើពួកគេចង់ចាប់ផ្តើមជាមួយការដោះស្រាយបញ្ហាមុន ឬជាមួយការពិនិត្យឡើងវិញលើភាពអនុលោមមុន។ ពួកគេអាចចាកចេញពីការដោះស្រាយបញ្ហា ឬការពិនិត្យឡើងវិញលើភាពអនុលោម នៅពេលណាក៏បាន។ ដំណើរការបន្ត ដែលពួកគេកំពុងស្ថិតនៅ នឹងត្រូវបានបញ្ឈប់ ប្រសិនបើអ្នកដាក់សំណើចាកចេញ[៤២]។ អ្នកដាក់សំណើមិនអាចដាក់សំណើពាក់ព័ន្ធជាមួយនឹងបញ្ហាដដែល ទៅកាន់ OSPF ឬ CRP លើសពីម្តងបានឡើយ។ CRP នឹងស្នើឱ្យគណៈគ្រប់គ្រងផ្តល់ការឆ្លើយតប បន្ទាប់ពីបានទទួលសំណើរួច និងមុនពេលធ្វើការកំណត់ពីភាពសមស្របរបស់សំណើ។ ជាការឆ្លើយតបទៅនឹងលទ្ធផលរកឃើញរបស់ CRP, គណៈគ្រប់គ្រងនឹងលើកជាអនុសាសន៍អំពីវិធានការ និង/ឬសកម្មភាព ដើម្បីធ្វើឱ្យគម្រោងមានភាពអនុលោម។ OSPF និង CRP នឹងកំណត់ពីភាពសមស្របរបស់សំណើនីមួយៗ ដោយឯករាជ្យពីគ្នា។

១៥៩. ជំហានដែលត្រូវអនុវត្តតាម មានរៀបរាប់ខាងក្រោម។ គ្រប់ចំនួនថ្ងៃទាំងអស់ គឺសំដៅលើចំនួនថ្ងៃធ្វើការលើកលែងតែកាលបរិច្ឆេទសម្រាប់ឱ្យក្រុមប្រឹក្សាភិបាលធ្វើការពិចារណា ដែលគិតតាម ២១ ថ្ងៃប្រតិទិន ផ្អែកតាមវិធានដែលមានស្រាប់របស់ធនាគារអភិវឌ្ឍន៍អាស៊ី។

### ១. ការទទួលសំណើ

១៦០. **ជំហានទី ១: ការទទួលសំណើ** - អ្នកដាក់សំណើ ឬតំណាងរបស់ពួកគេដាក់សំណើទៅកាន់មន្ត្រីទទួលពាក្យបណ្តឹង (CRO)។ សំណើ ដែលទទួលដោយនាយកដ្ឋាន ឬការិយាល័យផ្សេងទៀតរបស់ធនាគារអភិវឌ្ឍន៍អាស៊ី នឹងត្រូវផ្ញើទៅកាន់ CRO។ CRO ត្រូវបញ្ជាក់ថាបានទទួលសំណើនេះភ្លាម ហើយត្រូវផ្ញើកញ្ចប់ព័ត៌មានជាមូលដ្ឋានអំពីយន្តការគណនេយ្យភាពដល់អ្នកដាក់សំណើ។ CRO ត្រូវជូនដំណឹងដល់អ្នកសម្របសម្រួលគម្រោងពិសេស (SPF), ប្រធាន CRP និងនាយកដ្ឋានប្រតិបត្តិការដែលពាក់ព័ន្ធអំពីការទទួលបានសំណើនេះ ហើយត្រូវចម្លងលិខិតរបស់អ្នកដាក់សំណើ ផ្ញើជូនអ្នកទាំងនេះ។

១៦១. **ជំហានទី ២: ការជួបប្រជុំជាមួយ OSPF** - ក្នុងកំឡុងពេល ២ ថ្ងៃបន្ទាប់ពីបានទទួលសំណើរួច, CRO នឹង

---

[៤២] ដំណើរការដោះស្រាយបញ្ហា ឬពិនិត្យឡើងវិញលើភាពអនុលោម នឹងត្រូវបានបញ្ឈប់ ប្រសិនបើអ្នកដាក់សំណើដកខ្លួនចេញ។

ជួបជាមួយ SPF ឬជាមួយបុគ្គលិករបស់ OSPF ដែលត្រូវបាន SPF ចាត់តាំងឱ្យរួមគ្នាពិនិត្យ និងការធ្វើការសម្រេចចិត្តថាតើត្រូវបន្តបញ្ជូនសំណើនេះទៅកន្លែងណាទៀត។ CRO និងបុគ្គលិករបស់ OSPF នឹងរៀបចំលិខិតរួមគ្នាមួយ ដើម្បីបញ្ជាក់ពីមូលហេតុនៃការបញ្ជូនសំណើនេះ ទៅកាន់នាយកដ្ឋាន ឬការិយាល័យជាក់លាក់ណាមួយ។ លិខិតនេះត្រូវផ្ញើទៅកាន់ SPF, ប្រធាន CRP និងនាយកដ្ឋានប្រតិបត្តិការដែលពាក់ព័ន្ធ និងចម្លងជូន BCRC។ ប្រសិនបើអ្នកដាក់សំណើ មិនបានបង្ហាញច្បាស់លាស់អំពីការចង់ឱ្យមានការពិនិត្យឡើងវិញលើភាពអនុលោម និងមិនបានបង្ហាញព័ត៌មានគ្រប់គ្រាន់ និងច្បាស់លាស់អំពីការខិតខំប្រឹងប្រែងដោយសុច្ឆន្ទៈរបស់ខ្លួន ដើម្បីដោះស្រាយបញ្ហាជាមួយនាយកដ្ឋានប្រតិបត្តិការនោះទេ នោះសំណើនេះនឹងត្រូវផ្ញើទៅកាន់ OSPF ឬ នាយកដ្ឋានប្រតិបត្តិការ។

១៦២. **ជំហានទី ៣ - ការបន្តបញ្ជូនសំណើ** - មិនឱ្យហួសពីរយៈពេល ១ ថ្ងៃ ក្រោយកិច្ចប្រជុំនៅក្នុងជំហានទី ២, CRO នឹងបន្តបញ្ជូនសំណើទៅកាន់ (i) OSPF ប្រសិនបើអ្នកដាក់សំណើបង្ហាញពីបំណងចង់ឱ្យមានការដោះស្រាយបញ្ហាជាមុនសិន ឬមិនបានបង្ហាញពីបំណងអ្វីទាំងអស់ និងបានបង្ហាញនូវព័ត៌មានយ៉ាងច្បាស់លាស់ និងគ្រប់គ្រាន់អំពីកិច្ចខិតខំប្រឹងប្រែងដោយសុច្ឆន្ទៈរបស់ពួកគេ ដើម្បីដោះស្រាយបញ្ហា ជាមួយនាយកដ្ឋានប្រតិបត្តិការ និងយន្តការដោះ-ស្រាយការកើតទុក្ខមិនសុខចិត្តរបស់គម្រោង ដែលពាក់ព័ន្ធ, (ii) OCRP ប្រសិនបើអ្នកដាក់សំណើចង់ចាប់ផ្ដើមជាមួយនឹងការពិនិត្យឡើងវិញលើភាពអនុលោម និងបានបង្ហាញនូវព័ត៌មានយ៉ាងច្បាស់លាស់ និងគ្រប់គ្រាន់អំពីកិច្ចខិតខំប្រឹងប្រែងដោយសុច្ឆន្ទៈរបស់ពួកគេ ដើម្បីដោះស្រាយបញ្ហា ជាមួយនាយកដ្ឋានប្រតិបត្តិការ និងយន្តការដោះស្រាយការកើតទុក្ខមិនសុខចិត្តរបស់គម្រោង ដែលពាក់ព័ន្ធ, (iii) នាយកដ្ឋានប្រតិបត្តិការ ប្រសិនបើអ្នកដាក់សំណើមិនបានប្រឹងប្រែងដោយសុច្ឆន្ទៈ ដើម្បីដោះស្រាយបញ្ហាជាមួយនាយកដ្ឋានប្រតិបត្តិការ និងជាមួយយន្តការដោះស្រាយការកើតទុក្ខមិនសុខចិត្តរបស់គម្រោង ដែលពាក់ព័ន្ធ, ឬមិនបានផ្ដល់នូវព័ត៌មានច្បាស់លាស់ និងគ្រប់គ្រាន់អំពីកិច្ចខិតខំប្រឹងប្រែងទាំងនេះ, (iv) ការិយាល័យប្រឆាំងអំពើពុករលួយ និងសុច្ចរិតភាព (OAI) ប្រសិនបើសំណើពាក់ព័ន្ធជាមួយនឹងអំពើពុករលួយ, (v) ការិយាល័យសេវាប្រតិបត្តិការកណ្ដាល (COSO) និង/ឬ OAI ប្រសិនបើសំណើពាក់ព័ន្ធនឹងលទ្ធកម្ម, (vi) នាយកដ្ឋាន ឬការិយាល័យដទៃទៀត ទៅតាមការសមស្រប។

១៦៣. CRO នឹងចម្លងសំណើនេះទៅកាន់ SPF, ប្រធាន CRP ឬនាយកដ្ឋានប្រតិបត្តិការ ដែលពាក់ព័ន្ធ។CRO នឹងជូនដំណឹងដល់អ្នកដាក់សំណើ និងតំណាងដែលទទួលបានការអនុញ្ញាតពីពួកគេ អំពីស្ថានភាពនៃសំណើ និងអ្នកដែលត្រូវទាក់ទង សម្រាប់ជំហានបន្តបន្ទាប់ទៀត។

១៦៤. **ជំហានទី ៤: ការចុះបញ្ជីសំណើ** - មិនឱ្យលើសពីរយៈពេល ២ ថ្ងៃ ក្រោយពេលបញ្ជូនសំណើទៅកាន់នាយក-

ដ្ឋាន និងការិយាល័យពាក់ព័ន្ធ, CRO នឹងចុះបញ្ជីសំណើនេះ នៅលើគេហទំព័រដែលពាក់ព័ន្ធ ហើយផ្ញើការបញ្ជាក់ថាបានទទួលទៅកាន់អ្នកដាក់សំណើ ។

១៦៥. សម្រាប់សំណើ ដែលត្រូវបានបញ្ជូនបន្តទៅកាន់នាយកដ្ឋានប្រតិបត្តិការ ដោយសារតែកង្វះកិច្ចខិតខំប្រឹងប្រែងដោយសុច្ឆន្ទៈជាមុនរបស់អ្នកដាក់សំណើ, នាយកដ្ឋានប្រតិបត្តិការនឹងធ្វើការដោះស្រាយបញ្ហា ។ នៅចុងដំណើរការនេះ នាយកដ្ឋានប្រតិបត្តិការនឹងចេញនូវរបាយការណ៍មួយ សង្ខេបពីសំណើ, បញ្ហា, ជំហានដែលបានធ្វើ ដើម្បីដោះស្រាយបញ្ហាទាំងនេះ, ការសម្រេចចិត្តរបស់ភាគីដែលពាក់ព័ន្ធ, កិច្ចព្រមព្រៀងដែលឈានដល់, លទ្ធផល និងមេរៀននានា ។ នាយកដ្ឋានប្រតិបត្តិការនឹងផ្សព្វផ្សាយរបាយការណ៍នេះ តាមរយៈគេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។

## ២. មុខងារដោះស្រាយបញ្ហា

១៦៦. ដំណើរការដោះស្រាយបញ្ហា ត្រូវបានគេគិតទុកថា នឹងប្រើរយៈពេលប្រហែលជា ១៦០ថ្ងៃ ដោយគិតចាប់តាំងពីថ្ងៃស្នើសុំជាមួយធនាគារអភិវឌ្ឍន៍អាស៊ី រហូតដល់ទទួលបានការព្រមព្រៀងគ្នាទៅលើសកម្មភាពដែលត្រូវកែតម្រូវ ។ រយៈពេលនេះ មិនរាប់បញ្ចូលពេលវេលាបកប្រែ ការស្នើសុំពន្យាពេលណាមួយដើម្បីផ្តល់ព័ត៌មាន ឬឯកសារ និងពេលវេលាដែលត្រូវការដោយភាគីពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហារបស់ពួកគេក្នុងអំឡុងពេលអនុវត្តទៅលើសកម្មភាព ដែលបានព្រមព្រៀងគ្នានោះឡើយ ។

១៦៧. ក្នុងអំឡុងពេលធ្វើកិច្ចពិគ្រោះយោបល់ប្រចាំប្រទេស នាឆ្នាំ ២០១០ សហគមន៍មូលដ្ឋានបានបង្ហាញពីសេចក្តីប្រាថ្នារបស់ពួកគេក្នុងការដោះស្រាយបញ្ហានៅក្នុងមូលដ្ឋានដើម្បីពន្លឿនដំណើរការ ឧទាហរណ៍ ការដោះស្រាយធ្វើដោយការិយាល័យតំណាងធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំប្រទេស ។ ដោយមើលឃើញបែបនេះ ក្នុងដំណាក់កាលណាមួយ OSPF អាចផ្ទេរអំណាចក្នុងការដោះស្រាយបញ្ហាដោយពេញលេញ ឬដោយផ្នែកណាមួយ ទៅនាយកដ្ឋានប្រតិបត្តិការដែលពាក់ព័ន្ធ ប្រសិនបើខ្លួនគិតថា ការផ្ទេរអំណាចនេះ នឹងជួយលើកកម្ពស់ប្រសិទ្ធភាពក្នុងការដោះស្រាយបញ្ហា ។ OSPF នឹងសម្រេចពីកម្រិត និងលក្ខណៈដែលខ្លួននឹងធ្វើការដោះស្រាយបញ្ហាទៅតាមករណីដោយករណី ។ ជំហាននីមួយៗ សម្រាប់ដោះស្រាយបញ្ហាត្រូវបានសង្ខេបជូនដូចខាងក្រោម ។

១៦៨. **ជំហានទី ១: ការកំណត់ភាពសមស្រប:** បន្ទាប់ពីទទួលស្គាល់សំណើក្នុងរយៈពេល២១ថ្ងៃ គិតចាប់ពីថ្ងៃទទួលបាន SPF នឹងត្រួតពិនិត្យសំណើ និងកំណត់ពីភាពសមស្រករបស់វា[៤៣] ។ ដើម្បីទទួលបានសំណើថាមានភាព

[៤៣] ការបញ្ជូនសំណើបន្តពី CRO ទៅ SPF មិនរារាំង SPF មិនឱ្យធ្វើការវាយតម្លៃដោយឯករាជ្យលើសំណើឡើយ ។

សមស្រប SPF ត្រូវការសំណើមានគ្រប់លក្ខណៈវិនិច្ឆ័យ ហើយស្ថិតនៅក្នុងបញ្ជីដូចបានលើកឡើងក្នុងផ្នែក E ខាងលើ។ ឧទាហរណ៍ SPF នឹងពិនិត្យឡើងវិញ ហើយបញ្ជាក់ថាតើមានកិច្ចខិតខំប្រឹងប្រែងដោយសុច្ឆន្ទៈគ្រប់គ្រាន់ ដោយអ្នកស្នើសុំដែរឬទេ ក្នុងការដោះស្រាយបញ្ហាជាមួយនាយកដ្ឋានប្រតិបត្តិ។ នេះមានសារៈសំខាន់ណាស់ ពីព្រោះថា ក្នុងករណីខ្លះ វាមិនអាចធ្វើទៅបានទេសម្រាប់ CRO ដើម្បីធ្វើការសម្រេច ថាតើកិច្ចខិតខំប្រឹងប្រែងដោយសុច្ឆន្ទៈបានធ្វើហើយ ឬនៅ។ SPF គួរតែស្វែងយល់ផងដែរ ថាតើមានការស្នើសុំឱ្យរក្សាភាពសម្ងាត់ដែរទេ។

១៦៩. ជាការបន្ថែម SPF តម្រូវឱ្យមាន (i) សំណើរច្បាស់លាស់ ហើយមិនស្ថិតនៅក្នុងការមិនរាប់បញ្ចូលណាមួយ។ ហើយ (ii) SPF ជឿថា នៅក្នុងមុខងារដាច់ដោយឡែករបស់ខ្លួន ការជាប់ពាក់ព័ន្ធរបស់ខ្លួន វាអាចមានប្រយោជន៍ច្រើន។ កត្តាផ្សេងៗសម្រាប់ធ្វើការពិចារណា រួមបញ្ចូលថាតើ ADB ត្រូវតែមាន ឬក៏ត្រូវបន្តអំណាចរបស់ខ្លួនដើម្បីធ្វើការផ្លាស់ប្តូរ និងថាតើការដោះស្រាយបញ្ហានឹងត្រូវបានជ្រៀតជ្រែក ឬក៏រារាំងដោយដំណើរការពាក់ព័ន្ធណាមួយមុនពេលទៅដល់តុលាការ ការកាត់ក្តីដោយមជ្ឈត្តកម្ម ឬស្ថាប័នត្រួតពិនិត្យណាមួយប្រហាក់ប្រហែលគ្នានេះ។

១៧០. អ្នកដែលរងផលប៉ះពាល់ក៏ត្រូវការការណែនាំផងដែរទៅលើយន្តការគណនេយ្យភាព ហើយតម្រូវឱ្យមានចំណេះដឹងគ្រប់គ្រាន់ ដើម្បីធ្វើការជ្រើសរើស។ ក្នុងដំណាក់កាលកំណត់ពីភាពសមស្រប ក៏នឹងពន្យល់ពីយន្តការគណនេយ្យភាពដល់អ្នកស្នើសុំផងដែរ។ SPF នឹងផ្តល់ព័ត៌មានដល់អ្នកស្នើសុំនូវជម្រើសពីរដូចតទៅ: (i) អ្នកស្នើសុំអាចបន្តយកដំណើរការដោះស្រាយបញ្ហា ឬ (ii) អ្នកស្នើសុំអាចបោះបង់ដំណើរការដោះស្រាយបញ្ហា ហើយដាក់ពាក្យស្នើសុំ ដើម្បីធ្វើការពិនិត្យភាពអនុលោមឡើងវិញ។ SPF នឹងបញ្ជាក់ភាពខុសប្លែកគ្នាក្រោមមុខងារទាំងពីរនេះ ឧទាហរណ៍ បង្ហាញថា មុខងារដោះស្រាយបញ្ហាមានគោលបំណងដោះស្រាយបញ្ហានៅហ្នឹងកន្លែង និងសម្របសម្រួលការដោះស្រាយបញ្ហា ហើយការកែតម្រូវទាំងឡាយក្រោមមុខងារត្រួតពិនិត្យភាពអនុលោមឡើងវិញ គឺផ្តោតទៅលើការពិនិត្យភាពអនុលោមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ទៅនឹងគោលនយោបាយ និងនីតិវិធីប្រតិបត្តិការការងារផ្សេងៗទៀតរបស់ខ្លួន។ ដំណើរការនេះអាច ឬមិនអាចកាត់បន្ថយភាពខូចខាត ដោយផ្អែកទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលលើ លទ្ធផលពិនិត្យឡើងវិញលើភាពអនុលោម ដែលបានមកពីការកំណត់បង្ហាញនៃភាពមិនអនុលោមទៅនឹងគោលនយោបាយ និងនីតិវិធីប្រតិបត្តិការការងារផ្សេងៗរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ SPF នឹងផ្តល់ទៅអ្នកស្នើសុំចំនួន ៧ ថ្ងៃ គិតចាប់ពីទទួលបានរបាយការណ៍រកឃើញរបស់ SPF ដើម្បីឆ្លើយតបដល់ SPF ដោយភ្ជាប់ជាមួយសេចក្តីសម្រេចរបស់អ្នកស្នើសុំ។

១៧១. ក្នុងអំឡុងពេលកំណត់ភាពសមស្រប SPF អាចពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធទាំងអស់ រួមទាំង

បុគ្គលិកធនាគារអភិវឌ្ឍន៍អាស៊ី អ្នកស្នើសុំទាំងឡាយ រដ្ឋាភិបាលរបស់ប្រទេសកំពុងអភិវឌ្ឍជាសមាជិក ឬអ្នកឧបត្ថម្ភគម្រោងឯកជន និងសមាជិកក្រុមប្រឹក្សាភិបាលដែលតំណាងឱ្យប្រទេសដែលពាក់ព័ន្ធ។ ការកំណត់ភាពសមស្របមានរួមទាំង ការពិនិត្យឯកសារឡើងវិញក្នុងការិយាល័យ ឬការចុះត្រួតពិនិត្យមូលដ្ឋាន។

១៧២. SPF នឹងធ្វើរបាយការណ៍ស្តីពីសេចក្តីសម្រេចចិត្តទៅលើភាពសមស្របដល់ប្រធានធនាគារអភិវឌ្ឍន៍អាស៊ី ហើយចំលង ជូនអនុប្រធានធនាគារអភិវឌ្ឍន៍អាស៊ី ដែលពាក់ព័ន្ធ។

១៧៣. **ជំហានទី ២: ការពិនិត្យឡើងវិញ និងការវាយតម្លៃ:** SPF នឹងពិនិត្យ និងវាយតម្លៃសំណើដើម្បី (i) យល់ដឹងពីប្រវត្តិនៃសំណើ (ii) បញ្ជាក់អះអាងអ្នកដែលពាក់ព័ន្ធ (iii) ស្រាយបភ្លឺបញ្ហា និងជម្រើសសម្រាប់ដោះស្រាយ (iv) ស្វែងរកការត្រៀមខ្លួនជាស្រេចរបស់អ្នកពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហារួមគ្នា និង (iv) ផ្តល់អនុសាសន៍ថាតើ ត្រូវធ្វើដូចម្តេចដើម្បីឱ្យដំណើរការដោះស្រាយបញ្ហាអាចដំណើរការបានល្អបំផុត។

១៧៤. ការត្រួតពិនិត្យឡើងវិញអាចរួមបញ្ចូល ការចុះពិនិត្យមូលដ្ឋាន ធ្វើសម្ភាសន៍ ប្រជុំជាមួយអ្នកស្នើសុំ រដ្ឋាភិបាល ឬអ្នកឧបត្ថម្ភគម្រោងឯកជន ក៏ដូចជាអ្នកពាក់ព័ន្ធដទៃទៀតដែល SPF យល់ឃើញថាមានប្រយោជន៍។ SPF នឹងទទួលព័ត៌មានពីនាយកដ្ឋានប្រតិបត្តិ ហើយប្រសិនជាចាំបាច់ នឹងស្នើសុំយោបល់ និងការគាំទ្រពីនាយកដ្ឋានប្រតិបត្តិ។ SPF នឹងរៀបចំបេសកកម្មស្វែងយល់មួយ ឬលើសពីមួយដោយខ្លួនឯង ឬចូលរួមក្នុងការពិគ្រោះយោបល់ជាមួយនាយកដ្ឋានប្រតិបត្តិ នៅក្នុងបេសកកម្មត្រួតពិនិត្យគម្រោងពិសេស ដែលធ្វើឡើងដោយនាយកដ្ឋានប្រតិបត្តិ។ SPF នឹងបញ្ចប់ការពិនិត្យឡើងវិញ និងការវាយរម្លៃ ហើយធ្វើរបាយការណ៍ពីការរកឃើញរបស់ខ្លួនទៅប្រធាន ADB ដោយមានចំលងជូនអនុប្រធាន ADB ដែលពាក់ព័ន្ធ។ SPF នឹងផ្ញើរជូនការរកឃើញរបស់ខ្លួនទៅអ្នកស្នើរសុំ នាយកដ្ឋានប្រតិបត្តិ និងរដ្ឋាភិបាល ឬអ្នកទ្រទ្រង់គម្រោងឯកជន ដើម្បីស្នើសុំយោបល់។ ដោយផ្អែកលើការវាយតម្លៃ និងយោបល់ដែលទទួលបាន SPF នឹងសម្រេចថាតើ (i) បន្តដោះស្រាយបញ្ហា ឬកំណត់ថា គ្មានការបន្តដោះស្រាយបញ្ហាតទៅទៀត ហើយបញ្ចប់ដំណើរការ។ SPF នឹងមាន ១២០ ថ្ងៃ គិតចាប់ពីការកំណត់ភាពសមស្របដើម្បីបញ្ចប់ដំណាក់កាលនេះ។

១៧៥. **ជំហានទី ៣: ដំណើរការដោះស្រាយបញ្ហា:** ប្រសិនបើ SPF សម្រេចបន្តដំណើរការ ខ្លួននឹងជួយភាគីដែលពាក់ព័ន្ធឱ្យចូលរួមក្នុងដំណើរការពិគ្រោះយោបល់ ដែលមានគោលបំណងដោះស្រាយបញ្ហា។ ដំណើរការដោះស្រាយបញ្ហា នឹងផ្អែកទៅលើស្ថានភាពដាច់ដោយឡែកពីគ្នា ហើយអាចរួមបញ្ចូលក្នុងចំណោមយុទ្ធវិធីដទៃទៀតដូចជា (i) ការពិគ្រោះយោបល់ (ii) ការចែករំលែកព័ត៌មាន (iii) ការស្វែងរកការពិតរួម ឬ (iv) ការសម្របសម្រួល។

១៧៦. ការអនុវត្តន៍ដំណើរការដោះស្រាយបញ្ហាតម្រូវឱ្យមានការព្រមព្រៀងពីគ្រប់ភាគីដែលពាក់ព័ន្ធ។ ភាគីដែលពាក់ព័ន្ធទាំងអស់ លើកលែងតែ SPF អាច “ដើរចេញ” ពីដំណើរការដោះស្រាយបញ្ហា ប្រសិនបើពួកគេគិតថា ដំណើរការនេះ គ្មានចេតនាដោះស្រាយបញ្ហាច្បាស់លាស់ ឬគ្មានការឯកច្ឆន្ទលើរបៀបដោះស្រាយបញ្ហា។ បើយើងសម្រេចធ្វើដូចនេះ ត្រូវបានគេចាត់ទុកថា នឹងបិទដំណើរការដោះស្រាយបញ្ហាជាផ្លូវការ។

១៧៧. សកម្មភាពកែតម្រូវដែលបានអនុម័តចេញពីដំណើរការដោះស្រាយបញ្ហា នឹងឆ្លុះបញ្ចាំងពីកិច្ចព្រមព្រៀងមួយរវាងភាគីដែលពាក់ព័ន្ធ ហើយក្នុងករណីភាគច្រើនសកម្មភាគកែតម្រូវទាំងនេះ នឹងត្រូវបានគេបញ្ជាក់ក្នុងកិច្ចព្រមព្រៀងជាលាយលក្ខ័អក្សរមួយ ឬក៏បញ្ជាក់ក្នុងកិច្ចព្រមព្រៀងតាមលំដាប់ដែលរៀបចំដោយភាគីដែលពាក់ព័ន្ធ។ សកម្មភាពកែតម្រូវទាំងនេះទាក់ទងនឹងការផ្លាស់ប្តូរដ៏ធំមួយនៅក្នុងគម្រោង ហើយនឹងតម្រូវឱ្យមានការអនុម័តដោយគណៈគ្រប់គ្រង ឬក្រុមប្រឹក្សាភិបាល ដោយយោងទៅលើនីតិវិធីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងកិច្ចព្រមព្រៀងជាមួយអ្នកខ្ចី។

១៧៨. នៅពេលដែលដំណោះស្រាយបញ្ហាត្រូវបានបញ្ចប់ (ទោះជាមាន ឬគ្មានដំណោះស្រាយក៏ដោយ) SPF នឹងដាក់ជូនរបាយការណ៍ទៅប្រធាន ហើយចំលងជូននាយកដ្ឋានប្រតិបត្តិ ដោយធ្វើការសង្ខេបពីសំណើ វិធីអនុវត្តដើម្បីដោះស្រាយបញ្ហា ការសម្រេចដោយភាគីដែលពាក់ព័ន្ធ និងកិច្ចព្រមព្រៀង (ប្រសិនជាមាន) ដែលបានព្រមព្រៀងដោយភាគីដែលពាក់ព័ន្ធ។ SPF នឹងចេញរបាយការណ៍នេះ ហើយផ្ញើរជូនអ្នកស្នើសុំ រដ្ឋាភិបាល ឬអ្នកទ្រទ្រង់គម្រោងឯកជន និងក្រុមប្រឹក្សាភិបាលសម្រាប់ជាព័ត៌មាន។ បន្ទាប់ពីដាក់ជូនក្រុមប្រឹក្សាភិបាល របាយការណ៍នឹងត្រូវបានផ្សព្វផ្សាយជាសាធារណៈ ដោយយោងទៅលើការឯកភាពរបស់អ្នកស្នើសុំ និងរដ្ឋាភិបាល ឬអ្នកទ្រទ្រង់គម្រោងឯកជន។

១៧៩. **ជំហានទី ៤: ការត្រួតពិនិត្យ:** SPF នឹងត្រួតពិនិត្យរាល់ការអនុវត្តន៍នៃសកម្មភាពកែតម្រូវទាំងឡាយដែលបានព្រមព្រៀងគ្នា។ SPF នឹងធ្វើរបាយការណ៍ជាប្រចាំឆ្នាំទៅប្រធាន ដោយមានចំលងជូនក្រុមប្រឹក្សាភិបាលទាក់ទងនឹងការអនុវត្តន៍នៃសកម្មភាពកែតម្រូវទាំងឡាយ។ ជាផ្នែកមួយនៃសកម្មភាពត្រួតពិនិត្យ SPF នឹងពិគ្រោះយោបល់ជាមួយនាយកដ្ឋានប្រតិបត្តិ អ្នកស្នើសុំ និងរដ្ឋាភិបាល ឬក៏អ្នកឧបត្ថម្ភគម្រោងឯកជន។ ពេលវេលាសម្រាប់ត្រួតពិនិត្យ នឹងផ្តោតលើសកម្មភាពជាក់លាក់របស់គម្រោង ប៉ុន្តែជាទូទៅមិនលើសពីពីរឆ្នាំឡើយ។ អ្នកដែល ជាប់ពាក់ព័ន្ធទាំងអស់ រួមទាំងផ្នែកសាធារណៈ អាចផ្ញើរព័ត៌មានទាក់ទងនឹងការអនុវត្តន៍រាល់សកម្មភាពកែតម្រូវទៅ SPF។ របាយការណ៍ត្រួតពិនិត្យរបស់ SPF នឹងផ្ញើរជូនអ្នកស្នើសុំ និងរដ្ឋាភិបាល ឬអ្នកឧបត្ថម្ភគម្រោងឯកជន ហើយនឹងចុះ

ផ្សាយលើគេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ប៉ុន្តែត្រូវមានការយល់ព្រមពីអ្នកស្នើសុំ និងរដ្ឋាភិបាល ឬអ្នកឧបត្ថម្ភគម្រោងឯកជនសិន បន្ទាប់ពីត្រូវបានដាក់ជូនទៅប្រធាន ហើយបន្តទៅក្រុមប្រឹក្សាភិបាលសម្រាប់ជាព័ត៌មាន។

១៨០. **ជំហានទី ៥: សេចក្តីសន្និដ្ឋាននៃដំណើរការដោះស្រាយបញ្ហា:** នៅពេលការអនុវត្តន៍នៃសកម្មភាពកែតម្រូវត្រូវបានបញ្ចប់ SPF នឹងរៀបចំរបាយការណ៍ចុងក្រោយមួយ ហើយផ្ញើរជូនប្រធាន អ្នកស្នើសុំ នាយកដ្ឋានប្រតិបត្តិ រដ្ឋាភិបាល ឬអ្នកឧបត្ថម្ភគម្រោងឯកជន និងក្រុមប្រឹក្សាភិបាលសម្រាប់ជាព័ត៌មាន។ របាយការណ៍ចុងក្រោយនឹងផ្សព្វផ្សាយជាសាធារណៈ ប៉ុន្តែត្រូវមានការយល់ព្រមពីអ្នកស្នើសុំ និងរដ្ឋាភិបាល ឬអ្នកឧបត្ថម្ភគម្រោងឯកជនជាមុនសិន។

## ៣. មុខងារពិនិត្យឡើងវិញលើភាពអនុលោម

១៨១. អ្នកស្នើសុំនឹងដឹងថាតើ ក្រុមប្រឹក្សាភិបាលបានអនុញ្ញាតឱ្យមានការត្រួតពិនិត្យឡើងវិញទៅលើភាពអនុលោមដែលពួកគេបានស្នើសុំ ប្រហែលជា៦០ថ្ងៃក្រោយពីទទួលបានការចុះឈ្មោះស្នើសុំត្រួតពិនិត្យឡើងវិញទៅលើភាពអនុលោម។ ពួកគេនឹងដឹងលទ្ធផលនូវសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលប្រហែលជា ២៤០ថ្ងៃគិតចាប់ពីថ្ងៃទទួលការចុះឈ្មោះសម្រាប់ស្នើសុំឱ្យមានការត្រួតពិនិត្យឡើងវិញទៅលើភាពអនុលោម។ រយៈពេលនេះមិនរួមបញ្ចូលពេលវេលាសម្រាប់រៀបចំបកប្រែ និងការស្នើសុំណាមួយសម្រាប់ពន្យាពេលដើម្បីផ្តល់ព័ត៌មាន និងឯកសារផ្សេងៗទៀត។ ជំហានដែលបានបង្ហាញសម្រាប់ការត្រួតពិនិត្យឡើងវិញទៅលើភាពអនុលោមបានសង្ខេបជូនដូចខាងក្រោម។

១៨២. **ជំហានទី ១: ស្នើសុំការឆ្លើយតបពីគណៈគ្រប់គ្រង** - CRP នឹងបញ្ជូនសំណើទៅកាន់គណៈគ្រប់គ្រង និងស្នើសុំការឆ្លើយតបពីគណៈគ្រប់គ្រង នៅក្នុងកំឡុងពេល ២១ ថ្ងៃ។ CRP ក៏ត្រូវជូនដំណឹងដល់សមាជិករបស់ក្រុមប្រឹក្សាភិបាល ដែលតំណាងឱ្យប្រទេសកំពុងអភិវឌ្ឍជាសមាជិក អំពីសំណើនេះផងដែរ។ នៅក្នុងការឆ្លើយតបរបស់ខ្លួន, គណៈគ្រប់គ្រងត្រូវផ្តល់ភ័ស្តុតាងបង្ហាញថា (i) ខ្លួនបានអនុលោមទៅតាមគោលនយោបាយ និងនីតិវិធីប្រតិបត្តិការការងារដែលពាក់ព័ន្ធរបស់ធនាគារអភិវឌ្ឍន៍អាស៊ី, ឬ (ii) មានការខកខានធ្ងន់ធ្ងរ ដោយសារតែសកម្មភាព ឬការខកខានមិនបានធ្វើសកម្មភាព អនុលោមទៅតាមគោលនយោបាយ និងនីតិវិធីប្រតិបត្តិការការងារដែលពាក់ព័ន្ធរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ប៉ុន្តែគណៈគ្រប់គ្រងមានបំណងចាត់វិធានការ ដើម្បីធានាឱ្យមានភាពអនុលោម, ឬ (iii) មានការខកខានធ្ងន់ធ្ងរ ដោយសារតែអ្នកខ្ចីកម្ចី ឬដោយសារកត្តាដទៃទៀត នៅខាងក្រៅធនាគារអភិវឌ្ឍន៍អាស៊ី, ឬ (iv) មានការខកខានធ្ងន់ធ្ងរ ដែលអាចកើតឡើង ដោយសារតែការអមិនអនុលោមរបស់ធនាគារ

អភិវឌ្ឍន៍អាស៊ី និងដោយសារអ្នកខ្ចីកម្ចី ឬភាគីខាងក្រៅដទៃទៀត។ OCRP ត្រូវចម្លងជូន BCRC នូវការឆ្លើយតបរបស់ខ្លួនជាមួយអ្នកគ្រប់គ្រង។

១៨៣. **ជំហានទី ២: កំណត់ពីភាពសមស្រប** – ក្នុងកំឡុងពេល ២១ ថ្ងៃ បន្ទាប់ពីបានទទួលការឆ្លើយតបពីគណៈ-គ្រប់គ្រង, CRP នឹងកំណត់ពីភាពសមស្រប[៨៨] របស់សំណើ។ ដើម្បីកំណត់ពីភាពសមស្រប, CRP នឹងធ្វើការពិនិត្យឡើងវិញលើសំណើ, ការឆ្លើយតបរបស់គណៈគ្រប់គ្រង និងឯកសារពាក់ព័ន្ធដទៃទៀត។ ដើម្បីចាត់ទុកសំណើមួយថាមានភាពសមស្រប, CRP ត្រូវតែពេញចិត្តថា សំណើនេះបានបំពេញទៅតាមលក្ខណៈវិនិច្ឆ័យកំណត់ពីភាពសមស្រប និងមិនស្ថិតនៅក្នុងករណីដកចេញ ដែលត្រូវបានរៀបរាប់នៅក្នុងផ្នែក ង ខាងលើ។ ឧទាហរណ៍ CRP នឹងពិនិត្យឡើងវិញ រួចធ្វើការបញ្ជាក់ថាតើអ្នកដាក់សំណើបានខិតខំប្រឹងប្រែងដោយសុច្ឆន្ទៈគ្រប់គ្រាន់ នៅក្នុងការដោះស្រាយបញ្ហាជាមួយនាយកដ្ឋានប្រតិបត្តិការ ដែលពាក់ព័ន្ធដែរឬទេ។ ការបញ្ជាក់បែបនេះគឺមានសារៈសំខាន់ណាស់ ដោយសារតែនៅក្នុងករណីមួយចំនួនមន្ត្រីទទួលពាក្យបណ្តឹងមិនអាចធ្វើការសម្រេចថាតើកន្លងមក មានកិច្ចខិតខំប្រឹងប្រែង ដោយសុច្ឆន្ទៈដែរឬអត់នោះទេ។ CRP គួរពិនិត្យថាតើមានការស្នើឱ្យរក្សាការសម្ងាត់ដែរឬទេ។ លើសពីនេះ CRP ក៏ត្រូវពេញចិត្តផងដែរថា (i) មានភ័ស្តុតាងបង្ហាញពីភាពមិនអនុលោម, (ii) ភាពមិនអនុលោមនេះបានបង្ក ឬទំនងជាបង្កឱ្យមានផលប៉ះពាល់ដោយផ្ទាល់ និងគួរឱ្យកត់សម្គាល់ ដល់អ្នកដែលរងផលប៉ះពាល់ដោយសារគម្រោង និង (iii) ភាពមិនអនុលោមនេះមានលក្ខណៈធ្ងន់ធ្ងរ ដែលតម្រូវឱ្យមានការពិនិត្យឡើងវិញលើភាពអនុលោម។

១៨៤. អ្នកដែលរងផលប៉ះពាល់ក៏ត្រូវការដំបូន្មានអំពីយន្តការគណនេយ្យភាពផងដែរ និងត្រូវការចំណេះដឹងគ្រប់គ្រាន់ ដើម្បីធ្វើការសម្រេចចិត្ត។ ដំណាក់កាលកំណត់ពីភាពសមស្របនេះ ក៏នឹងមានការពន្យល់ដល់អ្នកដាក់សំណើអំពីយន្តការគណនេយ្យភាពនេះផងដែរ។ CRP ត្រូវជូនដំណឹងដល់អ្នកដាក់សំណើនូវជម្រើស ២ ដូចខាងក្រោម: (i) អ្នកដាក់សំណើអាចបន្តដំណើការដោះស្រាយបញ្ហានេះបន្តទៀត ឬ (ii) អ្នកដាក់សំណើអាចបោះបង់ចោលដំណើការដោះស្រាយបញ្ហា ហើយដាក់សំណើឱ្យមានការពិនិត្យឡើងវិញលើភាពអនុលោមវិញ។ CRP នឹងបង្ហាញពីភាពខុសគ្នានៃមុខងារទាំងពីរនេះ ឧ. បង្ហាញថា មុខងារដោះស្រាយបញ្ហា មានគោលបំណងឆ្លើយតបទៅនឹងបញ្ហានៅនឹងមូលដ្ឋានជាក់ស្តែង និងសម្របសម្រួលការដោះស្រាយបញ្ហា ហើយការកែតម្រូវក្រោមមុខងារពិនិត្យឡើងវិញលើភាពអនុលោមវិញផ្តោតសំខាន់លើការស៊ើបអង្កេតលើភាពអនុលោមរបស់ធនាគារអភិវឌ្ឍន៍ ទៅតាមគោលនយោបាយនិងនីតិវិធីប្រតិបត្តិការការងាររបស់ខ្លួន។ គេអាចកាត់បន្ថយផលប៉ះពាល់នានា ប្រសិនបើសមស្រប បន្ទាប់មានការ

---

[៨៨] ការបញ្ជូនសំណើបន្តពី CRO ទៅ CRP មិនរារាំង CRP មិនឱ្យធ្វើការវាយតម្លៃដោយឯករាជ្យលើសំណើឡើយ។

សម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាលអំពីលទ្ធផលនៃការពិនិត្យឡើងវិញលើភាពអនុលោម ដែលធ្វើឱ្យមានការកំណត់ពីភាពមិនអនុលោមរបស់ធនាគារអភិវឌ្ឍន៍ ទៅតាមគោលនយោបាយ និងនីតិវិធីប្រតិបត្តិការការងាររបស់ខ្លួន។ CRP នឹងផ្តល់ពេល ៧ ថ្ងៃ ដល់អ្នកដាក់សំណើ ឱ្យធ្វើការឆ្លើយតបចំពោះ CRP ជាមួយនឹងការសម្រេចចិត្តរបស់ខ្លួន បន្ទាប់ពីបានទទួលលទ្ធផលរកឃើញរបស់អ្នកសម្របសម្រួលគម្រោងពិសេសរួចមក។

១៨៥. នៅក្នុងដំណាក់កាលកំណត់ពីភាពសមស្របនេះ, CRP អាចពិគ្រោះយោបល់ជាមួយគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ដូចជា គណៈគ្រប់គ្រង និងបុគ្គលិក, អ្នកដាក់សំណើ, រដ្ឋាភិបាលរបស់ប្រទេសកំពុងអភិវឌ្ឍជាសមាជិក ឬអ្នកឧបត្ថម្ភគម្រោងឯកជន និងសមាជិកក្រុមប្រឹក្សាភិបាលតំណាងឱ្យប្រទេសដែលពាក់ព័ន្ធ។ ការកំណត់ពីភាពសម-ស្រប អាចមានជាការពិនិត្យឡើងវិញក្នុងការិយាល័យ និង/ឬការចុះទៅកាន់ទីតាំងជាក់ស្តែង។ CRP នឹងរៀបចំរបាយការណ៍បង្ហាញពីភាពសមស្រប។ ប្រសិនបើ CRP កំណត់ថា សំណើនេះមិនមានលក្ខណៈសមស្របទេ, CRP នឹងជូនដំណឹងដល់ក្រុមប្រឹក្សាភិបាលអំពីភាពមិនសមស្របរបស់សំនេះនេះ។ ប្រសិនបើ CRP កំណត់ថា សំណើនេះមានលក្ខណៈសមស្រប, CRP នឹងផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលថា អាចអនុញ្ញាតឱ្យមានការពិនិត្យឡើងវិញលើភាពអនុលោមបាន។ CRP នឹងជូនដំណឹងដល់អ្នកដាក់សំណើអំពីការសម្រេចចិត្តរបស់ខ្លួន បន្ទាប់ពីកំណត់ភាពសមស្របរួច។

១៨៦. **ជំហានទី ៣: ការអនុញ្ញាតរបស់ក្រុមប្រឹក្សាភិបាលឱ្យធ្វើការពិនិត្យឡើងវិញលើភាពអនុលោម** - CRP ត្រូវដាក់អនុសាសន៍របស់ខ្លួនទៅកាន់ក្រុមប្រឹក្សាភិបាល ដោយមានភ្ជាប់ជាមួយនូវសំណើ និងការឆ្លើយតបរបស់គណៈ-គ្រប់គ្រង។ ក្នុងរយៈពេល ២១ ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលអនុសាសន៍របស់ CRP, ក្រុមប្រឹក្សាភិបាលនឹងធ្វើការពិចារណា ហើយអនុញ្ញាតឱ្យមានការពិនិត្យឡើងវិញលើភាពអនុលោម។ ក្នុងកំឡុងពេល ៧ ថ្ងៃ បន្ទាប់ពីបានទទួលការអនុញ្ញាតពីក្រុមប្រឹក្សាភិបាល, អ្នកដាក់សំណើនឹងទទួលបានព័ត៌មានអំពីការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាល និងរបាយការណ៍បង្ហាញពីភាពសមស្រប ហើយការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាលនឹងត្រូវផ្សព្វផ្សាយ តាមរយៈគេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

១៨៧. **ជំហានទី ៤: ការធ្វើការពិនិត្យឡើងវិញលើភាពអនុលោម** - CRP នឹងចាប់ផ្តើមធ្វើការពិនិត្យឡើងវិញលើភាពអនុលោម ភ្លាមៗបន្ទាប់ពីបានទទួលការអនុញ្ញាតពីក្រុមប្រឹក្សាភិបាល។ ប្រធាន CRP ដោយមានការពិគ្រោះ-យោបល់ជាមួយ BCRC នឹងធ្វើការសម្រេចចិត្តជ្រើសរើសសមាជិករបស់គណៈកម្មការ (ម្នាក់ ឬច្រើននាក់) ដើម្បីធ្វើការពិនិត្យឡើងវិញនេះ។ ការពិនិត្យឡើងវិញរបស់ CRP ពុំមានពេលវេលាកំណត់ឡើយ ដោយសារតែរយៈពេល

មានការប្រែប្រួល អាស្រ័យទៅតាមលក្ខណៈ, ភាពស្មុគស្មាញ និងវិសាលភាពរបស់គម្រោង និងការចោទប្រកាន់អំពីភាពមិនអនុលោមទៅតាមគោលនយោបាយ។ BCRC នឹងផ្តល់ការឯកភាពលើលក្ខខណ្ឌយោង (TOR) និងក្របខ័ណ្ឌពេលវេលា សម្រាប់ការពិនិត្យឡើងវិញលើភាពអនុលោមនេះ។ មិនឱ្យហួសពី ១៤ ថ្ងៃ បន្ទាប់ពីបានទទួលការអនុញ្ញាតរបស់ក្រុមប្រឹក្សាភិបាលលើការពិនិត្យឡើងវិញរួចមក, CRP នឹងបញ្ចេញលក្ខខណ្ឌយោង ដែលមានបង្ហាញពីវិធីសាស្ត្រ, ក្របខ័ណ្ឌពេលវេលាប៉ាន់ស្មានសម្រាប់ការពិនិត្យឡើងវិញ, ថវិកា និងសមាជិករបស់ (ម្នាក់ ឬច្រើននាក់) ដែលនឹងធ្វើការពិនិត្យឡើងវិញ។ លក្ខខណ្ឌយោងនេះនឹងត្រូវផ្សព្វផ្សាយ នៅក្នុងបញ្ជីចុះសំណើ។

១៨៨. នៅពេញដំណើរការពិនិត្យឡើងវិញលើភាពអនុលោម, CRP នឹងពិគ្រោះយោបល់ជាមួយគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ដូចជា គណៈគ្រប់គ្រង និងបុគ្គលិកធនាគារ, អ្នកដាក់សំណើ, រដ្ឋាភិបាលរបស់ប្រទេសកំពុងអភិវឌ្ឍជាសមាជិក ឬអ្នកឧបត្ថម្ភគម្រោងឯកជន និងសមាជិកក្រុមប្រឹក្សាភិបាល ដែលតំណាងឱ្យប្រទេសពាក់ព័ន្ធ។ ការពិនិត្យឡើងវិញនេះអាចរួមមាន ការពិនិត្យឡើងវិញក្នុងការិយាល័យ, កិច្ចប្រជុំ, ការពិភាក្សា និងការចុះដល់ទីតាំងជាក់ស្តែង។

១៨៩. **ជំហានទី ៥: សេចក្តីព្រាងរបាយការណ៍ និងការឆ្លើយតបរបស់ CRP** - បន្ទាប់ពីបានបញ្ចប់ការពិនិត្យឡើងវិញលើភាពអនុលោមរួចហើយ, CRP នឹងចេញនូវសេចក្តីព្រាងរបាយការណ៍មួយអំពីលទ្ធផលរកឃើញរបស់ខ្លួនសម្រាប់ដាក់ជូនគណៈគ្រប់គ្រង, អ្នកខ្ចីកម្ចី និងអ្នកដាក់សំណើ ដើម្បីសុំជាយោបល់ និងការឆ្លើយតប ក្នុងកំឡុងពេលមិនឱ្យយូរជាង ៤៥ ថ្ងៃ។ CRP ក៏នឹងបញ្ជូនសេចក្តីព្រាងរបាយការណ៍នេះទៅកាន់ BCRC ដើម្បីសុំជាយោបល់ផងដែរ។ របាយការណ៍របស់ CRP ដាក់បញ្ចូលលទ្ធផលរកឃើញ ពាក់ព័ន្ធជាមួយនឹងភាពមិនអនុលោម និងផលប៉ះពាល់នានា។ របាយការណ៍នេះផ្តោតសំខាន់លើថាតើធនាគារអភិវឌ្ឍន៍អាស៊ីខកខានក្នុងកម្រិតធ្ងន់ធ្ងរ មិនបានអនុលោមទៅតាមគោលនយោបាយ និងនីតិវិធីប្រតិបត្តិការការងាររបស់ខ្លួន នៅក្នុងការបង្កើត ដំណើរការ ឬការអនុវត្តគម្រោង ដែលពាក់ព័ន្ធជាមួយនឹងផលប៉ះពាល់អវិជ្ជមានដោយប្រយោល និងគួរឱ្យកត់សម្គាល់ ដូចនៅក្នុងការចោទប្រកាន់ដែរឬទេ។ នៅក្នុងករណីដែលរកឃើញថាមានភាពមិនអនុលោម, របាយការណ៍នេះនឹងផ្តោតសំខាន់លើការកំណត់ពីទំនាក់ទំនងរវាងផលប៉ះពាល់អវិជ្ជមានដោយផ្ទាល់ និងគួរឱ្យកត់សម្គាល់ ដែលត្រូវបានចោទប្រកាន់ នៅក្នុងសំណើ ជាមួយនឹងការខកខានក្នុងកម្រិតធ្ងន់ធ្ងររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងការអនុលោមទៅតាមគោល-នយោបាយ និងនីតិវិធីប្រតិបត្តិការការងាររបស់ខ្លួន[៤៥]។ ដើម្បីវាយតម្លៃលើផលប៉ះពាល់អវិជ្ជមានដោយផ្ទាល់ និងគួរ

---

[៤៥] នៅក្នុងពេលកំណត់ពីលក្ខណៈសមស្រប ឬនៅដំណាក់កាលពិនិត្យឡើងវិញ, ប្រសិនបើ CRP រកឃើញថាផលប៉ះពាល់អវិជ្ជមាន ដោយផ្ទាល់ និងគួរឱ្យកត់សម្គាល់ មិនបង្កឡើងទាំងស្រុង ឬដោយផ្នែក ដោយសារភាពមិនអនុលោមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី, ភាពសមស្រប ឬសេចក្តី

ឱ្យកត់សម្គាល់, គេគួរប្រើប្រាស់ស្ថានភាពគ្មានគម្រោង ជាមូលដ្ឋានសម្រាប់ធ្វើការប្រៀបធៀប ដោយប្រើប្រាស់ព័ត៌មានដែលមាន។ ការមិនសម្រេចទៅតាមលទ្ធផល និងការរំពឹងទុក ដែលមិនបង្កើតនូវផលប៉ះពាល់ដោយផ្ទាល់ និងគួរឱ្យកត់សម្គាល់ បើប្រៀបជាមួយនឹងស្ថានភាពគ្មានគម្រោង នឹងត្រូវបានដកចេញ។ ភាគីនីមួយៗមានសេរីភាពក្នុងការផ្តល់យោបល់លើសេចក្តីព្រាងរបាយការណ៍នេះ ប៉ុន្តែមានតែទស្សនៈយល់ឃើញចុងក្រោយរបស់ CRP លើបញ្ហាទាំងនេះតែប៉ុណ្ណោះ ដែលនឹងត្រូវឆ្លុះបញ្ចាំង នៅក្នុងរបាយការណ៍ចុងក្រោយ។ CRP នឹងរៀបចំតារាងម៉ាទ្រិចមួយសង្ខេបពីការឆ្លើយតបរបស់ខ្លួនចំពោះយោបល់ ដែលបានលើកឡើងដោយគណៈគ្រប់គ្រង, អ្នកដាក់សំណើ និងអ្នកខ្ចីកម្ចី។

១៩០. ការឆ្លើយតបរបស់គណៈគ្រប់គ្រង នឹងបរិយាយពីគោលជំហររបស់គណៈគ្រប់គ្រងលើលទ្ធផលរកឃើញរបស់ CRP។ ប្រសិនបើ CRP សន្និដ្ឋានថា មានផលប៉ះពាល់ដោយផ្ទាល់ និងគួរឱ្យកត់សម្គាល់ ដោយសារភាពមិនអនុលោមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី, នោះការឆ្លើយតបរបស់គណៈគ្រប់គ្រងគួរបញ្ចូលអនុសាសន៍ និង/ឬផែនការសកម្មភាព ដើម្បីធ្វើឱ្យគម្រោងអនុលោមទៅតាមគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងឆ្លើយតបទៅនឹងលទ្ធផលរកឃើញអំពីផលប៉ះពាល់អវិជ្ជមាន ដែលពាក់ព័ន្ធ។ ដោយសារតែភាពជាម្ចាស់ស្របច្បាប់លើគម្រោងអាស្រ័យទៅតាមរដ្ឋាភិបាលរបស់ប្រទេសកំពុងអភិវឌ្ឍជាសមាជិក ឬអ្នកឧបត្ថម្ភគម្រោងឯកជន, ការអនុវត្តអនុសាសន៍ និង/ឬផែនការសកម្មភាព ត្រូវតែមានការឯកភាពពីរដ្ឋាភិបាល ឬអ្នកឧបត្ថម្ភគម្រោងឯកជន។ ការឆ្លើយតបរបស់គណៈគ្រប់គ្រង នឹងត្រូវបានក្រុមប្រឹក្សាភិបាលយកមកធ្វើការពិចារណារួមគ្នាជាមួយនឹងរបាយការណ៍របស់ CRP។

១៩១. **ជំហានទី ៦: របាយការណ៍ចុងក្រោយរបស់ CRP** – ក្នុងកំឡុងពេល ១៤ ថ្ងៃ បន្ទាប់ពីទទួលបានការឆ្លើយតបពីគណៈគ្រប់គ្រង, អ្នកខ្ចីកម្ចី និងអ្នកដាក់សំណើ លើសេចក្តីព្រាងរបាយការណ៍របស់ខ្លួន, CRP នឹងធ្វើការពិចារណាលើការឆ្លើយតបទាំងនេះ និងធ្វើការផ្លាស់ប្តូរទៅតាមការចាំបាច់ មុនពេលចេញរបាយការណ៍ចុងក្រោយទៅឱ្យក្រុមប្រឹក្សាភិបាល ដោយមានភ្ជាប់ជាមួយនូវការឆ្លើយតប ដែលទទួលបានពីគណៈគ្រប់គ្រង, អ្នកខ្ចីកម្ចី និងអ្នកដាក់សំណើ។ លទ្ធផលរកឃើញរបស់ CRP ត្រូវមានការឯកភាពជារួម នៅក្នុងចំណោមសមាជិករបស់គណៈកម្មការនេះ។ នៅក្នុងករណីដែលមិនមានការឯកភាពគ្នាជារួម នឹងមានការបញ្ជាក់ពីទស្សនៈយល់ឃើញភាគច្រើន និងភាគតិច។

---

ព្រាងរបាយការណ៍ពិនិត្យឡើងវិញ នឹងលើកឡើងពីចំណុចនេះ ដោយមិនធ្វើការវិភាគពីផលប៉ះពាល់អវិជ្ជមានដោយផ្ទាល់ គួរឱ្យកត់សម្គាល់ ឬមូលហេតុនៃផលប៉ះពាល់នេះឡើយ។

១៩២. **ជំហានទី ៧៖ ការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាល** - ក្នុងកំឡុងពេល ២១ ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលរបាយការណ៍ចុងក្រោយរបស់ CRP និងការឆ្លើយតបរបស់គណៈគ្រប់គ្រងរួចមក, ក្រុមប្រឹក្សាភិបាលនឹងធ្វើការពិចារណាលើរបាយការណ៍នេះ និងធ្វើការសម្រេចចិត្តចុងក្រោយពាក់ព័ន្ធនឹងអនុសាសន៍ និង/ឬផែនការសកម្មភាពដែលគណៈគ្រប់គ្រងស្នើឡើង ដើម្បីឱ្យគម្រោងមានភាពអនុលោមវិញ និង/ឬកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននានា។ ក្នុងកំឡុងរយៈពេល ៧ ថ្ងៃ ក្រោយការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាល, ការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាល, របាយការណ៍ចុងក្រោយរបស់ CRP ដោយមានភ្ជាប់ជាមួយការឆ្លើយតបរបស់អ្នកខ្ចីកម្ចី និងអ្នកដាក់សំណើ (ទៅតាមការព្រមព្រៀងរបស់ភាគីពាក់ព័ន្ធ) និងការឆ្លើយតបរបស់គណៈគ្រប់គ្រង នឹងត្រូវផ្ញើទៅឱ្យអ្នកដាក់សំណើ និងអ្នកខ្ចីកម្ចី ហើយបន្ទាប់មក ផ្សព្វផ្សាយលើគេហទំព័រ។

១៩៣. **ជំហានទី ៨៖ ការពិនិត្យតាមដាន និងការវាយតម្លៃ** - CRP នឹងពិនិត្យតាមដានការអនុវត្តសកម្មភាពកែតម្រូវនានា។ សកម្មភាពកែតម្រូវទាំងឡាយ ក្នុងវិសាលភាព ឬការអនុវត្តគម្រោង ដែលទទួលបានការឯកភាពពីក្រុមប្រឹក្សាភិបាល នឹងត្រូវអនុវត្ត ទៅតាមនីតិវិធីពាក់ព័ន្ធរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ CRP នឹងរាយការណ៍ពីវឌ្ឍនភាពនៃការអនុវត្តសកម្មភាពកែតម្រូវទាំងនេះជាប្រចាំឆ្នាំ ប្រសិនបើក្រុមប្រឹក្សាភិបាលមិនកំណត់កាលវិភាគផ្សេង សម្រាប់ការរាយការណ៍។ ប្រធាន CRP ដោយមានការពិគ្រោះយោបល់ជាមួយ BCRC នឹងធ្វើការកំណត់ពីសមាជិករបស់ CRP ដែលនឹងធ្វើការពិនិត្យតាមដានប្រចាំឆ្នាំ ជារៀងរាល់ឆ្នាំ។ ក្របខ័ណ្ឌពេលវេលាសម្រាប់ការពិនិត្យតាមដាន គឺអាស្រ័យទៅតាមគម្រោងនីមួយៗ ប៉ុន្តែជាទូទៅមិនត្រូវលើសរយៈពេល ៣ ឆ្នាំឡើយ។ របាយការណ៍ពិនិត្យតាមដានចុងក្រោយ នឹងបញ្ចប់ដំណើរការពិនិត្យឡើងវិញលើភាពអនុលោម។ ការពិនិត្យតាមដានអាចរួមមានការពិគ្រោះយោបល់ជាមួយគណៈគ្រប់គ្រង, អ្នកដាក់សំណើ, រដ្ឋាភិបាលរបស់ប្រទេសកំពុងអភិវឌ្ឍជាសមាជិក ឬអ្នកឧបត្ថម្ភគម្រោងឯកជន និងសមាជិកក្រុមប្រឹក្សាភិបាល, ការពិនិត្យឯកសារ និងការចុះដល់ទីតាំងជាក់ស្តែង។ CRP ក៏នឹងពិចារណាលើព័ត៌មាននានា ដែលទទួលបានពីអ្នកដាក់សំណើ និងសាធារណជន ពាក់ព័ន្ធនឹងស្ថានភាពនៃការអនុវត្តផងដែរ។ CRP នឹងផ្ញើសេចក្តីព្រាងរបាយការណ៍ពិនិត្យតាមដានរបស់ខ្លួន ទៅឱ្យ BCRC ពិនិត្យ។ CRP នឹងបង្ហើយបញ្ចប់របាយការណ៍ទាំងនេះ ដោយពិគ្រោះយោបល់ជាមួយនឹង BCRC មុននឹងផ្តល់របាយការណ៍ទៅឱ្យក្រុមប្រឹក្សាភិបាល, គណៈគ្រប់គ្រង, អ្នកដាក់សំណើ, រដ្ឋាភិបាលរបស់ប្រទេសកំពុងអភិវឌ្ឍជាសមាជិក ឬអ្នកឧបត្ថម្ភគម្រោងឯកជន និងសាធារណជនទូទៅ។

## ៥.　តម្លាភាព និងការផ្សព្វផ្សាយព័ត៌មាន

១៩៤. ការងារដែលបំពេញដោយ OSPF និង CRP នឹងមានតម្លាភាពបំផុត តាមដែលអាចធ្វើបាន ទាំងនៅក្នុងក្របខ័ណ្ឌធនាគារអភិវឌ្ឍន៍អាស៊ី ទាំងចំពោះសាធារណជនទូទៅ។ ការបង្ហាញព័ត៌មានដល់សាធារណជន នឹងធ្វើឡើងស្របទៅតាមគោលនយោបាយប្រាស្រ័យទាក់ទងសាធារណៈរបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ចំណុចដៅជាក់លាក់ដែលពាក់ព័ន្ធជាមួយនឹងការបង្ហាញព័ត៌មាន រួមមាន បញ្ជីសំណើ, ការកំណត់ពីភាពសមស្រប, ការពិនិត្យឡើងវិញ និងការវាយតម្លៃរបស់ SPF, របាយការណ៍ចុងក្រោយរបស់ SPF, លក្ខខណ្ឌយោង (TOR) សម្រាប់ការពិនិត្យឡើងវិញលើភាពអនុលោម, របាយការណ៍ចុងក្រោយរបស់ CRP, ការឆ្លើយតបរបស់គណៈគ្រប់គ្រងចំពោះលទ្ធផលរកឃើញរបស់ CRP, ការឆ្លើយតបរបស់អ្នកដាក់សំណើ និងអ្នកខ្ចីកម្ចី (ទៅតាមការឯកភាពជាមួយភាគីពាក់ព័ន្ធ), ការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាលលើការពិនិត្យឡើងវិញលើភាពអនុលោម, របាយការណ៍ពិនិត្យតាមដានរបស់ CRP និងរបាយការណ៍ប្រចាំឆ្នាំរបស់យន្តការគណនេយ្យភាព ដែលបង្កើតរួមគ្នាដោយ OSFP, OCRP, IED និង RSDD។

១៩៥. OSPF និង OCRP នឹងមានគេហទំព័រផ្ទាល់ខ្លួន ហើយមានសញ្ញាសម្គាល់ និងក្បាលលិខិតពិសេសរៀងៗខ្លួន។ ប៉ុន្តែ គេហទំព័ររបស់ស្ថាប័នទាំងពីរនេះនឹងត្រូវដាក់បញ្ចូល និងភ្ជាប់ទំនាក់ទំនងតាមរយៈទំព័រគោលនៃយន្តការរបស់គណនេយ្យភាពសង្គម ដែលត្រូវបានធ្វើបច្ចុប្បន្នកម្ម និងកែលំអជាប្រចាំ។ ការផ្សព្វផ្សាយព័ត៌មានរបស់ OSPF និង OCRP ទៅកាន់សាធារណជន រួមមានការបង្ហាញជាទូទៅអំពីយន្តការគណនេយ្យភាពជាទូទៅ និងមានការផ្តោតសំខាន់លើប្រធានបទជាក់លាក់។

១៩៦. ធម្មជាតិនៃការដោះស្រាយបញ្ហា និងការពិនិត្យឡើងវិញលើភាពអនុលោម តម្រូវឱ្យមានការរក្សាការសម្ងាត់ក្នុងកម្រិតមួយសមស្រប។ ឧទាហរណ៍ សេចក្តីពិពណ៌នាជាទូទៅអំពីដំណើរការ និងដំណោះស្រាយចុងក្រោយអាចផ្សព្វផ្សាយជាសាធារណៈបាន ប៉ុន្តែព័ត៌មានលំអិតអំពីការពិភាក្សានឹងត្រូវរក្សាជាព័ត៌មានលាក់ការ។ កិច្ចព្រមព្រៀង និងដំណោះស្រាយចុងក្រោយ ក៏នឹងត្រូវលាក់ការសម្ងាត់ផងដែរ ប្រសិនបើភាគីព្រមព្រៀងដូច្នេះ។ ឯកសារ ឬព័ត៌មានទាំងឡាយ ដែលភាគីណាមួយ ផ្ញើទៅកាន់ SPF ឬ CRP ក្នុងទម្រង់ជាឯកសារ ឬព័ត៌មានលាក់ការ មិនអាចបញ្ចេញទៅឱ្យភាគីដទៃទៀត ដោយពុំមានការឯកភាពពីភាគី ដែលផ្ញើឯកសារ ឬព័ត៌មាននោះឡើយ។ នៅពេលមានការស្នើសុំ, SPF និង CRP អាចលាក់អត្តសញ្ញាណរបស់អ្នកដាក់សំណើ មិនឱ្យអ្នកពាក់ព័ន្ធផ្សេងទៀតដឹង។

១៩៧. SPF និង CRP មានសមត្ថកិច្ចចេញសេចក្តីប្រកាសព័ត៌មាន និងធ្វើការប្រាស្រ័យទាក់ទងជាមួយសាធារណ-

ជន។ មុនពេលចេញផ្សាយសេចក្ដីប្រកាសព័ត៌មាន ឬការផ្សព្វផ្សាយព័ត៌មានតាមរយៈប្រព័ន្ធផ្សព្វផ្សាយដទៃទៀត, SPF ឬ CRP ត្រូវជូនដំណឹងដល់នាយកដ្ឋានទំនាក់ទំនងសាធារណៈ មិនមែនសម្រាប់គោលបំណងពិនិត្យឡើងវិញឡើយ ប៉ុន្តែដើម្បីផ្ដល់ឱកាសឱ្យធនាគារអភិវឌ្ឍន៍អាស៊ីត្រៀមការឆ្លើយតបចំពោះសំណួរនានា ដែលអាចចោទសួរដោយប្រព័ន្ធផ្សព្វផ្សាយ ឬដោយសាធារណជន។

១៩៨. SPF និង CRP និងបុគ្គលិកទាំងអស់ ដែលធ្វើការងារផ្នែកយន្តការគណនេយ្យភាព ត្រូវប្រើប្រាស់ឆន្ទានុសិទ្ធិ និងមិនត្រូវទាក់ទាញការចាប់អារម្មណ៍ពីអ្នកដទៃខ្លាំងពេកឡើយ នៅពេលចុះទៅទីតាំងជាក់ស្ដែង ឬបំពេញការងារនៅក្នុងប្រទេសខ្ចីកម្ចី។ SPF និង CRP នឹងមិនផ្ដល់ការសម្ភាសដល់ប្រព័ន្ធផ្សព្វផ្សាយឡើយ នៅដំណាក់កាលណាក៏ដោយនៃដំណើរការរបស់យន្តការគណនេយ្យភាពនេះ។

## ឈ. គោលវិធី

### ១. គោលវិធីទូទៅ

១៩៩. SPF និង CRP នឹងបន្តប្រមូលព័ត៌មានអំពីការអនុវត្តល្អៗ ពាក់ព័ន្ធនឹងការដោះស្រាយបញ្ហា និងការពិនិត្យឡើងវិញលើភាពអនុលោម។ SPF និង CRP អាចប្រើប្រាស់ការពិនិត្យឡើងវិញក្នុងការិយាល័យ, ការសម្ភាស, ការពិភាក្សា, សិក្ខាសាលា, ការពិគ្រោះយោបល់ជាមួយអ្នកជំនាញក្នុងប្រទេស, ការចុះដល់ទីតាំងជាក់ស្ដែង និងគោលវិធីដទៃទៀត។ SPF និង CRP ក៏អាចជួលអ្នកជំនាញ/ទីប្រឹក្សាឱ្យជួយធ្វើការងារខ្លះឱ្យខ្លួនផងដែរ។

### ២. ការចុះដល់ទីតាំងជាក់ស្ដែង

២០០. ក្រុមការងារកំពុងពិចារណាលើជម្រើសជាច្រើន ដើម្បីឆ្លើយតបទៅនឹងបញ្ហានៃការចុះដល់ទីតាំងជាក់ស្ដែងនេះប្រកបដោយប្រសិទ្ធភាព។ ក្រុមការងារនឹងបង្ហើយបញ្ចប់ទស្សនយល់ឃើញរបស់ខ្លួន ដោយធ្វើការពិចារណាលើគ្រប់យោបល់ទាំងអស់ ដែលទទួលបានកន្លងមក និងពីការពិគ្រោះយោបល់ ដែលនឹងធ្វើឡើងបន្តទៀត។

## ញ. ការអនុវត្ត

២០១. យន្តការគណនេយ្យភាពនេះអាចអនុវត្តបានចំពោះគម្រោង ដែលទទួលបានជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ីទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជន។ យន្តការគណនេយ្យភាពនេះក៏អាចអនុវត្តបានចំពោះប្រតិបត្តិការការងារ ដែលប្រើប្រព័ន្ធរបស់ប្រទេសផងដែរ។ ការប្រើប្រាស់ប្រព័ន្ធរបស់ប្រទេសនឹងមិនធ្វើឱ្យមានការផ្លាស់ប្ដូរ

តម្រូវការ និងលក្ខណៈនៃការដោះស្រាយបញ្ហាឡើយ។ ការពិនិត្យឡើងវិញលើភាពអនុលោម នឹងផ្តោតសំខាន់លើតួនាទី និងការទទួលខុសត្រូវ របស់ធនាគារអភិវឌ្ឍន៍អាស៊ី នៅក្នុងការបង្កើត, ដំណើរការ និងអនុវត្តគម្រោង ដោយអនុលោមទៅតាមគោលនយោបាយ ដែលមានចែងពីវិសាលភាពគ្របដណ្តប់លើការប្រើប្រាស់ប្រព័ន្ធរបស់ប្រទេស ដូចជា គោលនយោបាយស្តីពីការការពារសង្គម និងបរិស្ថាន ជាដើម។ យន្តការគណនេយ្យភាពនេះក៏អាចអនុវត្តបានចំពោះសហហិរញ្ញប្បទាន ដែលចាត់ចែងដោយធនាគារអភិវឌ្ឍន៍អាស៊ីផងដែរ។

## VII. ការអនុវត្ត និងតម្រូវការធនធាន

### ក. ការយល់ដឹង និងការរៀនសូត្រ

២០២. OSPF និង OCRP គួរធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានរបស់ខ្លួនជាប្រចាំ (ឧទាហរណ៍ រៀងរាល់ ៣ ឆ្នាំម្តង) និងអនុវត្តសកម្មភាពផ្សព្វផ្សាយ ៣ ប្រភេទផ្សេងៗពីគ្នា។

(i) ក្រុមគោលដៅខាងក្នុង - បង្កើនការយល់ដឹង និងផ្សព្វផ្សាយមេរៀនដល់បុគ្គលិក តាមរយៈសិក្ខាសាលា, វគ្គបណ្តុះបណ្តាល និងវគ្គតម្រង់ទិស។ យន្តការគណនេយ្យភាពគួរដាក់បញ្ចូលជាផ្នែកមួយនៃវគ្គបណ្តុះបណ្តាលបុគ្គលិកជាប្រចាំ ជាពិសេស សម្រាប់អ្នកដឹកនាំបេសកកម្ម។

(ii) ការផ្សព្វផ្សាយនៅកម្រិតគម្រោងគោលដៅ - គោលនយោបាយការពារសង្គម និងបរិស្ថានតម្រូវឱ្យមានការបង្កើតយន្តការដោះស្រាយការកើតទុក្ខមិនសុខចិត្ត នៅកម្រិតគម្រោង។ ធនាគារអភិវឌ្ឍន៍អាស៊ី និងបុគ្គលិករដ្ឋាភិបាល ដែលធ្វើការងារផ្នែកយន្តការដោះស្រាយការកើតទុក្ខមិនសុខចិត្ត គួររៀបចំសិក្ខាសាលាបង្កើនការយល់ដឹង រួមគ្នាជាមួយ ការិយាល័យតំណាងប្រចាំប្រទេស, ក្រុមការងារគម្រោង, អង្គភាពរបស់រដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិ និងទីភ្នាក់ងារប្រតិបត្តិ។ ខិតប័ណ្ណព័ត៌មានសរសេរជាភាសាជាតិ, ក្តារខៀនព័ត៌មានសហគមន៍ និងសម្ភារសោតទស្សន៍ គួរប្រើប្រាស់ ដើម្បីផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋ។ ភាពញឹកញាប់ និងទម្រង់របស់សកម្មភាពនេះ គឺអាស្រ័យទៅតាមលក្ខណៈរបស់គម្រោង។ ធនាគារអភិវឌ្ឍន៍អាស៊ីអាចរិះរកលទ្ធភាពជួលឱ្យអង្គការក្រៅរដ្ឋាភិបាល ឬអង្គការសង្គមស៊ីវិល ដែលមានឈ្មោះល្បី អនុវត្តសកម្មភាពទាំងនេះ។ បញ្ហាយេនឌ័រក៏គួរត្រូវបានយកមកធ្វើការពិចារណា នៅពេលបង្កើតយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានផងដែរ

(iii) កម្រិតជាតិ - OSPF និង OCRP គួរអនុវត្តសកម្មភាពផ្សព្វផ្សាយព័ត៌មានជាទៀងទាត់ នៅ

ក្នុងប្រទេសកំពុងអភិវឌ្ឍជាសមាជិក។ នៅតាម ការិយាល័យតំណាងប្រចាំប្រទេសនីមួយៗ គួរមានការតែងតាំង បុគ្គលិកម្នាក់ ធ្វើជាជនបង្គោលទទួលបន្ទុកដោះស្រាយការកើតទុក្ខមិនសុខចិត្ត ហើយការអនុវត្តល្អបែបនេះ គួរពង្រីកនៅតាមគ្រប់ការិយាល័យតំណាងប្រចាំប្រទេសទាំងអស់។

២០៣. ការបង្កើនការយល់ដឹងអំពីយន្តការគណនេយ្យភាព តម្រូវឱ្យបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី បំពេញតួនាទីជាច្រកផ្សព្វផ្សាយព័ត៌មានអំពីយន្តការគណនេយ្យភាពដល់សហគមន៍មូលដ្ឋាន។ នាយកដ្ឋានប្រតិបត្តិការគួរផ្តោតការយកចិត្តទុកដាក់ជាពិសេសលើគម្រោង ដែលមានលទ្ធភាពខ្ពស់ធ្វើឱ្យមានសំណើ ដូចជា គម្រោងហេដ្ឋារចនាសម្ព័ន្ធធំៗ និងគម្រោង ដែលមានការតាំងទីលំនៅជាថ្មីច្រើន។ គម្រោងទាំងនេះ គួរបង្កើតនូវយន្តការដោះស្រាយការកើតទុក្ខមិនសុខចិត្តនៅថ្នាក់មូលដ្ឋាន ទៅតាមការតម្រូវរបស់គោលនយោបាយការពារសង្គម និងបរិស្ថាន។ បុគ្គលិករបស់គម្រោង គួរផ្សព្វផ្សាយព័ត៌មានឱ្យបានឆាប់ ពោលគឺនៅដើមវដ្តគម្រោង អំពីយន្តការគណនេយ្យភាព និងការប្រើប្រាស់យន្តការនេះសម្រាប់ដោះស្រាយបញ្ហា នៅក្នុងករណីដែលវិធីសាស្ត្រឆ្លើយតបចំពោះផលប៉ះពាល់អវិជ្ជមានរបស់គម្រោងផ្សេងទៀត មិនទទួលបានជោគជ័យ។ យន្តការគណនេយ្យភាព គួរត្រូវបានគេមើលឃើញថាជា ឧបករណ៍ដ៏សំខាន់មួយសម្រាប់ការរៀនសូត្រ និងធានាគុណភាព និងប្រសិទ្ធភាពនៃការអភិវឌ្ឍរបស់គម្រោង។ យន្តការគណនេយ្យភាព, គណៈគ្រប់គ្រង និងបុគ្គលិករបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងក្រុមប្រឹក្សាភិបាល គួរលើកកម្ពស់ឱ្យមានការផ្លាស់ប្តូរវប្បធម៌ ដើម្បីលុបចោលនូវការយល់ឃើញ ដែលថាយន្តការគណនេយ្យភាពនេះ គឺជាយន្តការអវិជ្ជមាន។

## ខ. ការចំណាយ និងតម្រូវការធនធាន

២០៤. ការផ្លាស់ប្តូរ ដែលបានស្នើឡើង ត្រូវការចំណាយបន្ថែម សម្រាប់ផ្នែកខាងក្រោម។

(i) ចំណាយបន្ថែមសម្រាប់ OSPF និង OCRP អាស្រ័យទៅតាមបន្ទុកការងារ។ OSPF ទទួលបានករណីចំនួន ១៣ នៅក្នុងឆ្នាំ ២០០៩ និងចំនួន ៧ នៅក្នុងឆ្នាំ ២០១០។ គោលនយោបាយបច្ចុប្បន្នកម្ម អាចធ្វើឱ្យចំនួនសំណើឱ្យមានការពិនិត្យឡើងវិញលើភាពអនុលោមមានការកើនឡើង ដែលនាំឱ្យមានការកើនឡើងនូវតម្រូវការធនធាន ទាំងធនធានមនុស្ស ទាំងធនធានហិរញ្ញវត្ថុ។

(ii) ការបង្កើនការផ្សព្វផ្សាយព័ត៌មាន។

(iii) ជនបង្គោលទទួលបន្ទុកដោះស្រាយការកើតទុក្ខមិនសុខចិត្តរបស់ ការិយាល័យតំណាងប្រចាំប្រទេស។ មានការស្នើឱ្យការិយាល័យតំណាងប្រចាំប្រទេសនីមួយៗ តែងតាំងបុគ្គលិកម្នាក់ធ្វើជាជនបង្គោលទទួលបន្ទុកដោះស្រាយការកើតទុក្ខមិនសុខចិត្ត។ បុគ្គលិករូបនេះអាចជាបុគ្គលិកក្រៅម៉ោង ឬពេញម៉ោង អាស្រ័យទៅតាមចំនួនសំណើ។

២០៥. ការសន្សំសំចៃចំណាយ អាចធ្វើបានតាមរយៈការបង្កើតនូវរចនាសម្ព័ន្ធយន្តការគណនេយ្យភាពជាមូលដ្ឋានឱ្យបានសមស្រប និងមានភាពបត់បែនគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង។ តុល្យភាពរវាងការបង្កើនចំណាយ និងការសន្សំសំចៃចំណាយ បង្ហាញថា ពុំមានភាពពាក់ព័ន្ធផ្នែកថវិកាជារួមគួរឱ្យកត់សម្គាល់ឡើយ នៅក្នុងការអនុវត្តយន្តការគណនេយ្យភាពថ្មីនេះ បើប្រៀបជាមួយនឹងគោលនយោបាយបច្ចុប្បន្ន។

### គ. កាលបរិច្ឆេទចូលជាធរមាន និងរយៈពេលអន្តរកាល

២០៦. យន្តការគណនេយ្យភាពបច្ចុប្បន្នកម្មនេះ នឹងចូលជាធរមាន ៦ ខែ ចាប់គិតពីកាលបរិច្ឆេទនៃការឯកភាពរបស់ក្រុមប្រឹក្សាភិបាល លើគោលនយោបាយនេះ។ សំណើ ដែលត្រូវបានដាក់ក្រោមយន្តការគណនេយ្យភាពបច្ចុប្បន្ននេះ នឹងត្រូវផ្ទេរឱ្យមកនៅក្រោមយន្តការគណនេយ្យភាពបច្ចុប្បន្នកម្មនេះវិញ។ ដោយសារតែការផ្លាស់ប្តូរ ដែលបានស្នើឡើងនេះ គឺជាការបន្ថែមថ្មី, គេរំពឹងថាអន្តរកាលនឹងមានភាពរលូនទៅមុខ។ បន្ទាប់ពីមានការឯកភាពរបស់ក្រុម-ប្រឹក្សាភិបាលលើគោលនយោបាយនេះរួចមក, សៀវភៅណែនាំអំពីប្រតិបត្តិការការងារនឹងត្រូវបានកែសម្រួល ជំនួសឱ្យសៀវភៅណែនាំបច្ចុប្បន្ន។[៨៦]

## VIII. សំណើសុំការណែនាំពីក្រុមប្រឹក្សាភិបាល

២០៧. នឹងមានការស្នើសុំការណែនាំរបស់ក្រុមប្រឹក្សាភិបាលលើការកែសម្រួល ដែលបានស្នើឡើង លើគោលនយោ-បាយឆ្នាំ ២០០៣ នេះ ដូចដែលបានដាក់ចេញនៅក្នុងផ្នែកទី VI និង VII របស់ឯកសារនេះ។

---

[៨៦] យន្តការគណនេយ្យភាពបច្ចុប្បន្ននេះតម្រូវឱ្យ OSPF, CRP, និង BCRC រៀបចំនីតិវិធីប្រតិបត្តិការ និងរដ្ឋបាល។ នីតិវិធីទាំងនេះមិនត្រូវបានផ្តល់អនុសាសន៍ឱ្យបង្កើតឡើងឡើយ ក្រោមគោលនយោបាយនេះ ដើម្បីកាត់បន្ថយការធ្វើការងារត្រួតគ្នា និងបង្កើនតម្លាភាព។ នីតិវិធីប្រតិបត្តិការ និងរដ្ឋបាល ដែលចាំបាច់នានា គួរត្រូវបានឆ្លុះបញ្ចាំង នៅក្នុងសៀវភៅណែនាំអំពីប្រតិបត្តិការការងារ។

# លក្ខខណ្ឌយោងសម្រាប់ការពិនិត្យឡើងវិញលើយន្តការគណនេយ្យភាព

១. នៅក្នុងឆ្នាំ ១៩៩៥, ធនាគារអភិវឌ្ឍន៍អាស៊ីបានបង្កើតនូវមុខងារអធិការកិច្ចមួយ សម្រាប់ធ្វើជាវេទិកាឱ្យអ្នកទទួលផលរបស់គម្រោង ធ្វើការតវ៉ាទៅកាន់ស្ថាប័នឯករាជ្យអំពីបញ្ហា ដែលពាក់ព័ន្ធជាមួយនឹងភាពអនុលោមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ជាមួយនឹងគោលនយោបាយ និងនីតិវិធីប្រតិបត្តិការការងាររបស់ខ្លួន នៅក្នុងគម្រោង ដែលទទួលបានជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ី[១]។ នៅក្នុងឆ្នាំ ២០០៣, បន្ទាប់ពីមានដំណើរការពិនិត្យឡើងវិញដោយល្អិតល្អន់រួចមក, ធនាគារអភិវឌ្ឍន៍អាស៊ីបានដាក់ឱ្យអនុវត្តនូវយន្តការគណនេយ្យភាពបច្ចុប្បន្ននេះ[២] បន្ថែមពីលើមុខងារអធិការកិច្ច។ យន្តការគណនេយ្យភាពនេះត្រូវបានរៀបចំឡើង ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអភិវឌ្ឍ និងគុណភាពគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី, ឆ្លើយតបចំពោះការព្រួយបារម្ភរបស់អ្នកដែលរងផលប៉ះពាល់ដោយសារគម្រោង និងផ្តល់យុត្តិធមិដល់គ្រប់អ្នកពាក់ព័ន្ធទាំងអស់, ឆ្លុះបញ្ចាំងពីស្តង់ដាវិជ្ជាជីវៈ និងបច្ចេកទេសនៅកម្រិតខ្ពស់បំផុត នៅក្នុងការចាត់ចែងបុគ្គលិក និងប្រតិបត្តិការរបស់ខ្លួន, មានឯករាជ្យភាព និងតម្លាភាពបំផុត តាមដែលអាចធ្វើទៅបាន, និងមានប្រសិទ្ធភាពចំណាយ ប្រសិទ្ធភាពទូទៅ និងបំពេញបន្ថែមលើប្រព័ន្ធត្រួតពិនិត្យ, សវនកម្ម, ត្រួតពិនិត្យគុណភាព និងវាយតម្លៃដទៃទៀត ដែលកំពុងអនុវត្តរួចហើយ នៅក្នុងធនាគារអភិវឌ្ឍន៍អាស៊ី។ យន្តការគណនេយ្យភាពនេះត្រូវបានប្រកាសចូលជាធរមាន នៅថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៣។ នៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំលើកទី ៤៣ របស់ក្រុមប្រឹក្សាភិបាលរបស់ធនាគារអភិវឌ្ឍន៍អាស៊ី នៅទីក្រុង Tashkent ចាប់ពីថ្ងៃទី ១ ដល់ថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១០, ប្រធានធនាគារអភិវឌ្ឍន៍អាស៊ីបានប្រកាសថា ធនាគារអភិវឌ្ឍន៍អាស៊ីនឹងធ្វើការពិនិត្យឡើងវិញរួមគ្នារវាងក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង លើយន្តការគណនេយ្យភាពរបស់ខ្លួន។ ក្រុមការងារចម្រុះដែលមានសមាសភាពពីក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងមួយ ត្រូវបានបង្កើតឡើង សម្រាប់គោលបំណងនេះ។

២. ការពិនិត្យឡើងវិញនេះ មានគោលបំណងពិនិត្យលើវិសាលភាព សម្រាប់ធ្វើការកែលំអយន្តការគណនេយ្យ-ភាព។ ការពិនិត្យឡើងវិញនេះនឹងមានមូលដ្ឋានទូលំទូលាយ ដោយដាក់បញ្ចូលនូវទិដ្ឋភាពដូចខាងក្រោម ក្នុងចំណោមទិដ្ឋភាពដទៃទៀត៖

---

[១] *ការបង្កើតមុខងារអធិការកិច្ច* ធនាគារអភិវឌ្ឍន៍អាស៊ី ១៩៩៥, ម៉ានីល។

[២] *ការពិនិត្យឡើងវិញលើមុខងារអធិការកិច្ច: ការបង្កើតយន្តការគណនេយ្យភាពថ្មី* ធនាគារអភិវឌ្ឍន៍អាស៊ី ២០០៣, ម៉ានីល ("គោលនយោបាយយន្តការគណនេយ្យភាព")

១) ការវាយតម្លៃបទពិសោធន៍ផ្នែកយន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ចាប់តាំងពីឆ្នាំ ២០០៣ មក ដោយធ្វើការឆ្លុះបញ្ចាំងពីបម្លាស់ប្តូរបរិបទនៃប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ជាពិសេស ជាមួយនឹងការអនុម័តលើយុទ្ធសាស្ត្រ ២០២០។

២) ការវិភាគ និងប្រៀបធៀបយន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ជាមួយនឹងយន្តការរបស់ស្ថាប័នប្រហាក់ប្រហែលគ្នា។

៣) ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ដូចជា សាធារណៈជន, អ្នកដែលរងផលប៉ះពាល់ដោយសារគម្រោង, រដ្ឋាភិបាល, សមាជិកក្រុមប្រឹក្សាភិបាលរបស់ធនាគារអភិវឌ្ឍន៍អាស៊ី, គណៈគ្រប់គ្រង, បុគ្គលិកប្រតិបត្តិការ, អង្គការក្រៅរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល។

៤) ការដោះស្រាយបញ្ហាសំខាន់ៗ ដែលរកឃើញចេញពីការវិភាគ, ការប្រៀបធៀប, ការវាយតម្លៃ និងការពិគ្រោះយោបល់។

៥) អនុសាសន៍អំពីការផ្លាស់ប្តូរ និងការកែលំអ នៅក្នុងគោលនយោបាយ, ការបំពេញមុខងាររបស់យន្តការគណនេយ្យភាព និងនីតិវិធីប្រតិបត្តិការការងារ និងរដ្ឋបាលរបស់ធនាគារ ផ្អែកទៅតាមការវិភាគខាងលើ

៣. ការពិនិត្យឡើងវិញនេះ នឹងមានដំណើរការពិគ្រោះយោបល់ជាសាធារណៈមួយ។ ការពិគ្រោះយោបល់នេះគ្រោងនឹងរៀបចំឡើង ដោយមាន ៣ ដំណាក់កាល។ ដំណាក់កាលទី ១ នឹងមានការអញ្ជើញឱ្យសាធារណជនផ្តល់យោបល់លើគោលនយោបាយយន្តការគណនេយ្យភាពបច្ចុប្បន្ន តាមរយៈគេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ ដំណាក់កាលទី ២ គឺជាការពិគ្រោះយោបល់ក្នុងប្រទេសអភិវឌ្ឍផង និងប្រទេសកំពុងអភិវឌ្ឍផង។ ទីតាំងដែលស្នើឡើង រួមមាន ទីក្រុងវ៉ាស៊ីងតោន, ប្រ៊ែងហ្វើដ, តូក្យូ, អ៊ីស្លាម៉ាបាដ និងម៉ានីល។ ការពិគ្រោះយោបល់នេះនឹងមានការចូលរួមពីរដ្ឋាភិបាល, អង្គការក្រៅរដ្ឋាភិបាល, វិស័យឯកជន និងអ្នកទទួលផល និងអ្នករងផលប៉ះពាល់ដោយសារគម្រោង តាមដែលអាចធ្វើទៅបាន។ ដំណាក់កាលទី ៣ នឹងមានការអញ្ជើញសាធារណជនឱ្យផ្តល់យោបល់លើរបាយការណ៍របស់ក្រុមការងារ តាមរយៈគេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី។ គេហទំព័រមួយ ត្រូវបានបង្កើតឡើង សម្រាប់ការពិនិត្យឡើងវិញលើយន្តការគណនេយ្យភាពនេះ។

៤. គេរំពឹងថាការពិនិត្យឡើងវិញនេះនឹងធ្វើឡើង ចាប់ពីខែ មេសា ឆ្នាំ ២០១០ ដល់ ខែ មេសា ឆ្នាំ ២០១១។

៥. បញ្ហាសំខាន់ៗខាងក្រោមនេះ ត្រូវបានដាក់បញ្ចូលទៅក្នុងលក្ខខណ្ឌយោងសម្រាប់អ្នកជំនាញ ដែលជួលមកពីខាងក្រៅ។

i. គោលវិធីសម្រាប់ចុះដល់ទីតាំងគម្រោងជាក់ស្តែង ដែលតម្រូវក្រោមយន្តការគណនេយ្យភាពបច្ចុប្បន្ន ដែលតម្រូវឱ្យមានការអនុញ្ញាតពីប្រទេសខ្ចីកម្ចី ដើម្បីអាចចុះដល់ទីតាំងគម្រោងជាក់ស្តែងបាន។

ii. ការប្រើប្រាស់ដំណាក់កាលពិនិត្យឡើងវិញលើភាពអនុលោម នៅមានកម្រិតតិចតួច។

iii. កម្រិតឯករាជ្យភាពរបស់យន្តការ ដូចជា ឋានានុក្រមនៃការរាយការណ៍, ភាពជាម្ចាស់ និងការផ្សព្វផ្សាយឯកសារយន្តការគណនេយ្យភាព និងបញ្ញាថវិកា, បុគ្គលិក, ការវាយតម្លៃលទ្ធផលការងារ, ការទទួលបានដំបូន្មានច្បាប់ ដោយឯករាជ្យ និងសិទ្ធិជួលអ្នកជំនាញ និងទីប្រឹក្សាឱ្យជួយបំពេញការងារ។

iv. លទ្ធភាពប្រើប្រាស់យន្តការនេះ ពីសំណាក់អ្នកដែលរងផលប៉ះពាល់។

v. លក្ខណៈវិនិច្ឆ័យ ដើម្បីកំណត់ពីភាពសមស្របសម្រាប់ដាក់ពាក្យបណ្តឹង។

vi. ប្រសិទ្ធភាពរបស់ការិយាល័យនៃគណៈកម្មការពិនិត្យឡើងវិញលើភាពអនុលោម (OCRP) និងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី នៅក្នុងការផ្សព្វផ្សាយព័ត៌មាន និងបង្កើនការយល់ដឹងរបស់សាធារណជន (កម្រិតនៃការយល់ដឹងអំពីយន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី)។

vii. ការវាយតម្លៃលើភាពពាក់ព័ន្ធ សម្រាប់ធ្វើឱ្យគម្រោងមានភាពអនុលោម ផ្នែកពេលវេលាដែលចាំបាច់, ការពន្យារពេល និងការកើនឡើងនូវចំណាយហិរញ្ញវត្ថុ។

viii. ការពិចារណាអំពីការព្រួយបារម្ភ ដែលលើកឡើងដោយប្រទេសកំពុងអភិវឌ្ឍជាសមាជិក, ការសង្កេតលើផលប៉ះពាល់ទូលំទូលាយ ដែលយន្តការគណនេយ្យភាពមានមកលើគោលវិធីសម្រាប់ធ្វើសេចក្តីសម្រេចចិត្ត និងជ្រើសរើសគម្រោង របស់ធនាគារអភិវឌ្ឍន៍អាស៊ី។

ix. ការពិនិត្យ និងយោបល់លើវិសាលភាពនៃប្រយោជន៍ ដែលអ្នកដាក់ពាក្យបណ្តឹង និង/ឬអ្នករងផលប៉ះពាល់ជាអវិជ្ជមានទទួលបាន ផ្អែកទៅតាមបទពិសោធន៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី និងស្ថាប័នប្រហាក់ប្រហែលគ្នាដទៃទៀត។

x. បញ្ហាដទៃទៀត ដែលមានសារៈសំខាន់សម្រាប់ធ្វើការកែលំអយន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។

## ការប្រៀបធៀបយន្តការគណនេយ្យភាព

| លរ | វិស័យ | ធនាគារអភិវឌ្ឍន៍អាស៊ី | ធនាគារពិភពលោក | ស្ថាប័នដទៃទៀត |
|---|---|---|---|---|
| ១ | ចំណុចដៅ | គណៈកម្មការអធិការកិច្ច ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៥។<br><br>គណៈកម្មការអធិការកិច្ច ត្រូវបានពិនិត្យឡើងវិញ ក្នុងឆ្នាំ ២០០២/ ២០០៣។<br><br>យន្តការគណនេយ្យភាព ត្រូវបានបង្កើតឡើងក្នុង ឆ្នាំ២០០៣។<br><br>បច្ចុប្បន្ន យន្តការគណ-នេយ្យភាពកំពុងត្រូវបាន ពិនិត្យឡើងវិញ (២០១០)។ | ដំបូង បង្កើតនៅក្នុងចំណោម MDBs -គណៈកម្មការអធិការកិច្ច ត្រូវបានបង្កើតឡើងនៅ ក្នុងឆ្នាំ ១៩៩៣។<br><br>គណៈកម្មការអធិការកិច្ចត្រូវ បានត្រួតពិនិត្យឡើងវិញក្នុងឆ្នាំ ១៩៩៦ និង ១៩៩៩ ដែល នាំឱ្យមានការបញ្ជាក់ក្នុងឆ្នាំ ១៩៩៦ និង ១៩៩៩។ | **IFC:** ការិយាល័យប្រជាពលរដ្ឋ សម្រាប់ ផ្តល់ប្រឹក្សាអំពីភាពអនុលោម (CAO) ត្រូវបានបង្កើតក្នុងឆ្នាំ ១៩៩៩។ CAO បានធ្វើវិសោធនកម្មទៅលើគោលការណ៍ ណែនាំប្រតិបត្តិឆ្នាំ ២០០៤ របស់ខ្លួនក្នុង ឆ្នាំ ២០០៦ និង ២០០៧។<br><br>**IADB** បានបង្កើតយន្តការស៊ើបអង្កេត ឯករាជ្យក្នុងឆ្នាំ ១៩៩៤។ សកម្មភាពនេះ ត្រូវបានពង្រឹងបន្ថែមក្នុងឆ្នាំ ២០១០ ក្នុង លក្ខណៈជាការពិគ្រោះយោបល់ឯករាជ្យ និងយន្តការស៊ើបអង្កេត (ICIM) ។<br><br>**AfDB:** យន្តការពិនិត្យឡើងវិញ ដោយ អ្នកឯករាជ្យ (IRM) ត្រូវបានបង្កើតឡើង ក្នុងឆ្នាំ ២០០៤។ យន្តការនេះត្រូវបានធ្វើ វិសោធនកម្ម ក្នុងខែឧសភា ឆ្នាំ ២០១០ បន្ទាប់ពីការត្រួតពិនិត្យឡើងវិញមួយ ក្នុង ឆ្នាំ២០០៩។<br><br>**EBRD:** មានយន្តការឧបាស្រ័យឯករាជ្យ នៅចន្លោះខែកក្កដា ២០០៤ និង ខែមីនា ២០១០។ យន្តការបណ្តឹងថ្មីរបស់គម្រោង (PCM) ចាប់ផ្តើមដំណើរការ ក្នុងខែមីនា ២០១០។<br><br>**EIB:** យន្តការបណ្តឹងថ្មីត្រូវបានអនុម័ត |

| លរ | វិស័យ | ធនាគារអភិវឌ្ឍន៍អាស៊ី | ធនាគារពិភពលោក | ស្ថាប័នដទៃទៀត |
|---|---|---|---|---|
| | | | | ក្នុងខែកុម្ភៈ ឆ្នាំ២០១០ ដែលយន្តការនេះមានសុពលភាពជំនួសឱ្យគោលនយោបាយយន្តការបណ្តឹង ដែលបានចូលជាធរមានក្នុងខែមិថុនា ២០០៨។<br><br>**JBIC** បានអនុម័តទៅលើ *សេចក្តីសង្ខេបនីតិវិធីដើម្បីដាក់ការជំទាស់ពាក់ព័ន្ធទៅនឹងគោលការណ៍ណែនាំរបស់ JBIC ដើម្បីបញ្ជាក់អំពីការពិចារណាទៅលើបញ្ហាបរិស្ថាន និងសង្គម* ក្នុងឆ្នាំ២០០៣។ នីតិវិធីត្រូវបានធ្វើបច្ចុប្បន្នកម្មក្នុងខែតុលា ២០០៩។<br><br>ក្រុមប្រឹក្សាភិបាល **OPIC** បានអនុម័តទៅលើគោលនយោបាយទូទៅ និងគោលការណ៍ណែនាំស្តីពី *គណនេយ្យភាព* និង *យន្តការប្រឹក្សាយោបល់សម្រាប់ OPIC* និង បានបង្កើតការិយាល័យគណនេយ្យភាពមួយ (OA) ក្នុងឆ្នាំ ២០០៥។ |
| ២ | ចំនួនករណី | ២០០៤-២០១០<br>**SPF**: សរុបចំនួន ៣២។ មានលក្ខណៈសមស្រប ចំនួន១១។<br><br>**CRP**: សរុបចំនួន ៤។ មានលក្ខណៈសមស្រប | ១៩៩៥-២០១០<br>ក្រុមអធិការកិច្ច : សរុប ចំនួន ៧១ ក្នុងនោះ ៣២ មាន លក្ខណៈសមស្រប | **IFC** (២០០០-០៩) សរុបចំនួន ១១០។ មានលក្ខណៈសមស្របសម្រាប់ការដោះស្រាយបញ្ហា ចំនួន ៤៩ , មានលក្ខណៈសមស្របសម្រាប់ធ្វើសវនកម្មទៅលើភាពអនុលោម ចំនួន ៩ , មានលក្ខណៈសមស្របសម្រាប់ការវាយតម្លៃទៅលើភាពអនុលោមចំនួន៩។ គ្មានលក្ខណៈសមស្រប |

| លរ | វិស័យ | ធនាគារអភិវឌ្ឍន៍អាស៊ី | ធនាគារពិភពលោក | ស្ថាប័នដទៃទៀត |
|---|---|---|---|---|
| | | ចំនួន៣។ | | ចំនួន៤៣។<br><br>**IADB** (១៩៩៤-២០១០): មានចំនួន ៣ ចាប់តាំងពីខែកុម្ភៈ ឆ្នាំ ២០១០។<br><br>**AfDB** (២០០៤-១០): សរុបចំនួន៦ ចាប់តាំងពីឆ្នាំ ២០០៧។<br><br>**EBRD** (២០០៤-១០): សរុបចំនួន ៦។<br><br>**EIB** (២០០៧-០៨): សរុបចំនួន ៩។<br><br>**JBIC** (២០០៣-២០១០): គ្មានលក្ខណៈសមស្របចំនួន ១។<br><br>**OPIC** (២០០៥-១០): សរុបចំនួន ៦ ការដោះស្រាយបញ្ហាចំនួន ៣, ការពិនិត្យឡើងវិញទៅលើភាពអនុលោម ចំនួន ៣។ |
| ៣ | ការគ្រប់ដណ្ដប់គោលនយោ-បាយ | គ្រប់គោលនយោបាយ និងនីតិវិធីប្រតិបត្តិទាំងអស់ដែលពាក់ព័ន្ធទៅនឹង ការបង្កើត ការរៀបចំ ដំណើរការ និងការ អនុវត្តន៍គម្រោង ដែលផ្ដល់ហិរញ្ញប្បទាន ដោយធនាគារអភិវឌ្ឍន៍ អាស៊ី។ | គោលនយោបាយប្រតិបត្តិ និងនីតិវិធីផ្ទាល់ខ្លួនរបស់ធនាគារពិភពលោក ពាក់ព័ន្ធទៅនឹង ការរៀបចំ ការវាយតម្លៃ និង/ឬការអនុវត្តគម្រោង។ | **IFC:** ផ្ដោតលើទិដ្ឋភាពផ្នែកបរិស្ថាន និងសង្គម។<br><br>**IADB** និង **AfDB:** គោលនយោបាយប្រតិបត្តិ និងនីតិវិធី។<br><br>**EBRD:** ផ្ដោតលើទិដ្ឋភាពផ្នែកបរិស្ថាន សង្គម និងការបង្ហាញព័ត៌មានជាសាធារណៈ ។<br><br>**EIB:** គោលនយោបាយស្ដីពីអភិបាលកិច្ច |

| លរ | វិស័យ | ធនាគារអភិវឌ្ឍន៍អាស៊ី | ធនាគារពិភពលោក | ស្ថាប័នដទៃទៀត |
|---|---|---|---|---|
| | | | | ស្ថាប័ន, គោលការណ៍ណែនាំយុទ្ធសាស្ត្រ ក្រមសីលធមិ តម្លាភាព និងការទទួលខុសត្រូវរួម, ការប្រឆាំងទៅនឹងអំពើលួចបន្លំ, គោលនយោបាយស្តីពីការផ្តល់កម្ចីតាមវិស័យ, គោលនយោបាយស្តីពីភូមិសាស្ត្រ កិច្ចសហប្រតិបត្តិការជាមួយភាគីទី ៣ និង/ឬ អង្គការអន្តរជាតិ, គោលនយោបាយដែលទាក់ទងទៅនឹងវដ្តគម្រោង និងលទ្ធកម្ម។<br><br>**JBIC:** អ្នកត្រួតពិនិត្យទៅលើគោលការណ៍ណែនាំស្តីពីបរិស្ថាន គឺត្រូវផ្តោតជាក់លាក់ទៅលើការធានាអនុវត្តស្របទៅតាម “*គោលការណ៍ណែនាំសម្រាប់បញ្ជាក់អំពីការពិចារណាទៅលើបញ្ហាបរិស្ថាន និងសង្គម*”។<br><br>**OPIC:** បទដ្ឋានលើផ្នែកបរិស្ថាន សង្គម ពលកម្ម សិទ្ធិមនុស្ស និងតម្លាភាព។ |
| ៤ | លទ្ធកម្ម និង អំពើពុករលួយ | មិនត្រូវបានរាប់បញ្ចូល | មិនត្រូវបានរាប់បញ្ចូល | ស្ថាប័នទាំងអស់សុទ្ធសឹងតែមិនបានរាប់បញ្ចូលទិដ្ឋភាពទាំងពីរនេះ លើកលែងតែ EIB ដែលមានបញ្ចូលលទ្ធកម្ម។ |
| ៥ | កាលបរិច្ឆេទឱសានវាទ | អាស្រ័យទៅតាមការអនុម័តយល់ព្រមរបស់ PCR។ | ត្រូវរៀបចំសំណើជាមុន មុនពេលដកសាច់ប្រាក់កម្ចីក្នុងបរិមាណច្រើនគួរឱ្យកត់សម្គាល់ (ការដកសាច់ប្រាក់ | គិតចាប់ពីពេលបញ្ចប់គម្រោង រហូតដល់រយៈពេល ១២ ខែក្រោយពេលបញ្ចប់គម្រោង លើកលែងតែ EIB ដែលត្រូវដាក់បណ្តឹងក្នុងរយៈពេល ១ ឆ្នាំ ចាប់ពី |

| លរ | វិស័យ | ធនាគារអភិវឌ្ឍន៍អាស៊ី | ធនាគារពិភពលោក | ស្ថាប័នដទៃទៀត |
|---|---|---|---|---|
| | | | រហូតដល់ ៩៥%)។ | កាលបរិច្ឆេទ ដែលអ្នកដាក់ពាក្យបណ្តឹងអាចមានពេលវេលាសមស្រប ដើម្បីជ្រាបអំពីអង្គហេតុនៃមូលដ្ឋាននៃការចោទប្រកាន់ ដែលអង្គហេតុដែលជាមូលដ្ឋាននៃការចោទប្រកាន់ និង IFC ដែលពុំមានកាលបរិច្ឆេទឱសានវាទឡើយ។ |
| ៦ | ចំនួនមនុស្សអប្បបរមា | ២ នាក់ ឬច្រើនជាងនេះ | ២ នាក់ ឬច្រើនជាងនេះ | (១) **AfDB** និង **JBIC**: ២ នាក់ ឬច្រើនជាងនេះ។<br>(២) **IFC, IADB, EIB, EBRD,** និង **OPIC:** ១ នាក់ ឬច្រើនជាងនេះ។ |
| ៧ | ឥទ្ធិពលផ្ទាល់ និងប្រយោល | ចំពោះតែអ្នកដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់ អ្នកដែលទទួលរងផលប៉ះពាល់គួរឱ្យកត់សម្គាល់ និងអ្នកដែលទទួលរងផលប៉ះពាល់អវិជ្ជមាន ប៉ុណ្ណោះ។ | ចំពោះតែអ្នកដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់ អ្នកដែលទទួលរងផលប៉ះពាល់គួរឱ្យកត់សម្គាល់ និងអ្នកដែលទទួលរងផលប៉ះពាល់អវិជ្ជមានប៉ុណ្ណោះ។ | ស្ថាប័នទាំងអស់ត្រូវការពិនិត្យមើល ទៅលើផលប៉ះពាល់ដោយផ្ទាល់ និងគួរឱ្យកត់សម្គាល់ ដើម្បីកំណត់ពីលក្ខណៈសមស្រប លើកលែងតែ EIB និង (អាចជា) IFC ផងដែរ។ |
| ៨ | រចនាសម្ព័ន្ធ | SPF/OSPF<br>CRP/OCRP | គណៈកម្មការអធិការកិច្ច និងលេខាធិការដ្ឋានរបស់គណៈកម្មការ | (១) **IFC, EBRD, EIB, JBIC,** និង **OPIC:** ស្ថាប័ននីមួយៗមានអង្គភាព/ការិយាល័យមួយដែលទទួលខុសត្រូវសម្រាប់ការដោះស្រាយបញ្ហា និងការត្រួតពិនិត្យឡើងវិញទៅលើភាពអនុលោម។ អង្គភាពទាំងនោះរាយការណ៍ទៅប្រធាន (ឬគណៈកម្មាធិការគ្រប់គ្រង |

| លរ | វិស័យ | ធនាគារអភិវឌ្ឍន៍អាស៊ី | ធនាគារពិភពលោក | ស្ថាប័នដទៃទៀត |
|---|---|---|---|---|
| | | | | នៅក្នុងករណី EIB)។<br><br>(២). **AfDB**: ប្រធានអង្គភាពពិនិត្យឡើងវិញទៅលើភាពអនុលោម និង ការសម្រុះសម្រួល (CRMU) គ្រប់គ្រងការងារលើផ្នែកដោះស្រាយបញ្ហា និងគាំទ្រដល់អ្នកជំនាញលើការត្រួតពិនិត្យឡើងវិញទៅលើភាពអនុលោម។<br><br>(៣). **IADB**: មន្ត្រីការិយាល័យប្រជាពលរដ្ឋ គណៈកម្មការ លេខាប្រតិបត្តិ រាយការណ៍ ជូនដល់ក្រុមប្រឹក្សាភិបាល។ |
| ៩ | ការណាត់ជួប និងការផ្តល់របាយការណ៍ | SPF ត្រូវបានតែងតាំងដោយប្រធាន បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សា-ភិបាល និងត្រូវរាយការណ៍ជូនប្រធាន។<br><br>សមាជិក CRP ត្រូវបានតាំងដោយក្រុមប្រឹក្សាភិបាល ដោយតាមអនុសាសន៍របស់ប្រធាន។<br><br>លេខា OCRP ត្រូវបានតែងតាំងដោយ | មានការត្រួតពិនិត្យឡើងវិញទៅលើភាពអនុលោម ដោយគណៈកម្មការអធិការកិច្ចប៉ុណ្ណោះ ។ ពុំមានដំណាក់កាលដោះស្រាយបញ្ហាជាលក្ខណៈផ្លូវការឡើយ។<br><br>សមាជិកគណៈកម្មការធនាគារពិភពលោក ត្រូវបានតែងតាំងដោយក្រុមប្រឹក្សាភិបាល ដោយផ្អែកលើការចាត់តាំងរបស់ប្រធាន ។ គណៈកម្មការនេះ រាយការណ៍ជូនក្រុមប្រឹក្សាភិបាល។ | (១). **AfDB**. ប្រធានអង្គភាពត្រួតពិនិត្យឡើងវិញទៅលើភាពអនុលោម និងការសម្រុះសម្រួល (CRMU) ត្រូវបានតែងតាំងដោយប្រធាន ដោយមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល ។ ប្រធានអង្គភាពផ្តល់របាយការណ៍រដ្ឋបាលជូនដល់ប្រធាន និងផ្តល់របាយការណ៍មុខងារជូនដល់ក្រុមប្រឹក្សាភិបាលសម្រាប់គម្រោងដែលក្រុមប្រឹក្សាភិបាលបានអនុម័ត និងផ្តល់របាយការណ៍ជូនប្រធាន សម្រាប់សំណើគម្រោង ដែលមិនទាន់ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល។ គណៈកម្មការអ្នកឯកទេសត្រូវបានតែងតាំងដោយក្រុមប្រឹក្សាភិបាល |

| លរ | វិស័យ | ធនាគារអភិវឌ្ឍន៍អាស៊ី | ធនាគារពិភពលោក | ស្ថាប័នដទៃទៀត |
|---|---|---|---|---|
| | | ប្រធាន ។ | លេខាប្រតិបត្តិ ៖ ត្រូវបានតែងតាំងដោយប្រធាន បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាភិបាល ។ | ផ្អែកលើអនុសាសន៍របស់ប្រធាន ។<br><br>(២). **IFC, OPIC, EBRD,** និង **EIB** ៖ គ្មានលេខាធិការដ្ឋាន ។ ប្រធានអង្គភាព AM ត្រូវបានតែងតាំងដោយប្រធាន និងត្រូវរាយការណ៍ជូនប្រធាន ។ អង្គភាព EIB រាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រង ។<br><br>(៣). **JBIC** ៖ អ្នកត្រួតពិនិត្យត្រូវបានតែងតាំង និងត្រូវរាយការណ៍ជូនប្រធាន ។ លេខាត្រូវបានតែងតាំងដោយផ្នែកធនធានមនុស្ស ។<br><br>(៤). **IADB** : មន្ត្រីការិយាល័យប្រជា-ពលរដ្ឋ គណៈកម្មការ និងលេខាប្រតិបត្តិត្រូវបានតែងតាំងដោយក្រុមប្រឹក្សាភិបាល និងត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាល ។ |
| ១០ | ទស្សនកិច្ចតាមមូលដ្ឋាន | ទស្សនកិច្ចតាមមូលដ្ឋានធ្វើឡើងដោយមានការពិគ្រោះយោបល់ជាមួយប្រទេសខ្ចីកម្ចី ។ | (១). ប្រើប្រាស់ការិយាល័យប្រចាំប្រទេស ដើម្បីទទួលបានការអនុញ្ញាតធ្វើបេសកកម្ម និងកិច្ចប្រជុំនានា ដូចគ្នាទៅនឹងបេសកកម្មដទៃទៀតដែរ ។<br><br>(២). អធិការកិច្ចនៅក្នុងទឹកដីរបស់ប្រទេសមួយ ត្រូវធ្វើឡើងដោយមានការយល់ព្រមជាមុនពីប្រទេសនោះ (ការប្តេជ្ញាចិត្ត | ១. **IADB** ៖ ផ្នែកណាមួយនៃដំណើរការនេះ ដែលត្រូវធ្វើឡើងនៅក្នុងទឹកដីរបស់ប្រទេសខ្ចីកម្ចី/ប្រទេសទទួលបានថវិកា អាចត្រូវបានធ្វើឡើង បន្ទាប់ពីបានទទួលលិខិតមិនជំទាស់ជាលាយលក្ខណ៍អក្សរពីប្រទេសជាម្ចាស់ផ្ទះប៉ុណ្ណោះ (គោល-នយោបាយឆ្នាំ ២០១០ កឋាខណ្ឌទី ៤៥) ។<br><br>២. **AfDB, EBRD, EIB,** និង **OPIC** ៖ |

| លរ | វិស័យ | ធនាគារអភិវឌ្ឍន៍អាស៊ី | ធនាគារពិភពលោក | ស្ថាប័នដទៃទៀត |
|---|---|---|---|---|
| | | | ឆ្នាំ ១៩៩៣ កឋាខណ្ឌទី ២១)។<br><br>(៣). ទស្សនកិច្ចតាមមូលដ្ឋានបន្ថែមទៀត ត្រូវមានការអញ្ជើញពីប្រទេសដែលជាម្ចាស់ផ្ទះ (សេចក្តីបញ្ជាក់ឆ្នាំ ១៩៩៩ កឋាខណ្ឌទី ១៦)។ | វិធាននានា បានចែងថា គេអាចចុះធ្វើទស្សនកិច្ចតាមមូលដ្ឋានបាន។ ប៉ុន្តែពុំមានការរៀបរាប់អំពីសេចក្តីលម្អិតឡើយ។<br><br>៣. **JBIC** : ពុំមានការរៀបរាប់អំពីទស្សនកិច្ចតាមមូលដ្ឋានឡើយ ប៉ុន្តែអ្នកត្រួតពិនិត្យអាចធ្វើកិច្ចសម្ភាសន៍បាន។ ខ្លឹមសារសង្ខេបរបស់ប្រធានថ្លែងថា JBIC "*គឺជាស្ថាប័នរដ្ឋាភិបាល ដូច្នេះស្ថាប័ននេះ ត្រូវធ្វើការពិចារណាគ្រប់ជ្រុងជ្រោយទៅលើអធិបតេយ្យភាពរបស់ប្រទេសទទួលថវិកា*"។ |

AfDB = ធនាគារអភិវឌ្ឍន៍អាហ្វ្រិច, EBRD = ធនាគារអឺរ៉ុបសម្រាប់ការអភិវឌ្ឍ និងស្តាបនាឡើងវិញ, EIB = ធនាគារវិនិយោគអឺរ៉ុប, IADB = ធនាគារអភិវឌ្ឍន៍អន្តរអាមេរិច, IFC = សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ, JBIC = ធនាគារជប៉ុនសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ, MDB = ធនាគារអភិវឌ្ឍន៍ពហុភាគី, OPIC = សាជីវកម្មវិស័យឯកជនក្រៅប្រទេស (US)។

## ចំនួនករណីនៅក្នុងយន្តការគណនេយ្យភាពផ្សេងៗគ្នា

| **យន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី** | ២០០៤ រហូតដល់ ១៩ វិច្ឆិកា ២០១០ | គណៈកម្មការពិនិត្យឡើងវិញទៅលើភាពអនុលោម | | | អ្នកសម្របសម្រួលគម្រោងពិសេស | | | |
|---|---|---|---|---|---|---|---|---|
| | | សរុប | មានលក្ខណៈសមស្រប | គ្មានលក្ខណៈសមស្រប | សរុប | មានលក្ខណៈសមស្រប | គ្មានលក្ខណៈសមស្រប | លក្ខណៈសមស្រប កំពុងត្រូវបានពិនិត្យសម្រេច |
| | | ៣ | ២ | ១ | ៣២ | ១០ | ២០ | ២ |

ប្រភព : ការចុះបញ្ជីពាក្យបណ្ដឹង គិតត្រឹមថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០១០ (http: //www.adb.org/SPF/registry.asp)

| **គណៈកម្មការអធិការកិច្ចរបស់ធនាគារពិភពលោក** | ១៩៩៤ រហូតដល់ ថ្ងៃទី៨ វិច្ឆិកា ២០១០ | ចំនួនសំណើសរុបដែលបានទទួល | មានលក្ខណៈសមស្រប សម្រាប់ធ្វើការស៊ើបអង្កេត | គ្មានលក្ខណៈសមស្រប សម្រាប់ធ្វើការស៊ើបអង្កេត | គ្មានការផ្ដល់អនុសាសន៍ | ការបន្តមានលក្ខណៈសមស្រប |
|---|---|---|---|---|---|---|
| | | ៧០ | ៣២ | ១៦ | ២០ | ២ |

ប្រភព : របាយការណ៍របស់គណៈកម្មការអធិការកិច្ចរបស់ធនាគារពិភពលោក គិតត្រឹមថ្ងៃទី ៨ ខែវិច្ឆិកា ឆ្នាំ២០១០

| **ការិយាល័យប្រជាពលរដ្ឋទទួលបន្ទុកធ្វើការត្រួតពិនិត្យឡើងវិញទៅលើភាពអនុលោមនៃសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ** | ២០០០ - ២០០៩ | សរុបពាក្យបណ្ដឹងថ្មី | គ្មានលក្ខខណ្ឌសមស្រប | **ការិយាល័យប្រជាពលរដ្ឋ** | **ភាពអនុលោម** | | | |
|---|---|---|---|---|---|---|---|---|
| | | | | សរុប | ត្រូវបានបិទបន្ទាប់ពីមានការវាយតម្លៃពីការិយាល័យប្រជាពលរដ្ឋ និងការវាយតម្លៃទៅលើភាពអនុលោម | សវនកម្មទៅលើភាពអនុលោម | ករណីដែលបន្តមានភាពអនុលោម | សរុប |
| | | ១១០ | ៤៣ | ៤៩ | ៩ | ៦ | ៣ | ១៨ |

ប្រភព : របាយការណ៍ប្រចាំឆ្នាំរបស់ CAO ២០០៨-០៩

| ការពិគ្រោះយោបល់ឯករាជ្យ និងយន្តការស៊ើបអង្កេត នៃធនាគារអភិវឌ្ឍន៍អន្តរអាមេរិច | ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៤ ត្រូវបានទទួលស្គាល់ក្នុងខែ កុម្ភៈ ឆ្នាំ ២០១០ | សរុបករណីដែលបានចុះបញ្ជី (ចាប់តាំងពីខែ កុម្ភៈ ឆ្នាំ ២០១០) |
|---|---|---|
| | | ៣ |

ប្រភព : http://www.iadb.org/en/mici/registry-of-cases,1805.html

| យន្តការត្រួតពិនិត្យឡើងវិញឯករាជ្យ នៃធនាគារអភិវឌ្ឍន៍អាហ្វ្រិច | ២០០៤-២០១០ | សរុបចំនួនករណីចុះបញ្ជីនៅក្នុង IRM (ចាប់តាំងពីឆ្នាំ ២០០៧) |
|---|---|---|
| | | ៦ |

ប្រភព : http://www.afdb.org/en/about-us/structure/independent-review-mechanism/requests-register/

| យន្តការបណ្ដឹងរបស់គម្រោងនៃធនាគារអឺរ៉ុបសម្រាប់ការអភិវឌ្ឍ និងការស្ថាបនាឡើងវិញ | មានយន្តការឧបាស្រ័យឯករាជ្យ ចាប់តាំងពីឆ្នាំ ២០០៤ និងជំនួសដោយ PCM ខែមីនា ២០១០ | យន្តការបណ្ដឹងរបស់គម្រោង (PCM) | យន្តការជម្រើសឯករាជ្យ |
|---|---|---|---|
| | | មានចំនួន ១ ដែលបានចុះបញ្ជី (គិតត្រឹមថ្ងៃទី ២៣ ខែមិថុនា ២០១០) | បណ្ដឹងចំនួន ៥ ដែលបានចុះបញ្ជី |

| | | |
|---|---|---|
| ការិយាល័យបណ្ដឹងនៃធនាគារវិនិយោគអឺរ៉ុប | អនុម័តនៅក្នុងខែកុម្ភៈ ឆ្នាំ ២០១០ (មានប្រសិទ្ធិភាពគ្រប ដណ្ដប់ទៅលើគោលនយោបាយបណ្ដឹងឆ្នាំ២០០៨) | ករណី EIB រាប់បញ្ចូលករណីលទ្ធកម្ម ។ មានបណ្ដឹងចំនួន ១៥ ក្នុង ឆ្នាំ ២០០៧ និងមានបណ្ដឹងចំនួន ៤០ ក្នុងឆ្នាំ ២០០៨ ដែលភាគច្រើន គឺជាបញ្ហាលទ្ធកម្ម ។ មាន២ករណី ដែលទាក់ទងទៅនឹងផលប៉ះពាល់បរិស្ថាន និងសង្គម ក្នុងឆ្នាំ ២០០៧ និងមាន ៧ ករណី ក្នុងឆ្នាំ ២០០៨ ។ |

ប្រភព : Complaints Office Annual Activity Report 2008.

| | | |
|---|---|---|
| នីតិវិធីជំទាស់របស់ធនាគារជប៉ុន សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ | ២០០៣-២០១០ | បានទទួលបណ្ដឹងចំនួន ១ ក្នុងឆ្នាំ ២០០៧ (គ្មានលក្ខណៈសមស្រប) |

ប្រភព : របាយការណ៍ប្រចាំឆ្នាំរបស់អ្នកត្រួតពិនិត្យគោលការណ៍ណែនាំស្ដីពីបរិស្ថាន (ឆ្នាំ ២០០៩)

| ការិយាល័យគណនេយ្យភាពនៃសាជីវកម្មវិស័យឯកជនក្រៅប្រទេស | ២០០៥-២០១០ | សំណើដោះស្រាយបញ្ហា | ចំនួនសរុបនៃសំណើត្រួតពិនិត្យឡើងវិញទៅលើភាពអនុលោម |
|---|---|---|---|
| | | ៣ | ៣ |

ប្រភព : http://www.opic.gov/doing-business/accountability/registry (ដោនឡូតនៅថ្ងៃទី ១៩ វិច្ឆិកា ២០១០)

# សេចក្តីសង្ខេបនៃបណ្តឹងមានលក្ខណៈសមស្រប ដែលដោះស្រាយដោយការិយាល័យអ្នកសម្រប សម្រួលគម្រោងពិសេសៈ ២០០៤-២០១០

| គម្រោង | អ្នកដាក់ពាក្យបណ្តឹង និងបញ្ហា | ស្ថានភាព |
|---|---|---|
| **១. កម្ចី 1820-NEP (SF) ៖ គម្រោងផ្គត់ផ្គង់ទឹកនៅមេឡាំជី (MWSP)** អនុម័តនៅថ្ងៃទី ២១ ធ្នូ ២០០០ (ADB៖ ១២០ លានដុល្លារ - មានភាគីបដិភាគចំនួន ៧) ។ | បានទទួលបណ្តឹងនៅថ្ងៃទី ៣ ឧសភា ២០០៤ ។ បុគ្គលចំនួន ៤ រូប បានរៀបចំពាក្យបណ្តឹងសម្រាប់បញ្ហាខាងក្រោម ៖<br>(១) ការទទួលបានព័ត៌មាន<br>(២) ការប៉ាន់ប្រមាណទៅលើបរិស្ថាន និងផលប៉ះពាល់<br>(៣) ការទទួលបានដីធ្លី សំណង និងការតាំងទីលំនៅឡើងវិញ<br>(៤) ជនជាតិភាគតិច<br>(៥) កម្មវិធីលើកកម្ពស់សង្គម<br>(៦) កសិកម្ម<br>(៧) ព្រៃឈើ<br><br>OSPF បានអនុវត្តធ្វើការត្រួតពិនិត្យឡើងវិញ និងចុះធ្វើទស្សនកិច្ចផ្ទាល់ ។ OSPF បានធ្វើការសន្និដ្ឋានថា អ្នកដាក់ពាក្យបណ្តឹងចំនួន ២ រូប ពុំបានទទួលរងផលប៉ះពាល់អវិជ្ជមាន និងគួរឱ្យកត់សម្គាល់ឡើយ ខណៈពេលដែលអ្នកដាក់ពាក្យបណ្តឹងចំនួន ២ រូបទៀតបាន ទទួលរងផលប៉ះពាល់ ប៉ុន្តែពួកគេបានទទួលការដោះស្រាយដោយភាពយុត្តិធម៌ពីគម្រោង និងក្នុងករណីសមស្រប ពួកគេថែមទាំងបានទទួលសំណងទៀតផង ។ | អ្នកដាក់ពាក្យបណ្តឹងបានដកបណ្តឹងរបស់ពួកគេទៅវិញ និងបានរៀបចំសំណើមួយ ទៅកាន់ CRP នៅថ្ងៃទី ៦ ខែធ្នូ ឆ្នាំ ២០០៤ ។ (ក្រោយការចុះធ្វើបេសកកម្មស្របច្បាប់របស់ខ្លួន CRP បានចាត់ទុកថាករណីនោះ ពុំមានលក្ខណៈសមស្រប) ។ |
| **២. កម្ចី 1711-SRI (SF) ៖** | បានទទួលបណ្តឹងនៅថ្ងៃទី ៩ ខែឧសភា ឆ្នាំ ២០០៤ ។ អង្គការមិនមែនរដ្ឋាភិបាលចំនួន ៣ ដែល | បណ្តឹងត្រូវបានបញ្ចប់ដោយគ្មានដំណោះស្រាយ ។ អ្នកសម្រុះសម្រួលខាងក្រៅម្នាក់ ត្រូវបានគេរក្សា |

| គម្រោង | អ្នកដាក់ពាក្យបណ្តឹង និងបញ្ហា | ស្ថានភាព |
| --- | --- | --- |
| **គម្រោងអភិវឌ្ឍផ្លូវគមនាគមន៍ភាគខាង ត្បូង (STDP)** អនុម័តនៅថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ (ADB ៩០ លាន ដុល្លារ , JBIC : ១២០ លានដុល្លារ) ។ | តំណាងឱ្យអ្នកដាក់ពាក្យបណ្តឹងចំនួន ២៥ រូប ។ បញ្ហា រួមមាន :<br>(១) ការប៉ាន់ប្រមាណទៅលើផលប៉ះពាល់បរិស្ថាន<br>(២) ការប៉ាន់ប្រមាណទៅលើផលប៉ះពាល់សង្គម<br>(៣) សំណង និងការតាំងទីលំនៅជាថ្មី | ទុក ។ អ្នកសម្រុះសម្រួល មានអារម្មណ៍ថាការមិនសុខចិត្តរបស់អ្នកដាក់ពាក្យបណ្តឹងមិនអាចដោះស្រាយបាននៅក្នុងវេទិកាសម្រុះសម្រួលដោះស្រាយបញ្ហាបានឡើយ ។ អ្នកដាក់ពាក្យបណ្តឹងបានរៀបចំសំណើមួយទៅ កាន់ CRP នៅថ្ងៃទី ២ ខែធ្នូ ឆ្នាំ២០០៤ ។ |
| **៣. កម្ចី 1765- ការផ្តល់អំណាចដល់សហគមន៍ INO សម្រាប់គម្រោងអភិវឌ្ឍជនបទ** អនុម័ត នៅថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ២០០០ (ABD : ១៧០,២ លានដុល្លារ) | បានទទួលបណ្តឹងនៅថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០០៥<br>មានមនុស្ស៨នាក់ ដែលនៅក្នុងនោះ ៣នាក់តំណាងឱ្យអង្គការមិនមែនរដ្ឋាភិបាល និង ៥ នាក់ជាអ្នកភូមិ (ដែលបានស្នើសុំឱ្យរក្សាការសម្ងាត់) បញ្ហាដែលបានលើកឡើង រួមមាន:<br>(១) ហេដ្ឋារចនាសម្ព័ន្ធភូមិ (ការរៀបចំ និងការកសាងមិនបានត្រឹមត្រូវ)<br>(២) ការរៀបចំលំដាប់លំដោយនៃសមាសធាតុគម្រោង<br>(៣) ព័ត៌មាន និង<br>(៤) ការចូលរួម និងការធ្វើសេចក្តីសម្រេចចិត្ត | បញ្ហាត្រូវបានដោះស្រាយក្នុងកម្រិតមួយ ដែលធ្វើឱ្យភាគីទាំងអស់មានការពេញចិត្ត ។<br>របាយការណ៍បញ្ចប់របស់ OSPF បានធ្វើសេចក្តី-សន្និដ្ឋានថា ស្ថាប័ននេះ "ជឿជាក់ថា បណ្តឹងនៅពេលអនាគត នឹងត្រូវបានដោះស្រាយប្រកបដោយប្រសិទ្ធភាព តាមរយៈយន្តការបណ្តឹងរបស់គម្រោង នៅថ្នាក់មូលដ្ឋាន" ។ |
| **៤. កម្ចី 2231 (SF)-PK : កម្មវិធីវិនិយោគ វិស័យអភិវឌ្ឍផ្លូវជាតិ** | បានទទួលបណ្តឹងនៅថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ២០០៦ ។<br>គណៈកម្មាធិការនៃជនដែលទទួលរងផលប៉ះពាល់ពីច្រកផ្លូវកាត់មូហ្សាហ្វាហ្គា (រួមមានសមាជិក | បញ្ហាដែលត្រូវបានលើកឡើងនៅក្នុងបណ្តឹងត្រូវបានដោះស្រាយក្នុងកម្រិតមួយ ដែលធ្វើឱ្យគ្រប់ភាគីទាំងអស់មានការពេញចិត្ត ។ |

| គម្រោង | អ្នកដាក់ពាក្យបណ្ដឹង និងបញ្ហា | ស្ថានភាព |
|---|---|---|
| **(NHDSIP),** អនុម័ត នៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៦ [ADB : MFF រហូត ដល់ ៧៧០ លាន ដុល្លារ (OCR) និង ៣ លានដុល្លារ (SPF)] ។ | ចំនួន ៥៣នាក់) បានរៀបចំពាក្យបណ្ដឹង ។ បញ្ហាដែលបានលើកឡើង រួមមាន :<br><br>(១) ធ្វើការបន្សុីឡើងវិញដើម្បីឱ្យមានច្រកផ្លូវកាត់មួយ<br>(២) ការតាំងទីលំនៅឡើងវិញ និងសំណងទៅលើការបាត់បង់<br>(៣) ព័ត៌មាន និងការពិគ្រោះយោបល់ | របាយការណ៍ប្រចាំឆ្នាំរបស់ OSPF បានធ្វើការកត់សម្គាល់ថា "អ្នកដាក់ពាក្យបណ្ដឹងបានបញ្ជាក់ថាពួកគេមានការពេញចិត្តទៅនឹងសំណងរបស់ពួកគេ និងផ្លូវខាងក្រោម ។ ដូច្នេះ បណ្ដឹងនេះត្រូវបានដោះស្រាយជាស្ថាពរ" ។ |
| **៥. កម្ចី 1659 – CAM : គម្រោងកសាងផ្លូវថ្នល់ភ្ជាប់ពីរាជធានីភ្នំពេញទៅទីក្រុងហូជីមិញ** អនុម័តនៅថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៨ (ABD : ៤០ លាន ដុល្លារ) | បានទទួលបណ្ដឹងនៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៧ ។<br><br>អង្គការវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល (កម្ពុជា) បានរៀបចំបណ្ដឹងជំនួសឱ្យប្រជាជនដែលទទួលរងផលប៉ះពាល់ នៅក្នុងភូមិក្រាំងកក់ចំនួន ៤១ នាក់ និងស្ទឹងស្លូតចំនួន ២២ នាក់ លើបញ្ហា ដូចខាងក្រោម :<br><br>(១) សំណង<br>(២) ប្លង់ដី<br>(៣) មុខរបរចិញ្ចឹមជីវិត | របាយការណ៍ប្រចាំឆ្នាំរបស់ OSPF បានធ្វើ ការកត់សម្គាល់ថា :<br>"យោងតាមសំណើរបស់អ្នកដាក់ពាក្យបណ្ដឹង OSPF បានពន្យារពេលដំណើរការពិគ្រោះយោបល់ ខណៈពេលដែលរដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ីនិវាសនដ្ឋានបេសកកម្ម ប្រចាំប្រទេសកម្ពុជា បន្តកិច្ចខិតខំដើម្បីដោះស្រាយបញ្ហាទាំងនេះ ។ ក្នុងអំឡុងឆ្នាំ ២០០៩ ADB បានអនុម័តទៅលើ TA មួយសម្រាប់កម្មវិធី ស្ដារប្រាក់ចំណូល ក្នុងគោលបំណងជួយដល់ប្រជាជនដែលទទួលរងផលប៉ះពាល់ឱ្យដោះស្រាយបញ្ហាកំណើននៃបន្ទុកបំណុលរបស់ពួកគេ ព្រមទាំងរៀបចំបង្កើតសកម្មភាពប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគេឡើងវិញ ។ ការអភិវឌ្ឍនេះផ្ដល់នូវឱកាសមួយដើម្បីដោះស្រាយបញ្ហានានា ដែលអ្នកដាក់ពាក្យបណ្ដឹងបាន លើកឡើងទៅកាន់ OSPF ពីដំបូង ។<br><br>នៅក្នុងន័យនេះ និងដោយពិចារណាថា ដំណើរការ |

| គម្រោង | អ្នកដាក់ពាក្យបណ្ដឹង និងបញ្ហា | ស្ថានភាព |
|---|---|---|
| | | ពិគ្រោះយោបល់ត្រូវបានផ្អាកជិត ២ ឆ្នាំ OSPF បានជូនដំណឹងដល់អ្នកដាក់ពាក្យបណ្ដឹង នៅចុងឆ្នាំ ២០០៩ ថា បណ្ដឹងនឹងត្រូវបានបិទ ។ |
| **៦. កម្ចី 2176-PRC : គម្រោងកែលម្អបរិស្ថាននៅ ហ្វូចូវ** អនុម័តនៅ ថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០០៥ (ABD: ៥៥.៨ លានដុល្លា ជាមួយនឹងការផ្ដល់ហិរញ្ញប្បទានពាណិជ្ជកម្ម) ។ | បានទទួលបណ្ដឹងនៅថ្ងៃទី ១៥ ខែមករា ឆ្នាំ២០០៩ ។<br><br>ប្រជាជនមួយក្រុម រួមមាន ៧ គ្រួសារដែលត្រូវតាំងទីលំនៅជាថ្មីឡើងវិញ ក្រោមសមាសធាតុទន្លេកោះណាន់ថៃនៃគម្រោងនេះ បានរៀបចំបណ្ដឹងទៅលើបញ្ហាខាងក្រោម :<br><br>ការតាំងទីលំនៅឡើងវិញ : អ្នកដាក់ពាក្យបណ្ដឹងពុំបានចុះបញ្ជីជាប្រជាពលរដ្ឋរស់នៅក្នុងមូលដ្ឋានឡើយ ប៉ុន្តែពួកគេបានមករស់នៅក្នុងតំបន់នេះក្នុងឆ្នាំ ១៩៩៤ ដែលពួកគេបានទិញដីពីកសិករក្នុងមូលដ្ឋាន និងបានសាងសង់ផ្ទះរបស់ពួកគេ ។ រដ្ឋា-ភិបាលបានចាត់ទុកថា ការទិញដីបែបនេះ គឺជាសកម្មភាពខុសច្បាប់ ហើយយោងតាមច្បាប់របស់រាជរដ្ឋាភិបាល ពួកគេនឹងមិនមានសិទ្ធិទទួលបានសំណងដូចគ្នាទៅនឹងប្រជាជនដទៃទៀត ដែលរស់នៅស្របច្បាប់ក្នុងតំបន់នោះឡើយ ។ អ្នកដាក់ពាក្យបណ្ដឹងមានអារម្មណ៍ថា ទង្វើបែបនេះមិនស្រប ទៅនឹងផែនការស្ដីពីការតាំងទីលំនៅជាថ្មីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ឆ្នាំ ២០០៤ ឡើយ ។ | នៅក្នុងការរៀបចំបង្កើតកម្រងសកម្មភាព OSPF ជឿថា គេត្រូវការឱ្យមាននូវដំណើរការពិគ្រោះយោបល់បែបចូលរួមក្រោមរចនាសម្ព័ន្ធមួយ ដោយមានជំនួយពីអ្នកសម្របសម្រួលឯករាជ្យម្នាក់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងក្នុងចំណោមភាគីនានា ព្រមទាំងជួយឱ្យពួកគេយល់អំពីគ្នាទៅវិញទៅមក និងគាំទ្រដល់សកម្មភាពស្រាវជ្រាវរួមគ្នាមួយ ដើម្បីស្វែងរកដំណោះ ស្រាយ ។ SPF បានជួលអ្នកសម្រុះសម្រួលម្នាក់មកពីទីក្រុងហុងកុង ប្រទេសចិន ។ រដ្ឋាភិបាលបានយល់ព្រមផ្ដល់ផ្ទះតូចៗមួយចំនួន ជូនដល់ប្រជាជនដែលទទួលរងផល ប៉ះពាល់ ។ គ្រួសារចំនួន ៥ បានយល់ព្រមទទួលយកផ្ទះទាំងនោះ និងគ្រួសារចំនួន ២ មិនយល់ព្រម ។ ក្រោយមក រដ្ឋាភិបាលបានផ្លាស់ប្ដូរការរៀបចំគម្រោង និងបានផ្អាកការស្នើសុំឱ្យគ្រួសារទាំងនោះ ធ្វើការតាំងទីលំនៅឡើងវិញ ។ គ្រួសារទាំងពីរដែល<br>មិនយល់ព្រមទទួលយកផ្ទះទាំងនោះ បានរៀបចំសំណើឱ្យធ្វើការត្រួតពិនិត្យឡើងវិញ ទៅលើភាពអនុលោមទៅកាន់ CRP ។ |
| **៧. កម្ចី 2060/ 2061-PAK: គម្រោង សេវាកម្ម** | បានទទួលបណ្ដឹងនៅថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ ២០០៩ ។<br><br>ភាគីហត្ថលេខី គឺជាបុគ្គលម្នាក់ ដែលបានអះអាង ថា | យោងតាមរបាយការណ៍ប្រចាំឆ្នាំរបស់ OSPF "ADB បានបិទកម្ចីនៅចុងខែកក្កដា ឆ្នាំ ២០០៩ និងកំពុងពិភាក្សាជាមួយរដ្ឋាភិបាល ថាតើត្រូវ |

| គម្រោង | អ្នកដាក់ពាក្យបណ្តឹង និងបញ្ហា | ស្ថានភាព |
|---|---|---|
| **មូលដ្ឋានតំបន់ទីក្រុង នៅផាន់ចាប់ភាគខាងត្បូង**អនុម័តនៅ ថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ២០០៣ (ABD: ៤៥ លានដុល្លារ) | គឺជាតំណាងរបស់អ្នកដាក់ពាក្យបណ្តឹងចំនួន ៥៨ នាក់ (បុរស ៤៣ នាក់ និងស្ត្រី ១៥ នាក់) ដែលទូលរងផលប៉ះពាល់អវិជ្ជមាន ដោយរោងចក្រប្រព្រឹត្តិកម្មទឹកសំណល់ទឹក ។ បញ្ហារួមមាន :<br>(១) ការតាំងទីលំនៅឡើងវិញ<br>(២) បរិស្ថាន | បញ្ចូលសមាសធាតុស្តីពីប្រព្រឹត្តិកម្ម ទឹកសំណល់ ក្រោមគម្រោងថ្មីមួយ ដែលគេរំពឹងថា នឹងត្រូវបាន អនុម័តនៅក្នុងឆ្នាំ ២០១០ ដែរឬទេ" ។ |
| **៨. កម្ចី 2211-PAK/ 2212-PAK (SF) : គម្រោងកែលម្អបរិស្ថាននៅឯ រ៉ាវ៉ាល់ភីនឌី (សមាសធាតុរោងចក្រប្រព្រឹត្តិកម្មទឹកល្វ)** អនុម័តនៅថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៥ (ADB: ២០ លានដុល្លារ) ។ | បានទទួលបណ្តឹងនៅថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩ ។<br>ព័ត៌មានអំពីអ្នកដាក់ពាក្យបណ្តឹងពុំទាន់មានលក្ខណៈជា សាធារណៈនៅឡើយទេ ។ បញ្ហាដែលបានលើកឡើង រួមមាន :<br>(១) ការទទួលបានដីធ្លី<br>(២) សំណង | យោងតាមរបាយការណ៍ប្រចាំឆ្នាំរបស់ OSPF "លទ្ធភាពរបស់ OSPF ក្នុងការបន្តធ្វើការពិគ្រោះយោបល់ ត្រូវបានកម្រិតដោយស្ថានភាពសន្តិសុខនៅក្នុងប្រទេសប៉ាគីស្ថាន ដែលមិនអនុញ្ញាតឱ្យគេអាចបន្ត ធ្វើបេសកកម្មបន្តបន្ទាប់ទៀតបាន នៅក្នុងឆ្នាំ ២០០៩ ។ ទីប្រឹក្សារបស់ OSPF បានរៀបចំកិច្ចប្រជុំមួយ នៅក្នុងខែ ធ្នូ ឆ្នាំ ២០០៩ ដើម្បីពន្យល់អំពីដំណើរការនៃការកំណត់តម្លៃដីធ្លីជូនដល់អ្នកដាក់ពាក្យបណ្តឹង និងផ្តល់ឱកាសមួយជូនដល់ពួកគេ ADB និងរដ្ឋាភិបាលដើម្បីចែករំលែកព័ត៌មាន លើកឡើងនូវបញ្ហាកង្វល់ព្រមទាំង ធ្វើការពិភាក្សាអំពីជំហានបន្ទាប់ ។ ADB បានបិទកម្ចីនៅចុងខែ សីហា ឆ្នាំ ២០០៩ ព្រមទាំងកំពុងពិភាក្សាជាមួយរដ្ឋាភិបាលថាតើត្រូវបញ្ចូលសមាសធាតុស្តីពីរោងចក្រប្រព្រឹត្តិកម្មទឹកល្វ ទៅក្នុងគម្រោងថ្មីដែល គ្រោងអនុវត្តក្នុងឆ្នាំ ២០១០ ដែរឬទេ ។ បើទោះជាដូច្នេះក្តី គេឃើញថាការសាងសង់រោងចក្រ អាចត្រូវបានពន្យារពេល អាស្រ័យ |

| គម្រោង | អ្នកដាក់ពាក្យបណ្តឹង និងបញ្ហា | ស្ថានភាព |
|---|---|---|
| | | ដោយភាពមិនច្បាស់លាស់អំពីទំហំរបស់រោងចក្រ និងការរៀបចំបែងចែកថវិកាបដិភាគ" ។ |
| **៩. កម្ចី 2562-KAZ : កម្មវិធីវិនិយោគរបៀងដឹកជញ្ជូនទី ១ របស់ CAREC** អនុម័ត នៅថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៨ [ADB: ៣៤០ លានដុល្លារ (ដំណាក់កាលទី១) និង ១៨៧ លាន ដុល្លារ (ដំណាក់កាលទី២)] ។ | បានទទួលបណ្តឹងនៅថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ។<br><br>អ្នកដាក់ពាក្យបណ្តឹងរួមមានហត្ថលេខីចំនួន ២ ។ ពួកគេបានអះអាងថា ពួកគេតំណាងឱ្យប្រជាពលរដ្ឋនៅក្នុងភូមិ យ៉ាងហោចណាស់ចំនួន ៣០ នាក់ដទៃទៀត ។ អង្គការមិនមែនរដ្ឋាភិបាលមួយ ដែលមានឈ្មោះ ថាសហភាពសាធារណៈនៃក្លឹបសារព័ត៌មានថារ៉ាានសម្របសម្រួលរៀបចំពាក្យបណ្តឹង ។ បញ្ហា ដែលបានលើកឡើង រួមមាន :<br><br>(១) ព័ត៌មាន<br>(២) ការចូលរួម<br>(៣) ផ្លូវសម្រាប់សត្វពាហនៈឆ្លងកាត់<br>(៤) ផ្លូវខាងក្រោមសម្រាប់គ្រឿងចក្រកសិកម្ម ។ | ការពិគ្រោះយោបល់កំពុងបន្ត ។ |
| **១០.កម្ចី 2053 – TAJ : គម្រោងកំណែទម្រង់វិស័យអប់រំ** អនុម័តនៅថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៣ (ADB: ៧,៥ លាន ដុល្លារ) | បានទទួលបណ្តឹងនៅថ្ងៃទី ៥ ខែសីហា ឆ្នាំ២០០៩ ។<br><br>ពុំទាន់មានព័ត៌មានលម្អិតជាសាធារណៈនៅឡើយ ។ | ការពិគ្រោះយោបល់កំពុងបន្ត ។ |
| **១១.កម្ចី 2533 – KGZ : គម្រោងទី** | បានទទួលបណ្តឹងនៅថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ២០១០ ។ | ការពិគ្រោះយោបល់កំពុងបន្ត ។ |

| គម្រោង | អ្នកដាក់ពាក្យបណ្តឹង និងបញ្ហា | ស្ថានភាព |
|---|---|---|
| **២ ដែល ផ្តោតលើ ការកសាងរបៀង ដឹកជញ្ជូនទី១ របស់ CAREC (ផ្លូវថ្នល់ដែលភ្ជាប់ ពីប៊ីស្កេក ទៅ តូរូហ្គាត់)** អនុម័តនៅថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៩ (ADB ៖ ៥០ លានដុល្លារ) ។ | ពុំទាន់មានព័ត៌មានលម្អិតជាសាធារណៈនៅឡើយ ។ | |

## សង្ខេបសំណើពិនិត្យឡើងវិញលើភាពអនុលោម : ឆ្នាំ ២០០៤-២០១០

| គម្រោង | សំណើ | ការឆ្លើយតប | លទ្ធផល |
| --- | --- | --- | --- |
| **១. កម្ចី 1146-PAK: គម្រោងស្រោចស្រពតាមច្រាំងទន្លេ ចាស្មា** ត្រូវបានអនុម័ត នៅខែ ធ្នូ ឆ្នាំ ១៩៩១ (ADB: ១៨៥ លាន ដុល្លារក្នុង ឆ្នាំ ១៩៩១ ។ ហិរញ្ញប្បទានបន្ថែមចំនួន ៣៣.៥ លាន ដុល្លារ ក្នុងខែ មិថុនា ឆ្នាំ ១៩៩៩) ។ | សំណើត្រូវបានទទួល នៅថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០២ ក្រោមមុខងារអធិការកិច្ចមុន១របស់ធនាគារអភិវឌ្ឍន៍អាស៊ី ។<br><br>បណ្តឹងត្រូវបានដាក់ដោយបុគ្គល ៤ រូប ដែលមានសិទ្ធិអំណាចក្នុងការតំណាងឱ្យអ្នកទទួលរងផលប៉ះពាល់ ។<br><br>អ្នកដាក់សំណើប្តឹងទាមទារថា ធនាគារអភិវឌ្ឍន៍ អាស៊ីបានរំលោភលើគោលនយោបាយ និងនីតិវិធីប្រតិបត្តិការការងាររបស់ខ្លួន ក្នុងការបង្កើត និងដំណើរការគម្រោងហិរញ្ញប្បទានបន្ថែម ដែលមានផលប៉ះពាល់អវិជ្ជមានទៅលើអ្នកទទួលរងផលប៉ះពាល់ Chashma ។ បញ្ហារួមមាន : ទឹកជំនន់បង្កឡើង ដោយសារគម្រោង និងការតាំង ទីលំនៅឡើងវិញ ដោយមិនស្ម័គ្រចិត្ត សំណងមិនគ្រប់គ្រាន់សម្រាប់ការបាត់បង់ដីធ្លី ទ្រព្យសម្បត្តិផ្សេងទៀត និងមធ្យោបាយចិញ្ចឹមជីវិត និងកង្វះ ការចែករំលែកព័ត៌មាន ការពិគ្រោះយោបល់ និងការចូលរួមពីសំណាក់ប្រជាជនដែលទទួលរងផលប៉ះពាល់ ។ | នៅក្នុងខែ មីនា ឆ្នាំ ២០០៣ BIC បានដាក់របាយការណ៍របស់ខ្លួនទៅកាន់ក្រុមប្រឹក្សា-ភិបាល ដោយណែនាំឱ្យមានការធ្វើអធិការកិច្ចដែលត្រូវចាប់ផ្តើមក្នុងខែ ធ្នូ ឆ្នាំ ២០០៣ ។ ក្រុមប្រឹក្សាភិបាលបានឯកភាពលើអនុសាសន៍នេះ ហើយគណៈកម្មការអធិការកិច្ចមួយបានធ្វើការស៊ើបអង្កេតនៅដើមឆ្នាំ ២០០៤ ។ របាយការណ៍ចុងក្រោយត្រូវបានដាក់ជូន ក្នុងខែ មិថុនា ឆ្នាំ ២០០៤ ។<br><br>CRP បានកត់សម្គាល់ថា នៅក្នុងខែ មីនា ឆ្នាំ ២០០៤ នៅពេលដែលគណៈកម្មការអធិការកិច្ចអនុវត្តការស៊ើបអង្កេតរបស់ខ្លួន នៅក្នុងតំបន់គម្រោង ដោយសារតែ *"...ការមិនពេញចិត្តជាមួយដំណើរការអភិវឌ្ឍន៍ និងពិគ្រោះយោបល់ដែលទាក់ទងទៅនឹងគណៈកម្មាធិការដោះស្រាយ និងទូទាត់សំណង (GRSC) និងអនុសាសន៍របស់ខ្លួនការគាំទ្ររបស់ក្រុមប្រឹក្សាភិបាលចំពោះ GRSC និងការបង្កើតផែនការសកម្មភាព"* ។<br><br>នៅក្នុងខែ សីហា ឆ្នាំ ២០០៤ ក្រុមប្រឹក្សា-ភិបាលបានឯកភាពលើការពិនិត្យតាមដានដោយ CRP ទៅលើការអនុវត្តវិធានការឧបាស្រ័យដើម្បីធ្វើឱ្យគម្រោងត្រឡប់មករកភាពអនុលោមវិញ ។<br><br>CRP បានរៀបចំ និងចេញរបាយការណ៍ពិនិត្យតាមដានប្រចាំឆ្នាំ ក្នុងឆ្នាំ ២០០៥, ២០០៦, ២០០៧ និង ២០០៨ ។ របាយ-ការណ៍ពិនិត្យតាមដានលើកទីប្រាំ ( គ្រប | ក្រោយពីរយៈពេល ៥ ឆ្នាំនៃការពិនិត្យតាមដាន CRP បានធ្វើការសន្និដ្ឋាននៅខែ មិថុនា ឆ្នាំ ២០១០ ថា ADB :<br><br>(i) បានគោរពតាមអនុសាសន៍ចំនួន ២៤ ក្នុងចំណោមអនុសាសន៍ចំនួន ២៩ ។<br>(ii) គោរពតាម មួយផ្នែក ចំពោះអនុ-សាសន៍ចំនួន ៤ និង<br>(iii) អនុសាសន៍ចំនួន ១ ត្រូវបានជំនួសដោយព្រឹត្តិការណ៍<br><br>ក្នុងចំណោមអនុសាសន៍ចំនួន ៤ ដែលធនាគារអភិវឌ្ឍន៍អាស៊ីសម្រេចបានភាពអនុលោម មួយផ្នែក គណៈ-កម្មការបានសន្និដ្ឋានថា វឌ្ឍនភាពគ្រប់គ្រាន់ត្រូវបានធ្វើឡើង និងថា នៅក្នុងកាលៈទេសៈនេះ គណៈកម្មការមិនចាំបាច់ពង្រីកអាណត្តិពិនិត្យ |

| គម្រោង | សំណើ | ការឆ្លើយតប | លទ្ធផល |
|---|---|---|---|
| | | ដណ្តប់ឆ្នាំ ២០០៨ / ២០០៩) គឺជារបាយ-ការណ៍ចុងក្រោយដែលត្រូវបានធ្វើឡើង ។ | តាមដានរបស់ខ្លួនហួសពី ៥ ឆ្នាំឡើយ ។ |
| **២. គម្រោងផ្គត់ផ្គង់ទឹកនៅមេឡាំជីប្រទេសនេប៉ាល់ (1820-NEP (SF)) ។** កម្ចី ADB ចំនួន ១២០ លានដុល្លារ សម្រាប់គម្រោង ត្រូវបានអនុម័ត នៅខែ ធ្នូ ឆ្នាំ ២០០០ ។ | CRP បានទទួលសំណើពីអ្នកដាក់សំណើ ៤ រូប នៅថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ។ បណ្តឹងដូចខាងក្រោមត្រូវបានលើកឡើង :<br>(i) ការបង្ហាញព័ត៌មានមិនសមស្រប ឬមិនត្រឹមត្រូវ<br>(ii) ការផ្លាស់កន្លែង និងកង្វះសំណង់គ្រប់គ្រាន់ និងការតាំងទីលំនៅឡើងវិញ<br>(iii) ការបាត់បង់មធ្យោបាយចិញ្ចឹមជីវិត ដោយសារការបិទម៉ាស៊ីនដើរដោយកម្លាំងទឹក (រោងម៉ាស៊ីនកិនគ្រាប់ធុញ្ញជាតិ) និងរោងចក្រវារីអគ្គិសនីខ្នាតតូចសម្រាប់ការប្រើប្រាស់ថាមពលក្នុងមូលដ្ឋាន<br>(iv) ការបំផ្លិចបំផ្លាញព្រៃសហ-គមន៍<br>(v) ការបំផ្លិចបំផ្លាញប្រឡាយស្រោចស្រព<br>(vi) ការខូចខាតចំពោះដំណាំ និងមធ្យោបាយចិញ្ចឹមជីវិតដោយសារលំហូរទឹកថយចុះ និង<br>(vii) ការផ្លាស់កន្លែង និងផលប៉ះពាល់អវិជ្ជមានទៅលើ | CRP ទទួលបានពី SPF នូវសម្ភារៈទាក់ទងទៅនឹងបណ្តឹងនៅក្នុងដំណាក់កាលពិគ្រោះយោបល់ ។ CRP បានអនុវត្តការពិនិត្យឡើងវិញដែលធ្វើឡើងនៅការិយាល័យទៅលើសម្ភារៈដែលពាក់ព័ន្ធ ដោយពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ។ CRP ក៏អនុវត្តបេសកកម្មពិនិត្យឡើងវិញផងដែរលើភាពមានសិទ្ធិ នៅក្នុងប្រទេសនេប៉ាល់ រួមទាំង ការចុះដល់ទីតាំងជាក់ស្តែងរបស់គម្រោង ។ | CRP បានដាក់បេសកកម្មមួយ ហើយមិនអាចផ្ទៀងផ្ទាត់ការខូចខាតដោយផ្ទាល់ និងគួរឱ្យកត់សម្គាល់ និងការរំលោភគោលនយោបាយដែលត្រូវបានចោទប្រកាន់ឡើយ ហើយបានចាត់ទុកសំណើនោះថាមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។ |

| គម្រោង | សំណើ | ការឆ្លើយតប | លទ្ធផល |
|---|---|---|---|
| | ជនជាតិដើមភាគតិច និង សហគមន៍ ។ | | |
| **៣. កម្ចី 1771- SR (SF): គម្រោងអភិវឌ្ឍន៍ផ្លូវគមនាគមន៍ភាគខាងត្បូង** ដែលអនុម័តនៅ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៩៩ (ADB: ៩០ លានដុល្លារ ជាកម្ចីបន្ថែមត្រូវបានអនុម័តក្នុងខែ មីនា ឆ្នាំ ២០០៨) | សំណើត្រូវបានដាក់ជូនដោយអង្គការចម្រុះនៃសហគមន៍ទទួលរងផលប៉ះពាល់នៃមហាវិថី Colombo Matara ដែលតំណាងឱ្យប្រជាជន ២៨នាក់ ដែលទទួលរងផលប៉ះពាល់អវិជ្ជមានដោយសារគម្រោង នៅថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៤ ។ អ្នកដាក់សំណើបានគូសបញ្ជាក់អំពីការរំលោភដែលបានចោទប្រកាន់ទៅលើគោល-នយោបាយ និង នីតិវិធីប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលបណ្តាលឱ្យមានការខូចខាតចំពោះពួកគេ រួមទាំងបរិស្ថាន ការតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្ត ការដាក់បញ្ចូលទិដ្ឋភាពសង្គមនៅក្នុងប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី អភិបាលកិច្ច ការវិភាគសេដ្ឋកិច្ច ការពិនិត្យតាមដាន និងវាយតម្លៃអត្ថប្រយោជន៍ យេនឌ័រ និងការអភិវឌ្ឍនៅក្នុងប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី, ដំណើរការនៃសំណើសុំកម្ចី ការរៀបចំ និងអនុវត្តកិច្ចសន្យាកម្ចី លទ្ធកម្មទំនិញ និងសេវា និងការប្រឆាំងអំពើពុករលួយ ។<br><br>ការខូចខាតដែលបានចោទប្រកាន់រួមមាន ការបាត់ផ្ទះសម្បែង ការ | CRP ធ្វើការពិនិត្យឡើងវិញយ៉ាងទូលំទូលាយលើឯកសារដែលមានស្រាប់នៅ Manila និង Colombo ។ CRP ក៏ធ្វើការសម្ភាសផងដែរជាមួយអ្នកដាក់សំណើ និងអ្នកទទួលរងផលប៉ះពាល់ដោយសារគម្រោង ព្រមទាំងបុគ្គលិក អ្នកពិគ្រោះ-យោបល់ និង អ្នកចុះកិច្ចសន្យាបច្ចុប្បន្ន និងអតីតកាល ដែលពាក់ព័ន្ធទៅនឹងគម្រោង ។ ជាមួយនឹងការគាំទ្រពីរដ្ឋាភិបាលស្រីលង្ការ (GOSL) ប្រជាជនស្រីលង្ការដែលទទួលរងផលប៉ះ ពាល់ និងបុគ្គលិក ADB, CRP បានធ្វើទស្សនកិច្ច ទៅកាន់ទីតាំងគម្រោងចំនួនពីរ ដងដើម្បីស្វែងយល់អំពីបញ្ហា និងបញ្ហាប្រឈមដែលភាគីពាក់ព័ន្ធទាំងអស់ជួបប្រទះ ។<br><br>CRP បានកំណត់ថា សំណើមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយក្រុមប្រឹក្សាភិបាលបានអនុញ្ញាតឱ្យមានការពិនិត្យឡើងវិញលើភាពអនុលោម ។ | CRP បានពិនិត្យតាមដានលើការអនុវត្តវិធានការឧបាស្រ័យ ដែលកំណត់នៅក្នុងរបាយការណ៍ចុងក្រោយអំពីការស៊ើបអង្កេត ។<br><br>CRP ធ្វើការសន្និដ្ឋាននៅក្នុងរបាយការណ៍ពិនិត្យតាមដានប្រចាំឆ្នាំលើកទី ៤សម្រាប់ STDP ថា មានការរីកចម្រើនគួរឱ្យកត់សម្គាល់នៅក្នុងការអនុវត្តអនុសាសន៍ដែលបង្កើតឡើងនៅក្នុងឆ្នាំ ២០០៥ ។ ក្នុងចំណោមអនុសាសន៍ដំបូងចំនួន ១៩ អនុសាសន៍ចំនួន ១៧ ត្រូវបានគោរពតាមយ៉ាងពេញលេញ ហើយមានតែអនុសាសន៍ចំនួន ២ ប៉ុណ្ណោះដែលត្រូវបានគោរពតាមមួយផ្នែក ។ |

| គម្រោង | សំណើ | ការឆ្លើយតប | លទ្ធផល |
|---|---|---|---|
| | បាត់បង់មធ្យោបាយចិញ្ចឹមជីវិត ការខូចខាតបរិស្ថាន ការចុះអន់ថយនៃតំបន់វាលភក់ ការបែកខ្ញែកសហគមន៍ចម្រុះ ការខូចខាតដល់ប្រាសាទចំនួន៥ ផលប៉ះពាល់អវិជ្ជមាននៃការតាំងទីលំនៅឡើងវិញ និងការរំលោភសិទ្ធិមនុស្ស ។ | | |
| ៤. **កម្ចី 2176-PRC: គម្រោងកែលម្អបរិស្ថាននៅហ្វូចូវ** ត្រូវបានអនុម័ត នៅ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៥ (ADB: ៥៥.៨ លានដុល្លារ ជាមួយហិរញ្ញប្បទានផ្នែកពាណិជ្ជកម្ម ។) | CRP បានទទួលសំណើមួយដែលចុះហត្ថលេខាដោយបុគ្គលចំនួន ២ រូប ដែលស្នើសុំឱ្យមានការពិនិត្យឡើងវិញលើភាពអនុលោម នៅថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៩ ។ SPF កន្លងមកបានដោះស្រាយបណ្ដឹងពីគ្រួសារចំនួន ៧ ដែលទទួលរងផលប៉ះពាល់ ។<br><br>បញ្ហានានាដែលលើកឡើងទាក់ទងទៅនឹងគោលនយោបាយតាំងទីលំនៅឡើងវិញដោយមិនស្ម័គ្រចិត្តរបស់ ADB (IRP) រួមមាន :<br><br>(i) សំណងមិនគ្រប់គ្រាន់ក្នុងការជំនួសលំនៅដ្ឋានរបស់ប្រជាជន ដែលបាត់បង់ដោយគ្មានប័ណ្ណកម្មសិទ្ធិស្របច្បាប់<br>(ii) អវត្តមាននៃវិធានការស្តារនីតិសម្បទាដើម្បីទូទាត់ការបាត់បង់ចំណូល និង<br>(iii) ការផ្សព្វផ្សាយព័ត៌មាន និងការពិគ្រោះយោបល់មិនគ្រប់គ្រាន់ ។ | CRP បានចាប់ផ្ដើមជាមួយឯកសារពិនិត្យឡើងវិញដែលធ្វើឡើងនៅការិយាល័យ និងបានពិចារណាថា ទស្សនកិច្ចទៅកាន់ទីតាំងគឺជាការចាំបាច់ ដើម្បីបញ្ជាក់អះអាងការទាមទារដែលធ្វើឡើងដោយភាគីស្នើសុំ និងដើម្បីធ្វើឱ្យ ពួកគេមានអន្តរកម្ម ដោយផ្ទាល់ជាមួយ CRP និងដើម្បីបង្ហាញភស្តុតាងប្រសើរបំផុតរបស់ពួកគេក្នុងការគាំទ្រការទាមទាររបស់ខ្លួន ។ រដ្ឋាភិបាលបានបដិសេធការធ្វើទស្សនកិច្ចទៅកាន់ទីតាំងដោយសារមូលហេតុដូចខាងក្រោម :<br><br>(i) ផែនការតាំងទីលំនៅឡើងវិញ គឺស្របតាមគោលនយោបាយពាក់ព័ន្ធទាំងរបស់ PRC ទាំងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី<br>(ii) ផ្លូវទៅកាន់ទន្លេ បានធ្វើឱ្យសំណើពិនិត្យឡើងវិញលើភាពអនុលោមមានភាពមិនចាំបាច់<br>(iii) មន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់មួយរូបដែលធ្វើទស្សនកិច្ចមកកាន់ទីតាំងគម្រោង បានអះអាងថា ភាគីស្នើសុំលែងរស់នៅក្នុងតំបន់នោះទៀត | CRP បានបញ្ជាក់ថាខ្លួនមិនអាចបញ្ចប់ការពិនិត្យឡើងវិញលើភាពអនុលោមបានឡើយ ដោយសារកង្វះទស្សនកិច្ចទៅកាន់ទីតាំង ។ |

| គម្រោង | សំណើ | ការឆ្លើយតប | លទ្ធផល |
|---|---|---|---|
| | | ហើយ និងជាចុងក្រោយ<br>(iv) ទស្សនកិច្ចមុនៗទៅកាន់ទីតាំងគម្រោង ដោយ OSPF គួរផ្តល់ឱ្យ CRP នូវព័ត៌មានគ្រប់គ្រាន់សម្រាប់ការពិនិត្យឡើងវិញលើភាពអនុលោមរបស់ខ្លួន ។ ដូច្នេះ តាមទស្សនៈរបស់រដ្ឋាភិបាល ទស្សនកិច្ចទៅកាន់ទីតាំងគម្រោងដែលបានស្នើឡើង លែងមានភាពចាំបាច់ទៀតហើយ ។<br><br>CRP បានទទួលស្គាល់សេចក្តីសម្រេចចិត្តរបស់ PRC ក្នុងការផ្លាស់ប្តូរប្លង់គម្រោង ប៉ុន្តែការផ្លាស់ប្តូរនេះត្រូវបានធ្វើឡើង ក្រោយពីសំណើពិនិត្យឡើងវិញលើភាពអនុលោមត្រូវបានដាក់ជូន ។ ជាផ្នែកមួយនៃដំណើរការមានសិទ្ធិ CRP បានបញ្ជាក់ថា ការផ្លាស់ប្តូរចំពោះប្លង់គម្រោងនឹងមិនបញ្ចៀសតម្រូវការក្នុងការស៊ើបអង្កេតថាតើធនាគារអភិវឌ្ឍន៍អាស៊ីបានខកខាន ក្នុងការគោរពតាមគោលនយោបាយ និងនីតិវិធីប្រតិបត្តិការការងាររបស់ខ្លួនមុនៗ ឬយ៉ាងណាឡើយ ។ | |

**សង្ខេបការវាយតម្លៃយន្តការគណនេយ្យភាពរបស់ ADB**

| វិស័យ | ចំណុចខ្លាំង | ចំណុចខ្សោយ | ការផ្លាស់ប្តូរដែលបានស្នើឡើង |
|---|---|---|---|
| | | **លទ្ធភាព** | |
| **ការយល់ដឹង** | (i) ការផ្សព្វផ្សាយព័ត៌មានជាលក្ខណៈប្រព័ន្ធ ។ | (i) ការយល់ដឹងមានកម្រិត ។ | (i) លើកកម្ពស់ការផ្សព្វផ្សាយព័ត៌មាន ។ |
| **ភាពមានសិទ្ធិ** | (i) កាលបរិច្ឆេទឱសានវាទយូរ ។ | (i) PCR ដោយសារ ពេលខ្លះ កាលបរិច្ឆេទកាត់ផ្តាច់ ខ្វះភាពច្បាស់លាស់ ។ | (ii) គួបញ្ជាក់អំពីកាលបរិច្ឆេទឱសានវាទ ។ |
| **ដំណើរការ** | (i) ពុំមានលក្ខខណ្ឌតម្រូវចាំបាច់សម្រាប់ការលើកឡើងនូវការរំលោភគោលនយោបាយជាក់លាក់ ។<br><br>(ii) តម្រូវការឯកសារអប្បបរមា ។<br><br>(iii) អាចប្រើភាសាអង់គ្លេស និងភាសាជាតិ ឬភាសាផ្លូវការផ្សេងៗទៀត ។<br><br>(iv) អាចត្រូវបានដាក់ជូនតាមរយៈមធ្យោបាយផ្សេងៗ និងទៅកាន់ចំណុចផ្សេងៗ ។ | (i) ភាពស្មុគស្មាញនៃដំណើរការ ។<br><br>(ii) ពុំមានចំណុចចូលតែមួយ ។ | (i) ធ្វើឱ្យសាមញ្ញនូវដំណើរការ ។<br><br>(ii) ណែនាំឱ្យមានចំណុចចូលតែមួយ ។ |
| | | **ភាពអាចជឿបាន** | |
| **ភាពឯករាជ្យ** | (i) កិច្ចព្រមព្រៀងដែល CRP រាយការណ៍ជូនក្រុមប្រឹក្សាភិបាល ហើយ SPF រាយការណ៍ជូនប្រធាន ឆ្លុះបញ្ចាំងយ៉ាងល្អអំពីលក្ខណៈលេចធ្លោ និងតម្រូវការនៃដំណើរការ ។ | (i) ការតែងតាំង CRP ដែលណែនាំដោយប្រធាន ។<br><br>(ii) កង្វះអន្តរកម្មរវាង CRP និងគណៈគ្រប់គ្រង និងបុគ្គលិក ឈានដល់ភាពឯកោ ។ | (i) លើកកម្ពស់ភាពឯករាជ្យរបស់ CRP តាមរយៈការតែងតាំងស្របតាម IED ។<br><br>(ii) លើកកម្ពស់អន្តរកម្មរវាង CRP គណៈគ្រប់គ្រង និងបុគ្គលិក ។ |
| **ការពិនិត្យតាមដាន** | (i) SPF និង CRP ត្រូវបានប្រគល់សិទ្ធិអំណាចឱ្យពិនិត្យតាមដាន | | |

| **វិស័យ** | **ចំណុចខ្លាំង** | **ចំណុចខ្សោយ** | **ការផ្លាស់ប្តូរដែលបានស្នើឡើង** |
|---|---|---|---|
| | ការអនុវត្តសកម្មភាព ។ | | |
| **តម្លាភាព** | (i). កម្រិតខ្ពស់នៃតម្លាភាពនៅក្នុងការបង្ហាញព័ត៌មានជាលក្ខណៈប្រព័ន្ធ និងលម្អិត ដោយផ្តល់ការពិចារណាសមស្របចំពោះភាពសម្ងាត់ ។ | (i) បណ្តឹងដែលបញ្ជូនត្រឡប់ទៅកាន់នាយកដ្ឋានប្រតិបត្តិការវិញ មិនត្រូវបានតាមដាន ។ | (i) តាមដានបណ្តឹងដែលបញ្ជូនត្រឡប់ទៅកាន់នាយកដ្ឋានប្រតិបត្តិការវិញ ។ |
| **ការចូលរួម** | (i) អ្នកដាក់សំណើ និងគណៈគ្រប់គ្រង ឆ្លើយតបទៅនឹងសេចក្តីព្រាងរបាយការណ៍ CRP ។<br><br>(ii) ការដោះស្រាយបញ្ហា ផ្តល់សិទ្ធិអំណាចដល់ដើមបណ្តឹង នូវតួនាទីដ៏សកម្ម នៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត ។ | (i) កង្វះការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង និង DMC ទៅនឹងសំណើនៅដំណាក់កាលមានសិទ្ធិ ។<br><br>(ii) របាយការណ៍ CRP មិនត្រូវបានចែករំលែកជាមួយប្រទេសខ្ចីកម្ចី ។ | (i) ណែនាំការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង ។<br><br>(ii) ជូនដំណឹង និងសម្របសម្រួលជាមួយប្រទេសខ្ចីកម្ចី ។ |
| | | **ប្រសិទ្ធផល** | |
| **រយៈពេល** | (i) រយៈពេលរំពឹងទុក ត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងគោលនយោបាយ ។ | (i) រយៈពេលជាក់ស្តែងនៃការពិគ្រោះយោបល់ និងការពិនិត្យឡើងវិញលើភាពអនុលោម លើសពីរយៈពេលរំពឹងទុក ។<br><br>(ii) រយៈពេលពិនិត្យតាមដានដ៏តឹងរ៉ឹង និងយូររបស់ CRP (៥ ឆ្នាំ) សម្រាប់គម្រោងនីមួយៗ ។ | (i) កំណត់រយៈពេលប្រាកដនិយម ។<br><br>(ii) សម្រួលដំណើរការនានា ។<br><br>(iii) ប្រើប្រាស់យ៉ាងពេញលេញ នូវយន្តការថ្នាក់មូលដ្ឋានសម្រាប់ការទប់ស្កាត់បញ្ហា ការដោះស្រាយបញ្ហា និងភាពអនុលោមឆាប់រហ័ស ។<br><br>(iv) ធ្វើឱ្យប្រសើរបំផុតចំពោះរយៈពេលពិនិត្យតាមដានរបស់ SPF និង CRP ។ |

| **វិស័យ** | **ចំណុចខ្លាំង** | **ចំណុចខ្សោយ** | **ការផ្លាស់ប្តូរដែលបានស្នើឡើង** |
|---|---|---|---|
| **ចំណាយ** | (i) ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់ធនធានគ្រប់គ្រាន់សម្រាប់យន្តការគណនេយ្យភាព ។ | (i) ចំណាយប្រតិបត្តិការសម្រាប់ករណីនីមួយៗ មានកម្រិតខ្ពស់បំផុត បើធៀបទៅនឹងយន្តការគណនេយ្យភាពដទៃៗទៀត ។<br>(ii) ចំនួនបុគ្គលិកដែលមានចែងនៅក្នុងគោលនយោបាយ ឈានដល់ភាពតឹងរ៉ឹងនាយកដ្ឋានប្រតិបត្តិការ ។ | (i) កំណត់ "ចំណាយថេរ" ដែលចាំបាច់ដោយមិនគិតអំពីចំនួនករណី ។<br>(ii) ធ្វើវិភាជន៍ចំណាយប្រែប្រួល នៅកម្រិតប្រសើរបំផុត ផ្អែកលើតម្រូវការ និងលក្ខខណ្ឌតម្រូវផ្នែកការងារ ។ |
| **ប្រសិទ្ធភាព** | | | |
| **រចនាសម្ព័ន្ធ** | (i) រចនាសម្ព័ន្ធពិគ្រោះយោបល់ និងពិនិត្យឡើងវិញលើភាពអនុលោមទ្វេដែលមានភាពសមស្របមួយត្រូវបានបង្កើតឡើង ។ | | |
| **ភាពពាក់ព័ន្ធ** | (i) ទាំងការពិគ្រោះយោបល់ ទាំងការពិនិត្យឡើងវិញលើភាពអនុ-លោម មានភាពពាក់ព័ន្ធ ។ | | |
| **លំដាប់** | (i) ការដោះស្រាយបញ្ហា ត្រូវបានផ្តល់អាទិភាពចម្បង ។<br>(ii) ដើមបណ្តឹងអាចចាកចេញពីដំណាក់កាលពិគ្រោះយោបល់ និងអាចដាក់ការពិនិត្យឡើងវិញលើភាពអនុលោម នៅទូទាំងដំណើរការទាំងមូល ។ | (i) ការពិនិត្យឡើងវិញលើភាពអនុលោមក្រោយពីបណ្តឹងទៅដល់ SPF មុនគេ បង្កើតនូវបញ្ហានៃការយល់ឃើញ និងបញ្ហាផ្នែកអនុវត្តន៍ ។ | (i) ធ្វើឱ្យមានលទ្ធភាព ដោយផ្ទាល់ទៅកាន់ CRP ។ |
| **អាណត្តិ** | (i) ការប្តេជ្ញាផ្តល់ការគាំទ្រចំពោះដំណាក់កាលពិគ្រោះយោបល់ និងភាពអនុលោម ។ | (i) អាណត្តិរបស់ CRP ក្នុងការផ្តល់អនុសាសន៍ ធ្វើឱ្យស្រពិចស្រពិល ដល់ភាពលេចធ្លោរវាងការដោះស្រាយបញ្ហា និងការពិនិត្យឡើងវិញលើភាព | (i) គួសបញ្ជាក់អាណត្តិរវាងការដោះស្រាយបញ្ហា ការពិនិត្យឡើងវិញលើភាពអនុលោម និងការគ្រប់គ្រង |

| **វិស័យ** | **ចំណុចខ្លាំង** | **ចំណុចខ្សោយ** | **ការផ្លាស់ប្តូរដែលបានស្នើឡើង** |
|---|---|---|---|
| | | អនុលោម និងរវាងការពិនិត្យឡើងវិញលើភាពអនុលោម និងការគ្រប់គ្រងគម្រោង ។<br><br>(ii) ការយល់ច្រឡំរវាងការពិនិត្យឡើងវិញលើអនុលោមភាព និងការពិនិត្យលទ្ធផលការងារ ។ | គម្រោង ។<br><br>(ii) គួសបញ្ជាក់អំពីតួនាទីរវាងការពិនិត្យលទ្ធផលការងារ និងការពិនិត្យឡើងវិញលើភាពអនុលោម ។ |
| **ការរៀនមេរៀន** | ការរៀនសូត្រជាលក្ខណៈប្រព័ន្ធត្រូវបានអនុវត្ត ។<br><br>តួនាទីផ្តល់ប្រឹក្សារបស់ OSPF មានអត្ថប្រយោជន៍ ។ | (i) ការរៀនសូត្រនៅមានកម្រិត នៅឡើយ ។<br>(ii) ការពិនិត្យឡើងវិញលើភាពអនុ-លោម ពេលខ្លះ ត្រូវបានចាត់ទុកថាមានលក្ខណៈប្រឆាំង ។ | (i) កែលម្អការរៀនសូត្រ<br>(ii) ជម្រុញឱ្យមានផ្លាស់ប្តូរផ្នែកវប្បធម៌ ។ |
| **ទស្សនកិច្ចទៅកាន់ទីតាំង** | (i) ត្រូវបានកំណត់នៅក្នុងគោលនយោបាយ ។ | (i) ការអនុវត្តជាក់ស្តែង មានការលំបាក ។ | (i) ការរៀនសូត្រពីបទពិសោធន៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី និងយន្តការគណនេយ្យភាពដទៃៗទៀត បង្កើតនូវគោលវិធីត្រឹមត្រូវមួយក្នុងការដោះស្រាយបញ្ហា ។ |
| **លទ្ធផល** | ការពិគ្រោះយោបល់ និងការពិនិត្យឡើងវិញលើភាពអនុលោម ផ្តល់នូវលទ្ធផលច្បាស់លាស់សម្រាប់ប្រជាជនដែលទទួលរងផលប៉ះពាល់ និងកែលម្អគុណភាពគម្រោង ។ | | ការដោះស្រាយបញ្ហាខាងលើនឹងរួមចំណែកដល់លទ្ធផលប្រសើរឡើង ។ |

ប្រភព : ធនាគារអភិវឌ្ឍន៍អាស៊ី